ទស្សនាវដ្ដីស្រាវជ្រាវ

# រាជបណ្ឌិត្យសភាកម្ពុជា

## Royal Academy of Cambodia Journal

លេខ១២ ខែមិថុនា ឆ្នាំ២០២៤ | Vol.12-June-2024




រក្សាសិទ្ធិគ្រប់យ៉ាង

**នាយកការផ្សាយ**

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**

**និពន្ធនាយក**

ឯកឧត្តមបណ្ឌិត **យង់ ពៅ**

**គណៈកម្មការនិពន្ធ**

ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី**
ឯកឧត្តមបណ្ឌិត **ផុន កសិកា**
ឯកឧត្តមបណ្ឌិត **អ៊ាំម បុណ្ណា**
ឯកឧត្តមបណ្ឌិត **នុត សម្បត្តិ**
ឯកឧត្តមបណ្ឌិត **គិន នា**
ឯកឧត្តមបណ្ឌិត **មាឃ បូរ៉ា**
ឯកឧត្តមបណ្ឌិត **គី សេរីវឌ្ឍន៍**
ឯកឧត្តម **សូត្រ សំណាង**
ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**
លោក **ហេង វីរិទ្ធិ**
លោក **សាន សុរាជនិត**

**លេខាធិការដ្ឋានបោះពុម្ពផ្សាយ**

លោកស្រី **កែវ ខេមរា**
លោក **ធឿន សុត្ថា**
លោក **ហេង ហុកវេន**
លោកស្រី **សំរិទ្ធ ចរិយា**
លោក **កៅ សុម៉ាឡេត**
លោក **ទ្រឿង មករា**
លោក **ភួយ បញ្ញា**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងការបោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍសង្គមជាតិ។ រាជបណ្ឌិត្យសភាកម្ពុជាដែលជាធនាគារខួរក្បាលរបស់ជាតិបានធ្វើការសិក្សាស្រាវជ្រាវលើមុខជំនាញជាច្រើន និងបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាជាច្រើនលេខរួចមកហើយ។ នៅក្នុងលេខទីដប់ពីរនេះមានអត្ថបទជាច្រើនទៀតដែលទាក់ទងនឹងអប់រំ វប្បធម៌ វិទ្យាសាស្ត្រសត្វ សេដ្ឋកិច្ច នីតិសាស្ត្រ ទស្សនវិជ្ជា និងរដ្ឋបាលសាធារណៈជាដើម ហើយសុទ្ធសឹងជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវផងដែរ។

ទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាបានរួមចំណែកផ្សព្វផ្សាយស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់បណ្ឌិត្យសភាចារ្យ អ្នកសិក្សាស្រាវជ្រាវ និងអត្ថបទសិក្សាស្រាវជ្រាវរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបេក្ខជនបណ្ឌិតផងដែរ។ ការបោះពុម្ពផ្សាយនូវស្នាដៃសិក្សាស្រាវជ្រាវថ្មីៗគឺដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់ការសិក្សាស្វែងយល់របស់អ្នកស្រាវជ្រាវ ក៏ដូចជាជួយជំរុញដល់អ្នកស្រាវជ្រាវទាំងឡាយឱ្យកាន់តែមានឆន្ទៈក្នុងការស្រាវជ្រាវប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំទស្សនាវដ្ដីសង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវនេះនឹងក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំរង់ចាំទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអាន និងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋាន ដើម្បីកែលម្អនូវចំណុចខ្វះខាត និងកំហុសឆ្គងដែលអាចកើតមានឡើងដោយអចេតនាទាំងលើខ្លឹមសារ និងផ្នែកបច្ចេកទេស ឱ្យកាន់តែមានសុក្រឹតភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

**គណៈកម្មការទស្សនាវដ្ដីស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា


១. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ បេក្ខជនបណ្ឌិត **ឫទ្ធី សុគន្ធារិទ្ធ** ------------------------------ ១

២. ឥទ្ធិពលអាករលើតម្លៃបន្ថែមលើកំណើនសេដ្ឋកិច្ចកម្ពុជា បេក្ខជនបណ្ឌិត **គង់ ចន្ថា** -------------១២

៣. ទម្រង់មតកសាសន៍ដោយលិខិតឯកជននិងលទ្ធភាពប្រតិបត្តិ បេក្ខជនបណ្ឌិត **ងួន រតនា**-------២៤

៤. ប្រព័ន្ធឃោជាកម្ពុជា បេក្ខជនបណ្ឌិត **ឌី សោភា** ------------------------------------------------- ៣៥

៥. ប្រសិទ្ធភាពការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់សេវាសាធារណៈ បេក្ខជនបណ្ឌិត **ភូន ភូម៉ូនីរតន៍** -----------------------------------------------------------------------------------------------------៤៥

៦. ទស្សនាទានអប់រំចរិយាធម៌តាមរយៈរឿងវិធុរបណ្ឌិត បេក្ខជនបណ្ឌិត **យ៉ា សារុន** ------------- ៥៣

៧. ការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បេក្ខជនបណ្ឌិត **សាន សេង** ----------------------------------------------------៦០

៨. ការលើកទឹកចិត្ត និងការដាក់វិន័យនៃការគ្រប់គ្រងធនធានមនុស្សក្នុងក្រសួងអប់រំ យុវជន និងកីឡា បេក្ខជនបណ្ឌិត **ទ្រី ចាន់** ----------------------------------------------------------------------៨៩

៩. ប្រសិទ្ធភាពនៃការលូតលាស់របស់មាន់ ដោយប្រើទងដំឡូងផ្វាលាយជាមួយចំណីសម្រេចដែលជាចំណីគ្រឹះ បេក្ខជនបណ្ឌិត **ហ៊ិន់ ហៀក** ----------------------------------------------------------៩៥

១០. ការវិភាគស្នាដៃគំនូរអំពីពណ៌ និស្សិត **កែវ សំរិត** -------------------------------------------១០៦

១១. ការអនុវត្តប្រព័ន្ធកសិកម្មឆ្លាតខ្នាតតូចតាមរយៈការប្រើប្រាស់សេនស័រសម្រាប់ប្រព័ន្ធស្រោចស្រពក្នុងការដាំដុះដំណាំ និស្សិត **ហ៊ី ឡេងសែ** ---------------------------------------------------១១៩

# ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

បេក្ខជនបណ្ឌិតៈ **ឫទ្ធី សុគន្ធារិទ្ធ**
ជំនាញៈ **រដ្ឋបាលសាធារណៈ**

កត្តាផ្ទៃក្នុងរបស់ប្រទេសនីមួយៗ និងកត្តាអន្តរជាតិទោះតិចឬច្រើនសុទ្ធតែមានឥទ្ធិពលដល់ការប្រតិបត្តិគោលនយោបាយដឹកនាំរបស់ប្រទេសនីមួយៗនោះដែរ កត្តាទាំងនោះមានជាអាទិ៍ ភាពក្រីក្រ បញ្ហាគ្មានការងារធ្វើ សុខុមាលភាពសង្គម ការជានារ៉ាប់រងសង្គម លំនៅដ្ឋាន និងលំនាំនៃសាកលភាវូបនីយកម្មក្រោមអាជ្ញាបញ្ញានៃអំពើហឹង្សា ការប្រកួតប្រជែង នវកម្ម ភាពមិនប្រាកដមិនទៀងក្នុងលក្ខណៈនយោបាយ សេដ្ឋកិច្ច និងសង្គម។ ដូចនេះ ប្រព័ន្ធគ្រប់គ្រង របស់ប្រទេសនីមួយៗក៏ត្រូវតែមានលក្ខណៈខុសៗគ្នា ទៅតាមលក្ខខណ្ឌ ទីតាំងភូមិសាស្ត្រ និងស្ថានភាពជាក់ស្តែងរបស់ប្រទេសនីមួយៗនោះដែរ ដែលប្រទេសមួយចំនួនអនុវត្តប្រព័ន្ធគ្រប់គ្រង ប្រទេសបែបសហព័ន្ធ និងប្រទេសមួយចំនួនអនុវត្តប្រព័ន្ធគ្រប់គ្រងប្រទេសបែបរដ្ឋទោលជាដើម។ ដើម្បីឈានទៅស្វែងយល់ពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដំបូងយើងគួរស្វែងយល់ពីអត្ថន័យមួយចំនួននៃពាក្យ "**ការគ្រប់គ្រង**" "**រដ្ឋបាលសាធារណៈ**" និង "**រដ្ឋបាលថ្នាក់ក្រោមជាតិ**" ជាមុនសិន។

## ១. និយមន័យនៃការគ្រប់គ្រង រដ្ឋបាលសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ

### ១.១. ការគ្រប់គ្រង

"**ការគ្រប់គ្រង**" មានន័យយ៉ាងទូលំទូលាយគឺវាអាស្រ័យទៅតាមការអនុវត្ត និងការបកស្រាយរបស់មនុស្សក្នុងវិស័យផ្សេងៗនៃការងារ ជួនកាលគេប្រើពាក្យ "**ការគ្រប់គ្រង**" នេះសម្រាប់ការពិពណ៌នាអំពីសកម្មភាពរបស់អ្នកដឹកនាំ និងអ្នកចាត់តាំងនៅក្នុងអង្គភាពមួយ ដូចជានៅពេលដែលគេនិយាយពីការចរចានៃការគ្រប់គ្រងកម្មករ។

នៅក្នុងបរិបទផ្សេងទៀត ពាក្យថា «**ការគ្រប់គ្រង**» អាចមានន័យសំដៅទៅលើប្រព័ន្ធការងារដែលអាចធ្វើឱ្យផលិតផលកើតមានឡើង។ **ការគ្រប់គ្រង** គឺជាការប្រើប្រាស់ធនធានមនុស្សនិងធនធានផ្សេងៗទៀតដើម្បីសម្រេចគោលដៅរបស់អង្គការ។ **ការគ្រប់គ្រង** គឺជាដំណើរការនៃការសម្រេចចិត្តពីរបៀបប្រើប្រាស់ធនធានរបស់អាជីវកម្មឱ្យល្អបំផុត ដើម្បីផលិតទំនិញ ឬផ្តល់សេវាកម្ម។ **ការគ្រប់គ្រង** ជាប់ទាក់ទងនឹងការបង្កើតមជ្ឈដ្ឋានការងារ ដែលធ្វើឱ្យមនុស្សអាចប្រើប្រាស់ធនធានផ្សេងៗយ៉ាងស័ក្តិសិទ្ធិ ដើម្បីសម្រេចគោលដៅដែលបានកំណត់[១]។

ម៉ារី ផាកឃើរ ហ្វូឃេ័ត (Mary Parker Follett) បានកំណត់ន័យ "**ការគ្រប់គ្រង**" ថា គឺជាដំណោះស្រាយនៃការសម្រេចលទ្ធផលតាមរយៈអ្នកដទៃ[២]។ ជាមួយគ្នានេះ បើតាមទស្សនៈរបស់ ហ្សាហ្វ្រីត និង រូសែល (Shafritz and Russell : 1997) បានឱ្យនិយមន័យ "**ការគ្រប់គ្រង**" គឺសំដៅទៅលើ

---

[១] Cooper and Schindle, 2001, 7th Edition, Business Reseach Methodologies, McGraw-Hill, USA

[២] Pigors and Mayers,1973:9, Personnel Administration: a point of view and a method

មនុស្សដែលទទួលខុសត្រូវសម្រាប់ដំណើរការអង្គភាព និងអភិក្រមសម្រាប់ដំណើរការអង្គភាពនោះតែម្តង ដោយប្រើប្រាស់នូវធនធានដើម្បីសម្រេចគោលបំណងរបស់អង្គភាព[៣]។

សរុបមក "**ការគ្រប់គ្រង**" សំដៅទៅលើមនុស្សដែលទទួលខុសត្រូវសម្រាប់ដំណើរការអង្គភាព និងអភិក្រមសម្រាប់ដំណើរការអង្គភាព ដោយប្រើប្រាស់នូវធនធានមនុស្សដើម្បីសម្រេចគោលបំណងរបស់អង្គភាពឱ្យមានប្រសិទ្ធភាព( Efficiency ) និងភាពស័ក្តិសិទ្ធិឬប្រសិទ្ធផល( Effectiveness )[៤]។[៥]

### ១.២. រដ្ឋបាលសាធារណៈ

"**រដ្ឋបាលសាធារណៈ**" សំដៅដល់ស្ថាប័នទាំងឡាយណាដែលមាននៅក្នុងរដ្ឋនីមួយៗមានតួនាទីបម្រើផលប្រយោជន៍សាធារណៈ ឬប្រយោជន៍រួមទូទៅ ហើយជាទូទៅស្ថិតក្រោមការដឹកនាំរបស់អង្គការនីតិប្រតិបត្តិ។ "**រដ្ឋបាលសាធារណៈ**" ត្រូវស្ថិតនៅក្នុងក្របខណ្ឌរបស់រដ្ឋក្នុងអំណាចសាធារណៈ គឺជាឧបករណ៍របស់រដ្ឋ ឬរបស់បក្សទៅលើប្រព័ន្ធការងារ ដែលអាចធ្វើឱ្យផលិតផលកើតមានឡើង[៦]។ ជារួមក្នុងការឱ្យន័យ "**រដ្ឋបាលសាធារណៈ**" គឺមិនមែនជាការងាយស្រួលពេកទេ។ បើតាមការឱ្យអត្ថន័យពីអ្នកប្រាជ្ញ និងអ្នកសិក្សាស្រាវជ្រាវនានា គឺឱ្យនិយមន័យខុសៗគ្នាពីសង្គម មួយទៅសង្គមមួយ ពីបរិបទមួយទៅបរិបទមួយ និងទៅតាមស្ថានភាពនយោបាយ ស្ថានភាពសេដ្ឋកិច្ច និងការរីកចម្រើនបច្ចេកវិទ្យាសាកលភាវូបនីយកម្ម និងការប្រកួតប្រជែងគ្នាជាលក្ខណៈអន្តរជាតិរបស់ប្រទេសនីមួយៗ។

### ១.៣. រដ្ឋបាលថ្នាក់ក្រោមជាតិ

"**រដ្ឋបាលថ្នាក់ក្រោមជាតិ**" សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់[៧]។ ដូច្នេះ "**ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**" គឺសំដៅលើប្រព័ន្ធការងារ និងការប្រើប្រាស់ ធនធានមនុស្ស និងធនធានផ្សេងៗទៀត ព្រមទាំងមានការទទួលខុសត្រូវលើកិច្ចដំណើរការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ដើម្បីផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ មានប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ ឬប្រសិទ្ធផល ផលិតភាព គណនេយ្យភាព គុណភាព ភាពងាយស្រួល ការឆ្លើយតបសាមញ្ញ អាចជឿទុកចិត្តបាន និងនវានុវត្តន៍។

---

[៣] Shafritz, Jay M.and Russell E.W., 1997, Introducing Public Administration. An imprint of Addison Wesley Longman, Inc.

[៤] ប្រសិទ្ធភាព គឺជាដំណើរការ ដែលទទួលបាននូវគោលដៅរបស់អង្គភាព ដោយការប្រើប្រាស់ធនធានតិចបំផុត។ ចំណែកភាពស័ក្តិសិទ្ធ ឬប្រសិទ្ធផលគឺជាដំណើរការដែលទទួលបាននូវគោលដៅរបស់អង្គភាព ដោយការបង្កើតបាននូវផលិតផល ឬសេវាកម្មដែលមានតម្លៃឆ្លើយតបទៅនឹងសេចក្តីចង់បាន និងសេចក្តីត្រូវការរបស់អ្នកដែលពាក់ព័ន្ធ ជាអាទិ៍ អតិថិជន អ្នកផ្គត់ផ្គង់ ដៃគូប្រកួតប្រជែង និងភ្នាក់ងារច្បាប់ ជាដើម។

[៥] Alan R, Nakervis, Robert L.Compton and Terence E.McCarthy 3rd Edition, Strategic Human Resources Management, Kin Keong, Singapore

[៦] កៅ មុយថង "*រដ្ឋបាលសាធារណៈទំនើប- Modern Public Administration*" ភ្នំពេញ រោងពុម្ព បណ្ណាគារអង្គរ បោះពុម្ពលើកទី១ ឆ្នាំ២០០៧ ទំព័រ៨។

[៧] រាជរដ្ឋាភិបាលកម្ពុជា "*កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨*" ឆ្នាំ២០១៥ - ឧបសម្ព័ន្ធទី៣ "សន្ទានុក្រម" ។

## ២. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅតាមប្រទេសនានាក្នុងតំបន់ និងសកលលោកតែងតែមានសណ្ឋាន និងរបៀបគ្រប់គ្រងខុសៗគ្នា ដោយផ្អែកទៅតាមកត្តានយោបាយ ភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ជាដើម។ល។ នៅក្នុងការគ្រប់គ្រងបែបរដ្ឋទោល ក៏មានលក្ខណៈខុសៗគ្នាដែរ គឺមានការគ្រប់គ្រងបែបប្រមូលផ្តុំសិទ្ធិអំណាចនៅថ្នាក់ជាតិ ដែលហៅថា ការគ្រប់គ្រងតាមបែបមជ្ឈការ និងការគ្រប់គ្រងបែបផ្តល់សិទ្ធិអំណាចទៅឱ្យរដ្ឋបាលមូលដ្ឋាន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលហៅថា ការគ្រប់គ្រងតាមបែបវិមជ្ឈការ។ ហើយក៏មានប្រទេសមួយចំនួន ក៏មានការផ្តល់សិទ្ធិអំណាចទៅឱ្យថ្នាក់មូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលមានលក្ខណៈចម្រុះគឺវិមជ្ឈការផង និងវិសហមជ្ឈការផង ដូចជានៅប្រទេសកម្ពុជាកំពុងអនុវត្តបច្ចុប្បន្នជាដើម។ តទៅនេះ គឺជាការបង្ហាញពីទម្រង់នៃការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិតាមបែបមជ្ឈការ វិមជ្ឈការ វិសហមជ្ឈការ និងតាមបែបចម្រុះ។

### ២.១. ការគ្រប់គ្រងរដ្ឋបាលតាមបែបមជ្ឈការ

«មជ្ឈការ» មានន័យថា ការប្រមូលផ្តុំអំណាច ឬអំណាចប្រមូលផ្តុំ គឺជាការគ្រប់គ្រងតាមបែបប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមួយប្រភេទដែលរដ្ឋបាលកណ្តាលដឹកនាំរដ្ឋបាលដោយផ្ទាល់។ លក្ខណៈនេះមិនអាចអនុវត្តបានទាំងស្រុងទេ យ៉ាងហោចណាស់ក៏រដ្ឋបានបង្កើតអាជ្ញាធរដែនដីត្រឹមថ្នាក់រាជធានី-ខេត្តដែរ។ ប៉ុន្តែរាជធានី-ខេត្តគ្មានសិទ្ធិសម្រេចអ្វីទាំងអស់ ពីព្រោះអំណាចទាំងអស់ត្រូវបានប្រមូលផ្តុំទៅលើអាជ្ញាធររដ្ឋបាលកណ្តាល។ ប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការនេះនឹងនាំឱ្យអាជ្ញាធររដ្ឋបាលកណ្តាលមានភាពរឹងមាំ ការតែងតាំងបុគ្គលឱ្យបម្រើការងារនៅថ្នាក់មូលដ្ឋានសុទ្ធតែជាមនុស្សមានសមត្ថភាព និងឯកភាពជាតិ។ ទន្ទឹមនឹងនេះ វាក៏បង្កនូវភាពយឺតយ៉ាវក្នុងការសម្រេច និងមិនយល់សភាពការណ៍ព្រមទាំងខ្វះលទ្ធិប្រជាធិបតេយ្យជាដើម។ ការគ្រប់គ្រងបែបនេះមានគោលបំណងធំបី[៨]៖

១- នីតិបុគ្គលសាធារណៈមានតែរដ្ឋ

២- អំណាចសម្រេចសេចក្តី និងបញ្ហា ស្ថិតនៅក្នុងរដ្ឋបាលកណ្តាលទាំងអស់

៣- រដ្ឋបាលទាំងអស់ត្រូវរៀបចំតាមឋានានុក្រម

ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធមជ្ឈការនេះ គឺគេធ្វើការគ្រប់គ្រងតាមតារាងសាជីជ្រុង ដោយអំណាចនៃការសម្រេចទាំងអស់ជារបស់រដ្ឋបាលកណ្តាលទាំងអស់។ ដូច្នេះរាល់ការបង្កើតនូវការសម្រេចការកែប្រែអ្វីដោយរដ្ឋបាលកណ្តាលទាំងអស់។

### ២.២. ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ

ការគ្រប់គ្រងតាមបែបវិមជ្ឈការជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមួយប្រភេទ ដែលអាជ្ញាធររដ្ឋបាលកណ្តាលទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការសម្រេចរបស់អាជ្ញាធរមូលដ្ឋាន ដោយមានចែងនៅក្នុងច្បាប់

---

[៨] សឿន សោភ័ណ "*សេចក្តីផ្តើមរដ្ឋបាលសាធារណៈ*" ភ្នំពេញ ឆ្នាំ ២០០៩ ទំព័រ ១៣១។

(អំណាចផ្ទេរ)។ នៅក្នុងការទទួលស្គាល់នូវសិទ្ធិអំណាចរបស់អាជ្ញាធរមូលដ្ឋាននេះ គឺជាការផ្ទេរអំណាច និងផ្ទេរការទទួលខុសត្រូវចំពោះកិច្ចការមួយចំនួនឱ្យទៅអាជ្ញាធរមូលដ្ឋានធ្វើការចាត់ចែង ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់របស់មូលដ្ឋានខ្លួន។ ប្រព័ន្ធនេះ អាជ្ញាធរមូលដ្ឋានកើតឡើងដោយការបោះឆ្នោត និងមានគោលបំណងលើកកម្ពស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ លើកកម្ពស់ជីវភាពរស់នៅ និងការផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសកាន់តែច្រើន ក្នុងការសម្រេចលើជោគវាសនាដោយខ្លួនឯង ព្រមទាំងធានាឱ្យមានកិច្ចអភិវឌ្ឍន៍មួយប្រកបដោយនិរន្តរភាព និងការផ្តល់សេវាសាធារណៈឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពទៅដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ ដើម្បីធ្វើឱ្យមានវិមជ្ឈការពិតប្រាកដនោះ ចាំបាច់ត្រូវឱ្យមានស្វ័យភាពនៃអំណាចមូលដ្ឋាន ចំពោះអំណាចកណ្តាល។ ប៉ុន្តែក៏មិនត្រូវឱ្យមានស្វ័យភាពពេញលេញពេកដែរ ព្រោះវានាំឱ្យធ្លាក់ចូលទៅក្នុងសម្ព័ន្ធភាពនិយម ពោលគឺការផ្តាច់ខ្លួន ដើម្បីទាមទារឯករាជ្យក្នុងមណ្ឌលដែនដីរបស់ខ្លួន។ ប៉ុន្តែ ក្នុងសង្គមប្រជាធិបតេយ្យពិតប្រាកដ ហើយដែលមានអ្នកចេះដឹងច្រើន គេតែងទទួលស្គាល់ឱ្យមានការគ្រប់គ្រងផលប្រយោជន៍រាស្ត្រតាមទីកន្លែង ដោយរាស្ត្រខ្លួនឯង[៩] ពីព្រោះថាផលប្រយោជន៍តាមទីកន្លែងមានដូចជានៅតាមឃុំ សង្កាត់ ភូមិ ជាដើម គឺជាផលប្រយោជន៍ផ្ទាល់នៅនឹងកន្លែងសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។

បើតាម Cheema and Rondinelli (1983:18) បានកំណត់ថា "វិមជ្ឈការ" គឺជាការផ្ទេរសិទ្ធិអំណាចនៃការធ្វើផែនការ ការសម្រេចចិត្ត ឬកិច្ចការរដ្ឋបាលពីរដ្ឋបាលថ្នាក់កណ្តាលទៅបណ្តាអង្គភាពរបស់ខ្លួននៅឯមូលដ្ឋាន បណ្តាផ្នែកនៃរដ្ឋបាលមូលដ្ឋាន បណ្តាអង្គភាពរបស់រដ្ឋ រដ្ឋបាលមូលដ្ឋាន និងបណ្តាអង្គការមិនមែនរដ្ឋាភិបាល[១០]។

ដូច្នេះ ការផ្តល់ស្វ័យភាពពីអំណាចរបស់រដ្ឋបាលកណ្តាលនេះ នៅតែអមដោយការត្រួតពិនិត្យខ្លាំងឬតិចពីរដ្ឋអំណាចកណ្តាល ដែលត្រួតពិនិត្យអាណាព្យាបាល ដែលប្រែប្រួលទៅតាមកាលនៃពេលវេលា។ ប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការនេះនាំឱ្យមានស្វ័យភាពលើការងារ និងចំណេញពេលវេលាក្នុងការសម្រេចរបស់អាជ្ញាធរមូលដ្ឋាន បើកទូលាយនូវសិទ្ធិសេរីភាពឱ្យប្រជាពលរដ្ឋចូលរួមសហការក្នុងការងាររបស់រដ្ឋ និងមានប្រជាធិបតេយ្យស៊ីជម្រៅនៅថ្នាក់មូលដ្ឋានជាដើម។ ទន្ទឹមនឹងនេះ វាក៏អាចបណ្តាលឱ្យបាត់បង់ការឯកភាពជាតិ បែកបាក់សាមគ្គីរវាងសមូហភាព និងសមូហភាព និងការអភិវឌ្ឍអាចតាមបែបអាណាធិបតេយ្យជាដើមផងដែរ។ ដោយហេតុផលនេះហើយ គឺត្រូវទាមទារមានការប្រុងប្រយ័ត្នខ្ពស់ ក្នុងការផ្តល់សិទ្ធិអំណាចជ្រុល ដែលអាចឈានដល់ការគ្រប់គ្រងបែបអប្បគមន៍។

ជារួម "វិមជ្ឈការ" គឺជាការបង្កើតនូវលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការអភិវឌ្ឍន៍មូលដ្ឋាន ព្រោះថា ឆ្លងកាត់នយោបាយវិមជ្ឈការនេះ យើងនឹងផ្តល់ជូនប្រជាពលរដ្ឋតាមមូលដ្ឋាននីមួយៗនូវសមត្ថកិច្ចសម្រាប់ធ្វើសេចក្តីសម្រេច ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនដោយខ្លួនឯង។ នេះជាមធ្យោបាយ

---

[៩] សាយ បូរី "***នីតិរដ្ឋបាលទូទៅ - Droit Administratif Général***" ភ្នំពេញ បណ្ណាគារអង្គរ បោះពុម្ពលើកទី៤ ឆ្នាំ២០១២ ទំព័រ ៣៩៤។

[១០] សយ រាសី "***កំណែទម្រង់រដ្ឋបាលសាធារណៈ***" ឯកសារបង្រៀនថ្នាក់បណ្ឌិត ឆ្នាំ២០១៩ ទំព័រ ៧០។

ដ៏ប្រសើរបំផុត ដោយហេតុថា សេចក្តីខ្វះខាត តម្រូវការជាក់ស្តែងរបស់ប្រជាជនតាមមូលដ្ឋានមានលក្ខណៈមិនដូចគ្នាទេ។ ដើម្បីបំពេញសេចក្តីត្រូវការនិងការខ្វះខាតទាំងនេះ វិធីដ៏ប្រសើរបំផុតគឺមានតែសហគមន៍នៃប្រជាពលរដ្ឋទាំងនោះទេដែលជាអ្នកម្ចាស់ការ រិះរកវិធានការដោះស្រាយជាមួយមធ្យោបាយសមស្រប ដែលបានប្រគល់ឱ្យ។ ធ្វើបានដូចនេះ យើងអាចកាត់បន្ថយបានការលំបាករបស់ប្រជាជន ពោលគឺកាត់បន្ថយភាពក្រីក្រ ហើយពេលដែលភាពក្រីក្រថយចុះ នោះមានន័យថា ការអភិវឌ្ឍន៍នឹងកើនឡើង។ ដូច្នេះ ច្បាស់លាស់ណាស់ ដំណើរការវិមជ្ឈការ គឺជាដំណើរការអភិបាលកិច្ចដ៏ទូលំទូលាយដែលមានទំនាក់ទំនងនៅគ្រប់ថ្នាក់រដ្ឋបាល[១១]។

ដូចនេះ ដើម្បីអនុវត្តនយោបាយវិមជ្ឈការឱ្យទទួលជោគជ័យ រាជរដ្ឋាភិបាលកម្ពុជា បានតាំងចិត្តយ៉ាងមុតមាំថា នឹងខិតខំសម្រេចឱ្យបាននូវការរៀបចំប្រព័ន្ធគ្រប់គ្រងថ្នាក់មូលដ្ឋានឱ្យបានសមស្របសម្រាប់ប្រទេសជាតិដោយមិនលឿនពេក ដោយមិនយឺតពេក ដោយមានលក្ខណៈសន្សឹមៗ ដើម្បីជៀសវាងនៅពេលដាក់ឱ្យអនុវត្តប្រព័ន្ធនេះនៅរដ្ឋបាលថ្នាក់ជាតិទទួលបរាជ័យ ករណីដូចប្រទេសឥណ្ឌូនេស៊ី និងប្រទេសមួយចំនួនទៀតកន្លងមក។ ឈរលើហេតុផលនេះទើបក្នុងរយៈពេលចុងក្រោយនេះ វិមជ្ឈការបាននិងកំពុងវិវឌ្ឍឥតឈប់ឈរនៅប្រទេសកម្ពុជា តាមរយៈក្របខណ្ឌគោលនយោបាយ ក្របខណ្ឌគតិយុត្ត និងក្របខណ្ឌស្ថាប័នដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ។ ហើយវិមជ្ឈការជាគោលដៅនយោបាយរបស់រដ្ឋ (រដ្ឋាភិបាល ឬរដ្ឋបាលកណ្តាល) ក្នុងការចែករំលែកអំណាចឱ្យសមូហភាពមូលដ្ឋាន ឬដែនដីដែលក្នុងការប្រតិបត្តិ រដ្ឋបាលត្រូវរ៉ាប់រងដោយសភាជាប់ឆ្នោត រីឯសមត្ថកិច្ច[១២]ត្រូវបំពេញដោយអង្គភាពកណ្តាល និងតំណាងដែនដី (អភិបាលខេត្ត-តំបន់)។ វិមជ្ឈការមានគោលដៅសំខាន់ពីរគឺ៖ ផ្តល់ស្វ័យភាពឱ្យសមូហភាពថ្នាក់ក្រោមជាតិ និងអនុញ្ញាតឱ្យអាជ្ញាធរដោះស្រាយបញ្ហានៅនឹងកន្លែង ដោយហេតុផលម្យ៉ាង អ្នកនៅនឹងកន្លែងស្គាល់បញ្ហាច្បាស់ និងម្យ៉ាងទៀតដំណោះស្រាយបញ្ហានៅនឹងកន្លែងនាំឱ្យចំណេញពេលវេលាច្រើន និងដោះស្រាយចំបញ្ហាមានប្រសិទ្ធភាពខ្ពស់។ មូលហេតុដែលប្រទេសមួយចំនួនលើពិភពលោកអនុវត្តការគ្រប់គ្រងតាមបែបវិមជ្ឈការគឺឈរលើគោលការណ៍ចំនួន ៤ រួមមាន៖

- សមូហភាពថ្នាក់ក្រោមជាតិ ត្រូវមានស្វ័យភាព និងការទទួលខុសត្រូវទាំងស្រុង។
- សមូហភាពថ្នាក់ក្រោមជាតិត្រូវមានសមត្ថកិច្ចទូលំទូលាយ និងមានមធ្យាបាយបច្ចេកទេស (មនុស្ស ហិរញ្ញវត្ថុ[១៣] និងធនធានសម្ភារៈ[១៤]) មានន័យថា សមូហភាពមូលដ្ឋាន ឬដែនដីទទួលបន្ទុកការងារច្រើនជាងមុន។
- សមូហភាពថ្នាក់ក្រោមជាតិ ត្រូវធ្វើការរវាងគ្នានិងគ្នា និងជាមួយរដ្ឋ ក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងស្មើភាព។

---

[១១]. ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ "***វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន តាមបែបប្រជាធិបតេយ្យនៅកម្ពុជា***" ភាគ I ខែតុលា ឆ្នាំ២០០២ ទំព័រ ៦។

[១២] សមត្ថកិច្ច៖ ជាសម្បទា ឬជាសមត្ថភាពរបស់អាជ្ញាធរក្នុងការប្រតិបត្តិលិខិតស្នាមគតិយុត្ត និងសេចក្តីសម្រេចរបស់យុត្តាធិការឬសាលាក្តី ។ល។

[១៣] មធ្យោបាយហិរញ្ញវត្ថុមានការចែករំលែកភារកិច្ចសារពើពន្ធជាដើម។

[១៤] មធ្យោបាយធនធានសម្ភារ មានដូចជាអគារ និងការផ្គត់ផ្គង់ផ្សេងៗ។

- រដ្ឋត្រូវអនុវត្តចំពោះខ្លួនឯង ទន្ទឹមគ្នានឹងនយោបាយវិមជ្ឈការដែលបានប្រគល់ឱ្យសមូហភាពថ្នាក់ក្រោមជាតិ។ ក្នុងខណៈនេះដែរ រដ្ឋាភិបាលឬរដ្ឋបាលកណ្តាលត្រូវអនុវត្តនយោបាយវិសហមជ្ឈការ ឬវិមជ្ឈការរដ្ឋបាលចំពោះតំណាងរបស់ខ្លួននៅមូលដ្ឋានដែរ។ ហើយនៅថ្នាក់សមូហភាពមូលដ្ឋាន ឬដែនដី វិមជ្ឈការអនុញ្ញាតឱ្យដោះស្រាយបញ្ហាទៅតាមផ្លូវច្បាប់។ ទន្ទឹមនឹងនេះ រដ្ឋក៏ត្រូវផ្ទេរអំណាចទៅអង្គភាពវិសហមជ្ឈការផងដែរ។

បើតាម Nugruho D.(2000:42) វិមជ្ឈការចែកចេញជាពីរ៖ វិមជ្ឈការដែនដី និងវិមជ្ឈការមុខងារ ឬវិមជ្ឈការបច្ចេកទេស[១៥]។

បើតាមទស្សនៈរបស់ Bryant and White (1989)វិញ វិមជ្ឈការមានពីរដែរ ប៉ុន្តែខុសពីទស្សនៈរបស់ Nugruho D. ខាងលើរួមមាន៖ វិមជ្ឈការនយោបាយ(Political Decentralization) និងវិមជ្ឈការរដ្ឋបាល(Administration Decentralization)។ ដែលវិមជ្ឈការនយោបាយ ហៅថា Devolution និងវិមជ្ឈការរដ្ឋបាល ហៅថា វិសហមជ្ឈការ (Deconcentration)[១៦]។

បើតាមទស្សនៈរបស់អ្នកប្រាជ្ញខាងលើ វិមជ្ឈការ មានច្រើនប្រភេទ ជាអាទិ៍ (១)វិមជ្ឈការមុខងារ ឬវិមជ្ឈការរដ្ឋបាល ឬវិសហមជ្ឈការ និង (២) វិមជ្ឈការនយោបាយ ឬវិមជ្ឈការប្រជាធិបតេយ្យ ឬ Devolution។ ប៉ុន្តែ ខ្លឹមសារ និងអត្ថន័យនៃពាក្យទាំងនោះពុំមានលក្ខណៈដូចគ្នាទាំងស្រុងនោះទេ ឧទាហរណ៍ដូចជា Devolution សំដៅដល់ការផ្ទេរអំណាចចំពោះមូលដ្ឋានមានកម្រិតមួយយ៉ាងខ្ពស់ បានន័យថា ឱ្យអំណាចសឹងទាំងដុលទៅមូលដ្ឋាន រីឯ វិមជ្ឈការនយោបាយ ឬវិមជ្ឈការប្រជាធិបតេយ្យ មានការផ្ទេរអំណាចចំពោះមូលដ្ឋាននៅមានកម្រិត។

ជាសន្និដ្ឋាន៖

១- វិមជ្ឈការក្រៅពីការផ្ទេរសមត្ថកិច្ច និងការលុបបំបាត់អាណាព្យាបាល បង្ហាញពីភាពស្វាហាប់នៃគ្រប់ថ្នាក់ដែនដី(ឃុំ សង្កាត់) និងបង្កើតលក្ខខណ្ឌនៃការផ្លាស់ប្តូរលទ្ធិប្រជាធិបតេយ្យ ដោយបង្ខិតប្រជាពលរដ្ឋទៅក្បែរជិតរដ្ឋបាល។ អំណាចមូលដ្ឋានកកើត និងបច្ចុប្បន្នត្រូវទទួលស្គាល់ពិសេស ភាពស្វាហាប់រស់រវើករបស់អំណាចនេះ។

២- សមូហភាពដែនដីបង្ហាញពីសមត្ថភាព ពីប្រសិទ្ធភាពនៃការគ្រប់គ្រង ពីកង្វល់ ដើម្បីដោះស្រាយបញ្ហាសង្គមធំៗរបស់មូលដ្ឋាន។ ប្រការនេះមិនធ្វើឱ្យរដ្ឋចុះខ្សោយទេ។ ផ្ទុយទៅវិញ ការឈានឡើងរបស់សមូហភាព ពង្រឹងសកម្មភាពលើបេសកកម្មជាតិធំៗ និងអះអាងនូវឧបនិស្ស័យ ជាអ្នកយុទ្ធសាស្ត្រ និងអាជ្ញាកណ្តាល។

៣- ជំរុញប្រជាធិបតេយ្យមូលដ្ឋានឱ្យកាន់តែមានការចូលរួម ធ្វើឱ្យច្បាស់លាស់នូវសមត្ថកិច្ចនៃបណ្តាថ្នាក់សមូហភាពមូលដ្ឋាន ឬជំរុញឱ្យកាន់តែមានប្រសិទ្ធភាព ធ្វើទំនើបកម្មរបបហិរញ្ញវត្ថុមូលដ្ឋាន និងពង្រឹងការរៀបចំវិសហមជ្ឈការរបស់រដ្ឋ គឺជាគោលដៅសំខាន់បំផុតនៃវិមជ្ឈការ។

---

[១៥] សយ រាសី "*កំណែទម្រង់រដ្ឋបាលសាធារណៈ*" ឯកសារបង្រៀនថ្នាក់បណ្ឌិត ឆ្នាំ២០១៩ ទំព័រ ៧០។

[១៦] សយ រាសី "*កំណែទម្រង់រដ្ឋបាលសាធារណៈ*" ឯកសារបង្រៀនថ្នាក់បណ្ឌិត ឆ្នាំ២០១៩ ទំព័រ ៧១។

៤- តាមពិតវិមជ្ឈការ ក៏មានចំណុចខ្វះខាត និងកំហុសឆ្គងដែរ ប៉ុន្តែ វិមជ្ឈការគឺជាគម្រោងសង្គមដែលឆ្លើយតបនឹងសង្គមសម័យទំនើបគឺ "ការចង់រស់នៅរួមគ្នា" អាចរៀបចំបានតែនៅក្បែរជិតប្រជាពលរដ្ឋប៉ុណ្ណោះ។

ជាសរុបមក វិមជ្ឈការ បានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់សង្គមមនុស្សជាតិ ព្រោះថា វាជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាភាពក្រីក្រ វិសមភាពយេនឌ័រ បញ្ហាបរិស្ថាន និងការលើកកម្ពស់ការថែទាំសុខភាព ការអប់រំ និងការទទួលបានបច្ចេកវិទ្យា។ ទន្ទឹមនេះ វិមជ្ឈការ មិនត្រឹមតែជះឥទ្ធិពលដល់រដ្ឋាភិបាល និងការផ្តល់សេវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាលក្ខខណ្ឌចាំបាច់ក្នុងការទាក់ទាញអង្គការសហគមន៍ អ្នកពាក់ព័ន្ធក្នុងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងប្រជាពលរដ្ឋថែមទៀតផង[១៧]។

## ២.៣. ការគ្រប់គ្រងរដ្ឋបាលតាមបែបវិសហមជ្ឈការ

ដើម្បីបន្ថយផលអាក្រក់ចំពោះការប្រមូលផ្តុំអំណាចទៅលើរដ្ឋបាលកណ្តាល នៃប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការ រដ្ឋបាលកណ្តាលមានវិធានការបែងចែកអំណាចកណ្តាល ឱ្យទៅភ្នាក់ងាររដ្ឋដែលនៅតាមទីកន្លែងជាប់ជាមួយប្រជាពលរដ្ឋ ហើយប្រទេសជាច្រើននៅលើពិភពលោកបានអនុវត្តប្រព័ន្ធនេះ ដើម្បីឱ្យរដ្ឋបាលកណ្តាលធ្វើការចែករំលែកអំណាច និងការទទួលខុសត្រូវមួយផ្នែកលើកិច្ចការរដ្ឋ ដោយឱ្យអាជ្ញាធររដ្ឋតាមថ្នាក់រដ្ឋបាល អនុវត្តតាមគោលដៅធ្វើឱ្យសេវាកម្មរបស់រដ្ឋខិតជិតមុខសញ្ញាដែលទទួល នោះគេហៅថា "វិសហមជ្ឈការ"[១៨]។ យើងក៏អាចនិយាយបានថា វិសហមជ្ឈការនេះគឺជាការធ្វើបដិភាគរដ្ឋបាលនៃវិមជ្ឈការ[១៩]។ បើតាមឯកសារស្រាវជ្រាវ ដកស្រង់ ប្រែសម្រួលពីឯកសារគោលនយោបាយរបស់ប្រទេសបារាំង និងចងក្រងដោយក្រុមការងារ គ.ជ.អ.ប. នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បានសរសេរថា "ត្រូវជម្នះការធ្វើវិសហមជ្ឈការថ្មីរបៀបសត្វលូន"[២០]។ ឧទាហរណ៍៖ រដ្ឋបាលកណ្តាលខ្លះធ្វើការណែនាំលម្អិតពេក រហូតមូលដ្ឋានពុំមានសេសសល់លទ្ធភាពសម្រាប់សម្របសម្រួលជាមួយស្ថានភាពរបស់ខ្លួន។

បើតាមឯកសារផ្សេងទៀតបាននិយាយថា "វិសហមជ្ឈការ" គឺជាបច្ចេកទេសរដ្ឋបាលមួយប្រភេទដែលអាជ្ញាធររដ្ឋបាលកណ្តាលរំលែកកិច្ចការមួយចំនួនទៅឱ្យរដ្ឋបាលមូលដ្ឋាន ធ្វើការសម្រេចចិត្តដោយខ្លួនឯង តាមរយៈការធ្វើការប្រតិភូកម្មដោយមានកំណត់ក្នុងបទបញ្ជា។ ប៉ុន្តែការធ្វើប្រតិភូកម្មអំណាច

---

[១៧] Robertson Work, *Overview of Decentralization Worldwide: A Stepping Stone to Improved Governance and Human Development* in 2nd International Conference on Decentralization, 25-27 July, 2002

[១៨] រាជរដ្ឋាភិបាលកម្ពុជា "*សិក្ខាសាលាស្តីពី វិមជ្ឈការ និងវិសហមជ្ឈការ ថ្ងៃទី២៨-២៩ ខែកុម្ភៈ ឆ្នាំ២០០០*" ភ្នំពេញ ឆ្នាំ ២០០០ ទំព័រ ១២។

[១៩] បដិភាគរដ្ឋបាលនៃវិមជ្ឈការ គឺចង់និយាយពី អ្នកជាប់ឆ្នោត និងអ្នកប្រើប្រាស់ត្រូវការគូសន្ទនាដែលមានសិទ្ធិសម្រេចឆាប់រហ័ស ដោយបែបបទខ្លី។

[២០] រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ "*បទពិសោធន៍របស់ប្រទេសបារាំងក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ*" ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ២៨។

នេះមិនមែនមានន័យថា ប្រគល់សិទ្ធិឱ្យសម្រេចដោយស្វ័យភាពក្នុងនាមជានីតិបុគ្គលនោះទេ។ ផ្ទុយទៅវិញ ការប្រគល់សិទ្ធិអំណាចឱ្យសម្រេចក្នុងនាមរដ្ឋដែលមានលក្ខខណ្ឌយ៉ាងច្បាស់លាស់ ដោយធ្វើជាលាយលក្ខណ៍អក្សរពីការកំណត់ព្រំដែននៃសិទ្ធិ និងស្ថិតនៅក្រោមការត្រួតពិនិត្យតាមឋានានុក្រមយ៉ាងហ្មត់ចត់ថែមទៀតផង។ ការអនុវត្តប្រព័ន្ធនេះនឹងនាំឱ្យមានការកាត់បន្ថយការប្រើប្រាស់អំណាចជ្រុលហួសហេតុ របស់អាជ្ញាធររដ្ឋបាលកណ្តាល ជួយសម្រួលជីវភាព និងកិច្ចការរបស់ប្រជាជន ព្រមទាំងការងារឆាប់រហ័ស និងកាត់បន្ថយការចំណាយ។ ទន្ទឹមនឹងនេះ វិសហមជ្ឈការ ក៏អាចនាំឱ្យមានបញ្ហាប្រឈមមួយចំនួនដូចជា ខ្វះលទ្ធិប្រជាធិបតេយ្យ អាជ្ញាធរមូលដ្ឋានគ្មានសមត្ថកិច្ចផ្ទាល់ និងគ្មានបុគ្គលភាពគតិយុត្តជាដើម។ល។ ដែលចំណុចនេះ ត្រូវនឹងនិយមន័យ វិសហមជ្ឈការ គឺជាការចែករំលែកសិទ្ធិអំណាច និងការទទួលខុសត្រូវពីបណ្តាការិយាល័យនៅថ្នាក់កណ្តាល ទៅឱ្យបណ្តាការិយាល័យរបស់ថ្នាក់ជាតិនៅឯមូលដ្ឋាន[២១]។

សរុបមក វិសហមជ្ឈការ ជាប្រព័ន្ធមួយដែលត្រូវបានរដ្ឋបាលកណ្តាលធ្វើការចែករំលែកសិទ្ធិអំណាច និងការទទួលខុសត្រូវមួយផ្នែកលើកិច្ចការរដ្ឋ តាមរយៈការធ្វើប្រតិភូកម្មអំណាច។ ប្រតិភូកម្មអំណាចនេះ គឺជាវិធីសាស្ត្រក្នុងការប្រគល់សិទ្ធិអំណាចលើកិច្ចការនានា ហើយដែលជួនកាលគេបញ្ជាក់ដោយពាក្យទូទៅមួយថា "ប្រតិភូកម្មសមត្ថកិច្ច"។ ប្រតិភូកម្មប្រភេទនេះចែកចេញជាពីរគឺ៖ ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា។

ជារួម ក្នុងការគ្រប់គ្រងរដ្ឋបាលតាមបច្ចេកទេសនេះគឺជាគ្រប់គ្រងតាមឋានានុក្រមរដ្ឋបាល ដែលរដ្ឋបាលកណ្តាលបានផ្តល់ឱ្យសម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។ រាល់ប្រព័ន្ធការងារគឺតំណាងរដ្ឋបាលកណ្តាលដោយគ្មានការបោះឆ្នោតជ្រើសតាំងអ្វីទេ ពោលគឺ អាជ្ញាធរមូលដ្ឋានកើតមានឡើងនូវសិទ្ធិក្នុងការសម្រេច អាស្រ័យដោយសប្បុរសធម៌របស់អាជ្ញាធររដ្ឋបាលថ្នាក់កណ្តាលប៉ុណ្ណោះ ហើយអាជ្ញាធរមូលដ្ឋានគ្មានថវិកាផ្ទាល់ខ្លួនទេ គឺប្រើថវិការបស់ជាតិ ហើយក៏គ្មានសិទ្ធិក្នុងការជ្រើសរើសបុគ្គលិកដែរ[២២]។ ជាមួយគ្នានេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិសហមជ្ឈការនេះ គឺមានគោលបំណងជាសារវន្ត ដូចខាងក្រោម៖

- កែលម្អការអនុវត្តមុខងាររបស់រដ្ឋ ដោយនាំយកមុខងារ និងភារកិច្ចទាំងឡាយរបស់រដ្ឋឱ្យកាន់តែខិតជិតប្រជាពលរដ្ឋ។
- ពង្រឹងរដ្ឋបាលដែនដីរបស់រដ្ឋ មានដូចជា រដ្ឋបាលខេត្ត និងរដ្ឋបាលស្រុកជាដើម។ អភិបាលខេត្ត អភិបាលស្រុក មន្ទីរជំនាញ និងការិយាល័យជំនាញស្រុក បានទទួលអំណាចពីរដ្ឋាភិបាល ក្នុងការធ្វើសេចក្តីសម្រេចចិត្តមួយចំនួនជំនួសមុខឱ្យរដ្ឋាភិបាល និងជំនួសមុខឱ្យអាជ្ញាធរកណ្តាលនៅតាមក្រសួង ស្ថាប័ននានា។

---

[២១] សយ រាសី *«កំណែទម្រង់រដ្ឋបាលសាធារណៈ»* ឯកសារបង្រៀនថ្នាក់បណ្ឌិត ឆ្នាំ២០១៩ ទំព័រ ៧១។

[២២] សឿន សោភ័ណ *"សេចក្តីផ្តើមរដ្ឋបាលសាធារណៈ"* ភ្នំពេញ ឆ្នាំ ២០០៩ ទំព័រ ១៣៧។

ជាសន្និដ្ឋានៈ

១- វិសហមជ្ឈការគឺជាការអនុវត្តតាមសុភវិនិច្ឆ័យ នៃគោលការណ៍ជាជំនួយដល់ការប្រតិបត្តិនៅថ្នាក់ដែលសមស្រប។

២- វិសហមជ្ឈការ គឺជាបដិភាគរដ្ឋបាលនៃវិមជ្ឈការ (អ្នកជាប់ឆ្នោត និងអ្នកប្រើប្រាស់ ត្រូវជាគូសន្ទនាដែលមានសិទ្ធិសម្រេចឆាប់រហ័សដោយបែបបទខ្លី)។

៣- វិសហមជ្ឈការ គឺជាគន្លាស់នៃកំណែទម្រង់។

៤- វិសហមជ្ឈការចាំបាច់ត្រូវអនុវត្តដោយគ្មានអន្តរាគមន៍។ បើការគ្រប់គ្រងមធ្យោបាយ (ថវិកាសម្រាប់ដំណើរការ និងការគ្រប់គ្រងបុគ្គលិក) ត្រូវធ្វើវិសហមជ្ឈការទូលំទូលាយ និងទាំងស្រុងជាសំណូមពរ គប្បីមានតម្លាភាពពិតប្រាកដនៃការកំណត់ឥណទាន មានវិសហមជ្ឈការពិតប្រាកដនៃយន្តការធ្វើឱ្យប្រសើរឥណទាន និងពិសេស ការរួចពន្ធសម្រាប់ការធ្វើឱ្យរៀបរយ ដែលជាលក្ខខណ្ឌនៃទំនើបកម្ម និងការទទួលខុសត្រូវរបស់សេវាវិសហមជ្ឈការ។ អាស្រ័យហេតុនេះ ត្រូវធ្វើឱ្យច្បាស់លាស់ពីសមត្ថកិច្ច និងបង្កើនការសម្រេចរបស់សមូហភាពមូលដ្ឋាន។

## ២.៤. ការគ្រប់គ្រងតាមបែបចម្រុះ

ឥទ្ធិពលនៃសេរីភាពបែបថ្មីដែលកើតមានក្នុងទសវត្សរ៍ទី៨០ និងទសវត្សរ៍ទី៩០ ដែលគេបានដឹងថា ប្រជាជនម្នាក់ៗពិតជាត្រូវការនូវស្ថាប័ននានារបស់រដ្ឋមានលក្ខណៈប្រជាធិបតេយ្យ សមត្ថភាពក្នុងការគ្រប់គ្រងប្រភពធនធាននានារបស់រដ្ឋ និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈនានានោះក្តី ក៏មានការក្រោកឈរប្រឆាំងទៅនឹងការប្រើប្រាស់អំណាចខ្លាំងជាសកលផងដែរ។ ជាតុពិត ប្រជាជនប្រាថ្នាចង់បានរដ្ឋ និងរដ្ឋបាលសាធារណៈដែលប្រព្រឹត្តជាអ្នកជំរុញសេដ្ឋកិច្ច និងសង្គម មានសមត្ថភាពនឹងធ្វើការបែងចែកកាលានុវត្តភាពឱ្យបានប្រកបដោយសមធម៌ ការគ្រប់គ្រងប្រកបដោយចីរភាពលើប្រភពធនធានផ្សេងៗ មានកាលានុវត្តភាពស្មើគ្នាទាំងខាងនយោបាយ សេដ្ឋកិច្ច និងវប្បធម៌។ ការអភិវឌ្ឍសេដ្ឋកិច្ចគឺមានសារៈសំខាន់ណាស់ គេត្រូវកសាងរដ្ឋបាលសាធារណៈមួយឱ្យមានវិចារណញ្ញាណហើយសារៈសំខាន់នេះវាមានភាពចាំបាច់ជាងការចង់បានតែការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលមានលក្ខណៈសេរី។ ដោយសារការចង់បាននេះហើយ ទើបប្រទេសនីមួយៗបង្កើតគោលការណ៍រៀបចំឱ្យមានប្រព័ន្ធរដ្ឋបាលថ្មីមួយរៀងៗខ្លួន នោះគឺការចែករំលែកអំណាចរបស់ថ្នាក់លើទៅឱ្យថ្នាក់ក្រោមសម្រេចក្នុងនាមខ្លួន ដែលប្រព័ន្ធនេះគេហៅថា ប្រព័ន្ធវិសហមជ្ឈការ តាមរយៈការធ្វើប្រតិភូកម្មអំណាច (ឬប្រតិភូកម្មសមត្ថកិច្ច) និងប្រព័ន្ធវិមជ្ឈការ (វិមជ្ឈការនយោបាយ និង Devolution) ដែលត្រូវបានគេប្រគល់សិទ្ធិឱ្យធ្វើការសម្រេចក្រោមលក្ខខណ្ឌច្បាប់ និង អំណាចអាណាព្យាបាល[២៣]។

នៅក្នុងការគ្រប់គ្រងរដ្ឋទំនើបមួយដែលមានលក្ខណៈប្រជាធិបតេយ្យ គឺត្រូវតែផ្សំបញ្ចូលគ្នារវាងការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ព្រោះថា ប្រព័ន្ធគ្រប់គ្រងទាំងពីរនេះបានបំពេញឱ្យ

---

[២៣] កៅ មុយថង "*រដ្ឋបាលសាធារណៈទំនើប - Modern Public Administration*" ភ្នំពេញ បណ្ណាគារអង្គរ បោះពុម្ពលើកទី ១ ឆ្នាំ២០០៧ ទំព័រ ៣៨ ។

គ្នាទៅវិញទៅមកក្នុងគោលបំណងរួមគឺសំដៅកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវានានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ទន្ទឹមនឹងការគ្រប់គ្រងរដ្ឋបាលតាមបែបមជ្ឈការមិនត្រូវបានបោះបង់ចោលដែរ ព្រោះថា ការគ្រប់គ្រងរដ្ឋប្រភេទនេះគឺមានចរិតជាយុទ្ធសាស្ត្រជាតិ ឬជាកិច្ចការដែលធានាដល់ផលប្រយោជន៍រួម ឬធានានូវឯកភាពជាតិ ឬអធិបតេយ្យភាពជាតិ មានដូចជា ការពារជាតិ សន្តិសុខជាតិ ការបោះពុម្ពក្រដាសប្រាក់ និងនយោបាយការបរទេស។ល។

## ៣. សេចក្តីសន្និដ្ឋាន

ជាសន្និដ្ឋាន ក្នុងស្ថានភាពជាក់ស្តែងរបស់កម្ពុជាបច្ចុប្បន្ន ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវតែជ្រើសរើសយកប្រព័ន្ធចម្រុះ គឺ វិមជ្ឈការ និងវិសហមជ្ឈការ។ ក្នុងការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវគោលដៅជាយុទ្ធ-សាស្ត្រចំនួនបីគឺ៖ (១)ពង្រឹងនិងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅមូលដ្ឋាន (២)លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និង (៣)ជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងតម្រូវការចាំបាច់នានានៅមូលដ្ឋាន សំដៅលើកកម្ពស់ភាពជាម្ចាស់របស់សហគមន៍មូលដ្ឋាន[២៤]។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណងដ៏ទូលំទូលាយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺបង្កើតវប្បធម៌ប្រជាធិបតេយ្យនៅមូលដ្ឋានដោយមានការចូលរួមពីប្រជាពលរដ្ឋ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាននីមួយៗ លើកស្ទួយគុណភាពជីវិត និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម[២៥]៕

---

[២៤] រាជរដ្ឋាភិបាលកម្ពុជា *"សៀវភៅណែនាំស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ"* ឆ្នាំ២០០៩ ទំព័រ ៨ ។

[២៥] រាជរដ្ឋាភិបាលកម្ពុជា *"កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០២១-២០៣០"* ឆ្នាំ២០២១ ទំព័រ ii ។

# គន្ថនិទ្ទេស

## ក. ឯកសារខេមរៈភាសា


១- កៅ មុយថង៖ *រដ្ឋបាលសាធារណៈទំនើប- Modern Public Administratio* ភ្នំពេញ រោងពុម្ព បណ្ណាគារ អង្គរ បោះពុម្ពលើកទី១ ឆ្នាំ២០០៧ ទំព័រ ៨, ៣៨

២- រាជរដ្ឋាភិបាលកម្ពុជា៖ *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥- ២០១៨* ឆ្នាំ២០១៥ - ឧបសម្ព័ន្ធទី៣ "សន្ទានុក្រម"

៣- រាជរដ្ឋាភិបាលកម្ពុជា៖ *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០២១-២០៣០* ឆ្នាំ២០២១ ទំព័រ ii

៤- រាជរដ្ឋាភិបាលកម្ពុជា៖ *សិក្ខាសាលាស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ថ្ងៃទី២៨-២៩ ខែកុម្ភៈ ឆ្នាំ ២០០០* ភ្នំពេញ ឆ្នាំ២០០០ ទំព័រ១២

៥- រាជរដ្ឋាភិបាលកម្ពុជា៖ *សៀវភៅណែនាំស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ* ឆ្នាំ២០០៩ ទំព័រ៨

៦- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ៖ "*បទពិសោធន៍របស់ប្រទេសបារាំងក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ*" ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ២៨

៧- សយ រាសី៖ *កំណែទម្រង់រដ្ឋបាលសាធារណៈ* ឯកសារបង្រៀនថ្នាក់បណ្ឌិត ឆ្នាំ២០១៩ ទំព័រ ៧០, ៧១

៨- សាយ បូរី៖ *នីតិរដ្ឋបាលទូទៅ - Droit Administratif Général* ភ្នំពេញ បណ្ណាគារអង្គរ បោះពុម្ពលើកទី៤ ឆ្នាំ២០១២ ទំព័រ ៣៩៤

៩- សឿន សោភ័ណ៖ *សេចក្តីផ្តើមរដ្ឋបាលសាធារណៈ* ភ្នំពេញ ឆ្នាំ២០០៩ ទំព័រ ១៣១, ១៣៧

១០- ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ៖ *វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន តាមបែបប្រជាធិបតេយ្យនៅកម្ពុជា* ភាគ I ខែតុលា ឆ្នាំ២០០២ ទំព័រ ៦


## ខ. ឯកសារបរទេស


១- Alan R, Nakervis, Robert L.Compton and Terence E.McCarthy 3rd Edition, *Strategic Human Resources Management*, Kin Keong, Singapore

២- Cooper and Schindle, 2001, 7th Edition, *Business Reseach Methodologies*, McGraw-Hill, USA

៣- Pigors and Mayers,1973:9, *Personnel Administration: a point of view and a method*

៤- Robertson Work, *Overview of Decentralization Worldwide: A Stepping Stone to Improved Governance and Human Development* in 2nd International Conference on Decentralization, 25-27 July, 2002

៥- Shafritz, Jay M.and Russell E.W., 1997, *Introducing Public Administration. An imprint of Addison Wesley Longman*, Inc.

# ឥទ្ធិពលអាករលើតម្លៃបន្ថែមលើកំណើនសេដ្ឋកិច្ចកម្ពុជា

បេក្ខជនបណ្ឌិត៖ គង់ ចន្ថា
ជំនាញ៖ វិទ្យាសាស្ត្រសេដ្ឋកិច្ច

## ១. ទិដ្ឋភាពការអាករលើតម្លៃបន្ថែម

នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៩៧ ច្បាប់ស្តីពីសារពើពន្ធត្រូវបានរដ្ឋសភាអនុម័តនាសម័យប្រជុំលើកទី៧ នីតិកាលទី១ និងប្រកាសឱ្យប្រើប្រាស់ជាលើកដំបូង[១]។ ចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៨ អាករលើតម្លៃបន្ថែមត្រូវបានបង្កើតឡើងចំពោះការផ្គត់ផ្គង់ជាប់អាករ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ[២]។ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលបានកំណត់បណ្តាទំនិញដែលនាំចូលត្រូវបង់អាករលើតម្លៃបន្ថែមតាមអត្រា១០ភាគរយនៃតម្លៃជាប់អាករ[៣]។ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវប្រកាសស្តីពីអាករលើតម្លៃបន្ថែម[៤]។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យកំណត់វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រង និងអនុវត្តអាករលើតម្លៃបន្ថែមលើកដំបូងហៅកាត់ថា អតប លើការផ្គត់ផ្គង់ទំនិញ ឬសេវានៅកម្ពុជា[៥]។ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលសម្រេចបង់ អតប ជំនួសក្រុមហ៊ុន ឬរោងចក្រ បន្ទាប់មកក្រុមហ៊ុន ឬរោងចក្រត្រូវទូទាត់សងរដ្ឋវិញនៅពេលក្រុមហ៊ុន ឬរោងចក្រពុំបានធ្វើការនាំចេញពិតប្រាកដតាមការកំណត់។បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏បានឯកភាពលើទស្សនៈគោលនយោបាយផ្តល់ការលើកទឹកចិត្តការផលិតពងមាន់ជំនួយដល់ការផ្គត់ផ្គង់ម្ហូបអាហារបន្ថែម ក្នុងពេលដែលផលិតផលនៃសាទត្រីថយចុះរួមមាន លើកលែងការបង់អតបចំពោះវត្ថុធាតុដើមទិញចំណីសត្វ ហើយការបង់អតបត្រូវជាបន្ទុករបស់រដ្ឋចំពោះការលក់ចេញផលិតផលដែលបានពីការធ្វើបសុកម្ម[៦]។ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០០ រាជរដ្ឋាភិបាលផ្តល់នូវយន្តការឱ្យអនុវត្តអាករលើតម្លៃបន្ថែមចំពោះសហគ្រាសផលិត និងផ្គត់ផ្គង់ថាមពលអគ្គិសនីត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់មិនជាប់អាករ[៧]។ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១ រដ្ឋាភិបាលបានដាក់ឱ្យអនុវត្តអាករលើតម្លៃបន្ថែមជាបន្ទុករដ្ឋលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួនសម្រាប់ទិសដៅកសិកម្ម និងត្រូវបូកសរុបជាចំណូលថវិកាប្រចាំខែ ហើយត្រូវកត់ត្រាក្នុងចំណាយអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ[៨]។ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ អាករលើតម្លៃបន្ថែមលើ

---

[១] ច្បាប់ស្តីសារពើពន្ធ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧។

[២] -ដ-។

[៣] ប្រកាសលេខ១០៣៧ ប្រកសហវ គរ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការណែនាំការអនុវត្តច្បាប់ស្តីពីសារពើពន្ធចំពោះអតប។

[៤] ប្រកាសលេខ ១០៣១ ប្រក សហវ ពដ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីអាករលើតម្លៃបន្ថែម។

[៥] អនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

[៦] លិខិតលេខ១១០ សជណ.ផក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ស្តីពីករណីអនុវត្តអាករលើតម្លៃបន្ថែម( VAT )លើជាតុចូលដែលនាំចូលដោយរោងចក្រផលិតសម្លៀកបំពាក់សម្រាប់នាំចេញ។

[៧] ប្រកាសលេខ៦០៥ ប្រក.សហវ.ពដ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០០ស្តីពីការអនុវត្ត អតប ចំពោះការផ្គត់ផ្គង់ថាមពលអគ្គិសនី។

[៨] ប្រកាសលេខ ៣០៣ សហវ.ពដ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួន។

ការនាំចូលធាតុនៃផលិតកម្ម និងសម្ភារៈបរិក្ខារផលិតកម្មសម្រាប់ផលិតបម្រើឱ្យការផ្គត់ផ្គង់ដោយផ្ទាល់ដល់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភណ្ឌ និងឧស្សាហកម្ម ផលិតស្បែកជើងត្រូវបានចាត់ទុកជាបន្ទុករដ្ឋ[៩]។ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ យន្តការអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋចំពោះមុខទំនិញសរសៃអំបោះសូត្រនាំចូលត្រូវបានដាក់ឱ្យអនុវត្ត[១០]។ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ស្របតាមគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល យន្តការលើកទឹកចិត្តពន្ធមួយចំនួនបន្ថែម ចំពោះសហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញរួមមាន ការផ្គត់ផ្គង់ស្រូវក្នុងស្រុក និងការនាំចេញអង្ករ ត្រូវជាប់អាករលើតម្លៃបន្ថែម 0% (សូន្យភាគរយ) ហើយអាករលើធាតុចូលដែលទាក់ទិននឹងការដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញត្រូវបានអនុញ្ញាតជាឥណទានឬបង្វិលសងអាករ[១១]។ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាល បានដាក់ចេញនូវយន្តការអនុគ្រោះមួយចំនួន ក្នុងការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ កាបូបដៃ ឧស្សាហកម្មផលិតមួក និងទំនិញនិងសេវា ដែលបានផ្គត់ផ្គង់ដោយឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាកម្រិតត្រឹមតែសំបកវេចខ្ចប់ សរសៃអំបោះ កំណាត់ ឡេវ ខ្សែរូត ទំពក់ព្យួរ តង្កៀប សម្លៀកបំពាក់ និងគ្រឿងភ្ជាប់នឹងសម្លៀកបំពាក់ ស្បែកជើង កាបូប និងមួក ព្រមទាំងសេវាបោកគក់ ជ្រលក់ បោះពុម្ពលើកំណាត់ ឬសម្លៀកបំពាក់ដេរប៉ាក់[១២] ។ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានសម្រេចសម្រួលយន្តការអាករលើតម្លៃបន្ថែម ដើម្បីលើកកម្ពស់សកម្មភាពកសិកម្ម ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច លើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួនដូចជា ជីកសិកម្មគ្រប់ប្រភេទ ពូជដំណាំគ្រប់ប្រភេទ បសុឱសថ ចំណីសត្វ ចំណីបន្ថែម ពូជសត្វគ្រប់ប្រភេទ គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មដែលអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ[១៣]។ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវយន្តការអាករលើតម្លៃបន្ថែមលើការផលិត និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់ដោយត្រូវបានកំណត់ជាការផ្គត់ផ្គង់មិនជាប់អាករ ដើម្បីជួយសម្រួល និងលើក

---

[៩] ប្រកាសលេខ២៩៨ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬ អ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់ផលិតផលឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង។

[១០] ប្រកាសលេខ៥៤០ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងការដាក់អាករលើតម្លៃបន្ថែមជាបន្ទុករដ្ឋជាបណ្តោះអាសន្នលើមុខទំនិញសរសៃអំបោះសូត្រនាំចូល។

[១១] ប្រកាសលេខ៧៧៩ សហវ.ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ស្តីពីការលើទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ។

[១២] ប្រកាសលេខ ៣១១ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៤ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក។

[១៣] ប្រកាសលេខ ៣១២ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០១៤ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួន។

កម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ[១៤]។ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានផ្ដល់នូវការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះវិស័យអប់រំមានគោលបំណងដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណវុឌ្ឍិខ្ពស់ និងជួយសម្រាលបន្ទុកចំណាយរបស់មាតាបិតា អាណាព្យាបាលសិស្ស និស្សិត និងក្នុងគោលដៅកំណត់នូវយន្តការក្នុងការអនុវត្តពន្ធលើប្រាក់ចំណេញ ពន្ធកាត់ទុក និងអាករលើតម្លៃបន្ថែមសម្រាប់គ្រឹះស្ថានសិក្សានៅព្រះរាជាណាចក្រកម្ពុជា[១៥]។ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវយន្តការ លើកលែងអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ក្នុងគោលដៅជួយគាំទ្រគោលនយោបាយនាំចេញអង្ករ និងជួយសម្រាលបន្ទុកចំណាយរបស់ប្រជាជនក្នុងការប្រើប្រាស់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដែលក្នុងនោះមានគ្រាប់ធញ្ញជាតិនានារួមទាំងស្រូវអង្ករផង[១៦]។ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានអនុវត្តអាករលើតម្លៃបន្ថែម ចំពោះការផ្គត់ផ្គង់មិនជាប់អាករនូវទំនិញឬសេវាមួយចំនួន ដូចមានចែងក្នុងមាត្រា៥៧ នៃ ច.ស.ប សំដៅធានាបាននូវសង្គតិភាពក្នុងការអនុវត្តអាករលើតម្លៃបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋ លើការប្រើប្រាស់ទំនិញ ឬសេវាចាំបាច់មួយចំនួនក្នុងជីវភាពរស់នៅប្រចាំថ្ងៃ[១៧]។ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានសម្រេចផ្ដល់ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល និងអាករលើតម្លៃបន្ថែមដល់ឧស្សាហកម្មក្នុងស្រុក ដើម្បីជំរុញការនាំចេញ និងបង្កើតការងារដល់កម្មករ កម្មការនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា[១៨]។ រាជរដ្ឋាភិបាល នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៨ បាន ប្រកាសដាក់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារមូលដ្ឋាន ក្នុងគោលដៅដើម្បីជួយសម្រួលជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ[១៩]។ ដើម្បីជំរុញ និងគាំទ្រដល់ផលិតកម្ម ការផ្គត់ផ្គង់ក្នុងស្រុក ឬការនាំចេញនូវផលិតផលកសិកម្ម នៅថ្ងៃទី១១ ខែមីនា ឆ្នាំ ២០១៩ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការលើកទឹកចិត្តផ្នែកពន្ធដារ ដែលអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ អនុវត្តចំពោះសហគ្រាសផលិត ផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញស្រូវ អង្ករ ពោត សណ្ដែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ ដែលសហគ្រាសមិនត្រូវគិតអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់របស់ខ្លួនទេ ប៉ុន្តែត្រូវបានអនុញ្ញាតឥណទានអាករលើធាតុចូលដែលទាក់ទិននឹងការផ្គត់ផ្គង់[២០]។

---

[១៤] ប្រកាសលេខ ៦៩០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែ មេសា ឆ្នាំ ២០១៥ ស្ដីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផលិតនិងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់។

[១៥] ប្រកាសលេខ៩០៤ ចុះថ្ងៃទី សហវ.ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ស្ដីពីការលើកទឹកចិត្តពន្ធដារចំពោះគ្រឹះស្ថានសិក្សា។

[១៦] ប្រកាសលេខ ៤៩៥ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ។

[១៧] ប្រកាសលេខ៥៥៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ។

[១៨] ប្រកាសលេខ ៧៤១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០១៨ ស្ដីពីវិធាន និងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធអាករនានាទាក់ទិននឹងសកម្មភាពកាត់ដេរ និងតម្រឹម របស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

[១៩] ប្រកាសលេខ៣៦១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៨ ស្ដីពីការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

[២០] ប្រកាសលេខ ២៥២ សហវ.ប្រក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ ២០១៩ ស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសផលិតផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ ស្រូវ អង្ករ ពោត សណ្ដែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ។

## ២. អាករលើតម្លៃបន្ថែម

អាករលើតម្លៃបន្ថែមជាប្រភេទពន្ធសំខាន់មួយ ហើយពន្ធនេះប្រមូលពីអ្នកប្រើប្រាស់ទំនិញ និងសេវានៅកម្ពុជា។ អាករនេះចាប់ផ្ដើមអនុវត្តដំបូងនៅកម្ពុជានៅឆ្នាំ១៩៩៩ ក្រោមច្បាប់ស្ដីពីសារពើពន្ធឆ្នាំ១៩៩៧ និងអនុក្រឹត្យលេខ១១៤ អនក្រ.បក ស្ដីពីការអាករលើតម្លៃបន្ថែមឆ្នាំ១៩៩៩។ នៅឆ្នាំអនុវត្តការប្រមូលអាករលើតម្លៃបន្ថែមដំបូង រាជរដ្ឋាភិបាលប្រមូលអាករបានចំនួន ៤៤ ៥៤៩លានរៀលក្នុងឆ្នាំ១៩៩៩ ហើយកំណើននៃការប្រមូលចំណូលពន្ធប្រភេទនេះមានការកើនឡើងជាបន្តបន្ទាប់។ ក្នុងរយៈពេលជាងពីរទសវត្សរ៍ អត្រាកំណើនអាករនេះជាមធ្យមប្រចាំឆ្នាំប្រមាណ ១៩,៦២% គិតមកដល់ឆ្នាំ២០២២។ ក្រោមការដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម(២០១៤-២០១៨) ចំណូលអាករនេះកើនពី ១ ១៧២ ៤៩៦លានរៀល ដែលស្មើនឹង៩,២៥% ធៀបនឹងឆ្នាំ២០១៣ ហើយបន្តកើនឡើងដល់ ៣ ២៨២ ០៨០លានរៀល គិតត្រឹមឆ្នាំ២០២២ដែលស្មើនឹង៣១,៦៩% ធៀបនឹងឆ្នាំ២០២១។

រូបភាព១៖ អាករលើតម្លៃបន្ថែមចាប់ពីឆ្នាំ១៩៩៩-២០២២ (គិតជាលានរៀល)




ប្រភព៖ ច្បាប់ស្ដីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ(១៩៩៤-២០២២)។

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះសង្កេតឃើញថា កំណើនអត្រាអាករលើតម្លៃបន្ថែមមាននិន្នាការថយចុះផងដែរ ពោលគឺកំណើនកើនឡើងជាមធ្យមប្រមាណ១១,៨២% (ឆ្នាំ២០១៣ ដល់ ២០២២) ក្នុងនោះឆ្នាំ២០១៨ អាករប្រភេទនេះសម្រេចបានគិតជាទឹកប្រាក់ចំនួន ២ ១០១ ២៤៨លានរៀលស្មើនឹង -២,៧១% និងសម្រេចបានចំនួន ២ ៦៩០ ២៦៨លានរៀល ស្មើនឹង-២,៩៥% ក្នុងឆ្នាំ២០២០ ព្រមទាំងថយចុះ-៧,៥៧% ក្នុងឆ្នាំ២០២១ ដែលគិតជាទឹកប្រាក់ប្រមាណ ២ ៤៨៧ ២០០ លានរៀល។ ការថយចុះចំណូលអាករនេះបណ្ដាលមកពីការអនុវត្តវិធានការគោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាល តាមរយៈការអនុគ្រោះពន្ធ និងការលើកលែងពន្ធលើវិស័យអទិភាពមួយចំនួនដូចជាវិស័យកសិកម្ម សេវាកម្ម និងឧស្សាហកម្មជាដើម។ ជាពិសេស ការបិទខ្ទប់សកម្មភាពសេដ្ឋកិច្ចក្នុងប្រទេស ដែលបណ្ដាលមកពីការរីករាលដាលនៃជំងឺកូវីដ១៩ក្នុងរយៈកាលកន្លងមក។ (សូមមើលរូបភាព២ ស្ដីពីអត្រាកំណើនអាករលើតម្លៃបន្ថែមប្រចាំឆ្នាំ)

រូបភាព២៖ អត្រាកំណើនអាករលើតម្លៃបន្ថែមប្រចាំឆ្នាំ




ប្រភព៖ គណនាចេញពីមូលដ្ឋានទិន្នន័យកំណត់ក្នុងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ(១៩៩៩-២០២២)

អាករលើតម្លៃបន្ថែមមានចំនួន០,៣% នៃផលិតផលស្រុកសរុបនៅឆ្នាំ១៩៩៩។ ចាប់ពីឆ្នាំ២០១៣ ទំហំផលធៀបជាមួយផ.ស.ស.របស់អាករប្រភេទនេះមានចំនួន២,៩% និងមានការកើនឡើងជាបន្តបន្ទាប់ រហូតដល់ ៥,៥% គិតត្រឹមឆ្នាំ២០២២។ ក្នុងមួយទសវត្សរ៍ (ឆ្នាំ២០១៣ ដល់២០២២) ចុងក្រោយ ផលធៀបអាករលើតម្លៃបន្ថែមជាមួយ ផ.ស.ស ស្ថិតក្នុងរង្វង់ ៤,០%។ ដូចនេះ អាករលើតម្លៃបន្ថែម ត្រូវបានសង្កេតឃើញថា មានកម្រិតចូលរួមចំណែកនៅក្នុងសេដ្ឋកិច្ច បន្ទាប់ពីពន្ធលើប្រាក់ចំណូល។ (សូមមើលរូបភាព៣ បន្ថែមស្តីពីបំណែងចែកអាករលើតម្លៃបន្ថែមធៀបជាមួយ ផ.ស.ស)

រូបភាព ៣៖ បំណែងចែកអាករលើតម្លៃបន្ថែមធៀបជាមួយ ផ.ស.ស




ប្រភព៖ គណនាចេញពីមូលដ្ឋានទិន្នន័យកំណត់ក្នុងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ និងទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ(១៩៩៩-២០២២)។

## ៣. កំណើនសេដ្ឋកិច្ចនៅកម្ពុជា

ការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយជាតិសំខាន់ៗ ជាពិសេស ការដាក់ចេញនូវគោលនយោបាយកំណែទម្រង់ទៅលើវិស័យអាទិភាព និង

ការអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាលសេដ្ឋកិច្ចកម្ពុជា រក្សាបាននូវកំណើនខ្ពស់គួរឱ្យកត់សម្គាល់ បើទោះបីជាជួបប្រទះបញ្ហាប្រឈមមួយចំនួនក្តី។ ក្នុងរយៈពេលជិតបីទសវត្សរ៍ (១៩៩៤ ដល់ ២០២២) មកនេះ កម្ពុជារក្សាបាននូវអត្រាកំណើនម៉ាក្រូសេដ្ឋកិច្ច ក្នុងរង្វង់ ៦,៧៤% ក្នុងមួយឆ្នាំ ព្រមទាំងសម្រេចបាននូវមហិច្ឆតា ប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ និងមានចក្ខុវិស័យឆ្ពោះទៅសម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ សម្រាប់រយៈពេលខ្លី និងមធ្យម(០៥ឆ្នាំ) ពោលគឺចាប់ពីឆ្នាំ២០០៤ ដល់២០០៨ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាទីមោនទនៈ ជូនជាតិមាតុភូមិ និងប្រជាជន ពោលគឺរក្សាបានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ៨,០៨% ក្នុងនោះសម្រេចបាននូវអត្រាកំណើនជាអតិបរមា ១៣,៣% នៅឆ្នាំ២០០៥ និងកំណើនអប្បបរមាត្រឹមតែ ៦,៧% នៅឆ្នាំ២០០៨។ ការណ៍នេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីការសម្រេចបានការអនុវត្តប្រកបដោយភាពជោគជ័យនូវការដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីមួយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងគោលដៅជំរុញលើកកម្ពស់កំណើនសេដ្ឋកិច្ចបង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ក្នុងសង្គម និងបង្កើនប្រសិទ្ធភាពវិស័យសាធារណៈ សម្រាប់ការអភិវឌ្ឍក្រប្រកដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ អត្រាកំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំសម្រាប់រយៈពេលមធ្យម (២០០៩-២០១៣) ស្ថិតក្នុងរង្វង់ប្រមាណ ៥,៥% ក្នុងនោះអត្រាកំណើនអប្បបរមា ០,១% នៅឆ្នាំ២០០៩ និងអត្រាកំណើនអតិបរមា ៧,៤% នៅឆ្នាំ២០១៣។ ក្នុងន័យនេះ សមទ្ធិផលសម្រេចបានគឺជាផ្លែផ្កានៃការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តសិទ្ធិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់គោលដៅជាសារវន្ត ដើម្បីធានាដល់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព តាមរយៈការបន្តជម្រុញការអនុវត្តវិធានការពិពិធភាវូបនីយកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជាជាដើម។ បន្ទាប់ពីបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបី ឆ្នាំ២០១៣-២០១៨ ក្នុងគោលដៅជាយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ កម្ពុជារក្សាបានអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំសម្រាប់រយៈពេលមធ្យម ៥,៦៣% និងមានកំណើនអតិបរមា ៧,៥% នៅឆ្នាំ២០១៨។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបួន រវាងឆ្នាំ ២០១៨-២០២៣ ត្រូវបានដាក់ចេញ ដើម្បីរក្សាសមទ្ធិផលដែលសម្រេចបានកន្លងមក ក្នុងគោលដៅធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងអត្រាមធ្យមប្រចាំឆ្នាំ៧% និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចថ្មីៗ ដោយទូលំទូលាយ និងមានភាពប្រកួតប្រជែងជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប ការធានាស្ថិរភាពអត្រាប្តូរប្រាក់ ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និងការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់នោះ អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានសម្រាប់រយៈពេលមធ្យម(៤ឆ្នាំ)១,២៧% ប្រចាំឆ្នាំ និងមានអត្រាកំណើនអប្បបរមា -៣,១%នៅឆ្នាំ២០២០។

រូបភាព៤៖ កំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ១៩៩៤-២០២២




ប្រភព៖ទិន្នន័យប្រមូលពីវិទ្យាស្ថានជាតិស្ថិតិ។

ការធ្លាក់ចុះនេះបណ្តាលមកវិបត្តិជំងឺកូវីដ១៩ ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក ក្រោមឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ចចិន និងអាមេរិក ព្រមទាំងវិបត្តិសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ (សូមមើលរូបភាព៤ បន្ថែម ស្តីពីកំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ១៩៩៤-២០២២)។

## ៤. ការវិភាគពីឥទ្ធិពលអាករលើតម្លៃបន្ថែមលើកំណើនសេដ្ឋកិច្ចកម្ពុជា

ផ្អែកលើលទ្ធផលវិភាគក្នុងតារាង១ បង្ហាញថា តម្លៃ F-Value មានចំនួន ៦,៥១៨ ធំជាងតម្លៃដែនកំណត់ខាងលើ(Upper Bounds) I(1) គឺសម្មតិកម្មសូន្យត្រូវបានបដិសេធនៅកម្រិតសារៈសំខាន់ ៥% ពោលគឺគេមានភស្តុតាងគ្រប់គ្រាន់ ដើម្បីអះអាងថា អាករលើតម្លៃបន្ថែមមានទំនាក់ទំនងសមតារយៈពេលវែង(Cointegration)ជាមួយកំណើនសេដ្ឋកិច្ចកម្ពុជា។ ក្នុងរយៈពេលវែង អាករលើតម្លៃបន្ថែមមានតម្លៃ P-Value ស្មើនឹង ០,០០% និងតម្លៃស្ថិតិ t ស្មើនឹង ១០,២៦ ដែលបញ្ជាក់ថា គេមានភស្តុតាងគ្រប់គ្រាន់ដើម្បីបដិសេធសម្មតិកម្មសូន្យនៅកម្រិតសារៈសំខាន់ ១% ៥% និង១០%។ ក្នុងន័យនេះ អាករលើតម្លៃបន្ថែមមានទំនាក់ទំនង និងជះឥទ្ធិពលជាវិជ្ជមានរយៈពេលវែងលើកំណើនសេដ្ឋកិច្ចកម្ពុជា ពោលគឺអាករលើតម្លៃបន្ថែមកើន ១% ជះឥទ្ធិពលជាវិជ្ជមានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាកើនឡើង ០,៣៦% ឬក្នុងកម្រិតជឿជាក់ ៩៥% អាករលើតម្លៃបន្ថែមជះឥទ្ធិពលជាវិជ្ជមានធ្វើឱ្យកំណើនសេដ្ឋកិច្ចកើនឡើងក្នុងចន្លោះ ០,២៩% ដល់ ០,៤៤% ក្នុងរយៈពេលវែង។ ក្នុងរយៈពេលខ្លី អាករលើតម្លៃបន្ថែមមានតម្លៃ P-Value ស្មើនឹង ១០,២% និងតម្លៃស្ថិតិ t ស្មើនឹង ១,៧៣% ដែលអះអាងថា គេមិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបដិសេធសម្មតិកម្មសូន្យនៅកម្រិតសារៈសំខាន់ ១% ៥% និង១០% ពោលអាករលើតម្លៃបន្ថែមមិនមានទំនាក់ទំនង និងជះឥទ្ធិពលរយៈពេលខ្លីជាមួយកំណើនសេដ្ឋកិច្ចកម្ពុជា។ ចំណែកឯ ល្បឿននៃការកែតម្រូវ ($ECM_{t-1}$) អវិជ្ជមានតូចជាង ១ និង មានតម្លៃ P-Value ស្មើនឹង ៥,៩% បដិសេធសម្មតិកម្មសូន្យនៅកម្រិតសារៈសំខាន់ ១០% មានន័យថា គម្លាតរយៈពេលខ្លីចេញពីលំនឹងរយៈពេលវែងក្នុងឆ្នាំមុនត្រូវធ្វើការកែតម្រូវ ៣៤% ដើម្បីឈានទៅដល់កម្រិតលំនឹងរយៈពេលវែងជារៀងរាល់ឆ្នាំ។ ផ្អែកលើលទ្ធផលវិភាគដដែល បានបង្ហាញពី $R^2$ ស្មើនឹង ៤៣,៤០% មានន័យថា អាករ

លើតម្លៃបន្ថែមចូលរួមពន្យល់ពីបំរែបំរួលកំណើនសេដ្ឋកិច្ចបាន៤៣,៤០% នៅក្នុងម៉ូដែល និងបង្ហាញពី $Adj\ R^2$ ស្មើនឹង ៣៦,៧៤% មានន័យថា អាករលើតម្លៃបន្ថែមមានសារៈសំខាន់ក្នុងការចូលរួមជួយពន្យល់ពីបំរែបំរួលកំណើនសេដ្ឋកិច្ចក្នុងម៉ូដែលបាន៣៦,៧៤% ។ ចំណែក ឬសនៃលម្អៀងមធ្យមការេ (Root MSE) ស្មើនឹង ២,៧៣% មានន័យថា លម្អៀងមធ្យមនៃតម្លៃប៉ាន់ស្មានក្នុងម៉ូដែល ជាមួយតម្លៃជាក់ស្តែង មានត្រឹមតែ ២,៧៣% ប៉ុណ្ណោះ។

តារាង១៖ លទ្ធផលនៃការវិភាគពីឥទ្ធិពលអាករលើតម្លៃបន្ថែមលើកំណើនសេដ្ឋកិច្ច

| Variable | Coefficient | Std. Error | t-Statistic | P-Value |
|---|---|---|---|---|
| Co-integration (Long-run relationships) | | | | |
| $\log VAT_t$ | 0.36 | 0.04 | 10.26 | 0.000 |
| 95% Conf. Interval | 0.29 to 0.44 | | | |
| ECM (Short-run relationships) | | | | |
| $\Delta\log VAT_t$ | 0.12 | 0.07 | 1.73 | 0.102 |
| Constant | 4.25 | 1.94 | 2.20 | 0.042 |
| $ECM_{t-1}$ | -0.34 | 0.18 | -2.02 | 0.059 |
| $R^2$=43.40% | $Adj\ R^2$ =36.74% | Root MSE =2.73% | | |
| ARDL Bounds Test | | | | |

| Variables | F-Statistics | K |
|---|---|---|
| F(logGDPG,logVAT) | 6.518 | 1 |
| Critical Value Bounds | I(0) [Lower Bound] | I(1) [Upper Bound] |
| 1% | 6.84 | 7.84 |
| 5% | 4.94 | 5.73 |
| 10% | 4.04 | 4.78 |

ប្រភព៖ គណនាចេញពីកម្មវិធី STATA ១៥.០។

ផ្អែកលើលទ្ធផលសង្ខេបនៃការធ្វើតេស្តសុពលភាពម៉ូដែលបានបង្ហាញថា គ្មានវត្តមាន Serial Correlation និង Heteroskedasticity ក្នុងម៉ូដែលទេ តម្លៃ P-Value នៃការធ្វើតេស្ត Serial Correlation មាន ១៤,៧៩% និងតម្លៃ P-Value នៃការធ្វើតេស្ត Heteroskedasticity មាន ៣៤,០៩% ដែលបញ្ជាក់ថា គេមិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបដិសេធសម្មតិកម្មសូន្យ (Null Hypothesis) នៅកម្រិតសារៈសំខាន់ ១% ៥% និង ១០%។ លទ្ធផលក៏បានបង្ហាញពីការធ្វើ Ramsey Reset Test ដើម្បីពិនិត្យមើលលក្ខណៈពេញលេញនៃអថេរក្នុងម៉ូដែលផងដែរ ក្នុងនោះតម្លៃ P-Value ស្មើនឹង ១៤,៧១% ដែលមានន័យថាសម្មតិកម្មសូន្យមិនត្រូវបានបដិសេធនៅកម្រិតសារៈសំខាន់ ១% ៥% និង១០% ពោលគឺគ្មានអថេរពន្យល់ណាមួយត្រូវបានលុបចោលនៅក្នុងម៉ូដែលនោះទេ។ មួយវិញទៀត ទិន្នន័យដែលយកមកប្រើក្នុងការវិភាគនេះគឺមានបំណែកចែក Normality ដែលមានតម្លៃ P-Value ស្មើនឹង ២៨,៩១% ពោលគឺគេមិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបដិសេធសម្មតិកម្មសូន្យនៅកម្រិតសារៈសំខាន់ ១% ៥% និង១០%។ បន្ថែមពីនេះ តាមរូបភាព៣៧ (c) បង្ហាញថា ខ្សែកោង CUSUM ស្ថិតក្នុងចន្លោះដែនកំណត់វិនិច្ឆ័យខាងលើ និងដែនកំណត់វិនិច្ឆ័យខាងក្រោម ក្នុងកម្រិតជឿជាក់៩៥%

ដែលសម្មតិកម្មសូន្យមិនត្រូវបានបដិសេធក្នុងកម្រិតសារៈសំខាន់ ៥% មានន័យថាមេគុណប៉ាន់ស្មាននៃម៉ូដែលមានស្ថិរភាពល្អ ឬគ្មាន Structure Break។ ដូចនេះ តាមរយៈលទ្ធផលធ្វើតេស្តវិនិច្ឆ័យនៃម៉ូដែលខាងលើបានបញ្ជាក់ថា ម៉ូដែលវិភាគ និងប៉ាន់ស្មានមានសុពលភាពល្អ សុក្រឹតភាព មិនលម្អៀង និងផ្តល់នូវលទ្ធផលវិភាគ និងប៉ាន់ស្មានបានត្រឹមត្រូវ (No Spurious Regression)។

## ៥. ការវាយតម្លៃអំពីឥទ្ធិពលអាករលើតម្លៃបន្ថែមលើកំណើនសេដ្ឋកិច្ចកម្ពុជា

អាករលើតម្លៃបន្ថែមមានទំនាក់ទំនងរយៈពេលវែង(Cointegration)ជាមួយកំណើនសេដ្ឋកិច្ច តែគ្មានទំនាក់ទំនងរយៈពេលខ្លីនោះទេ។ សម្រាប់រយៈពេលវែង អាករលើតម្លៃបន្ថែមកើនឡើង ១% បានជះឥទ្ធិពលធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាកើនឡើង ០,១២% ឬ ក្នុងកម្រិតជឿជាក់ ៩៥% អាករលើតម្លៃបន្ថែមបានជះឥទ្ធិពលធ្វើឱ្យកំណើនសេដ្ឋកិច្ចកើនឡើងក្នុងចន្លោះ ០,២៩% ដល់ ០,៤៤%។ សូមបញ្ជាក់ថា តាមបញ្ញត្តិ អាករលើតម្លៃបន្ថែមត្រូវអនុវត្តលើការផ្គត់ផ្គង់ជាប់អាករនូវទំនិញ និងសេវា ក្នុងព្រះរាជាណាចក្រកម្ពុជា ហើយអ្នកប្រើប្រាស់ចុងក្រោយជាអ្នកទទួលរងបន្ទុកអាករ។ ម្យ៉ាងទៀត អាករលើតម្លៃបន្ថែមជាប្រភេទពន្ធប្រយោល ប្រមូលលើចំណូលដែលបានពីការផ្គត់ផ្គង់ទំនិញ និងសេវា តាមអត្រា ១០% ហើយអាករនេះត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពថវិកាថ្នាក់ជាតិ។ អាករលើតម្លៃបន្ថែមមានចំនួន ៥,៥% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២២។ អាករលើតម្លៃបន្ថែមបានដើរតួនាទីជាឧបករណ៍គោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលដ៏មានសារៈសំខាន់ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក។ តាមរយៈលទ្ធផលខាងលើ ដើម្បីបង្កើនថវិកាជាតិពីអាករលើតម្លៃបន្ថែម ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលវែង កិច្ចការចាំបាច់ និងមានសារៈសំខាន់បំផុតដែលត្រូវធ្វើរួមមាន បន្តរៀបចំ និងអនុវត្តច្បាប់ បទបញ្ញត្តិ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រផ្សេងៗ ស្តីពីអាករលើតម្លៃបន្ថែមឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព បន្តការពង្រឹងអភិបាលកិច្ចសារពើពន្ធ ទប់ស្កាត់បទល្មើសពន្ធ ទប់ស្កាត់អំពើពុករលួយ ទប់ស្កាត់ការគេចវេះអាករប្រភេទនេះ ពង្រឹងវិធានការប្រកាសចំណូលពីការផ្គត់ផ្គង់របស់អ្នកជាប់ពន្ធ តាមរយៈបន្តការផ្សព្វផ្សាយអប់រំដល់ម្ចាស់សហគ្រាសស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ បន្តលើកទឹកចិត្ត និងជំរុញឱ្យអ្នកជាប់ពន្ធកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ ការលុបបំបាត់វិសមភាព និងអតុល្យភាពនៃការប្រមូលអាករលើតម្លៃបន្ថែម និងធានាលើការប្រកួតប្រជែងស្មើភាព តម្លាភាព និងមានគណនេយ្យភាពក្នុងចំណោមអ្នកជាប់ពន្ធ។ លទ្ធផលសិក្សានេះ ប្រហាក់ប្រហែលគ្នានឹងបណ្តាប្រទេសផ្សេងៗមួយចំនួនដូចជា ការសិក្សានៅក្នុងប្រទេសកេនយ៉ា(ឆ្នាំ២០១២) ការសិក្សានៅប្រទេសតង់ហ្សានី(ឆ្នាំ២០២០) ការសិក្សានៅប្រទេសហ្សកដានី(ឆ្នាំ២០១៧) ការសិក្សានៅបណ្តាប្រទេសចំនួន៥១ (ឆ្នាំ២០២០) ការសិក្សានៅប្រទេសអាហ្វ្រិចខាងត្បូង(ឆ្នាំ២០២២) ការសិក្សានៅប្រទេសប៉ាគីស្ថាន(ឆ្នាំ២០១៥) ការសិក្សានៅប្រទេសនីហ្សេរីយ៉ា(ឆ្នាំ២០២០) និងការសិក្សានៅប្រទេសនីហ្សេរីយ៉ា(២០១៩)។ ដោយឡែក ការសិក្សានៅកម្ពុជាបានរកឃើញលទ្ធផលខុសគ្នាពីប្រទេសមួយចំនួនផ្សេងៗទៀតផងដែរដូចជា សហភាពអឺរ៉ុប(ឆ្នាំ២០១៣) ជាដើម។

## ៦. សេចក្តីសន្និដ្ឋាន

អាករលើតម្លៃបន្ថែម មានទំនាក់ទំនងសមតារយៈពេលវែងជាមួយនឹងកំណើនសេដ្ឋកិច្ចកម្ពុជា។ អាករលើតម្លៃបន្ថែមកើនឡើង ១% បានជះឥទ្ធិពលជាវិជ្ជមានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាកើនឡើង ០,១២% ឬក្នុងកម្រិតជឿជាក់ ៩៥% អាករលើតម្លៃបន្ថែមកើនឡើង ១% បានជះឥទ្ធិពលជាវិជ្ជមានធ្វើឱ្យកំណើនសេដ្ឋកិច្ចកើនឡើងក្នុងចន្លោះ ០,២៩% ដល់ ០,៤៤% ក្នុងរយៈពេលវែង។ ក្នុងន័យនេះ អាករលើតម្លៃបន្ថែមត្រូវបានប្រើប្រាស់ជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព របស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។ តាមរយៈទស្សនាទានថវិកា គឺជាឧបករណ៍គោលនយោបាយសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសធារណៈ ដើម្បីធានាបានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការប្រើប្រាស់ធនធានសាធារណៈ និងការបង្កើនថវិកាជាតិ ដែលប្រមូលពីប្រភេទអាករនេះ ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចជាតិ គឺជាកិច្ចការចាំបាច់ និងមានសារៈសំខាន់បំផុត ទាំងសម្រាប់រយៈពេលវែង និងរយៈពេលខ្លី។ ដូចនេះ រាជរដ្ឋាភិបាលគួរថ្លឹងថ្លែងឱ្យមានតុល្យភាពល្អប្រសើរបំផុត ក្នុងការបន្តអនុវត្តអភិបាលកិច្ចសារពើពន្ធឱ្យបានល្អ ប្រកបដោយប្រសិទ្ធភាពបំផុត ទប់ស្កាត់អំពើគេចវេះពន្ធ ទប់ស្កាត់អំពើពុករលួយ រៀបចំនិងធ្វើវិសោធនកម្មនូវច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានាស្តីពីអាករលើតម្លៃបន្ថែម ឆ្លើយតបនឹងការវិវឌ្ឍស្ថានភាពសង្គម-សេដ្ឋកិច្ចបច្ចុប្បន្ន និងអនាគតឱ្យបានទាន់ពេលវេលា បន្តពង្រឹង និងអនុវត្តកំណែទម្រង់អភិបាលកិច្ចសារពើពន្ធ ប្រើប្រាស់យន្តការបច្ចេកវិទ្យាឌីជីថល និងការទូទាត់ប្រាក់ពន្ធអាករទាំងនេះតាមប្រព័ន្ធធនាគារ បន្តពង្រឹងវិធានការផ្សព្វផ្សាយ និងអប់រំដល់ម្ចាស់សហគ្រាស ក្នុងចំណោមវិនិយោគិនស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ បន្តលើកទឹកចិត្ត និងជំរុញឱ្យអ្នកជាប់ពន្ធប្រកាសពន្ធ និងបង់ពន្ធឱ្យបានត្រឹមត្រូវ បន្តអនុវត្តវិធានការទោសទណ្ឌ និងជំរុញឱ្យអ្នកជាប់ពន្ធឱ្យកាន់កាប់បញ្ជិកាគណនេយ្យអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (CIFRS) លុបបំបាត់វិសមភាព និងអតុល្យភាពនៃការប្រមូលពន្ធលើប្រាក់ចំណូល អាករលើតម្លៃបន្ថែម និងធានាលើការប្រកួតដែងស្មើភាព តម្លាភាពក្នុងចំណោមអ្នកជាប់ពន្ធទាំងរយៈពេលខ្លី និងរយៈពេលវែង។

ក្នុងរយៈពេលខ្លី អាករលើតម្លៃបន្ថែមគ្មានទំនាក់ទំនង និងឥទ្ធិពលជាមួយកំណើនសេដ្ឋកិច្ចកម្ពុជា។ ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចក្នុងរយៈពេលខ្លី រាជរដ្ឋាភិបាលគួរពិចារណាបន្តការប្រើប្រាស់យន្តការអនុគ្រោះ និងលើកលែងអាករប្រភេទនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ ជួយសម្រួលដល់ជីវភាពរស់នៅ និងសម្រាលបន្ទុកចំណាយរបស់ប្រជាពលរដ្ឋលើការប្រើប្រាស់ទំនិញ និងសេវាកម្ម។

# គន្ថនិទ្ទេស

១- ច្បាប់ស្តីសារពើពន្ធ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧។

២- អនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

៣- ប្រកាសលេខ ១០៣១ ប្រក សហវ ពដ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីអាករលើតម្លៃបន្ថែម។

៤- ប្រកាសលេខ១០៣៧ប្រក សហវ គរ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ស្តីពីការណែនាំការអនុវត្តច្បាប់ស្តីពីសារពើពន្ធចំពោះអាករលើតម្លៃបន្ថែម

៥- ប្រកាសលេខ៦០៥ ប្រក.សហវ.ពដ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០០ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់ថាមពលអគ្គិសនី។

៦- ប្រកាសលេខ ៣០៣ សហវ.ពដ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួន។

៧- ប្រកាសលេខ២៩៨ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់ផលិតផល ឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង។

៨- ប្រកាសលេខ៥៤០ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងការដាក់អាករលើតម្លៃបន្ថែមជាបន្ទុករដ្ឋ ជាបណ្តោះអាសន្នលើមុខទំនិញសរសៃអំបោះសូត្រនាំចូល។

៩- ប្រកាសលេខ៧៧៩ សហវ.ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ស្តីពីការលើទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ។

១០- ប្រកាសលេខ ៣១១ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៤ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យសាដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក។

១១- ប្រកាសលេខ ៣១២ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០១៤ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួន។

១២- ប្រកាសលេខ ៦៩០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែ មេសា ឆ្នាំ ២០១៥ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផលិតនិងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់។

១៣- ប្រកាសលេខ៩០៤សហវ.ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះគ្រឹះស្ថានសិក្សា។

១៤- ប្រកាសលេខ ៤៩៥ សហវ.ប្រក ចុះថ្ងៃទី០៦ខែមេសាឆ្នាំ២០១៦ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ។

១៥- ប្រកាសលេខ៥៥៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ។

១៦- ប្រកាសលេខ៧៤១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០១៨ ស្តីពីវិធាន និងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធអាករនានាទាក់ទិននឹងសកម្មភាពកាត់ដេរ និងតម្រឹម នៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

១៧- ប្រកាសលេខ៣៦១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញ ដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃប្រជាពលរដ្ឋ។

១៨- ប្រកាសលេខ ២៥២ សហវ.ប្រក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសផលិតផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ ស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ។

១៩- លិខិតលេខ១១០ សជណ.ផក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ស្តីពីករណីអនុវត្តអាករលើតម្លៃបន្ថែមលើធាតុចូលដែលនាំចូលដោយរោងចក្រផលិតសម្លៀកបំពាក់សម្រាប់នាំចេញ។

# ទម្រង់មតកសាសន៍ដោយលិខិតឯកជន និងលទ្ធភាពប្រតិបត្តិ

បេក្ខជនបណ្ឌិតៈ ងួន រតនា
ជំនាញៈ នីតិសាស្ត្រ

## ១. អ្វីជាមតកសាសន៍?

ផ្អែកលើទិដ្ឋភាពប្រវត្តិគតិយុត្តនៅប្រទេសកម្ពុជា **ទម្រង់មតកសាសន៍** ទើបតែមានវត្តមានពេលមានក្រមរដ្ឋប្បវេណីឆ្នាំ១៩២០[១] ប៉ុណ្ណោះ។ ការយល់អំពីអត្ថន័យនៃពាក្យថា «**មត៌ក**» នាំឱ្យមានការងាយយល់ពីមតកសាសន៍។ តាមសន្ទានុក្រមផ្នែកក្រមរដ្ឋប្បវេណី ពាក្យថា «**មត៌ក**» មានន័យថា ទ្រព្យសម្បត្តិជាកេរទាំងឡាយដែលបុគ្គលម្នាក់(មតកជន) បានបន្សល់ទុកក្រោយពេលស្លាប់។ រីឯ ពាក្យថា «**មតកសាសន៍**» មានន័យថា លិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។

ជាសត្យានុម័តលក្ខណៈពិសេសរបស់មតកសាសន៍ សំដៅលើទិដ្ឋភាពជាមូលដ្ឋានចំនួន ២ (ពីរ) រួមមានៈ «**ការផ្តល់**» និង «**ការទទួល**»។ ដោយហេតុថា ទាំងលើសកម្មភាពឯកតោភាគីដែលគ្មានភាគីម្ខាងទៀត និងមិនចាំបាច់ត្រូវទទួលការយល់ព្រមពីអ្នកទទួលជាមុននោះទេ។ ទិដ្ឋភាពផ្ទុត់គំនិតបែបនេះជាការឆ្លើយតបនឹងគោលការណ៍គ្រឹះដ៏សំខាន់ ក្នុងបញ្ហាសន្តតិកម្មគឺគោលការណ៍នៃការបន្តដោយស្វ័យប្រវត្តិលើបញ្ហាទ្រព្យមត៌ក[២] ដូចមានការបញ្ញត្តិក្នុងស្មារតីនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧(តទៅហៅថា ***ក្រមរដ្ឋប្បវេណី***)។ អត្ថន័យដែលថាមតកសាសន៍ជាលិខិតបណ្តាំជាការយល់ដ៏ត្រឹមត្រូវក្នុងទំហំមួយ ប៉ុន្តែលក្ខខណ្ឌដែលធ្វើឱ្យលិខិតបណ្តាំទទួលបានសុពលភាព ហើយអាចក្លាយជាមតកសាសន៍ត្រឹមត្រូវតាមច្បាប់ លុះត្រាតែ លិខិតបណ្តាំត្រូវបានធ្វើឡើងស្របតាមប្រភេទ ទម្រង់ណាមួយ ដែលត្រូវបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី[៣]។ ជាក់ស្តែង ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីទម្រង់មតកសាសន៍ ទៅតាមប្រភេទមតកសាសន៍ និងលក្ខខណ្ឌនីមួយៗជាក់លាក់ ដោយរាប់ទាំងទម្រង់មតកសាសន៍ដោយលិខិតឯកជនផងដែរ[៤]។

## ២. អ្វីទៅជា «មតកសាសន៍ដោយលិខិតឯកជន»?

តាមមាត្រា១១៧៤ (*មតកសាសន៍ដោយលិខិតឯកជន*) នៃក្រមរដ្ឋប្បវេណីបានចែងថាៈ

*១. មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និងចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ។ មតកសាសន៍ដោយលិខិតឯកជន*

---

[១] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០, ចាប់ពីមាត្រា៥៥៤ ដល់មាត្រា៥៦១។

[២] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦:គន្ថីទី៨-ទី៩, ឆ្នាំ២០១០។

[៣] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១។

[៤] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៤។

*ដែលត្រូវបានសរសេរជំនួសដោយអ្នកទៃ ឬដែលត្រូវសរសេរដោយប្រើម៉ាស៊ីនដូចជា អង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ។*

*២- ការបន្ថែម ការលុប ឬការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះជាពិសេស បើមិនបានចុះហត្ថលេខាទេ។*

ផ្អែកលើទិដ្ឋភាពដែលបានបញ្ញត្តិអំពីមតកសាសន៍ដោយលិខិតឯកជន បើពិចារណាទៅលើខ្លឹមសារនៃលក្ខខណ្ឌចំពោះការកំណត់ខ្លឹមសារ ជាដំបូងដោយផ្ទង់ទៅលើបុគ្គលជាប្រធាននៃសិទ្ធិនៅក្នុងការរៀបចំតាក់តែងនូវមតកសាសន៍។ លើសពីនេះទៀតជាលក្ខខណ្ឌទាមទារដាច់ខាតគឺពាក់ព័ន្ធនឹងបុគ្គលដែលជាម្ចាស់បណ្ដាំទើបជាអ្នកមានសិទ្ធិផ្ដាច់មុខ ក្នុងការសរសេរមតកសាសន៍ដោយលិខិតឯកជនបាន។ ទន្ទឹមនឹងនេះដែរ ចំពោះការចែងអំពីទិដ្ឋភាពនៃលក្ខខណ្ឌទម្រង់មតកសាសន៍ដោយលិខិតឯកជនតាមក្រមរដ្ឋប្បវេណី ជាការឆ្លុះបញ្ចាំងនូវទស្សនៈគតិយុត្តទៅលើការកំណត់លក្ខខណ្ឌនៃទម្រង់ ដោយមានវត្ថុបំណងធ្វើការគ្រប់គ្រងឱ្យមានសណ្ដាប់ធ្នាប់ទៅលើភាពរប៉ាត់រប៉ាយ ឬភាពសម្បូរបែបនៃទម្រង់មតកសាសន៍ធ្វើតាមទម្លាប់។ ហេតុដូចនេះ ចំពោះទម្រង់មតកសាសន៍ដោយលិខិតឯកជនតាមច្បាប់ជាទម្រង់ជាក់លាក់នៃកម្រងលក្ខខណ្ឌដែលត្រូវបានបញ្ញត្តិជាធរមាននៅក្នុងក្រមរដ្ឋប្បវេណី។ ការចែងអំពីលក្ខខណ្ឌទម្រង់មតកសាសន៍ដោយលិខិតឯកជន តម្រូវឱ្យមានការប្រតិបត្តិតាមពីសំណាក់ប្រជាពលរដ្ឋដើម្បីទទួលបាននូវគាំពារខាងផ្នែកគតិយុត្ត សម្រាប់ការសំដែងឆន្ទៈរបស់មតកជនដែលមានជាខ្លឹមសារនៅលើមតកសាសន៍ដោយលិខិតឯកជនដែលបានបន្សល់ទុក។ ម្ចាស់បណ្ដាំដែលបានធ្វើមតកសាសន៍ដោយលិខិតឯកជនបានត្រឹមត្រូវ និងស្របទៅតាមល័ក្ខខ័ណ្ឌតម្រូវរបស់ក្រមរដ្ឋប្បវេណីដែលបានចែង ទើបមតកសាសន៍ដោយលិខិតឯកជនមានអានុភាពផ្លូវច្បាប់។

ក្នុងរឿងរដ្ឋប្បវេណី បើទោះបីជាមានការបញ្ញត្តិរបស់ច្បាប់ ប៉ុន្តែការអន្តរាគមន៍របស់ច្បាប់ពុំមែនជាបុរេលក្ខខណ្ឌកំណត់ដាច់ខាត ដោយបំពាន**គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន**[៥] បានទេ ដោយហេតុថា គោលការណ៍នេះជាគោលការណ៍គ្រឹះដ៏ចម្បងនៅក្នុងរឿងរដ្ឋប្បវេណី។ បើយោងទៅលើក្រមរដ្ឋប្បវេណីត្រង់មាត្រា៣ (*គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន*) បានបញ្ញត្តិឡើងដោយគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល។ តាមរយៈការបញ្ញត្តិក្នុងទំហំខ្លឹមសារនេះ ជាការឆ្លុះបញ្ចាំងឱ្យឃើញថាក្រមរដ្ឋប្បវេណីត្រូវបានតាក់តែងឡើង ដោយតម្កល់ឧត្ដមប្រយោជន៍របស់បុគ្គលទៅតាមសេរីភាពនៃឆន្ទៈកាលបើសេរីភាពនៃឆន្ទៈមិនរងនូវវិការៈ ឬការតវ៉ា។ ទន្ទឹមនឹងនេះដែរ ដោយឈរទៅលើលក្ខខណ្ឌច្បាប់មតកសាសន៍មានលក្ខណៈសម្បត្តិពេញលេញបាន ត្រូវផ្អែកទៅលើធាតុសំខាន់ៗមួយចំនួនរួមមានៈភាពរូបីយរបស់មតកសាសន៍ ការចារឹកសំណេរជាលាយលក្ខណ៍អក្សរ មានការចុះថ្ងៃខែឆ្នាំ និងការចុះហត្ថលេខាជាដើម។ ជាទូទៅ គោលគំនិតដែលមានក្នុងលក្ខខណ្ឌនីមួយៗ សុទ្ធតែបានរំលេចនូវភាព

[៥] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៣។

ចាំបាច់ និងសារៈសំខាន់ផ្សេងពីគ្នា ខណៈបណ្ដុំនៃធាតុក្នុងសំណុំតែមួយទើបអាចបង្កើតបានជាប្រភេទនៃទម្រង់មតកសាសន៍ដោយលិខិតឯកជនដែលចាត់ទុកថា ត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី។ ចំពោះទិដ្ឋភាពទម្រង់មតកសាសន៍ដោយលិខិតឯកជន ប្រសិនបើម្ចាស់បណ្ដាំពុំអាចធ្វើឱ្យស្របតាមបញ្ញត្តិរបស់ក្រមរដ្ឋប្បវេណី មតកសាសន៍ដោយលិខិតឯកជនងាយរងការមោឃៈ។

## ៣. លក្ខខណ្ឌនៃទម្រង់មរតកសាសន៍ដោយលិខិតឯកជន

តាមក្រមរដ្ឋប្បវេណី ភាពចាំបាច់ចំពោះទម្រង់មតកសាសន៍ដោយលិខិតឯកជនទាមទារលក្ខខណ្ឌសំខាន់ចម្បងចំនួន ៣ (បី) ដែលរួមមាន៖ ម្ចាស់បណ្ដាំត្រូវសរសេរនូវពាក្យទាំងអស់ ម្ចាស់បណ្ដាំត្រូវចុះថ្ងៃខែឆ្នាំ និង ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតបណ្ដាំដោយខ្លួនឯង។ លក្ខខណ្ឌទាំងនេះជាខ្លឹមសារស្នូលដ៏ចាំបាច់ និងជាកម្រិតបទដ្ឋាននៃលក្ខខណ្ឌអប្បបរមារបស់ប្រភេទទម្រង់មតកសាសន៍ដោយលិខិតឯកជន ដែលទាមទារឱ្យម្ចាស់បណ្ដាំត្រូវតែប្រតិបត្តិតាមឱ្យបានគ្រប់លក្ខខណ្ឌដែលបានកំណត់។ ជាក់ស្ដែង ពាក់ព័ន្ធទិដ្ឋភាពប្រឈមក្នុងការអនុវត្ត ប្រសិនបើប្រជាពលរដ្ឋខ្មែរទាំងឡាយណាដែលមានចំណេះដឹងចាប់ពីថ្នាក់មធ្យមសិក្សាអាចទទួលស្គាល់ថា ពុំសូវលំបាកនៅក្នុងការប្រតិបត្តិតាមនោះទេ ដោយគាត់អាចមានលទ្ធភាពធ្វើតាមទម្រង់មតកសាសន៍ដោយលិខិតឯកជន តាមឆន្ទៈដែលជាបំណងប្រាថ្នារបស់ខ្លួនបាន។ ផ្ទុយទៅវិញ ចំពោះប្រជាពលរដ្ឋដែលខ្វះនូវល័ក្ខខ័ណ្ឌមូលដ្ឋានគ្រឹះដ៏ចម្បងដោយមិនចេះអក្សរពិតជាពុំអាចមានលទ្ធភាព ដើម្បីរៀបចំតាមទម្រង់មតកសាសន៍ដោយលិខិតឯកជនបានទេ។

មតិខ្លះបានលើកឡើងពីការយល់ឃើញថា ប្រាកដជាគ្មានបញ្ហាទេចំពោះបុគ្គលដែលមិនចេះអក្សរហើយមានឆន្ទៈចង់រៀបចំធ្វើមតកសាសន៍។ ដោយហេតុថា បើតាមក្រមរដ្ឋប្បវេណី ចំពោះបុគ្គលមិនចេះអក្សរដែលអលទ្ធភាព ធ្វើតាមទម្រង់នៃមតកសាសន៍ដោយលិខិតឯកជន អាចជំនួសការបំពេញឆន្ទៈរបស់ម្ចាស់បណ្ដាំនោះបាន ដោយបុគ្គលមានជម្រើសអាចធ្វើតាមទម្រង់មតកសាសន៍ផ្សេងបាន ដោយអាស្រ័យលទ្ធភាព និងសមត្ថភាពយល់ដឹងម្ចាស់បណ្ដាំ នៅក្នុងការជ្រើសរើសយកការរៀបចំធ្វើទៅតាមទម្រង់មតកសាសន៍ដោយលិខិតយថាភូត ឬទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ ដោយគ្រាន់តែម្ចាស់បណ្ដាំរងនូវកាតព្វកិច្ច ក្នុងការបង់ថ្លៃកម្រៃសេវាជូនសារការីជាការស្រេច។ មិនតែប៉ុណ្ណោះ ចំពោះទម្រង់មតកសាសន៍ទាំងនេះ សម្រាប់ប្រជាពលរដ្ឋខ្មែរទូទៅ សុទ្ធតែមានជម្រើសក្នុងការសម្រេចជ្រើសរើសដោយសេរីភាព។ ទស្សនៈនេះជាការត្រឹមត្រូវក្នុងទំហំមួយ តែពុំទាន់ជានាទាំងស្រុងនូវភាពគ្រប់ជ្រុងជ្រោយទេ។

ជាធម្មតា ការសង្គ្រោះស្ថានភាពពុំអាចធ្វើតាមទម្រង់មតកសាសន៍ដោយលិខិតឯកជន ពិតជានៅអាចធ្វើទៅតាមទម្រង់មតកសាសន៍ដោយលិខិយយថាភូត ឬទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់បាន។ ខណៈបំណកស្រាយនៃទស្សនៈខាងលើ ហាក់ដូចបានផ្ដោតតែជ្រុងមួយនៃទិដ្ឋភាពបុគ្គលដែលមានឆន្ទៈធ្វើបណ្ដាំប៉ុន្តែគាត់មិនចេះអក្សរ ហើយនៅបានគិតដែរថាគ្រប់បុគ្គលដែលមិនចេះអក្សរ សុទ្ធតែគ្រប់បុគ្គលមានលទ្ធភាពបង់ថ្លៃសេវាឱ្យសារការី ដើម្បីធ្វើមតកសាសន៍ឱ្យឬយ៉ាងណា។ ផ្ទុយទៅវិញ

ដាក់ស្តែង មិនមែនគ្រប់អ្នកដែលមិនចេះអក្សរសុទ្ធតែជាអ្នកមានលទ្ធភាពក្នុងការបង់ថ្លៃសេវាសារការី នោះទេ។ លើសពីនេះទៀត រហូតមកដល់បច្ចុប្បន្ននេះពុំទាន់មានយន្តការសង្គ្រោះ ឬការលើកលែងការបង់ថ្លៃសេវាសារការី ដើម្បីបានជាប្រយោជន៍ដល់អ្នកដែលមានបំណងមកទទួលសេវារបស់សារការី តែអលទ្ធភាពក្នុងការបង់ថ្លៃឱ្យសារការីនោះដែរ។ ទិដ្ឋភាពនៃបញ្ហាទាំងនេះពិតជាឧបសគ្គដែលបានទប់ស្កាត់ដោយទណ្ឌិកាភាពដល់បុគ្គលដែលមានឆន្ទៈធ្វើនូវលិខិតបណ្តាំមរតក តែពុំអាចធ្វើតាមបំណងបានមុនពេលដែលគាត់ទទួលមរណភាពបានឡើយ។

## ៤. កត្តាប្រជាពលរដ្ឋ និងលទ្ធភាពនៃការអនុវត្ត

នាពេលកន្លងមក ប្រជាពលរដ្ឋខ្មែរភាគច្រើនហាក់ពុំទាន់បានគិតទៅដល់ការរៀបចំជាមតកសាសន៍ឱ្យបានរួចជាស្រេច នៅពេលម្ចាស់ទ្រព្យមានសុខភាពល្អ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្ហាញឆន្ទៈ ដើម្បីធ្វើការបែងចែកនូវទ្រព្យសម្បត្តិដែលមានឱ្យបានរួចរាល់នៅមុនពេលទទួលមរណភាពនោះទេ។ ការមិនអើពើទៅលើការចាត់ចែងធ្វើជាមតកសាសន៍ ដោយហេតុថា ម្ចាស់ទ្រព្យបែរជាបានផ្តេកផ្តួលទៅលើស្ថានភាពជាក់ស្តែងទុកជាអ្នកដោះស្រាយឱ្យដោយមិនខ្វល់អ្វីទាំងអស់។ ម្ចាស់ទ្រព្យមួយចំនួនធំក្រោយពីបានទទួលមរណភាពពិតជាមិនបានបន្សល់ទុកនូវមត៌កទ្រព្យសន្តិភាពទេ បែរជាបន្សល់ទុកនូវមត៌កវិបត្តិ ហើយបណ្តោយទុកឱ្យពេលវេលាជាអ្នកជួយដោះស្រាយជំនួសខ្លួនទៅវិញ។ ជាផលវិបាក លទ្ធផលដំណោះស្រាយពិតជាពិបាកប៉ាន់ប្រមាណ ដោយហេតុថា ជាមួយនឹងភាពផុយស្រួយក្នុងការកើតមានជម្លោះនាំឱ្យមានការបែកបាក់នៅក្នុងក្រុមគ្រួសារ និងសាច់ញាតិ ជាអាទិ៍។ មិនតែប៉ុណ្ណោះ ពេលខ្លះតំណនៃមត៌កជម្លោះបានបន្តការសាយភាយទៅកូនចៅស្រករក្រោយទៀត ដែលពិបាកនឹងរកទីបញ្ចប់បាន។

ជាទូទៅ នៅតាមបណ្តាគ្រួសារដែលមាននូវកម្រិតជីវភាពសាមញ្ញធម្មតា នាដើមឡើយក៏ហាក់មិនសូវជាមានការអើពើដែរ ទៅលើការរៀបចំចាត់ចែងទ្រព្យតាមការធ្វើមត៌កសាសន៍ទេ។ ប៉ុន្តែ តាមរយៈសារព័ត៌មាន ដែលបានចុះផ្សាយជាហូរហែពីវិបត្តិមត៌កក្នុងគ្រួសារអ្នកដទៃរងនូវកំណើនគួរឱ្យកត់សម្គាល់ទើបអំណោះក្រោយមកប្រជាពលរដ្ឋខ្មែរកាន់តែច្រើនឡើងៗ បានងាកមកគិតគូរនិងចាប់ផ្តើមលើកយកប្រធានបទពីបញ្ហាមត៌កមកនិយាយ និងធ្វើការពិភាក្សា។ ម្យ៉ាងវិញទៀត បើតាមរបាយការណ៍របស់ក្រសួងយុត្តិធម៌បានបញ្ជាក់ឱ្យដឹងថា នៅឆ្នាំ២០២៣ សំណុំរឿងក្តីមត៌កត្រូវបានសាលាជម្រះក្តីនៅទូទាំងប្រទេស ចំណាត់ការរួចបានចំនួន ៨៨៩ (ប្រាំបីរយប៉ែតសិបប្រាំបួន) ករណី[៦]។ លើសពីនេះទៀត អ្នកខ្លះបានឈានទៅធ្វើការសិក្សាស្វែងយល់អំពីគុណតម្លៃរបស់មតកសាសន៍កាន់តែកើនជាលំដាប់ តាមរយៈការទទួលសេវាធ្វើជាមតកសាសន៍នៅតាមមន្ទីរសារការី និងអត្រាកំណើនបណ្តឹងពាក់ព័ន្ធមតកសាសន៍ជាអាទិ៍។ ចំពោះឧបសគ្គក្នុងការរៀបចំមតកសាសន៍ អាចបណ្តាលមកពីកត្តាច្រើនយ៉ាងទើបគុណតម្លៃនៃមតកសាសន៍មិនទាន់ត្រូវបានប្រជាពលរដ្ឋខ្មែរ ទទួលស្គាល់ឱ្យបានទូលំទូលាយនៅឡើយ។

---

[៦] ក្រសួងយុត្តិធម៌៖ របាយការណ៍ស្តីពីលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣, ថ្ងៃទី២៧-២៨-២៩ ខែមីនា ឆ្នាំ២០២៤, ទំព័រ១២។

ការកំណត់នូវលក្ខខណ្ឌដែលតម្រូវអ្នកធ្វើមតកសាសន៍ចេះអក្សរ ការណ៍នេះមិនទាន់ពិចារណាដល់ស្ថានភាពដែលប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងតែមានអត្រាមនុស្សចាស់ដែលមានអាយុលើសពី ៥០ (ហាសិប) ឆ្នាំ ជាច្រើននាក់ ដែលជាស្ថិតិអាយុដែលប្រជាពលរដ្ឋនៅក្នុងវង្វង់អាយុនេះតែងគិតពីអនាគតទ្រព្យសម្បត្តិខ្លួនមាន និងការរៀបចំជាមតកសាសន៍។ តាមស្ថានភាពបច្ចុប្បន្ន ដោយសារយន្តការផ្សព្វផ្សាយមានច្រើនរូបភាព ជាពិសេសតាមប្រព័ន្ធទំនាក់ទំនងសង្គម ទើបធ្វើឱ្យព័ត៌មានអំពីវិវាទជម្លោះរឿងដណ្តើមមត៌កកាន់តែបានជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋ។ ជាការបារម្ភដល់ប្រជាពលរដ្ឋដែលពុំទាន់ជួបរឿង និងបានចិញ្ចឹមឆន្ទៈមិនចង់ឱ្យកើតមានជម្លោះដណ្តើមមត៌កកើតនៅក្នុងគ្រួសារនាពេលអនាគត ទើបជំរុញឱ្យប្រជាពលរដ្ឋកាន់តែច្រើនឡើងៗងាកមកចាប់អារម្មណ៍ និងគិតពិចារណាដោយចិញ្ចឹមផ្នត់គំនិតត្រូវធ្វើការរៀបចំមតកសាសន៍ឱ្យរួចរាល់មុនពេលមរណភាព។

ការធ្វើមតកសាសន៍តាមទំនៀមទម្លាប់កន្លងមក ភាគច្រើនគឺម្ចាស់បណ្តាំប្រកាន់យកការធ្វើមតកសាសន៍ជាការសរសេរបណ្តាំតាមចិត្តចង់ ដោយមានខ្លឹមសារផ្តោតជាសំខាន់តែទៅលើទ្រព្យសម្បត្តិដែលម្ចាស់បណ្តាំមាន ចំនួនសន្តតិជនត្រូវទទួលបានមត៌ក និងអំពីទំហំនៃចំណែកមត៌ក ក្រៅពីនេះគ្រាន់ជាទិដ្ឋភាពខ្លឹមសារបន្ទាប់បន្សំ អាចជាដំបូន្មានអប់រំដល់កូនតែប៉ុណ្ណោះ។ ខ្លឹមសារមតកសាសន៍តាមទំនៀមទម្លាប់ ភាគច្រើនរមែងប្រឈមនឹងកង្វះការសិក្សាស្វែងយល់លើទិដ្ឋភាពជាធរមាននៃក្រមរដ្ឋប្បវេណីឱ្យបានត្រឹមត្រូវ តាមបញ្ញត្តិស្តីអំពីទម្រង់មតកសាសន៍ក្នុងក្រមរដ្ឋប្បវេណីឡើយ។ លើសពីនេះទៀត បើទោះបីជាមតកសាសន៍ត្រូវបានម្ចាស់បណ្តាំធ្វើបានរួចរាល់មែន ប៉ុន្តែបើពិនិត្យលើការថែទាំនិងការប្រតិបត្តិ ពុំឃើញមានជាមូលដ្ឋានណាមួយឱ្យបានច្បាស់លាស់ ដើម្បីគាំពារនិងការតម្កល់នូវតម្លៃឆន្ទៈរបស់មតកជនឡើយ។ បើសូម្បីតែរបៀបទុកដាក់មតកសាសន៍ ត្រូវបានម្ចាស់បណ្តាំខិតខំព្យាយាមលាក់ទុកមតកសាសន៍ដែលធ្វើរួចនៅតាមទីកន្លែង ដែលម្ចាស់បណ្តាំគិតថាអាចរក្សាបាននូវសុវត្ថិភាព ហើយនឹងត្រូវប្រាប់ដល់សន្តតិជនវិញពេលដង្ហើមចុងក្រោយ កាលបើករណីម្ចាស់បណ្តាំអាចមានលទ្ធភាពប្រាប់បានទាន់ពេល នៅមុនពេលដែលគាត់ទទួលមរណភាព ហើយពេលខ្លះម្ចាស់បណ្តាំបានស្លាប់ទាំងមិនបានប្រាប់អ្វីទាំងអស់អំពីមតកសាសន៍ដែលមានរួចហើយ។ ម្យ៉ាងវិញទៀត ពាក់ព័ន្ធនឹងស្ថានភាពដែលម្ចាស់បណ្តាំជាបុគ្គលដែលមិនចេះអក្សរនិងក្រីក្រ ម្ចាស់បណ្តាំប្រាកដជាគិតដល់ការជួយជំនួយពីអ្នកផ្សេងដែលម្ចាស់បណ្តាំគិតថា អាចជួយសរសេរមតកសាសន៍ឱ្យបាន។ អ្វីដែលជាផលវិបាកការធ្វើជាមតកសាសន៍តាមទំនៀមទម្លាប់ បើពិចារណាទៅលើទិដ្ឋភាពនៃទម្រង់មតកសាសន៍ពិតជាងាយរងការប្រឈមការកង្វះលក្ខខណ្ឌ ដែលក្រមរដ្ឋប្បវេណីតម្រូវ។

## ៥. សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់

តាមរដ្ឋធម្មនុញ្ញមាត្រា៣១ ចែងថា៖ "*ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់*"។ តាមរយៈស្មារតីនៃមាត្រានេះបានឆ្លុះបញ្ចាំងឱ្យឃើញថា បណ្តាបទបញ្ញត្តិគតិយុត្តផ្សេងដែលត្រូវបានបញ្ញត្តិឡើងត្រូវអនុលោមទៅតាមខ្លឹមសារនេះ ដោយមិនតម្រូវឱ្យទិដ្ឋភាពខ្លឹមសារនៃបទបញ្ញត្តិរំលេចឱ្យឃើញពីភាពលំអៀងបានឡើយ។ ទន្ទឹមនឹងនេះដែរ ប្រសិនបើស្មារតីបទបញ្ញត្តិគតិយុត្តណាមួយដែលត្រូវបាន

ចែងឡើង ដោយមានការប្រាសចាកអំពីគោលការណ៍គ្រឹះដែលជាមូលដ្ឋាននៃភាពស្មើគ្នានៅចំពោះមុខច្បាប់ នាំឱ្យទំហំការបញ្ញត្តិត្រូវរងនូវអធម្មនុញ្ញភាពជាក់ជាពុំខាន។ ហេតុដូច្នេះ តម្លៃនៃស្មារតីច្បាប់ដែលពាក់ព័ន្ធភាពស្មើគ្នា ចំពោះមុខច្បាប់ត្រូវបានបញ្ជ្រាបនៅគ្រប់ទិដ្ឋភាពច្បាប់ដែលមានក្នុងប្រទេសកម្ពុជា ដើម្បីចូលរួមអនុលោមឱ្យបានត្រឹមត្រូវតាមស្មារតីមាត្រា៣១ នៃរដ្ឋធម្មនុញ្ញដែលត្រូវបានបញ្ញត្តិឡើង។

បើសូម្បីការចូលរួមនៅក្នុងដំណើរការនីតិវិធីតុលាការ សម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានការយល់ដឹងអំពីច្បាប់នៅមានកម្រិត មិនត្រូវបានរដ្ឋធ្វើព្រងើយកន្តើយដោយមិនអើពើឡើយ។ ជាក់ស្តែងនៅក្នុងការចូលរួមកិច្ចនៃនីតិវិធីតាមផ្លូវតុលាការ ចំពោះប្រជាពលរដ្ឋខ្មែរដែលមានភាពជីវភាពក្រីក្រត្រូវបានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ផ្តល់ជូនមេធាវីដោយពុំតម្រូវឱ្យបង់ថ្លៃសេវាទេ ដែលត្រូវចូលរួមធ្វើការការពារសិទ្ធិជូនតាមនីតិវិធីតុលាការ ដើម្បីគាំពារសិទ្ធិដល់ប្រជាពលរដ្ឋខ្មែរដែលពុំមានលទ្ធភាពកុំឱ្យមានការរំលោភបំពានសិទ្ធិ ជាពិសេសទៅលើប្រជាពលរដ្ឋដែលក្រីក្រ និងពុំមានលទ្ធភាពជួលមេធាវី។ យន្តការផ្តល់សេវាមេធាវីការពារសិទ្ធិដែលមិនយកកម្រៃ ជាផ្នែកមួយចូលរួមយ៉ាងសកម្មដើម្បីបង្ហាញឱ្យឃើញលទ្ធភាពការតតាំងតាមផ្លូវច្បាប់ជូនដល់ប្រជាពលរដ្ឋក្រីក្រ និងមានការយល់ដឹងអំពីបញ្ហាច្បាប់នៅមានកម្រិត។

ក្រៅពីការជួយការពារសិទ្ធិដល់ប្រជាពលរដ្ឋក្រីក្រនៅក្នុងនីតិវិធីតាមផ្លូវតុលាការ នៅមានយន្តការគាំពារសិទ្ធិដល់ប្រជាពលរដ្ឋក្រីក្រ ដែលរងនូវការបំពារបំពានសិទ្ធិដែលអលទ្ធភាពក្នុង ការបង់ប្រាក់ប្រដាប់ក្តី ដើម្បីធ្វើបណ្តឹងទៅតាមផ្លូវតុលាការផងដែរ។ ក្នុងស្ថានភាពនេះត្រូវបានច្បាប់បានផ្តល់នូវយន្តការការពារយ៉ាងជាក់លាក់និងប្រាកដប្រជា តាមការជួយសង្គ្រោះពន្ធលើការដាក់ពាក្យបណ្តឹងតាមផ្លូវតុលាការ។[៧] ជាទូទៅ ការដោះស្រាយពាក្យបណ្តឹងតាមផ្លូវតុលាការត្រូវតម្រូវឱ្យភាគីដើមចោទ ដែលជាអ្នកផ្តើមដាក់ពាក្យបណ្តឹង ត្រូវតែបង់ប្រាក់ប្រដាប់ក្តីជាមុន ដើម្បីទទួលបាននូវការចំណាត់ការពាក្យបណ្តឹងទៅតាមនីតិវិធីតុលាការជូនគូភាគី។ ការមិនបានបង់ប្រាក់ប្រដាប់ក្តីទៅលើពាក្យបណ្តឹង មិនត្រូវបានតុលាការធ្វើការចំណាត់ការបណ្តឹងតាមនីតិវិធីជូនដល់អ្នកដាក់ពាក្យបណ្តឹងឡើយ។ ប៉ុន្តែតាមក្រមនីតិវិធីរដ្ឋប្បវេណី បើទោះបីជាប្រជាពលរដ្ឋខ្មែរក្រីក្រក៏ច្បាប់នៅតែបង្កលទ្ធភាពឱ្យដើម្បីធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការបានដោយមិនចាំបាច់បង់ពន្ធលើកម្មវត្ថុនៃបណ្តឹងឡើយ។ ករណីនេះ ជាការជួយសង្គ្រោះពន្ធដល់អ្នកដាក់ពាក្យប្តឹងជាប្រជាពលរដ្ឋក្រីក្រ ដោយរដ្ឋជាអ្នកទទួលបន្ទុកជំនួស។ ដូចគ្នាដែរនៅពេលប្រជាពលរដ្ឋក្រីក្រពុំមានលទ្ធភាពបង់ថ្លៃសេវាមេធាវី ដើម្បីធ្វើការពារសិទ្ធិនៅក្នុងនីតិវិធីតុលាការខាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាមានមេធាវី សម្រាប់ជួយការពារសិទ្ធិដល់ជនក្រីក្រផងដែរ។ ការជួយនេះ ជាគុណតម្លៃដ៏មានសារៈសំខាន់ទៅដល់ការការពារសិទ្ធិជូនប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ ដែលអលទ្ធភាពខាងផ្នែកសេដ្ឋកិច្ចនៅក្នុងការពឹងពាក់មេធាវីឯកជនដោយការបង់ថ្លៃ។ ជារួម ការដាក់ពាក្យបណ្តឹងក្នុងរឿងរដ្ឋប្បវេណីមានការជួយអន្តរាគមន៍ដល់ភាគីដែលជាអ្នកក្រីក្រនិងពុំមានលទ្ធភាព

---

[៧] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៦៩។

បង់ប្រាក់ប្រដាប់ក្តីដោយត្រូវឆ្លងតាមយន្តការសង្គ្រោះពន្ធ បំណងដើម្បីធានាដល់ប្រជាពលរដ្ឋដែលត្រូវបានគេបំពារបំពានសិទ្ធិត្រូវទទួលបានការគាំពារដោយរដ្ឋ។ ផ្ទុយទៅវិញ យន្តការសារការីពុំមានទេនូវការជួយសង្គ្រោះការបង់ថ្លៃកម្រៃសេវា ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រ និងមិនចេះអក្សរ ដែលមានបំណងចង់ធ្វើលិខិតបណ្តាំមរតកអាចមានលទ្ធភាពធ្វើជាមតកសាសន៍បានទេ។ ដ្បិតការជួយពីសំណាក់បុគ្គលជាសារការីអាចជួយដោយមិនតម្រូវឱ្យបង់ប្រាក់ក្តី តែការជួយក្នុងរូបភាពនេះជាលក្ខណៈបុគ្គលប៉ុណ្ណោះ ដែលពុំមែនជាយន្តការទូទៅសម្រាប់ការជួយដល់ប្រជាពលរដ្ឋដូចស្ថានភាពនៃការជួយសង្គ្រោះពន្ធនៅក្នុងការដាក់ពាក្យបណ្តឹង ឬការផ្តល់សេវាមេធាវីជួយជនក្រីក្រឡើយ។

ជាផលវិបាកគតិយុត្ត ចំពោះទម្រង់មតកសាសន៍ដោយលិខិតឯកជនដែលមិនបានឆ្លើយតបតាមទម្រង់មតកសាសន៍ដែលច្បាប់បានចែង នឹងផ្តល់ជាផលវិបាកជាការមោឃភាពទម្រង់មតកសាសន៍ទាំងស្រុង។ ការមោឃភាពលើទិដ្ឋភាពទម្រង់មតកសាសន៍ដោយលិខិតឯកជនមានន័យថា គ្មានទេនូវមតកសាសន៍ដោយលិខិតឯកជនត្រូវបានបន្សល់ទុក ហើយក៏គ្មានដែរនូវការសំដែងឆន្ទៈរបស់មតកជនទៅលើទ្រព្យសម្បត្តិជាមរតក ដែលមរតកជនសេសសល់ទេ។ ក្នុងស្ថានភាពមោឃមតកសាសន៍ដោយលិខិតឯកជន ស្មើនឹងការបដិសេធទាំងស្រុងនូវឆន្ទៈរបស់ម្ចាស់បណ្តាំដែលបានសំដែងចេញមក ហើយជាពិសេសនត្ថិភាពនៃការប្រើនូវសិទ្ធិសំដែងមតិចុងក្រោយរបស់សព ក្រោយការខិតខំក្នុងមួយជីវិត ដើម្បីបានជាប្រយោជន៍ដល់មនុស្សដែលខ្លួនស្រលាញ់ មនុស្សចេះជួយយកអាសា មើលថែទាំពេលមានជម្ងឺ និងពេលខ្លួនចាស់ជរា ជាអាទិ៍។

កំហុសលើចំណុចណាមួយនៃលក្ខខណ្ឌដែលមានលក្ខណៈតិចតួច ទៅលើបញ្ហាទម្រង់មតកសាសន៍ដែលមរតកជនប្រឹងរៀបចំ ស្ថានភាពនេះពុំគួរណាចាត់ជាកំហុស និងជាបន្ទុកទាំងស្រុងរបស់មរតកជននោះទេ។ អ្វីដែលគួរពិចារណាឡើងវិញ គួរធ្វើការពិនិត្យមើលខ្លឹមសារដែលជាលក្ខខណ្ឌឱ្យបានគ្រប់ចំណុច ទៅលើទម្រង់មតកសាសន៍ដោយលិខិតឯកជនតែម្តង ដោយសិក្សាមើលទៅលើទិដ្ឋភាពនៃការចែងជុំវិញលក្ខខណ្ឌទម្រង់ បានកំពុងស្ថិតក្នុងកម្រិតបទដ្ឋានខ្ពស់ពេកឬយ៉ាងណា ទើបបានម្ចាស់បណ្តាំជាទូទៅពុំអាចធ្វើការអនុវត្តបានឱ្យគ្រប់លក្ខខណ្ឌ។ លើសពីនេះទៀត បើទោះបីជានៅក្នុងកាលៈទេសៈ ឬតម្លៃណាក៏ដោយ ក៏គួរគប្បីត្រូវតែគាំពារនូវតម្លៃឆន្ទៈរបស់មតកជនឱ្យបានជាអតិបរមាទើបស័ក្តិសម និងជាការឱ្យតម្លៃដល់ការខិតខំប្រឹងប្រែងរបស់ម្ចាស់ទ្រព្យ ដែលបានខិតខំរហូតដល់ពេលត្រូវទទួលមរណភាព។ ហេតុដូចនេះ ចំពោះតម្លៃនៃឆន្ទៈរបស់មតកជនដែលបានបន្សល់ទុក គួរតែត្រូវទទួលបានការការពារ ដើម្បីឆ្លើយតបតម្លៃនៃកម្មសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិ វាលែងតែ អវត្តមានការបង្ហាញឆន្ទៈទើបយន្តការច្បាប់អាចធ្វើអន្តរាគមន៍ ដើម្បីឱ្យបានជាប្រយោជន៍ដល់សន្តតិជនដែលជាកូនរបស់មរតកជន។ ជាគោលការណ៍ម្ចាស់ទ្រព្យជាម្ចាស់កម្មសិទ្ធិផ្តាច់មុខលើទ្រព្យសម្បត្តិដែលមាន ទោះបីជាយ៉ាងណា ការស្លាប់របស់សាមីម្ចាស់ទ្រព្យពុំអាចនាំឱ្យមានការរលត់នូវសិទ្ធិ ឬត្រូវបានដកហូតសិទ្ធិទាំងស្រុងដែលម្ចាស់ទ្រព្យធ្លាប់មានលើទ្រព្យនោះបានឡើយ។ ប្រសិនការរលត់សិទ្ធិទាំងស្រុងរបស់ម្ចាស់កម្មសិទ្ធិករ ដោយសារការទទួលមរណភាពរបស់សាមីម្ចាស់ទ្រព្យ ពិតជាពុំមានភាពចាំបាច់ណាមួយដែលក្រមរដ្ឋប្បវេណី ត្រូវបានបញ្ញត្តិអំពីទិដ្ឋភាពបញ្ហាសន្តតិកម្មនោះឡើយ។

ម្យ៉ាងវិញទៀត តាមមាត្រា ២៦១ ក្រមព្រហ្មទណ្ឌចែងថា *«អំពើប៉ះពាល់ដល់បូរណភាព នៃសាកសពត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល»*។ ចំណែកមាត្រា ២៦២ នៃក្រមព្រហ្មទណ្ឌចែងថា *«អំពើប្រមាថតាមមធ្យោបាយណាមួយក៏ដោយទៅលើផ្នូរ ទីបញ្ចុះសព កោដ្ឋ ឬទៅលើសំណង់ដែលកសាងឡើង សម្រាប់រំលឹកវិញ្ញាណក្ខន្ធនៃអ្នកទទួលមរណភាពត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល»*[៨]។ ការចែងក្នុងក្រមព្រហ្មទណ្ឌលើបទប៉ះពាល់ដល់បូរណភាពនៃសាកសព និងបទប្រមាថទីបញ្ចុះសព បើពិចារណាឱ្យបានល្អិតល្អន់លើទំហំខ្លឹមសារដូចបានបញ្ញត្តិលើស្ថានភាពនៃបទល្មើស ហាក់បានបន្ទាបដោយតុល្យភាពដល់តម្លៃឆន្ទៈមរតកជនយ៉ាងខ្លាំង។ បើទោះបីជា ការចែងក្រមព្រហ្មទណ្ឌតែម្យ៉ាងស្តាប់ភ្លាមដូចល្អមែនទែន ប៉ុន្តែបើធៀបទៅនឹងការបដិសេធនូវឆន្ទៈមរតកជន តាមការមោឃភាពមតកសាសន៍ដោយលិខិតឯកជន ដែលម្ចាស់បណ្តាំត្រឹមមានកំហុសតិចតួចទៅលើលក្ខខណ្ឌទម្រង់ ពិតជាពុំមានភាពស័ក្តិសម និងអាចទទួលយកបានឡើយ។ អ្វីដែលចង់ធ្វើការប្រៀបធៀបនៅត្រង់ថា តើការការពារទៅដល់សាកពឬទីកន្លែងបញ្ចុះសពមានតម្លៃនៅត្រង់ណាសម្រាប់ជាគុណតម្លៃដ៏ពិតប្រាកដសម្រាប់ការព្យាយាមការពារ។ ខណៈតម្លៃនៃឆន្ទៈដែលបានរំលេចឡើងក្នុងទម្រង់មតកសាសន៍ដោយលិខិតឯកជន ដោយគ្រាន់តែខ្វះនូវលក្ខខណ្ឌណាមួយយ៉ាងតិចបែរជាត្រូវបានបដិសេធទាំងស្រុងឆន្ទៈមរតកជនដែលបានបន្សល់ទុកនោះ។ បើនិយាយខ្លីបែបសាមញ្ញធម្មតានៅក្នុងខ្លឹមសារថា ឆន្ទៈមនុស្សរស់មិនគិតប្រឹងធ្វើការការពារឱ្យបានល្អបែរជាប្រឹងការពាររូបកាយសាកសព ឬទីបញ្ចុះសព ដែលគ្មានវិចារណញ្ញាណវិញ។

ការលើកឡើងនូវបញ្ហាប្រឈមអាចមានការបកស្រាយថា ពាក់ព័ន្ធទម្រង់មតកសាសន៍ដែលមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីមានច្រើនដូចជា ទម្រង់មតកសាសន៍ដោយលិខិតឯកជន ទម្រង់មតកសាសន៍ដោយលិខិតយថាភូត និងទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់។ ក្នុងប្រភេទទម្រង់មតកសាសន៍ដោយលិខិតយថាភូត និងទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ បានតម្រូវឱ្យម្ចាស់បណ្តាំត្រូវបង់ថ្លៃសេវា ដើម្បីទទួលការជួយធ្វើមតកសាសន៍ឱ្យម្ចាស់បណ្តាំ។ រហូតមកដល់បច្ចុប្បន្ននេះ ពុំទាន់មានជាផ្លូវការនៅឡើយទេ ករណីការផ្តល់សេវាសារការីដោយមិនយកកម្រៃ។ ចំពោះទំហំការចំណាយទៅលើតម្លៃនៃសេវាត្រូវបានគេចាត់ទុកថា ជាឧបសគ្គ ចំពោះប្រជាពលរដ្ឋខ្មែរទាំងឡាយណាដែលមានជីវភាពក្រីក្រ។ ក្រៅពីលក្ខខណ្ឌដែលតម្រូវឱ្យបង់ថ្លៃសេវាសារការី នៅមិនទាន់ពិចារណាដល់ស្ថានភាពដែលប្រទេសកម្ពុជាពុំទាន់មានចំនួនសារការីឱ្យបានគ្រប់គ្រាន់ ដើម្បីចូលរួមផ្តល់សេវាឱ្យបានទូលំទូលាយនៅឡើយទេ។ បើតាមស្ថិតិរបស់ក្រសួងយុត្តិធម៌ គិតត្រឹមថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣ បានបញ្ជាក់ឱ្យដឹងថា មន្ទីរសារការីសរុបមានចំនួន ១៩ (ដប់ប្រាំបួន) មន្ទីរ នៅទូទាំងប្រទេសកម្ពុជាដែលបានកំពុងដំណើរការ

[៨] ក្រមព្រហ្មទណ្ឌ, ឆ្នាំ២០១០, មាត្រា២៦១ និងមាត្រា២៦២, ទំព័រ ៨៣-៨៤។

និងបានផ្តល់សេវាសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[៩] ជាការកត់សម្គាល់ ចំពោះមន្ទីរសារការីទាំង ១៩ (ដប់ប្រាំបួន) មានអាសយដ្ឋានតែក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ចំណែកនៅតាមបណ្តាខេត្ត-ក្រុង ពុំទាន់មានមន្ទីរសារការីនៅឡើយទេ។ ចំណុចនេះជាបញ្ហាសម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្តាខេត្ត-ក្រុង ដែលមានបំណងជ្រើសយកយន្តការសារការីក្នុងការជួយរៀបចំធ្វើមតកសាសន៍ឱ្យ។ លើសពីនេះទៀត នៅមានជាផលវិបាកចំពោះប្រជាពលរដ្ឋខ្មែរដែលមានឆន្ទៈចង់ធ្វើមតកសាសន៍ ប៉ុន្តែដោយសារតែកត្តាជីវភាពក្រីក្រ និងមិនចេះអក្សរ ហើយក៏ពុំមានលទ្ធភាពបង់ថ្លៃសេវាសារការី មានសេសសល់តែលទ្ធភាពមួយគត់ជាចុងក្រោយនិងគ្មានជម្រើសផ្សេង ដោយតម្រូវឱ្យម្ចាស់បណ្តាំត្រូវតែធ្វើមតកសាសន៍បានតែមួយប្រភេទ ដោយត្រូវធ្វើតាមទម្រង់មតកសាសន៍ដោយលិខិតឯកជនតែប៉ុណ្ណោះ។

## ៦. សេចក្តីសន្និដ្ឋាន

មាត្រា១១៧៤ នៃក្រមរដ្ឋប្បវេណីស្តីពីទិដ្ឋភាពទម្រង់មតកសាសន៍ដោយលិខិតឯកជន គឺមិនទាន់បានឆ្លើយតបទៅនឹងតថភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងបរិបទសង្គមកម្ពុជាឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ ខណៈដែលគោលគំនិតមាត្រាមួយនេះជុំវិញបញ្ហាទម្រង់មតកសាសន៍ដោយលិខិតឯកជននៅតែបន្តនូវការរើសអើងដោយភាពស្ងៀមស្ងាត់ឬតុណ្ហីភាព ចំពោះបុគ្គលជាសាមីម្ចាស់បណ្តាំ ដែលជាប្រជាពលរដ្ឋមិនចេះអក្សរ និងមានជីវភាពក្រីក្រ។ អ្វីដែលជាបញ្ហាធំចំពោះការមិនអើពើត្រូវបានឆ្លុះបញ្ចាំង ក្នុងស្ថានភាពដែលម្ចាស់បណ្តាំជាបុគ្គលមិនចេះអក្សរហើយមានជីវភាពក្រីក្រលំបាកថែមទៀត បើប្រជាពលរដ្ឋខ្មែរក្នុងប្រភេទបុគ្គលនេះមានឆន្ទៈចង់ធ្វើមតកសាសន៍ ពិតជាពុំមានលទ្ធភាពជ្រើសរើសធ្វើតាមលក្ខខណ្ឌនៃទម្រង់មតកសាសន៍ដោយលិខិតយថាភូត ឬតាមទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់បានទេ។ ដោយហេតុថា ជាឧបសគ្គសម្រាប់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ ការជ្រើសរើសយកការធ្វើបណ្តាំតាមទម្រង់មតកសាសន៍ដោយលិខិតយថាភូត ឬតាមមតកសាសន៍ដោយលិខិតសម្ងាត់មាននូវលក្ខខណ្ឌទាមទារ ដោយតម្រូវឱ្យម្ចាស់បណ្តាំដែលចង់ឱ្យសារការីធ្វើជាមតកសាសន៍ឱ្យត្រូវបង់ថ្លៃសេវាទើបតាមយន្តការសារការីដំណើរការជូនបាន។

ចំពោះប្រជាពលរដ្ឋដែលជាជនក្រីក្រ និងមានទ្រព្យសម្បត្តិបន្តិចបន្តួច ប្រឈមមុខនឹងលទ្ធភាពចំពោះការបង់ថ្លៃសារការី ពុំមានលទ្ធភាពព្រោះថ្លៃសេវាដែលត្រូវបង់អាចមានតម្លៃក្នុងរង្វង់ ២.០០០.០០០ (ពីរលាន) រៀលឡើងទៅ។ តាមគំហាត់ដោយកត្តាអលទ្ធភាពខាងផ្នែកសេដ្ឋកិច្ច ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រនិងមិនចេះអក្សរ នៅសល់តែជម្រើសមួយបើចង់ធ្វើមតកសាសន៍សម្រាប់ជីវិតចុងក្រោយ ត្រូវធ្វើតាមទម្រង់មតកសាសន៍ដោយលិខិតឯកជន ស្ថានភាពនេះជាការប្រឈមខាងឆន្ទៈដោយសារកត្តាសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ។ នៅពេលប្រជាពលរដ្ឋខ្មែរដែលគ្មានលទ្ធភាពខាងទ្រព្យធនអាចនិយាយបានថា ពុំមានជាទ្រព្យសម្បត្តិដែលមានតម្លៃជាធំដុំទេ។ ផ្ទុយទៅវិញ ការមានលទ្ធភាពធ្វើជាលិខិតបណ្តាំនៅក្នុងទំហំនៃច្បាប់ទទួលស្គាល់មានតម្លៃខ្លាំងណាស់សម្រាប់ជីវិតរបស់គាត់។ ដោយ

[៩] https://www.moj.gov.kh/kh/announcement/262, មើលថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤។

ហេតុថា នៅក្នុងទំហំនៃទ្រព្យសម្បត្តិដ៏តិចតួចនោះ គាត់ក៏ចង់មានសិទ្ធិធ្វើការចាត់ចែង និងបែងចែកនូវទ្រព្យដែលគាត់មានឱ្យចំមនុស្សដែលគាត់មានមនោសញ្ចេតនា និងក្ដីស្រលាញ់ផងដែរ ពុំមែនជាការបដិសេធនូវការសំដែងឆន្ទៈរបស់គាត់ ហើយបែរជាយកការបែងចែកទ្រព្យសម្បត្តិតាមច្បាប់មកចាប់បង្ខំដោយផ្ទុយទៅនឹងឆន្ទៈគាត់ទេ។ ទម្រង់មតកសាសន៍ដោយលិខិតឯកជនដែលបង្កលទ្ធភាពឱ្យគាត់ធ្វើបានពិតជាមានតម្លៃបំផុតនៅក្នុងសេចក្ដីលះបង់ ដែលបានប្រឹងប្រែងគ្រប់យ៉ាងក្នុងមួយជីវិតហើយត្រូវបានចាត់ទុកថាជាសំណូមពរខាងឆន្ទៈនៃវិនាទីចុងក្រោយក្នុងនាមជាមនុស្ស។

## ៧. អនុសាសន៍

ចំពោះប្រជាពលរដ្ឋខ្មែរដែលមិនចេះអក្សរនិងមានជីវភាពក្រីក្រ ហើយមានឆន្ទៈចិត្តចង់រៀបចំធ្វើជាមតកសាសន៍ឱ្យបានរួចមុនទទួលមរណភាព តាមក្រមរដ្ឋប្បវេណីស្ថានភាពរបស់ប្រជាពលរដ្ឋខ្មែរ ពុំអាចមានលទ្ធភាពឱ្យបានគ្រប់គ្រាន់ជម្រើសការធ្វើមតកសាសន៍ តាមទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ ឬទម្រង់មតកសាសន៍ដោយលិខិតយថាភូតបាននោះទេ។ ជាបញ្ហាប្រឈមចំពោះការប្រតិបត្តិតាមសេវាសារការីត្រូវតម្រូវឱ្យម្ចាស់បណ្ដាំបង់សេវាសារការី ទើបចំណាត់ការអន្តរាគមន៍តាមយន្តការសារការីចូលរួមជួយម្ចាស់បណ្ដាំបាន។ ដោយហេតុថា ការតម្រូវឱ្យបង់ថ្លៃសេវាសារការីរហូតមកដល់បច្ចុប្បន្នពុំទាន់មានទេនូវយន្តការជួយសង្គ្រោះទៅលើបញ្ហានេះដល់បណ្ដាម្ចាស់បណ្ដាំ ដែលអលទ្ធភាពក្នុងការបង់ថ្លៃសារការីនៅឡើយទេ។

ជាជម្រើសចុងក្រោយនិងគ្មានជម្រើសណាផ្សេងឡើយ តាមក្រមរដ្ឋប្បវេណីប្រជាពលរដ្ឋនៅមានលទ្ធភាពធ្វើមតកសាសន៍បាន ដោយត្រូវធ្វើតាមមតកសាសន៍ដោយលិខិតឯកជន។ ប៉ុន្តែលក្ខខណ្ឌទម្រង់ដែលបញ្ញត្តិជាធរមាន ហាក់បង្ហាញការគាំពារសុវត្ថិភាពដល់លក្ខខណ្ឌនៃទម្រង់មតកសាសន៍ដោយលិខិតឯកជនខ្លាំងពេក រហូតដល់ភ្លេចគិតទៅដល់ផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរដែលជីវភាពក្រីក្រនិងមិនចេះអក្សរ ពុំអាចសំដែងឆន្ទៈតាមទម្រង់នេះបាន។ ហេតុដូចនេះ គួរគប្បីធ្វើការបន្ធូរបន្ថយលក្ខខណ្ឌខ្លះ ពីការតម្រូវម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់មកជាបើកលទ្ធភាពឱ្យម្ចាស់បណ្ដាំ អាចធ្វើជាមតកសាសន៍ដោយលិខិតឯកជនបាននៅចំពោះមុខមេឃុំដែលម្ចាស់បណ្ដាំរស់នៅ និងមានស្មៀនជាលេខាកត់ត្រានូវសេចក្ដីថ្លែងការណ៍ដែលម្ចាស់បណ្ដាំបានសំដែងចេញតាមសាមីឆន្ទៈ។ រីឯ ការចុះហត្ថលេខាក៏គួរគប្បីបន្ថែមនូវស្ថានភាពអញ្ញត្រកម្ម ចំពោះអ្នកដែលមិនចេះចុះហត្ថលេខា គប្បីជំនួសការផ្ដិតស្នាមម្រាមដៃ ដោយគ្រាន់តែមានការបញ្ជាក់មូលហេតុ។ ការបន្ធូរទៅលើលក្ខខណ្ឌទាំងនេះជាភាពសាកសមទាំងលើមូលដ្ឋានគតិយុត្ត ទំនៀមទម្លាប់ប្រពៃណី អត្រាមន្ទីរសារការីនៅកម្ពុជាពុំទាន់មានភាពទូលំទូលាយ និងការសង្គ្រោះបង់ថ្លៃសារការីពុំទាន់មានការគាំពារតាមផ្លូវច្បាប់ ជាអាទិ៍។

# គន្ថនិទ្ទេស

## ឯកសារជាខេមរភាសា

១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

៤ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០

៥ ក្រមព្រហ្មទណ្ឌឆ្នាំ២០១០

៦ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៦:គន្ថីទី៨-ទី៩, ឆ្នាំ២០១០។

៧ គេហទំព័រក្រសួងយុត្តិធម៌, https://www.moj.gov.kh/kh/announcement/262,

៨ សៀវភៅវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត

៩ ក្រសួងយុត្តិធម៌, របាយការណ៍ស្តីពីលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣, ថ្ងៃទី២៧-២៨-២៩ ខែមីនា ឆ្នាំ២០២៤, ទំព័រ១២។

# ប្រព័ន្ធយោធាកម្ពុជា

បេក្ខជនបណ្ឌិតៈ **ឌី សោភា**
ជំនាញៈ **រដ្ឋបាលសាធារណៈ**

## ១-សេចក្តីផ្តើម

សន្តិភាព ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ក្នុងការធានាជុំវិញការអភិវឌ្ឍរបស់រដ្ឋមួយ ហើយការធានាបាននូវសន្តិភាព ស្ថេរភាព និងអធិបតេយ្យជាតិរបស់រដ្ឋមួយគឺជាកាតព្វកិច្ចចម្បងរបស់រដ្ឋាភិបាលនៃរដ្ឋនោះ។ បេសកកម្មដ៏ធំធេងនេះជាអន្តរកប្បយ៉ាងស្មុគស្មាញដែលប្រឈមគ្នាក្នុងបរិការណ៍នៃសង្គ្រាម សន្តិភាព យោធា អធិបតេយ្យជាតិ និងប្រព័ន្ធច្បាប់ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងជាតិ និងឆាកអន្តរជាតិ។ សន្តិភាព ស្ថេរភាព និងអធិបតេយ្យភាពជាតិត្រូវកើតចេញពីកណ្តាប់ដៃនៃរដ្ឋាភិបាលស្របច្បាប់មួយដែលមាន **កងកម្លាំងយោធា** ជាឧបករណ៍អំណាចរបស់រដ្ឋសម្រាប់ធានាការអនុវត្តគោលនយោបាយបាយការពាជាតិនៃរដ្ឋាភិបាល។ កងយោធពលខេមរភូមិន្ទគឺជាយោធាស្របច្បាប់ដែលមានភារកិច្ចបម្រើប្រទេសជាតិ។ បេសកកម្មកងយោធពលខេមរភូមិន្ទគឺត្រូវរៀបចំប្រើប្រាស់កម្លាំងកងយោធពលខេមរភូមិន្ទ ដើម្បីការពារ និងកសាងមាតុភូមិ និងដើម្បីបម្រើផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ប្រទេសជាតិ។ ការប្រើប្រាស់ និងគ្រប់គ្រងកម្លាំងយោធានៅកម្ពុជាមានការវិវត្តជាច្រើនសម័យកាល ដែលប្រទេសកម្ពុជាឆ្លងកាត់សង្គ្រាមស៊ីវិលជាច្រើនទសវត្សរ៍។

ក្រោយទទួលបានឯករាជ្យពីបារាំង យោធាកម្ពុជាត្រូវបានបង្កើតឡើង ដោយមានឈ្មោះថា "***កងយោធពលខ្មែរ*** *Royal Khmer Armed Forces (FARK)*" ដែលស្ថិតក្នុងសម័យសង្គមរាស្ត្រនិយម។ ក្រោយរដ្ឋប្រហារ លន់ ណុល ឈានដល់សម័យសាធារណរដ្ឋខ្មែរ កម្លាំងយោធាកម្ពុជាបានបង្កើត និងមានឈ្មោះថា "***កងកម្លាំងយោធាជាតិខ្មែរ*** *Khmer National Armed Forces* (FANK)"។ ក្រោយរបបលន់ ណុល ដួលរលំ របប ប៉ុល ពត ឡើងគ្រប់គ្រងអំណាចដោយបង្កើតកងកម្លាំងយោធារបស់ខ្លួនមានឈ្មោះថា "***កងកម្លាំងបដិវត្តន៍កម្ពុជា*** *Revolutionary Army of Kampuchea (RAK)*"។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ កម្ពុជាស្ថិតនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយបង្កើតកងកម្លាំងឈ្មោះថា "***កងកម្លាំងបដិវត្តន៍ប្រជាជនកម្ពុជា*** *Kampuchean People's Revolutionary Armed Forces (KPRAF)*" ដែលក្រោយមកប្តូរទៅជា ***កងកម្លាំប្រជាជនកម្ពុជា*** *Cambodian People's Armed Forces (CPAF)*"។ នៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ កម្ពុជាស្ថិតក្នុងការប្រទាញប្រទង់ និងសង្គ្រាមស៊ីវិលមិនទាន់បានបញ្ចប់ និងមិនទាន់ទទួលបានសន្តិភាព។ ក្រោយមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ កម្ពុជាឈានដល់ការស្រុះស្រួលនយោបាយ និងបញ្ចប់វិវាទ និងរៀបចំសង្គមកម្ពុជាឡើងវិញតាមគោលការណ៍ប្រជាធិបតេយ្យ។ បន្ទាប់មានការបោះឆ្នោត និងបង្កើតរដ្ឋាភិបាលឆ្នាំ១៩៩៣ កងកម្លាំងយោធាកម្ពុជាត្រូវបានរៀបចំឡើងវិញ ដោយស្ថិតនៅក្រោមក្រសួងការពារជាតិ ដែលមានឈ្មោះថា ***កងយោធពលខេមរភូមិន្ទ*** *"Royal Cambodian Army"*។

## ២. ប្រវត្តិនៃប្រព័ន្ធយោធាខ្មែរ

ប្រវត្តិវិទូ លោក **មីសែល ត្រាណេ** បានសន្និដ្ឋានថា កងទ័ពក្នុងចក្រភពកម្ពុជរដ្ឋមិនតិចជាង ២០០,០០០(ពីរសែន) ទៅ ៣០០,០០០(បីសែន)នាក់នោះទេ ដើម្បីការពារនូវអធិបតេយ្យភាព និង បូរណភាពទឹកដីខ្មែរ[១]។ ពាក់ព័ន្ធទៅនឹងកងទ័ពខ្មែរបុរាណ គប្បីជ្រាបថា កងទ័ពខ្មែរត្រូវបានបែងចែក ជាអង្គភាពធំៗគឺពលថ្មើរជើង ពលនាវា ពលដំរី និងពលសេះ អ្វីដែលមានឈ្មោះថា "ចតុរង្គសេនា"។ ពលថ្មើរជើងដែលមានចំនួនលើសលប់ គឺជាពលដែលដើរដោយជើងទទេ ស្លៀកពាក់ខ្លីសាមញ្ញបំផុត ភាគច្រើនគ្រាន់តែស្លៀកប៉ឹង[២] តាមរបៀបកុលសម្ព័ន្ធខ្មែរលើសព្វថ្ងៃនេះ។ ប្រវត្តិសាស្ត្របង្ហាញពីប្រភព នៃក្បាច់គុនរបស់កម្ពុជា។ នៅសម័យបុរាណប្រទេសកម្ពុជាបានយកឈ្នះឡាវ និងផ្នែកខ្លះប្រទេសថៃ និង ឧបទ្វីបម៉ាឡេ(Malay Peninsula) បានកាន់កាប់អំណាចលើតំបន់ដ៏ធំនៃអាស៊ីអាគ្នេយ៍។ យ៉ាងណាក៏ ដោយ វីរភាពក្បាច់គុន និងកងទ័ពរបស់ខ្មែរបានថយចុះនៅដើមសតវត្សទី១៥ ហើយក្រោយមកប្រទេស កម្ពុជាបានស៊ូទ្រាំពីការប្រជែង និងការឈ្លានពានដោយប្រទេសជិតខាងដែលមានអំណាចខ្លាំងក្លាជាង ពោលគឺប្រទេសថៃ និងវៀតណាម។

រយៈពេលដ៏វែងនៃការធ្លាក់ចុះនេះបានឈានដល់កម្រិតទាបបំផុតនៅដើមសតវត្សទី១៩ នៅ ពេលដែលប្រទេសកម្ពុជាជិតត្រូវបានបញ្ចប់ជារដ្ឋអធិបតេយ្យមួយដែលជាលទ្ធផល នៃការរំលោភបំពាន ដោយប្រទេសជិតខាងរបស់ខ្លួន។ នៅឆ្នាំ១៨៦៣ ព្រះមហាក្សត្រកម្ពុជាបានយល់ព្រមក្នុងការបង្កើត អាណាព្យាបាលបារាំងមួយលើជាតិរបស់ព្រះអង្គ ដើម្បីការពារវាពីការផុតពូជវង្សត្រកូល នៃអាណាចក្រ ខ្មែរ។ អំណាចរបស់អាណាព្យាបាលត្រូវបានពង្រីកជាញឹកញាប់ដោយអំណាចរបស់ បារាំង ហើយនៅ ទីបំផុតប្រទេសកម្ពុជាបានក្លាយជាអាណានិគមជាក់ស្តែងមួយដែលបានបង្កើតកំណើតរដ្ឋទំនើបដោយ មានកងកម្លាំងប្រដាប់អាវុធ និងគោលលទ្ធិយោធាផ្ទាល់ខ្លួន[៣] ។ អត្ថិភាពនៃប្រព័ន្ធយោធាខ្មែរទំនើប ត្រូវ បានកំណត់ត្រឹមសតវត្សរ៍ ទី១៩ ពោលគឺក្នុងសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្ន។ ដោយឡែក សម្រាប់វិស័យកងទ័ព ត្រូវបានកំណត់ពីឆ្នាំ១៩៤៦ ចាប់ពីពេលបង្កើតកងយោធពលខេមរភូមិន្ទដំបូង តាមរយៈអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី០៧ ខែមករា[៤]។ ក្នុងចន្លោះសង្គ្រាមស៊ីវិលនៅកម្ពុជា វត្តមាននៃ កងទ័ពរដ្ឋាភិបាលត្រូវបានផ្លាស់ប្តូរទៅតាមបេតនយោបាយ និងសង្គម ពោលគឺចាប់ពីសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ទៅរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងផ្លាស់ប្តូរទៅរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩) ព្រមទាំងការកំណែទម្រង់ទៅរដ្ឋាភិបាលនៃ រដ្ឋកម្ពុជា ឆ្នាំ(១៩៨៩-១៩៩៣) ។

---

[១] មីសែល ត្រាណេ "**ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ចក្រភពកម្ពុជទេស ពីស.វទី៩ ដល់ស.វទី១៣ នៃគ.ស ឆ្នាំ២០០៦**" ទំព័រ ២៨៣-២៨៤។

[២] ប៉ឹង គឺជាសំលៀកបំពាក់បុរាណ ដែលគេស្លៀកណ្ឌែបាំងកេរ្តិ៍ខ្មាស ដោយសំពត់មួយផ្ទាំងតូច (សម្លៀកបំពាក់ពួងប្រុស)។

[៣] Area Handbook Series: Cambodia: A Country Study Edited by Russell R. Ross Third Edition, First Printing, 1990.page 241.

[៤] "**កងទ័ពជើងគោក**" ប្រវត្តិសង្ខេប និងសមិទ្ធផលសំខាន់ៗ ១៩៩៩-២០១៦ បោះពុម្ពលើកទី១, ភ្នំពេញ ២០១៧ ដោយ គណៈកម្មការ ប្រវត្តិសាស្ត្រយោធា ក.ជ.គ ទំព័រ ១៦ ។

## ៣. មូលដ្ឋានគតិយុត្តិនៃការរៀបចំប្រព័ន្ធយោធាកម្ពុជាបច្ចុប្បន្ន

ប្រព័ន្ធយោធាកម្ពុជាត្រូវបានបញ្ញត្តិជាក់លាក់ដោយរដ្ឋធម្មនុញ្ញ ដោយស្ថិតនៅក្រោមការគ្រប់គ្រង និងអភិវឌ្ឍន៍ដោយស្ថាប័ននីតិប្រតិបត្តិ និងប្រព័ន្ធបញ្ជា ដែលអំណាចត្រួតពិនិត្យដោយស្ថាប័នអំណាចកំពូលផ្សេងទៀត ជាពិសេសអំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ ដោយផ្អែកតាមគោលការណ៍នៃការបែងចែកអំណាច ក្នុងប្រព័ន្ធរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ។ ប្រព័ន្ធយោធាកម្ពុជាត្រូវបានបញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញឱ្យមានតុល្យភាពក្នុងអំណាចនយោបាយសង្គម ពោលគឺក្រសួងការពារជាតិជាសេនាធិការឱ្យអំណាចនីតិប្រតិបត្តិ ហើយសមាសភាពរដ្ឋមន្ត្រីក្រសួងការពារជាតិត្រូវទទួលបានការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភា[៥]។ ផ្អែកតាមមាត្រា ១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ រដ្ឋមន្ត្រីក្រសួងការពារជាតិ គឺជាសមាជិកនៃរាជរដ្ឋាភិបាល មាត្រា ១១៩ថ្មី រាជរដ្ឋាភិបាលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ហើយអាចតែងតាំងគណៈរដ្ឋមន្ត្រីបាន លុះត្រាតែសមាជិកគណៈរដ្ឋមន្ត្រីទាំងមូលទទួលបានការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដោយដោយសំលេងលើសពី៥០% (៥០%+១ ឬហៅថាមតិភាគច្រើនដាច់ខាត)[៦]។

ជាមួយគ្នានេះ ក្នុងការរក្សាតុល្យភាពអំណាច រដ្ឋសភាគឺជាស្ថាប័នផ្តល់សេចក្តីទុកចិត្តលើក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលរួមទាំងវិស័យយោធា និងការពារជាតិ ព្រមទាំងឃ្លាំមើលការអនុវត្តគោលនយោបាយទាំងនោះផងដែរ។ ក្នុងក្របខ័ណ្ឌថវិកា រដ្ឋសភាអាចត្រួតពិនិត្យកញ្ចប់ថវិកានានាក្នុងក្របខ័ណ្ឌចំណាយប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល រួមទាំងវិស័យយោធា មុនរដ្ឋសភាអនុម័តយល់ព្រមលើមាតិកាថវិកាប្រចាំ[៧]។ ដើម្បីធានា និងឃ្លាំមើលការអនុវត្តគ្រប់វិស័យរួមទាំងវិស័យយោធា តាមរយៈមាត្រា៩៦ នៃរដ្ឋធម្មនុញ្ញ តំណាងរាស្ត្រអាចដាក់សំណួរទៅរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬ/និងរដ្ឋមន្ត្រីពាក់ព័ន្ធវិស័យយោធា ហើយរដ្ឋមន្ត្រីមានកាតព្វកិច្ចត្រូវឆ្លើយបំភ្លឺទៅកាន់សភា[៨]។ មិនត្រឹមតែប៉ុណ្ណោះ បើផ្អែកតាមមាត្រា ៩៨ថ្មី នៃរដ្ឋធម្មនុញ្ញ រដ្ឋសភាអាចទម្លាក់រដ្ឋមន្ត្រីក្រសួងការពារជាតិ ឬសមាជិករបស់គណៈរដ្ឋមន្ត្រីណាមួយបាន ឬទម្លាក់រាជរដ្ឋាភិបាលទាំងមូលតែម្តង តាមរយៈការធ្វើញត្តិបន្ទោស។

មួយវិញទៀតដើម្បីធានាតុល្យភាព និងអព្យាក្រឹត្យវិស័យយោធា រដ្ឋធម្មនុញ្ញបានប្រទានព្រះរាជតួនាទីជាអគ្គមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ[៩]។ ជាមួយគ្នានេះ ព្រះមហាក្សត្រទ្រង់ជាអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ទ្រង់ជាអ្នកប្រកាសសង្គ្រាមក្រោយសភាបានអនុម័តរួច ហើយទ្រង់ក៏មានតួនាទីជារដ្ឋបាលបវេណី ចេញព្រះរាជក្រឹត្យតែងតាំង និងផ្លាស់ប្តូរ និងឬបញ្ចប់តួនាទីមន្ត្រីយោធា តាមសំណើរបស់គណៈរដ្ឋមន្ត្រីផងដែរ[១០]។

---

[៥] មាត្រា១១៨ថ្មី និងមាត្រា១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ។

[៦] មាត្រា៩០ថ្មីពីរ កថាខណ្ឌ៨ នៃរដ្ឋធម្មនុញ្ញ។

[៧] មាត្រា៩០ថ្មីពីរ កថាខណ្ឌ២ នៃរដ្ឋធម្មនុញ្ញ។

[៨] នីតិវិធីនៃការដាក់សំណួរ និងការឆ្លើយបំភ្លឺរបស់រាជរដ្ឋាភិបាលមានចែងក្នុងមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ។

[៩] មាត្រា២៣ នៃរដ្ឋធម្មនុញ្ញ។

[១០] មាត្រា ២៤ ថ្មី និងមាត្រា ២១នៃរដ្ឋធម្មនុញ្ញ។

## ៤. ការបង្កើត និងការរៀបចំក្បាលម៉ាស៊ីនយោធា

ក្បាលម៉ាស៊ីនដឹកនាំបញ្ជាយោធាក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ត្រូវបានបង្កើតឡើងក្រោយពេលរូបមន្តនៃរដ្ឋាភិបាលចម្រុះបណ្ដោះអាសន្នត្រូវបានបង្កើត ដែលពេលនោះមិនទាន់ដាក់ឈ្មោះថាជា "កងយោធពលខេមរភូមិន្ទ" នៅឡើយទេ។ នៅក្នុងរដ្ឋាភិបាលបណ្ដោះអាសន្ន ដោយផ្អែកតាមព្រះរាជយោបល់របស់សម្ដេចព្រះ នរោត្តម សីហនុ យោធាកម្ពុជាកម្ពុជាត្រូវបានរដ្ឋាភិបាលបណ្ដោះអាសន្នកំណត់នាមកងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទដូចជា៖ ១.ប្រភេទកងទ័ពជើងគោកហៅថា "កងទ័ពជាតិកម្ពុជា" ជាភាសាខ្មែរ និង "Forces Annees Nationales du Cambodge" ជាភាសាបារាំង។ ២.ប្រភេទកងទ័ពជើងទឹកហៅថា "កងនាវាជាតិកម្ពុជា" ជាភាសាខ្មែរ និង "Marine Nationales du Cambodge" ជាភាសាបារាំង។ និង ៣.ប្រភេទកងទ័ពអាកាសហៅថា "កងទ័ពជាតិកម្ពុជា" ជាភាសាខ្មែរ និង "Aviation Nationales du Cambodge" ជាភាសាបារាំង[១១]។ យោងតាមសំណូមពររបស់សហប្រធាននៃរដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជាចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៣ ព្រះមហាក្សត្រសម្ដេចព្រះ នរោត្តម សីហនុ បានចេញក្រឹត្យតែងតាំងអគ្គសេនាធិការកងទ័ពជាតិកម្ពុជា១រូប (ឯកឧត្តមឧត្តមសេនីយ៍ឯក កែ គឹមយ៉ាន) អគ្គសេនាធិការរងទីមួយ១រូប (ឯកឧត្តមឧត្តមសេនីយ៍ឯក ញឹក ប៊ុនឆៃ) និងអគ្គសេនាធិការរងចំនួន ៦រូប (ឯកឧត្តមឧត្តមសេនីយ៍ឯក ប៉ុល សារឿន, ប៉ាន់ ថៃ, មាស សុភា, ខាន់ សារឿន, ម៉ែន ប៊ុនថន, និង លី សេងហុង)[១២]។

ក្រោយអនុម័ត និងប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញយោធាកម្ពុជាដែលមានឈ្មោះ "កងទ័ពជាតិកម្ពុជា" ត្រូវបានប្ដូរឈ្មោះទៅជា "កងយោធពលខេមរភូមិន្ទ" វិញដោយផ្អែកតាម មាត្រា ២៣ នៃរដ្ឋធម្មនុញ្ញ។ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យឡាយព្រះហស្តលេខាដោយព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ។ សហនាយករដ្ឋមន្ត្រីទាំងពីរជាសហអគ្គមេបញ្ជាការ (សម្ដេច ហ៊ុន សែន, សម្ដេច នរោត្តម រណឫទ្ធិ) នៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា។ អគ្គបញ្ជាការដ្ឋានជាស្ថាប័នខ្ពស់បំផុតនៅក្នុងឋានានុក្រមកងយោធពលខេមរភូមិន្ទ និងជាមូលដ្ឋានសម្រាប់ធ្វើការសម្របសម្រួលរវាងអគ្គសេនាធិការ និងក្រសួងការពារជាតិផងដែរ។ ទោះបីដូច្នេះក្ដីការដឹកនាំបញ្ជាកងទ័ពទាំងមូលនៅតែជាការទទួលខុសត្រូវរបស់អគ្គសេនាធិការដដែល។ ក្រោមការដឹកនាំរបស់ក្រសួងការពារជាតិ អគ្គសេនាធិការបានចាត់វិធានការជាបន្ទាន់ ក្នុងការបង្រួបបង្រួមកងទ័ពទាំង៣ ដើម្បីរៀបចំកសាងកងយោធពលខេមរភូមិន្ទឡើងវិញ ដោយទទួលស្គាល់កងទ័ពមកពីអតីតរដ្ឋកម្ពុជា អតីតកងទ័ពភាគីហ៊្វុនស៊ិនប៉ិច និងអតីតកងទ័ពរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ។ កងកម្លាំងទាំង ៣ភាគី ត្រូវបានរៀបចំបញ្ចូលទៅជាកងពលធំ កងពលតូច វរសេនាធំ តាមរចនាសម្ព័ន្ធរបស់អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ ដែលជាកងទ័ពជាតិតែមួយគត់បានប្រសូតចេញជារូបរាងប្រកបដោយជោគជ័យគួរឱ្យស្ងើចសរសើរ។

---

[១១] អនុក្រឹត្យនៃរដ្ឋាភិបាលបណ្ដោះអាសន្ន លេខ ០១ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៣ ស្ដីពីការកំណត់នាមកងទ័ពជាតិកម្ពុជា។

[១២] ក្រឹត្យព្រះនរោត្តម សីហនុ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ១៩៩៣។

## ៥. កិច្ចកំណែទម្រង់យោធាក្នុងបរិបទសន្តិភាព និងការអភិវឌ្ឍ

រដ្ឋាភិបាលបណ្តោះអាសន្នត្រូវបានអនុម័តដោយមានទម្រង់ជារដ្ឋាភិបាលចម្រុះ ពោលគឺនាយករដ្ឋមន្ត្រីទី១ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង នាយករដ្ឋមន្ត្រីទី២ ឯកឧត្តម ហ៊ុន សែន ហើយដែលក្នុងនោះនាយករដ្ឋមន្ត្រីទាំង២ គឺជារដ្ឋមន្ត្រី ក្រសួងការពារជាតិ និងមានអនុរដ្ឋមន្ត្រី ២រូប គឺឯកឧត្តម ទៀ បាញ់ និងឯកឧត្តម ទា ចំរ៉ាត់[១៣]។ រហូតដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៣ អគ្គសេនាធិការកងទ័ពជាតិត្រូវបានបង្កើតដោយមានឯកឧត្តម ឧត្តមសេនីយ៍ឯក កែ គឹមយ៉ាន ជានាយអគ្គសេនាធិការ និងឯកឧត្តម ឧត្តមសេនីយ៍ឯក ញឹក ប៊ុនឆៃ ជាអគ្គសេនាធិការរងទី១[១៤]។ ចាប់តាំងពីឆ្នាំ១៩៩៣ មកកំណែទម្រង់យោធានៅកម្ពុជាត្រូវបានជំរុញដោយការបញ្ចប់សង្គ្រាមស៊ីវិល។ លើសពីនេះទៀត ការធ្វើសមាហរណកម្មនៃកងទ័ពភាគីជម្លោះទាំងអស់ទៅជាកងយោធពលខេមរភូមិន្ទដែលមានប្រមាណ ២០៣ ៨២១នាក់។ គោលបំណងមួយទៀតសម្រាប់កំណែទម្រង់យោធា គឺដើម្បីកាត់បន្ថយការចំណាយផ្នែកយោធាក៏ដូចជាការផ្ទេរប្រាក់សន្សំទៅការអភិវឌ្ឍវិស័យអាទិភាពដូចជា សុខភាព ការអប់រំ និងការអភិវឌ្ឍជនបទ។ កំណែទម្រង់យោធាដ៏ធំមួយបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាក្នុងកំឡុងខែមីនា ឆ្នាំ១៩៩៥។ ក្រសួងការពារជាតិកម្ពុជាបានប្រកាសពីការកាត់កងទាហានសំខាន់ៗរបស់ខ្លួន ដោយចំនួនឧត្តមសេនីយ៍បានកាត់បន្ថយពីប្រហែល ២០០០ នាក់មកនៅចំនួនតិចជាង ២០០នាក់។ ឧត្តមសេនីយ៍ផ្កាយមួយ ផ្កាយពីរ និងផ្កាយបីទាំងអស់ ១៩៩នាក់បានរួចផុតពីកំណែទម្រង់នេះ ដោយបន្តកាន់មុខដំណែង។ កំណែទម្រង់នេះមានគោលបំណងផ្គាប់ចិត្តប្រទេសម្ចាស់ជំនួយធំៗដើម្បីជំរុញការគាំទ្រផ្នែកយោធាផងដែរ[១៥]។

ប្រទេសកម្ពុជាបានធ្វើកំណែទម្រង់យោធាដ៏ស្មុកស្មាញតាំងពីឆ្នាំ១៩៩៣ រហូតដល់មានគោលនយោបាយច្បាស់លាស់នៅឆ្នាំ២០០២ និងឆ្នាំ២០០៦ តាមរយៈសៀវភៅសការពារជាតិដែលជាត្រីវិស័យសម្រាប់កិច្ចការពារសន្តិសុខជាតិ និងអភិវឌ្ឍន៍កងយោធពលខេមភូមិន្ទ ដែលជាកងកម្លាំងការពារជាតិរបស់ខ្លួន។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ រដ្ឋាភិបាលកម្ពុជាបានអំពាវនាវដល់ប្រទេសម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិឱ្យផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងសម្ភារៈចំនួនប្រមាណ ១០៤ លានដុល្លារ ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ សម្រាប់ការរំសាយកងទ័ពប្រមាណ ៥៥,០០០នាក់។ លោក សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានធ្វើសំណើនេះនៅក្នុងសេចក្តីថ្លែងការណ៍មួយនៅថ្ងៃបើកសន្និសីទម្ចាស់ជំនួយរយៈពេលពីរថ្ងៃនៅទីក្រុងតូក្យូ។ លោកក៏បានបង្ហាញកាលវិភាគសម្រាប់ការកាត់បន្ថយកងទ័ពដោយលើកឡើងថាទាហាន ១១៥០០នាក់ នឹងត្រូវកាត់បន្ថយក្នុងឆ្នាំ២០០០ បន្ថយ ១១០០០នាក់ នៅឆ្នាំ២០០១ បន្ថយ ២០៥០០ នៅឆ្នាំ២០០២ និង ១២០០០នាក់ទៀតនៅឆ្នាំ២០០៣ (BBC ឆ្នាំ១៩៩៩)។ រដ្ឋាភិបាលបានប៉ាន់ស្មានថា មានទាហាន ១៤៨០០០នាក់ ទោះជា

---

[១៣] សូមមើល ក្រឹត្យចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលបណ្តោះអាសន្ននៃកម្ពុជា។

[១៤] សូមមើល ក្រឹត្យចុះថ្ងៃទី០៥ កក្កដា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងសមាសភាពដឹកនាំអគ្គសេនាធិការនៃកងទ័ពជាតិ កម្ពុជា។

[១៥] អត្ថបទចេញផ្សាយដោយ University of Notre Dame ( ND ) ចំណង់ជើង "Military Reform: Framework for a Comprehensive Political Settlement of the Cambodia Conflict" អានអត្ថបទ https://shorturl.at/fFST5 ។

យ៉ាងណាតួលេខនេះត្រូវបានជំទាស់យ៉ាងខ្លាំង។[១៦] នៅពេលបញ្ចប់កម្មវិធីនេះ រដ្ឋាភិបាលបានប៉ាន់ប្រមាណថា ចំណែកនៃការការពារក្នុងការចំណាយចរន្តនឹងត្រូវបានកាត់បន្ថយពីតួលេខឆ្នាំ១៩៩៨ ពី ៣៥,៨ភាគរយ មកត្រឹម ២០ភាគរយ។ ជាផ្នែកមួយនៃកម្មវិធីកែទម្រង់ មន្ត្រីយោធាជាន់ខ្ពស់ ១៤នាក់ត្រូវបានដំឡើងឋានៈជាអ្នកឧត្តមសេនីយ៍ត្រី (brigadier-general) និង ២៣នាក់ទៀត ទៅឋានៈជាឧត្តមសេនីយទោ (major-general)។ ការលើកកម្ពស់នេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរៀបចំរចនាសម្ព័ន្ធឡើងវិញ ដើម្បីបង្វែរថវិកាពីវិស័យនេះទៅសេវាកម្មសង្គម។ ការធ្វើទំនើបកម្មកងយោធពលខេមរភូមិន្ទគឺជាអាទិភាពចម្បងមួយនៅក្នុងដំណើរការកែទម្រង់យោធា ហើយការធ្វើទំនើបកម្មនេះនឹងមិនត្រឹមតែនៅមូលដ្ឋានកងទ័ពជើងទឹករាមនោះទេគឺនឹងត្រូវធ្វើនៅក្នុងវិស័យផ្សេងៗទៀតដូចជា ការពារអាកាស អាវុធធុនធ្ងន់ ការសង្គ្រោះ រក្សាសន្តិភាព ប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនជាដើម នេះបើតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការពារជាតិ[១៧]។ ក្នុងឆ្នាំ២០២២ រាជរដ្ឋាភិបាលបានសម្រេចលទ្ធផលថ្មីនៃគោលនយោបាយជាតិទំនើបកម្មមួយ តាមរយៈសៀវភៅសការពារជាតិឆ្នាំ២០២២ ហើយនេះគឺជាលើកទី៣ ដែលកម្ពុជាបានដាក់ចេញនូវសៀវភៅសការពារជាតិ វាមានគម្លាតរយៈពេល ១៦ឆ្នាំមកហើយ បន្ទាប់ពីសៀវភៅសការពាជាតិឆ្នាំ២០០៦។

## ៦. ការបំពេញកាតព្វកិច្ចយោធារបស់ពលរដ្ឋ

កាតព្វកិច្ចយោធារបស់ពលរដ្ឋ គឺជាកាតព្វកិច្ចចម្បងមួយដែលពលរដ្ឋត្រូវបំពេញក្នុងទិសដៅជាឧត្តមប្រយោជន៍ជាតិរបស់ខ្លួន ក្នុងកិច្ចការពារជាតិ។ កាតព្វកិច្ចយោធា គឺជាមូលដ្ឋានសម្រេចមួយដែលកំណត់អំពីបែបបទនៃការចូលបំពេញកាតព្វកិច្ច និងសិក្សាហ្វឹកហ្វឺន ជាអាទិ៍ ត្រូវបានកំណត់ដោយច្បាប់របស់រដ្ឋ។ ប្រទេសជាទូទៅលើសកលលោកតែងមានច្បាប់កំណត់អំពីកាតព្វកិច្ចយោធារបស់ប្រជាពលរដ្ឋរបស់ខ្លួន ព្រោះថាការបំពេញកាតព្វកិច្ចយោធា គឺមានវត្ថុបំណងបង្កើតយោធិន បម្រុងសម្រាប់កិច្ចការពារជាតិក្នុងស្ថានចាំបាច់ ដើម្បីជួយដល់យោធិនអាជីព។ នៅកម្ពុជា កាតព្វកិច្ចយោធាត្រូវបានប្រកាសក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងមានបញ្ញត្តិពិសេសដោយឡែកដោយច្បាប់ស្តីពីកាតព្វកិច្ចយោធាឆ្នាំ២០០៦ ច្បាប់នេះមានគោលដៅកំណត់បែបបទការអនុវត្តកាតព្វកិច្ច រួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិដូចមានចែងក្នុងមាត្រា ៤៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ កាតព្វកិច្ចយោធាជាករណីកិច្ចចាំបាច់ និងជាកិត្តិយសដ៏ឧត្តុងឧត្តមរបស់ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។ កាតព្វកិច្ចយោធា ជាមូលដ្ឋានគ្រឹះនៃប្រភពកសាងកម្លាំងសម្រាប់វិស័យការពារជាតិ និងការអភិវឌ្ឍកាយសម្បទា ដែលជាតម្រូវការរបស់ប្រទេសជាតិ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។ កាតព្វកិច្ចការពារមាតុភូមិ ត្រូវអនុវត្តតាមបញ្ញត្តិច្បាប់[១៨]។ កាតព្វកិច្ចយោធា គឺជាករណីកិច្ចចាំបាច់ និង

---

[១៦] អត្ថបទចេញផ្សាយដោយ University of Notre Dame (ND) ចំណងជើង "Military Reform: Framework for a Comprehensive Political Settlement of the Cambodia Conflict" អានអត្ថបទ https://shorturl.at/fFST5 ។

[១៧] ប្រកាសចេញផ្សាយជាផ្លូវការនូវសៀវភៅសការពារជាតិឆ្នាំ២០២២ (DWP2022) នៅថ្ងៃទី ១២ ខែឧសភា ។

[១៨] មាត្រា ៤៩ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។

ជាកិត្តិយសដ៏ឧត្តុងឧត្តមរបស់ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។ កាតព្វកិច្ចយោធាជាមូលដ្ឋានគ្រឹះនៃប្រភពកសាងកម្លាំងសម្រាប់វិស័យការពារជាតិ និងការអភិវឌ្ឍកាយសម្បទា ដែលជាតម្រូវការរបស់ប្រជាជាតិ[១៩]។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបទាំងពីរភេទដែលមានអាយុពី១៨ឆ្នាំ ដល់ ៣០ឆ្នាំ ត្រូវបំពេញកាតព្វកិច្ចយោធាតាមការកំណត់នៃច្បាប់កាតព្វកិច្ចយោធា។ ការបំពេញកាតព្វកិច្ចយោធារបស់ប្រជាពលរដ្ឋខ្មែរ ជាស្ត្រីភេទគ្រប់រូប ត្រូវផ្អែកតាមការស្ម័គ្រចិត្ត[២០]។

## ៧. សេចក្តីសន្និដ្ឋាន

ប្រព័ន្ធយោធាបែបទំនើបនៅកម្ពុជាបានកើតមាននៅសតវត្សទី២០ ក្នុងសម័យអាណានិគមបារាំង ហើយកម្ពុជាបានផ្តើមរៀបចំប្រព័ន្ធយោធាដោយស្វយ័តនិងឯករាជ្យខ្លួនឯងបណ្តើរៗចាប់តាំងពីឆ្នាំ១៩៤៦ មក រហូតទទួលបានឯករាជ្យពេញលេញនៅឆ្នាំ១៩៥៣ ដែលបច្ចុប្បន្នកម្ពុជាបានកំណត់យកថ្ងៃទី៩ ខែវិច្ឆិកា (១៩៥៣) ធ្វើជាថ្ងៃរំលឹកខួបនៃការចាប់កំណើតរបស់កងយោធពលខេមរភូមិន្ទ។ ប្រព័ន្ធយោធាកម្ពុជាបានវិវត្តន៍តាមនិន្នាការ និងរបបនយោបាយប្រាំសម័យកាលរហូតដល់ពេលបច្ចុប្បន្ន។ អ្វីដែលជាប្រវត្តិសាស្ត្រឈឺចាប់គឺកម្ពុជាមានសង្គ្រាមស៊ីវិល ហើយបង្កើតឱ្យមានប្រព័ន្ធ ឬរបបយោធា ៤ ក្រុម ឬរបប នៅលើទឹកដីខ្មែរតែមួយក្នុងពេលតែមួយ ហើយវាយកម្ទេចគ្នាឯងទៅវិញទៅមក។ សង្គ្រាម និងការឈឺចាប់នៅកម្ពុជាក៏បានរលត់ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ និងការឯកភាពជាតិក្រោយមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារី ២៣ តុលា ឆ្នាំ១៩៩១ និងការបោះឆ្នោត ដោយសេរី យុត្តិធម៌ដំបូងឆ្នាំ១៩៩៣។ កងយោធពលខេមរៈភូមិន្ទមានគុណបំណាច់ និងស្នាដៃដ៏ធំធេញសម្រាប់ជាតិ និងប្រជាជនកម្ពុជាតាមរយៈផ្តល់ឱ្យកម្ពុជានូវសន្តិភាពពេញលេញ ក្រោយកំចាត់អង្គការចាត់តាំងខ្មែរក្រហមទាំងស្រុងនៅឆ្នាំ១៩៩៨ ដែលភាគីដកខ្លួនចេញពីកិច្ចព្រមព្រៀង និងការបោះឆ្នោត និងបង្កើតតំបន់កាន់កាប់ភាគខាងលិចនៃទឹកដីកម្ពុជា។ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ប្រមុខរដ្ឋាភិបាលនៅពេលនោះ កងកម្លាំងទាំងបួនភាគីបានធ្វើសមាហរណកម្មបញ្ចូលគ្នាទៅជាកងយោធពលខេមរភូមិន្ទតែមួយ រហូតដល់ពេលបច្ចុប្បន្នប្រកបដោយភាពសុខដុម និងមោទនភាពក្រៃលែង។

ពីឆ្នាំ១៩៩៩ មកប្រព័ន្ធយោធាកម្ពុជាបានធ្វើការកំណែទម្រង់ដ៏ធំធេញពីប្រទេសរ៉ាំរ៉ៃក្នុងសង្គ្រាមទៅជាប្រទេសស្តារអភិវឌ្ឍន៍សេដ្ឋកិច្ចដើម្បីជីវភាព និងការរស់នៅរបស់ប្រជាជន។ ការកាត់បន្ថយកងទ័ព ការកាត់បន្ថយការចំណាយលើវិស័យកងទ័ព ដែលមានរហូត ៣០% នៃថវិកាជាតិសរុបនៅក្នុងអំឡុងឆ្នាំ១៩៩៦-៩៧ ការកែទម្រង់រចនាសម្ព័ន្ធចាត់តាំង និងការលើកកម្ពស់កម្រិតជីវភាពកងទ័ពគឺជាការ

[១៩] មាត្រា ១ នៃច្បាប់ស្តីពីកាតព្វកិច្ចយោធា ឆ្នាំ២០០៦។

[២០] មាត្រា ២ នៃច្បាប់ស្តីពីកាតព្វកិច្ចយោធា ឆ្នាំ២០០៦។

កែទម្រង់ដ៏មានឥទ្ធិពល និងមានគុណប្រយោជន៍យ៉ាងធំធេងសម្រាប់ជាតិ និងប្រជាជនកម្ពុជា។ ក្នុងបរិបទបច្ចុប្បន្នកម្ពុជា បាននិងកំពុងបន្តធ្វើកិច្ចកំណែទម្រង់ជាពិសេសលើគោលយោបាយ បទដ្ឋានគតិយុត្ត បច្ចេកវិទ្យា និងធនធានមនុស្ស។ ថ្វីត្បិតតែយោធាកម្ពុជាបន្តកែទម្រង់ និងអភិវឌ្ឍន៍ទៅមុខ តែយ៉ាងណាយើងក៏នៅសង្កេតឃើញមានបញ្ហាមួយចំនួន ដែលយោធាកម្ពុជាត្រូវពង្រឹងជាចាំបាច់សម្រាប់ទិសដៅអភិវឌ្ឍន៍ប្រព័ន្ធយោធានៅកម្ពុជា

## ៨. អនុសាសន៍

អ្នកស្រាវជ្រាវសូមបង្ហាញទស្សនៈដោះស្រាយមួយចំនួនដូចខាងក្រោម៖

– ធានាបាននូវគណនេយ្យភាពនៃការប្រើប្រាស់ធនធានទាំងបុគ្គលិក និងហិរញ្ញវត្ថុ អភិវឌ្ឍន៍ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីគ្រប់គ្រងបុគ្គលិក និងភស្តុភារដែលមានប្រសិទ្ធភាព និងគណនេយ្យភាព។

– ក្រៅពីបៀវត្ស ក្រសួងការពារជាតិអាចបង្កើតយន្តការគាំទ្រគ្រួសារយោធិនដូចជា ការលើកលែងលើការបង់ថ្លៃសេវាសាធារណៈមួយចំនួន ការគិតគូរអំពីការអប់រំកូនយោធិន ជាពិសេសអាហារូបករណ៍សិក្សានៅគ្រឹះស្ថានសិក្សារបស់ក្រសួងការពារជាតិសម្រាប់គ្រួសារ ឬកូនរបស់យោធិន។

– រៀបចំប្រព័ន្ធគុណភាពនៃការបណ្តុះបណ្តាល ពោលគឺគុណភាពនៃការបណ្តុះបណ្តាលដែលទាន់សភាពការណ៍សកល គឺ បច្ចេកវិទ្យា វិទ្យាសាស្ត្រ បច្ចេកទេស និងឌីជីថល ។

– ក្រសួងការពារជាតិគួរជំរុញឱ្យបានលឿនលើការរៀបចំបទដ្ឋានគតិយុត្ត និងក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ ព្រោះការអភិវឌ្ឍដែលរឹងមាំ និងចីរភាព គឺការអភិវឌ្ឍដែលមានបទដ្ឋានគតិយុត្តគ្រប់គ្រង ជាពិសេស បទដ្ឋានដែលពាក់ព័ន្ធនឹងការការពារសិទ្ធិយោធិន។

# គន្ថនិទ្ទេស


- រដ្ឋធម្មនុញ្ញខ្មែរពីឆ្នាំ១៩៤៧ ដល់ ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃកងយោធពលខេមរភូមិន្ទឆ្នាំ១៩៩៦
- ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ឆ្នាំ១៩៩៧
- ច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធានៃកងយោធពលខេមរភូមិន្ទ ឆ្នាំ១៩៩៤
- សៀវភៅ ស ការពារជាតិ ឆ្នាំ២០០០
- សៀវភៅ ស ការពារជាតិ ឆ្នាំ២០០៦
- សៀវភៅ ស ការពារជាតិ ឆ្នាំ២០២២
- វិវេចនាយុទ្ធសាស្ត្រការពារជាតិឆ្នាំ២០១៣
- កៅ គឹមហួន, អ៊ឹង តុងអាន *"ការកែទម្រង់យោធានៅកម្ពុជា៖ ការរំសាយ និងការធ្វើសមាហរណកម្មកងកម្លាំងប្រដាប់អាវុធ"* បោះពុម្ពផ្សាយដោយវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព ភ្នំពេញ, ឆ្នាំ២០០៣
- *"កងទ័ពជើងគោក"* ប្រវត្តិសង្ខេប និងសមិទ្ធផលសំខាន់ៗ ១៩៩៩-២០១៦ បោះពុម្ពលើកទី១, ភ្នំពេញ ២០១៧ ដោយគណៈកម្មការប្រវត្តិសាស្ត្រយោធា ក.ជ.គ ។
- ណឹម សុវត្ថិ *"ការបញ្ចប់សង្គ្រាមស៊ីវិល ប្រកពសន្តិភាពពេញលេញនៅកម្ពុជា"* បោះពុម្ពលើកទី១ ខែតុលា ឆ្នាំ២០១១
- ម៉ៅ សុផាន់ *"គោលនយោបាយឈ្នះ-ឈ្នះ"* បោះពុម្ព គ.ស.២០១៤
- មីសែល ត្រាណេ *"ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាចក្រកពកម្ពុជទេស ពីស.វទី៩ ដល់ស.វទី១៣ នៃគ.ស ឆ្នាំ២០០៦"*
- យ.យ.មីហេយេវ *"ប្រវត្តិសាស្ត្រសង្ខេប នៃប្រទេសកម្ពុជា"* ប្រែសម្រួលដោយបណ្ឌិត ឡុង សៀម បោះពុម្ព ឆ្នាំ១៩៨៥
- រស់ ចន្ទ្រាបុត្រ *"ដំណើរស្វែងរកសន្តិភាពនៅកម្ពុជា"* បោះពុម្ពឆ្នាំ២០១៦
- ហ៊ុន សែន *"១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩ - ១៩៨៩"* , ឧទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, រៀបចំទំព័រឡើងវិញ និងធ្វើអក្ខរកម្មកុំព្យូទ័រខ្មែរយូនីកូដ សម្រាប់ការផ្សព្វផ្សាយតាមគេហទំព័រ www.cnv.org.kh ខែមករា ឆ្នាំ២០១១
- Foreign Languages Press *"ស៊ី ជីនភីង អភិបាលកិច្ចប្រទេសចិន"* បោះពុម្ពឆ្នាំ២០១៧
- Harish C. Metha Julie B. Mehta, *"Hun Sen Strongman of Cambodia"*, Singapore, 1999 បកប្រែជាភាសាខ្មែរដោយ កែ សឿន រោងពុម្ពបាយ័ន។

- IPU and DCAF – Parliamentary oversight of the security sector: Principles, mechanisms and practices, 2003. បកប្រែ និងបោះពុម្ពផ្សាយជាភាសាខ្មែរដោយវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) ឆ្នាំ២០១៦
- Australian Government, Department of Defence *"Defence Economic Trends In The Asia-Pacific 2015"* DIO Reference Aid 15–003, March 2015
- Christina Wille *"How Many Weapons AreThere in Cambodia?"* Small Arms Survey Working Paper 4.2006
- Chap Sotharith *"Cambodia: Security Challenges and Implications for Defense Policy"* CICP working paper No:33 January 2010 page 7.
- *"Cambodia a Country Study"* Copyright 1990 United States Governmt-t as represented by the Secretary of the Army. Third Edition, First Printing, 1990.
- Boraden Nhem *"THE THIRD INDOCHINA CONFLICT: CAMBODIA'S TOTAL WAR"* Master of Military Art and Science ,2014
- Buzan, B. and L. Hansen (2009). The Evolution of International Security Studies. Cambridge, Cambridge University Press.
- Dr. Spencer C. Tucker (Editor) *"THE ENCYCLOPEDIA OF THE VIETNAM WAR: A Political, Social, and Military History"*, Second Edition 2011.

# ប្រសិទ្ធភាពការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់សេវាសាធារណៈ

បេក្ខជនបណ្ឌិត៖ **ភួន ភូម៉ូនីរតន៍**
ជំនាញ៖ **រដ្ឋបាលសាធារណៈ**

## ១. សេចក្តីផ្តើម

ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាពរយៈពេលវែង ក្នុងចក្ខុវិស័យរបស់រដ្ឋាភិបាលកម្ពុជា ការធានាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនខ្ពស់ ប្រកបដោយនិរន្តរភាព បរិយាបន្ន និងសមធម៌ ការលើកកម្ពស់ជីវភាពរស់នៅរបស់ពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រប្រកបដោយភាពធន់នឹងវិបត្តិនានា តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែង[១] តាមបរិបទសង្គម និងសកលលោកនៃការផ្លាស់ប្តូរឌីជីថល [២]។ ពីព្រោះបច្ចេកវិទ្យាឌីជីថលបានផ្តល់ឱកាសជាច្រើន ដែលពីមុនអាចប្រើបានតិចតួចប៉ុណ្ណោះ[៣] សម្រាប់កម្ពុជា គឺស្របពេលនឹងដំណើរការផ្លាស់ប្តូរគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភាបានបន្តដំណើរមកដល់សហសម័យកម្ពុជាដែលជាយុគសម័យទំនើប រីកចម្រើនទៅមុខ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរការការកសាងរដ្ឋាភិបាលឌីជីថលនៅកម្ពុជា ដែលកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការធ្វើឌីជីថលូបនីយកម្មតាមបណ្តាស្ថាប័នរដ្ឋនានា ដែលនៅមិនទាន់មានភាពស៊ីសង្វាក់គ្នាពេញលេញនៅឡើយ។

## ២. សារៈសំខាន់នៃការផ្លាស់ប្តូរ

យោងតាមស្នាដៃនានាពីបរទេស ការផ្លាស់ប្តូររដ្ឋបាល និងសេវាសាធារណៈប្រពៃណីជំនួសឱ្យការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់សេវាសាធារណៈ ត្រូវបានកំណត់ដំណាក់កាលនៃឌីជីថលភាវូបនីយកម្ម វាយតម្លៃសមិទ្ធផលនៃឌីជីថលូបនីយកម្មដោយផ្អែកលើកម្មវិធីដំណើរការក្នុងស្ថាប័ន ការវិភាគពីសេវាកម្មអេឡិចត្រូនិក និងការពិពណ៌នាអំពីឧបករណ៍ឌីជីថលថ្មីៗ[៤] លើលក្ខណៈពិសេសក្នុងគោលបំណងការប្រើប្រាស់ឌីជីថលសម្រាប់ការផ្តល់សេវាថា ជាសមិទ្ធផលជាក់លាក់ មានតម្លាភាព មានសុចរិតភាព និងគណនេយ្យភាព នៅក្នុងដំណោះស្រាយកម្មវិធីដែលត្រូវបានអនុវត្តយ៉ាងសកម្មនៃសេវាសាធារណៈប្រពៃណី ទៅជាសេវាកម្មទំនើបគួរតែត្រូវបានដាក់ឱ្យដំណើរការឌីជីថលភាវូបនីយកម្មនៃការផ្លាស់ប្តូរឌីជីថលលើវិស័យសេវាសាធារណៈតាមគោលដៅប្រកបដោយមហិច្ឆតាថ្មី ដែលទាមទារភាពបត់បែន និងល្បឿននៃការប្រតិបត្តិដោយទំនុកចិត្ត និងភាពជឿជាក់ ដើម្បីបន្តនិរន្តរភាពការងារសេវាជាចាំបាច់បានត្រូវកំណត់នូវអ្វីដែលមានការរារាំងនៅក្នុងដំណើរការនៃការផ្លាស់ប្តូរការប្រើប្រាស់នេះ។

---

[១] យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

[២] (World Bank Group, 2019).

[៣] (Belyakova & Pyrkina ២០២១; Belyakova et al., ២០២០).

[៤] (Prendville, ២០១៨; Osman et al., ២០១៩) និង (Dobrolyubova et al., ២០១៧).

ដូច្នេះការផ្លាស់ប្តូររដ្ឋបាលសាធារណៈប្រពៃណីនឹងត្រូវបានសំដៅដល់ការផ្លាស់ប្តូរ តាមគន្លងថ្មីឌីជីថលលើសេវាសាធារណៈ ព្រោះវាជាផ្នែកមួយដ៏សំខាន់នៃការធ្វើទំនើបកម្មស្ថាប័នរដ្ឋក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក ជាភារកិច្ចចម្បង គឺដើម្បីធ្វើឌីជីថលលើការគ្រប់គ្រងការផ្តល់សេវាឱ្យលឿន ហើយសចំណេញពេលវេលា ចំណាយតិច និងមាននូវផ្នែកសំខាន់ៗដទៃមួយចំនួនទៀតដល់គោលដៅរួមក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិកតាមស្ថាប័ន។

## ៣. អត្ថន័យ ឬគោលគំនិតនៃការផ្លាស់ប្តូរការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល

ខ្ញុំមានករណីគួរឱ្យចាប់អារម្មណ៍ ដើម្បីទាញយកធាតុផ្សំលើវិធីសាស្ត្រសេវាកម្មសាធារណៈតាមគន្លងថ្មីត្រូវបានផ្អែកលើផលប្រយោជន៍ និងតម្រូវការប្រជាពលរដ្ឋ ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣[៥] នៅក្នុងកំណែទម្រង់រដ្ឋបាលនិងសេវាសាធារណៈ ដែលភ្ជាប់ជាមួយការផ្លាស់ប្តូរសេវាសាធារណៈប្រពៃណី ជំនួសឱ្យការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលមានដំណោះស្រាយនៅក្នុងបរិយាកាសខាងក្នុង និងខាងក្រៅគឺការវាយតម្លៃពីគុណសម្បត្តិមន្ត្រីសាធារណៈដោយការប្រកួតប្រជែង និងរួមបញ្ចូលគ្នាជាផ្លូវមួយក្នុងចក្ខុវិស័យដើម្បីក្លាយជាការប្រកួតប្រជែងរកផលប្រយោជន៍ និងផលចំណេញឱ្យកាន់តែច្រើនទៅដល់ស្ថាប័នក្នុងដំណើរការវាយតម្លៃការគ្រប់គ្រង និងប្រើប្រាស់បច្ចេកវិទ្យាជំនាញធនធានមនុស្សរបស់មន្ត្រីសាធារណៈក្នុងពេលនៃការផ្លាស់ប្តូរតាមកំណែទម្រង់ស្ថាប័ន ថាជាដំណើរការនៃការធ្វើឱ្យប្រាកដទៅលើគុណភាពផ្នែកសេវាសាធារណៈ និងការឆ្លើយតបយ៉ាងត្រឹមត្រូវចំពោះសង្គមប្រជាពលរដ្ឋ វាទាមទារឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត ឥរិយាបទ និងអាកប្បកិរិយាបុគ្គលជាមូលដ្ឋានដែលក្នុងនោះកំណែទម្រង់សំដៅឆ្ពោះទៅរកការផ្លាស់ប្តូរគុណតម្លៃ ក្រមសីលធម៌វិជ្ជាជីវៈ ក៏ដូចជាការពង្រឹងសមត្ថភាពសេវារដ្ឋបាលសាធារណៈផ្តោតលើកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនការលើកទឹកចិត្ត កសាងទំនុកចិត្ត និងការបង្កើតបានក្រុមជំនាញបច្ចេកវិទ្យានៃមុខវិជ្ជាជីវៈ ជាឱកាសកាន់តែច្រើនក្នុងផលចំណេញ និងភាពជោគជ័យដល់បរិយាកាសនយោបាយដែលបណ្តុះបាននូវគណនេយ្យភាពសង្គម ស្មើភាព តម្លាភាព និងមានការទទួលខុសត្រូវច្បាស់លាស់ចំពោះមុខប្រជាពលរដ្ឋ។

**ពាក្យគន្លឹះ ៖ បច្ចេកវិទ្យាឌីជីថល គឺការផ្លាស់ប្តូរឌីជីថលសម្រាប់ការគ្រប់គ្រងរដ្ឋបាល និងសេវាសាធារណៈ បែបប្រពៃណី ទៅជាឌីជីថល និងក្នុងការធ្វើទំនើបកម្មរដ្ឋាភិបាល។**

## ៤. គោលបំណងនៃការផ្លាស់ប្តូរធ្វើឱ្យមានភាពប្រសើរឡើង

គោលបំណងនៃការសិក្សានេះ គឺដើម្បីវិភាគ និងបង្ហាញពីវឌ្ឍនភាពនៃការផ្លាស់ប្តូររដ្ឋបាលសេវាសាធារណៈប្រពៃណី ជំនួសដោយបច្ចេកវិទ្យាឌីជីថលសម្រាប់សេវាសាធារណៈ។ ការបង្ហាញយ៉ាងច្បាស់ៗពីបញ្ហាដែលមានស្រាប់នៅក្នុងស្ថាប័នរដ្ឋតែម្តង ចាំបាច់ក្នុងការកំណត់លក្ខណៈនៃមុខងាររបស់ស្ថាប័នក៏ដូចជាការលំបាកនានាដែលទាក់ទងនឹងការផ្តល់សេវា និងដំណោះស្រាយបន្តបន្ទាប់ដើម្បីកំណត់នូវអ្វីដែលនឹងធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តការផ្លាស់ប្តូរ និងអ្វីដែលជាផលប៉ះពាល់ចម្បងដែល

---

[៥] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

ទទួលបានពីលទ្ធផលនៃការផ្លាស់ប្តូរសេវាប្រពៃណីនេះ នឹងឱ្យយើងវាយតម្លៃពីវឌ្ឍនភាពដែលត្រូវបានធ្វើឡើងនៅស្ថាប័នរដ្ឋជាមួយដៃគូឯកជន ក្នុងការលើកកម្ពស់ កែលម្អស្ថានភាពស្ថាប័នរដ្ឋបច្ចុប្បន្ន និងទៅពេលអនាគត។

ដូច្នេះ! **តើស្ថាប័នរដ្ឋអាចយកឈ្នះការផ្លាស់ប្តូរនេះដោយរបៀបណា?** ក្នុងរយៈពេលយូរជំនួសដោយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលលើកត្តាសំខាន់នៃការផ្លាស់ប្តូរដែលថា ៖ **ហេតុអ្វីបានជាស្ថាប័នមួយនឹងពិចារណាការផ្លាស់ប្តូរយុទ្ធសាស្ត្រដោយសារមានឥទ្ធិពលពីកត្តាខាងក្រៅ និងផលប៉ះពាល់ដល់កត្តាខាងក្នុង?**។ យើងចាំបាច់ត្រូវកំណត់អត្តសញ្ញាណបញ្ហាជាច្រើន ដែលរារាំងដំណើរការប្រើប្រាស់សេវាកម្មឌីជីថលនីយកម្មនៅក្នុងស្ថាប័នរដ្ឋ គឺការតភ្ជាប់យ៉ាងជិតស្និទ្ធជាមួយការប្រមូលផ្តុំទិន្នន័យព័ត៌មាន និងការដាក់ចេញជាអនុសាសន៍សម្រាប់ការលុបបំបាត់ភាពអសកម្មនៃរដ្ឋបាលប្រពៃណី ជំនួសដោយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់សេវាសាធារណៈនាពេលអនាគតរបស់កម្ពុជា។

## ៥. វិធីសាស្ត្រនៃការផ្លាស់ប្តូរ

ដើម្បីធ្វើឱ្យការស្រាវជ្រាវកាន់តែមានសារៈសំខាន់ និងផលប្រយោជន៍ ខ្ញុំបាទបានប្រើពីវិធីសាស្ត្ររួមបញ្ចូលគ្នានៃវិធីសាស្ត្រស្រាវជ្រាវលើទិន្នន័យដែលមានស្រាប់ និងវិធីសាស្ត្រចុះសម្ភាសន៍ មានប្រើជាកម្រងសំណួរយកមកជាមូលដ្ឋានវិភាគ សំយោគ និងប្រៀបធៀប ហើយការសិក្សានេះត្រូវបានបំពេញបន្ថែមដោយវិធីសាស្ត្រនៃការវិភាគតាមបរិមាណវិស័យ និងគុណវិស័យលើកត្តាធនធានមនុស្ស។ ផ្អែកលើវិធីសាស្ត្រប្រៀបធៀបពីទិន្នន័យស្តីពីសមិទ្ធផលឌីជីថលនីយកម្ម ក្នុងការស្រាវជ្រាវយកបទពិសោធន៍ការអនុវត្តន៍ជាមួយនឹងសូចនាករមួយចំនួននៃសម័យកាលមុនៗ ស្តីពីសេវាសាធារណៈបែបប្រពៃណីដោយការកំណត់ទិសដៅនៃការផ្លាស់ប្តូរពីប្រសិទ្ធភាព និងប្រសិទ្ធផល ជាហេតុផលនាំឱ្យយើងមានឱកាសដើម្បីប្រៀបធៀបសូចនាករ ក្នុងល្បឿនមួយសម្រាប់ការផ្លាស់ប្តូររដ្ឋបាលប្រពៃណី ជំនួសដោយសេវាកម្មឌីជីថលក្នុងក្នុងពេលបច្ចុប្បន្ន ភ្ជាប់នឹងបទប្បញ្ញត្តិនានាតាមការវិភាគបកស្រាយលើទិន្នន័យជាក់ស្តែងសម្រាប់សេវាទាំងនៅថ្នាក់ជាតិនិងនៅក្រោមជាតិ ដែលអាចកំណត់បានលើដំណើរការឌីជីថល ជាមួយនឹងការលើកកម្ពស់ការកែលម្អស្ថាប័នរដ្ឋ [៦]។

## ៦. ការធ្វើសំយោគពីប្រសិទ្ធភាពនៃការផ្លាស់ប្តូរឌីជីថល

ការរកឃើញតាមការវិភាគដែលបានធ្វើឡើងលើទិន្នន័យជាក់ស្តែងបង្ហាញថា បច្ចេកវិទ្យាឌីជីថលត្រូវបានប្រើប្រាស់យ៉ាងសកម្មនៅក្នុងរដ្ឋបាលសាធារណៈទាំងនៅក្នុងតំបន់ និងសកលលោក។ មេដឹកនាំធំៗនៅក្នុងវិស័យរដ្ឋបាលសាធារណៈតម្រូវឱ្យមានការផ្លាស់ប្តូរ ហើយបច្ចុប្បន្នមានប្រទេសឈានមុខគេគឺចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងកូរ៉េខាងត្បូង ដោយប្រទេសទាំងអស់នេះបានបង្កើតនូវកម្មវិធីឌីជីថល លើការផ្តល់សេវាកម្មសាធារណៈបានយ៉ាងទូលំទូលាយ នេះបើតាម (Omar et al., ២០១៧)។

ជាពិសេស ការពិនិត្យឡើងវិញរបស់ធនាគារពិភពលោកលើសេវាអេឡិចត្រូនិករដ្ឋាភិបាលចក្រភពអង់គ្លេសបានបង្ហាញថា ប្រសិនបើសេវាសាធារណៈបែបប្រពៃណីដែលផ្តល់ឱ្យត្រឹមតែមួយភាគបី

[៦] Digital Mckinsey (Aptekman et al., 2017; World Bank Group, 2019)

ត្រូវបានបំប្លែងទៅជាទម្រង់ឌីជីថល ការសន្សំប្រចាំឆ្នាំនឹងមានចំនួនលើសពីមួយពាន់លានដោន [៧] ជាង នេះទៅទៀត អន្តរកម្មរវាងប្រជាពលរដ្ឋ និងស្ថាប័នរដ្ឋក្នុងទម្រង់នេះ គឺមានតម្លៃថោកជាង ៥០ដងក្នុងទម្រង់ប្រតិបត្តិការទល់មុខគ្នា។

សម្រាប់ប្រទេសកម្ពុជា ប្រសិនបើសេវាសាធារណៈប្រពៃណីទាំងអស់ត្រូវបានបំប្លែងទៅជាទម្រង់ឌីជីថល នោះអត្ថប្រយោជន៍ដែលបានប៉ាន់ប្រមាណនឹងមានប្រហែលជាង ៥០ពាន់-ពាន់លានរៀលក្នុងមួយឆ្នាំៗ ហើយនេះគឺជាតួលេខគួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ ដែលពន្យល់ពីមូលហេតុ**ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា** ជាអាទិភាពនោះ វាត្រូវបានបង្ហាញដោយការកើនឡើងនៃទំហំវិនិយោគនៅក្នុងប្រទេសនេះតែម្តង។ ឧទាហរណ៍ ការត្រឡប់មកវិញលើការវិនិយោគក្នុងវិស័យសាធារណៈប្រពៃណីក្នុងឆ្នាំ២០១៨ មានចំនួន ៨៣,៤ពាន់លានរៀល មានការកើនឡើង៧.៥% បើប្រៀបធៀបទៅនឹងទិន្នន័យឆ្នាំ២០១៧ ហើយអតិថិជនធំបំផុតគឺស្ថាប័នរដ្ឋតំណាងដោយស្ថាប័នរដ្ឋ និងអាជ្ញាធរសាធារណៈប្រពៃណីនិងថ្នាក់ក្រោមជាតិ។ ថ្មីៗនេះតាមសន្ទស្សន៍ការអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិករបស់កម្ពុជាក៏ខ្ពស់ផងដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ វាបានរីកចម្រើនយ៉ាងខ្លាំង ហើយត្រូវបានវាយតម្លៃថា **"ខ្ពស់"** ដោយអង្គការសហប្រជាជាតិ ដែលធ្វើឱ្យកម្ពុជាឈានដល់លេខរៀងទី៣២ ក្នុងការវាយតម្លៃជារួមការអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់ផ្លាស់ប្តូរការផ្តល់សេវាសាធារណៈប្រពៃណីឈានឆ្ពោះទៅការផ្តល់សេវាដោយការប្រើប្រាស់ឌីជីថល(គន្លងថ្មី)។

នៅកម្ពុជាចុងឆ្នាំ២០១៩ មនុស្សជាង ៧លាននាក់ ត្រូវបានចុះឈ្មោះនៅលើវិបផតថលផ្លូវការនៃសេវាកម្មសាធារណៈឌីជីថល ចំនួននៃសេវាកម្មដែលបានផ្តល់តាមអនឡាញមានចំនួនច្រើនជាង ១២,៦ពាន់លានរៀល កើនឡើងនាំឱ្យមានការបង្កើតមជ្ឈមណ្ឌលពហុមុខងារជាច្រើនក្នុងច្រកតែមួយនៃសេវាសាធារណៈប្រពៃណី ប្រព័ន្ធអន្តរកម្មអេឡិចត្រូនិកជាអន្តរនៃផ្នែកសេវាកម្មឌីជីថលភាវូបនីយកម្មក្នុងវិស័យសាធារណៈប្រពៃណីត្រូវបានបានផ្លាស់ប្តូរជាបណ្តើរៗនៅក្នុងស្ថាប័នរដ្ឋ និងកើនឡើងយ៉ាងខ្លាំងកំឡុងពេល និងក្រោយពេលជំងឺរាតត្បាតកូវីដ-១៩ ដែលបម្រើឱ្យជាការលើកទឹកចិត្តដ៏សំខាន់មួយរវាងស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍ និងសង្គមប្រជាពលរដ្ឋមានក្នុងឆ្នាំ២០២០ សេវាឌីជីថលពេញលេញចំនួនជាង៣៥ ត្រូវបានចាប់ផ្តើម រួមទាំងការទូទាត់តាមអាប់ ការចុះឈ្មោះលិខិតឆ្លងដែនអេឡិចត្រូនិកយានយន្ត ក្រុមហ៊ុន និងការទូទាត់ប្រាក់ដោយឌីជីថលលើសេវាកម្មអនឡាញផ្សេងៗ។ល។ ទាំងអស់នេះអាចទទួលបានដោយមិនចាំបាច់ចាកចេញពីផ្ទះចំណេញពេលវេលា និងថវិកា។

ដើម្បីកំណត់ឱ្យកាន់តែច្បាស់អំពីអត្ថប្រយោជន៍ ការប្រើប្រាស់សេវាបច្ចេកវិទ្យាឌីជីថលបាននាំមកនូវភាពចាំបាច់ដំបូងគេ យើងត្រូវកំណត់លក្ខណៈពិសេសនៃវិស័យរដ្ឋបាល និងសេវាសាធារណៈប្រពៃណីនូវរបៀបធ្វើការក្នុងទំនាក់ទំនងពហុបណ្តាញ ដែលបណ្តាញទាំងមូលមានភាពស្មុគស្មាញនិងមានលក្ខណៈទ្រង់ទ្រាយធំ លើសពីនេះទៀតនោះ មន្ត្រីសាធារណៈក្នុងស្ថាប័នរដ្ឋបាលសាធារណៈប្រពៃណី អនុវត្តការងារប្រភេទផ្សេងៗគ្នាដែលតម្រូវឱ្យមានការប្រើប្រាស់មធ្យោបាយមិនស្វ័យប្រវត្តិកម្ម[៨]

---

[៧] (World Bank Group, 2019)។

[៨] (Troshani et al , ២០១៨)។

ហើយដោយមិនគួរឱ្យសង្ស័យទេថា វាក៏មានសារៈសំខាន់ផងដែរដែលមន្ត្រីសាធារណៈផ្នែកសេវាកម្មប្រពៃណីត្រូវបំពេញតាមឆន្ទៈរបស់ថ្នាក់ដឹកនាំស្ថាប័ន សម្រាប់ការដាក់ និងទទួលឯកសារ។ ផលប៉ះពាល់ចម្បងដែលកើតចេញពីការផ្លាស់ប្តូររដ្ឋបាលសាធារណៈប្រពៃណី ជំនួសដោយការប្រើប្រាស់នូវសេវាបច្ចេកវិទ្យាឌីជីថលនឹងត្រូវបានកាត់បន្ថយដល់ការបង្កើនមន្ត្រីសាធារណៈ និងការថយចុះពេលវេលាធ្វើការសម្រេចចិត្ត ជាមួយការបង្កើតឱកាសការងារថ្មីសម្រាប់ការគ្រប់គ្រងថ្នាក់ជាតិ និងក្រោមជាតិ អាចធានាដល់ការគ្រប់គ្រងឯកសារអេឡិចត្រូនិកបានក្នុងពេលតែមួយ គឺជាប្រភពព័ត៌មានតែមួយ ដូចជាការប្រមូលផ្តុំបទពិសោធន៍ និងកែលម្អសកម្មភាពតាមរយៈការរួមបញ្ចូលគ្នានៃមូលដ្ឋានទិន្នន័យ វិបផតថលព័ត៌មាន ប្រព័ន្ធស្វែងរកសាជីវកម្ម ការកែលម្អភាពការងារ និងងាយបត់បែនក្នុងការសម្រេចចិត្តលើការគ្រប់គ្រង ដោយកាត់បន្ថយចំនួននៃកំហុសក្នុងការសម្រេចចិត្ត កាត់បន្ថយពេលវេលាបានឆាប់ជាងបង្រួមបានប្រតិបត្តិការលឿនលើមុខងារសេវាបានដោយភាពត្រឹមត្រូវនូវតម្លាភាព សុចរិតភាព និងភាពច្បាស់លាស់។

គ្រប់យ៉ាងដែលបានរៀបរាប់ខាងលើ បានបង្ហាញពីឱកាសដែលការផ្លាស់ប្តូររដ្ឋបាលសាធារណៈប្រពៃណី ជំនួសដោយឌីជីថល ផ្តល់ឱ្យក្នុងលក្ខខណ្ឌដែលទទួលយកបានពីគុណភាព ប្រសិទ្ធភាព មានលទ្ធផលនៃមុខងារកាន់តែប្រសើរឡើង និងការកាត់បន្ថយចំណាយលើដំណើរការនៃការគ្រប់គ្រងក្នុងស្ថាប័នរដ្ឋ និងការចំណាយលើគម្រោងថវិកាជាតិ នោះវាចាំបាច់ក្នុងការពិចារណាបន្ថែមពីអ្វីដែលរារាំងការរីកចំរើននៅក្នុងស្ថាប័នរដ្ឋនេះទៀតផងដែរ។ បច្ចុប្បន្នក៏នៅមានជាឧបសគ្គចំពោះការអភិវឌ្ឍដូចជាបទដ្ឋានបទប្បញ្ញត្តិមិនគ្រប់គ្រាន់ កម្រិតថវិកានៅមានមានកំណត់ កង្វះមន្ត្រីដែលមានសមត្ថភាពជំនាញប្រើប្រាស់បច្ចេកវិទ្យា កង្វះសម្ភារៈឧបករណ៍កម្រិតស្តង់ដារបច្ចេកវិទ្យា និងសុវត្ថិភាពព័ត៌មាននៅកម្រិតទាប ហើយមិនមានគ្រប់គ្រាន់គួរឱ្យទុកចិត្តបាន ក្នុងការវិភាគលើប្រព័ន្ធឌីជីថលបច្ចុប្បន្នទៅតាមតម្រូវការ។ ជាទូទៅសម្រាប់ទំនើបកម្មស្ថាប័នរដ្ឋដែលនឹងគិតគូរទៅលើការអនុវត្តន៍ពីប្រសិទ្ធភាពនៃការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់សេវាសាធារណៈ ការកំណត់បាននូវការរីករាលដាលនៃបច្ចេកវិទ្យាឌីជីថល គឺជាដំណើរការចំណាយដ៏ថ្លៃមួយដែលត្រូវការការវិនិយោគ ជាពិសេសនៅដំណាក់កាលដំបូងនៃការធ្វើឌីជីថល ខណៈដែលការត្រឡប់មកវិញលើការវិនិយោគនឹងមិនបានមកវិញលឿននោះទេ នេះជាមូលហេតុដែលស្ទើរតែគ្រប់ប្រទេសទាំងអស់ក្នុងសកលលោកបានជួបប្រទះកន្លងមក។

សម្រាប់ប្រទេសកម្ពុជា ក៏មិនមានករណីលើកលែងខុសពីករណីខាងលើបែបនោះដែរ បច្ចុប្បន្នកម្ពុជាកំពុងជួបប្រទះបញ្ហាហិរញ្ញវត្ថុ នៅពេលអនុវត្តឌីជីថលនីយកម្មនៅក្នុងវិស័យដែលបានវិភាគលើមុខងារផ្សេងៗ ក្នុងបរិបទនៃការបង្កើនប្រសិទ្ធភាពតម្លៃ វាមិនទំនងដើម្បីផ្តល់ហិរញ្ញប្បទានដល់ផ្នែកនេះពេញលេញទេ ដែលជាហេតុអាចរារាំងល្បឿននៃការធ្វើឌីជីថលលើបញ្ហានៃស្តង់ដារបច្ចេកវិទ្យាមិនគ្រប់គ្រាន់ នៅត្រង់ចំណុចនេះ យើងប្រឈមមុខនឹងស្ថានភាពផុយស្រួយយ៉ាងខ្លាំង។ ហើយម្យ៉ាងវិញទៀតកម្ពុជាត្រូវបានកំណត់លក្ខណៈដោយភាពយឺតយ៉ាវផ្នែកបច្ចេកវិទ្យាមួយចំនួន គឺដោយសារតែប្រទេសកម្ពុជាបានចាប់ផ្តើមឌីជីថលនីយកម្មយឺតជាងប្រទេសក្នុងតំបន់ និងបណ្តាប្រទេសផ្សេងទៀតនៅលើសកលលោក។ ដូច្នេះត្រូវការពេលវេលាដើម្បីតាមទាន់ពួកគេ ហើយយើងក៏នៅមានបញ្ហាចំពោះមន្ត្រីសាធារណៈមួយចំនួនទៀតផងដែរ រួមមានកង្វះមន្ត្រីដែលមានសមត្ថភាពខ្ពស់បច្ចេកវិទ្យា ដោយមន្ត្រីខ្លះ

នៅមានកម្រិតទាបនៃចំណេះដឹងកុំព្យូទ័រ ដែលរារាំងការប្រើប្រាស់ឱ្យបានសកម្មនៃបច្ចេកវិទ្យាឌីជីថលនៅក្នុងការងាររបស់ពួកគេ ហើយក៏មិនមែនមន្ត្រីទាំងអស់មានឆន្ទៈក្នុងការទទួលបានជំនាញថ្មីៗនោះទេ។ ក៏ប៉ុន្តែវាច្បាស់ណាស់ថា យើងគួរតែបន្តធ្វើការលើការងាររួមបញ្ចូលប្រព័ន្ធព័ត៌មានស្ថាប័នរដ្ឋនីមួយៗឱ្យទៅជាឯកតាតែមួយ និងស៊ីសង្វាក់គ្នា ដែលបង្កប់ន័យដល់ការអភិវឌ្ឍន៍នូវកម្រងកម្មវិធីរួមគ្នា លើការបង្កើតឧបករណ៍ស្តង់ដារ និងភាពងាយស្រួលប្រើសម្រាប់ការផ្លាស់ប្តូរសេវាសាធារណៈប្រពៃណី ជាមួយឌីជីថល ដែលអ្នកប្រើប្រាស់ថ្មីៗរាប់លាននាក់អាចចូលប្រើប្រាស់បានយ៉ាងងាយស្រួលនៅក្នុងគម្រោងកម្មវិធីឌីជីថលនេះ។

ដើម្បីដោះស្រាយបញ្ហានេះ ចាំបាច់ត្រូវលើកទឹកចិត្តដល់មន្ត្រីសាធារណៈឱ្យប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យសកម្ម ដើម្បីបង្កើនកម្រិតនៃចំណេះដឹងកុំព្យូទ័រ ឱ្យចូលរួមក្នុងសិក្ខាសាលា និងសិក្ខាសាលាតាមគេហទំព័រ ដែលគួរធ្វើឡើងទៀងទាត់ក្នុងស្ថាប័នសាធារណៈប្រពៃណីលើបញ្ហានៃបទដ្ឋាននិយ័តកម្មមិនគ្រប់គ្រាន់ នៃឌីជីថលនីយកម្មវិស័យសេវាសាធារណៈ ពីកង្វះការសម្របសម្រួលរវាងកិច្ចខិតខំប្រឹងប្រែងដែលកំពុងបន្តនូវការផ្លាស់ប្តូរឌីជីថលលើសកម្មភាពច្បាប់ និងបទប្បញ្ញត្តិសេវារដ្ឋបាលលបច្ចុប្បន្ន។ វាក៏មានតម្លៃផងដែរក្នុងការនិយាយអំពីភាពមិនល្អឥតខ្ចោះនៃច្បាប់ និងកង្វះស្តង់ដារតែមួយនៅពេលជ្រើសរើសយកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល។ ទោះជាយ៉ាងណាក៏ដោយ យើងគួរតែត្រូវបានគិតថាការវិនិយោគនេះនឹងសងវិញយ៉ាងឆាប់រហ័ស ដោយសារតែការសន្សំពេលវេលា ប្រាក់ និងធនធានមនុស្សដ៏សំខាន់ ដូច្នេះចាំបាច់ត្រូវបន្តដំណើរការ និងជំរុញការផ្លាស់ប្តូររដ្ឋបាលសាធារណៈប្រពៃណីជំនួសឌីជីថលលើការផ្តល់សេវា ដើម្បីឱ្យមានប្រសិទ្ធភាព លឿន រហ័ស តម្លាភាព សុចរិតភាព មានគណនេយ្យភាព និងការកសាងទំនុកចិត្តពីប្រជាពលរដ្ឋ។

ជាទូទៅការរំពឹងទុករបស់កម្ពុជា ទាក់ទងនឹងការផ្លាស់ប្តូររដ្ឋបាលសាធារណៈប្រពៃណី ជំនួសការប្រើប្រាស់ឌីជីថល វានឹងមានភាពភ្លឺស្វាងនឹងមានសក្តានុពលដ៏សំខាន់សម្រាប់ការអភិវឌ្ឍ នេះបើយោងតាមក្រុមអ្នកជំនាញ Digital Mckinsey ការធ្វើឌីជីថលនៃសេដ្ឋកិច្ចរបស់កម្ពុជានឹងធ្វើឱ្យផលិតផលក្នុងស្រុកសរុបកើនឡើងពី ៤,១ ដល់ ៨,៩ ពាន់ពាន់លានរៀលនៅឆ្នាំ២០២៥ វាត្រូវបានព្យាករទុកដើម្បីជានាពីដំណើរការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជា។

## ៧. សេចក្តីសន្និដ្ឋាន

តាមការសិក្សាបានអនុញ្ញាតឱ្យយើងកំណត់អត្តសញ្ញាណសមិទ្ធផលក្នុងការផ្លាស់ប្តូរ នោះគឺជាមធ្យោបាយមួយបន្ថែមទៀតដើម្បីលើកកម្ពស់កែលម្អការការងារក្នុងស្ថាប័ន ដែលការធ្វើឱ្យមានទំនើបកម្មស្ថាប័នរដ្ឋក្នុងការអភិវឌ្ឍស្តង់ដារថ្មីលើប្រព័ន្ធសេវាកម្មឌីជីថលរបស់កម្ពុជាចូលទៅក្នុងតំបន់ និងពិភពលោក។ ខណៈពេលដែលកម្ពុជាកំពុងអភិវឌ្ឍនូវកម្មវិធីថ្មីៗបន្ថែមទៀត នៃដំណើរការនៃឌីជីថលនីយកម្មព័ត៌មានបច្ចេកវិទ្យា ដែលនឹងជួយបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលការងារស្ថាប័នរដ្ឋ ហើយដែលកម្ពុជាគួរតែស្នើឱ្យមានគោលនយោបាយ ឬបទប្បញ្ញត្តិថ្មីៗ ដើម្បីឆ្លើយតបទៅនឹងល្បឿននៃការផ្លាស់ប្តូរនៅក្នុងបរិវត្តកម្មឌីជីថលនៃប្រទេសក្នុងតំបន់ និងសកលលោក ដោយការធ្វើឌីជីថលក្នុងស្ថាប័នរដ្ឋ ឱ្យបានលឿន រហ័ស ការកសាងទំនុកចិត្តឱ្យមានការចូលរួមពីប្រជាពលរដ្ឋបានកាន់តែមានភាពប្រសើរឡើងពីការប្រើប្រាស់បច្ចេកវិទ្យាដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជាឱ្យមានភាពស្មើគ្នាលើឆាកអន្តរជាតិ។

## ៨. អនុសាសន៍

ដើម្បីការលើកកម្ពស់គុណភាពស្ថាប័ន៖

- ការធ្វើកំណែទម្រង់លើរចនាសម្ព័ន្ធ មុខងារ តួនាទី ភារកិច្ចឱ្យស្របទៅនឹងក្របខ័ណ្ឌនៃមន្រ្តីរាជការទៅតាមនិន្នាការនយោបាយ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ស្ថាប័នរដ្ឋ។
- ជំរុញកសាង និងបង្កើនទំនុកចិត្តពីអ្នកចូលរួម និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែសកម្មចំពោះការប្រើប្រាស់សេវាឌីជីថលក្នុងគោលបំណងបង្កើនការវិនិយោគក្នុងស្រុកនិងក្រៅស្រុក ដើម្បីជានាដល់និរន្តរភាពក្នុងទិសដៅអភិវឌ្ឍសេដ្ឋកិច្ចសង្គម។
- លុបបំបាត់ភាពអសកម្ម ការិយាធិប្បតេយ្យ វប្បធម៌អន្តរាគមន៍ យកទម្លាប់ធំជាងច្បាប់របស់ថ្នាក់ដឹកនាំមួយចំនួនតូច។
- ការបង្កើតបទបញ្ញាតិ និងច្បាប់ឱ្យមានលក្ខណៈរឹងមាំ ហើយអនុវត្តឱ្យបានទន់ភ្លន់ និងមានគោលនយោបាយត្រឹមត្រូវ និងច្បាស់លាស់។
- បង្កើនជំនាញធនធានមនុស្សឌីជីថលដែលមានកម្រិតវិជ្ជាជីវៈខ្ពស់ មានក្រមសីលធម៌ល្អ មានអាកប្បកិរិយាល្អ ឥរិយាបថការងារស្អាតស្អំ ព្រមទាំងការសហការចូលរួមអនុវត្តយ៉ាងសស្រាក់សស្រាំ មានភាពប្រទាក់ក្រឡា ស៊ីសង្វាក់គ្នាពីគ្រប់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ។
- ការពង្រឹងនូវការគោរព និងការប្រតិបត្តិច្បាប់ឱ្យបានត្រឹមត្រូវគ្រប់មន្រ្តីសាធារណៈទាំងថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ ដោយប្រកាន់ភ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងស្មើភាពគ្នានៅចំពោះមុខច្បាប់។
- មានវិធានការដាក់ទោសទណ្ឌចំពោះមន្រ្តីសាធារណៈទាំងថ្នាក់កំពូលធំ-តូច និងខ្សែថ្នាក់ដឹកនាំឱ្យស្មើភាពគ្នាដែលល្មើសនឹងច្បាប់ ចំពោះមុខច្បាប់ ហើយនេះជាគំរូល្អដល់មន្រ្តីសាធារណៈ។

# គន្ថនិទ្ទេស

១- ក្រមសីលធម៌ និងកិរិយាមារយាទមន្ត្រីរាជការគយ និងរដ្ឋាករកម្ពុជាឆ្នាំ២០០៧។

២. Aptekman A, Kalabin, V, Klintsov, V, Kuznetsova, E, Kulagin, V, & Yasenovets, I. (2017). Digital Russia: A new reality.

៣. Belyakova, O. V, Pertsevaya, E. A, & Cherkasova, E. V. (2020). The features of digital transformation of public administration. European Proceedings of Social and Behavioural Sciences, 79, 395-400.

៤. Belyakova, O. V, & Pyrkina, N. A. (2021). App-based multimedia in foreign language teaching: Options for language learner. In S. Ashmarina, & V. Mantulenko (Eds.), Current Achievements, Challenges and Digital Chances of Knowledge Based Economy. Lecture Notes in Networks and Systems, 133 (pp. 549-557). Springer.

៥. Dobrolyubova, E, Alexandrov, O, & Yefremov, A. (2017). Is Russia ready for digital transformation? In D. Alexandrov, A. Boukhanovsky, A. Chugunov, Y. Kabanov & O. Koltsova (Eds.), Proceedings of the International Conference on Digital Transformation and Global Society. Communications in Computer and Information Science, 745 (pp 431-444). Springer.

៦. Omar, A, Weerakkody, V, & Sivarajah, U. (2017). Digitally enabled service transformation in the UK public sector: A case analysis of universal credit. International Journal of Information Management, 37(4), 350-356.

៧. Osman, I.H, Anouze, A.L, Irani, Z, Lee, H, Medeni, T. D, & Weerakkody, V. (2019). A cognitive analytics management framework for the transformation of electronic government services from users' perspective to create sustainable shared values. European Journal of Operational Research, 278(2), 514-532.

៨. Passport of Federal program "Digital economy of the Russian Federation" (2018).

៩. Prendville, A. (2018). Amplifying relations through place and locality in the design of local digital services. She Ji: The Journal of Economics and Innovation, 4(1), 47-59.

១០. Theam, R. (2015). Public Service Culture in Cambodia: Impacts on the Delivery of Core Public Services (Doctoral dissertation).

១១. Troshani, I., Janssen, M., Lymer, A., & Parker, L. D. (2018). Digital transformation of business-to-government reporting: An institutional work perspective. International Journal of Accounting Information Systems, 31, 17-36.

១២. World Bank Group (2016). Digital government 2020 Prospects for Cambodia.

# ទស្សនាទានអប់រំចរិយាធម៌តាមរយៈរឿងវិធុរបណ្ឌិត

បេក្ខជនបណ្ឌិត៖ **យ៉ា សារុន**
ជំនាញ៖ **អក្សរសិល្ប៍**

## ១- សេចក្តីផ្តើម

រឿងវិធុរបណ្ឌិត ជាប្រភេទស្នាដៃពុទ្ធនិយមមួយប្រភេទ ក្នុងចំណោមស្នាដៃពុទ្ធនិយមដទៃទៀត ក្នុងចរន្តអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម។ រឿងនេះ ប្រភពដើមកើតចេញពីការនិទានផ្ទាល់របស់ព្រះពុទ្ធ ក្រោយការត្រាស់ដឹងរបស់ព្រះអង្គ។ ក្រោយវត្តមានពុទ្ធសាសនាបានចូលមកក្នុងសង្គមខ្មែរ រឿងនេះ ត្រូវបានអ្នកប្រាជ្ញខ្មែរកត់ត្រាចម្លងចូលក្នុងគម្ពីរសាស្ត្រាស្លឹករឹត ក្រោយមកទើបមានការចម្លងបោះពុម្ព ចេញជាគម្ពីរក្បួនខ្នាតផ្នែកពុទ្ធសាសនា។ ក្នុងពេលបច្ចុប្បន្ន រឿងវិធុរបណ្ឌិតនេះ មាននៅក្នុងគម្ពីរព្រះត្រៃបិដក ត្រង់ខុទ្ទនិកាយ ជាតក ទ្វាទសមាសភាគ៦៣ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស.២៥០៣។ បើតាមអ្នកប្រាជ្ញអក្សរសាស្ត្រ បានបញ្ជាក់ថាគម្ពីរដើមបង្អស់ ប្រហែលជាកើតនៅក្នុងគ្រិស្តសតវត្សន៍ទី១៨ ឬ១៩ (ប្រហែលក្នុងរជ្ជកាលព្រះបាទអង្គឌួង គ.ស.១៧៩៦-១៨៦០)[១]។ រឿងនេះ ឯកសារដើមជាភាសាបាលី ក្រោយមកទើបមានការប្រែសម្រួលជាភាសាខ្មែរ ដោយព្រះគ្រូបុរត្ថិមវាសី អ៊ូ ថៃវ គង់វត្តលង្កា ក្នុងពុទ្ធសករាជ ២៤៨៩។ ក្រោយមកទើបមានការបោះពុម្ពផ្សាយក្នុងឆ្នាំ១៩៥៨។ ក្នុងគ.ស.១៩៥៨ ដដែល រឿងនេះត្រូវបានគណៈកម្មការរៀបចំកម្មវិធីសិក្សានៃក្រសួងអប់រំជាតិ បានបញ្ចូលទៅក្នុងកម្មវិធីសិក្សាថ្នាក់ទី២ទំនើប។ នៅគ.ស.១៩៥៩ រឿងវិធុរបណ្ឌិតនេះដែរ ត្រូវបានបណ្ឌិតមហា ឈឹម សុមន៍ យកមកសិក្សាជាថ្មី ដោយបញ្ចូលជាមួយរឿងឯទៀតៗក្នុងស្នាដៃ ***សង្ខេបទសជាតក*** របស់លោក និងបានបោះពុម្ពផ្សាយចំនួន ៦លើក កន្លងមកហើយ។

គួរកត់សម្គាល់ថា រឿងវិធុរបណ្ឌិតនេះ ក៏បានជ្រាបចូលក្នុងចិត្តសន្តាននៃប្រជាជនខ្មែរទាំងចាស់ក្មេងស្ទើរទូទាំងប្រទេសផងដែរ។ មិនតែប៉ុណ្ណោះ ស្នាដៃជាតកនេះ ក៏បានជ្រួតជ្រាបក្នុងសន្តានចិត្តនៃប្រជាជនមួយចំនួននៅតំបន់អាស៊ីភាគអាគ្នេយ៍ផងដែរ ជាពិសេសគឺបណ្តាប្រទេសដែលនិយមគោរពប្រតិបត្តិតាមពុទ្ធសាសនា ដូចជា ថៃ ឡាវ ភូមា ជាដើម។

## ២- សិក្សារឿងវិធុរបណ្ឌិត

ក្នុងការសិក្សានៅលើស្នាដៃរឿងវិធុរបណ្ឌិតនេះ គ្រាន់តែជាផ្នែកមួយនៃការស្រាវជ្រាវរបស់យើងខ្ញុំនៅលើប្រធានបទ «**ទស្សនាទានអប់រំចរិយាធម៌តាមរយៈអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ**» (Khmer Ethics Education Perspective Through Buddhism Literature) តែប៉ុណ្ណោះ ហើយក្នុងការសិក្សានេះទៀតសោត យើងខ្ញុំបានផ្តោតជាសំខាន់ទៅលើតែតម្លៃអប់រំចរិយាធម៌ក្នុងស្នាដៃ និងស្វែងយល់ពីលក្ខណៈឆ្លុះបញ្ចាំងក្នុងសង្គមខ្មែរតែប៉ុណ្ណោះ។

---

[១] លាង ហាប់ អាន ***អត្ថាធិប្បាយកថា រឿងមហាវេស្សន្តរជាតក*** ភ្នំពេញ ផ្សាយចេញពីរោងពុម្ពសឹង-ហេង គ.ស.១៩៦៥ ទំព័រ៣-៤។

តាមការសិក្សានៅលើស្នាដៃរឿងវិធុរបណ្ឌិតនេះ យើងបានមើលឃើញនូវតម្លៃអប់រំមួយចំនួនដូចខាងក្រោម៖

**ក- អំពីសច្ចៈ**

រឿងវិធុរបណ្ឌិត បានបង្ហាញនូវតម្លៃអប់រំអំពីការរក្សានូវពាក្យសម្តីពិត ឬពាក្យសច្ចៈ។ សច្ចៈ ប្រែថា ការពិត, សេចក្តីពិត, ដំណើរទៀង, ទៀងទាត់, ត្រឹមត្រូវ, ប្រាកដ, ដំណើរទៀងត្រង់, ការណ៍មែន[២]។ ប្រើជាមួយពាក្យសម្តី ឬការនិយាយស្តី ទៅជាសម្តីពិត, សម្តីទៀងទាត់, សម្តីត្រឹមត្រូវ ឬសម្តីពិតប្រាកដ ជាដើម។ តាមរយៈរឿងវិធុរបណ្ឌិត បានបង្ហាញនូវតម្លៃអប់រំ អំពីពាក្យសម្តីពិតនេះ។ ការបង្ហាញអំពីការពិតក្នុងរឿងនេះកើតមកតាមរយៈពាក្យសម្តីរបស់តួអង្គវិធុរបណ្ឌិតផ្ទាល់តែម្តង។ ត្រង់ចំណុចមួយពេលដែលបុណ្ណកយក្ស សាកសួរទៅកាន់ វិធុរបណ្ឌិតថា តើលោកជាអ្វីនឹងព្រះរាជា? ជាខ្ញុំកំដរ ឬជាព្រះញាតិ? ព្រះពោធិសត្វ បានត្រិះរិះថា មានតែសេចក្តីពិតទេ ដែលជាគុណធម៌ប្រសើរជាងគេ, ទើបលោកប្រាប់ទៅបុណ្ណក យក្សថា ខ្ញុំជាខ្ញុំរបស់ព្រះរាជាតាំងពីកំណើតមក សេចក្តីចម្រើន និងវិនាសមានដល់ព្រះរាជាក៏ដូចជាមានដល់ខ្ញុំដែរ។ សេចក្តីបញ្ជាក់ «*...យើងពិតជាទាសៈកើតអំពីកំណើតព្រះរាជាមានសេចក្តីចំរើនក្តី ព្រះរាជាមានសេចក្តីមិនចំរើនក្តី (យើងមិនអាចនឹងពោលកុហកបានទេ) យើងបើទុកជាទៅកាន់ទីដទៃ ក៏គង់នៅជាទាសៈរបស់ព្រះសម្មតិទេព ម្នាលមាណព ព្រះរាជាគួរប្រទានយើងដល់អ្នកដោយធម៌*»[៣]។ តាមរយៈពាក្យសម្តីដែលវិធុរបណ្ឌិតបានពោល គឺជាការគោរពឬឱ្យតម្លៃទៅលើអ្វីដែលជាការពិត។ វិធុរបណ្ឌិតសុខចិត្តលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីការពារនូវរឿងរ៉ាវពិត។ លោកសុខចិត្តលំបាកខ្លួន ក៏មិនបោះបង់ពាក្យពិតត្រង់ចោលដែរ។ នេះជាការឱ្យតម្លៃទៅលើសច្ចៈ ឬការពិត របស់តួអង្គវិធុរបណ្ឌិត។ តាមរយៈពំនោលនេះ យើងអាចនិយាយបានថា រឿងវិធុរបណ្ឌិត ពិតជាបានផ្តល់នូវតម្លៃអប់រំអំពីសច្ចៈយ៉ាងពិតប្រាកដ។

**ខ- អំពីតួនាទីរបស់អ្នកគ្រប់គ្រងផ្ទះ**

រឿងវិធុរបណ្ឌិត បានបង្ហាញនូវតម្លៃអប់រំអំពីតួនាទី ឬកាតព្វកិច្ចរបស់អ្នកគ្រប់គ្រងផ្ទះ។ តួនាទី ឬកាតព្វកិច្ចរបស់អ្នកគ្រប់គ្រងផ្ទះក្នុងរឿងនេះ បានបង្ហាញតាមរយៈការសម្តែងអំពីឃរាវាសធម៌ របស់តួអង្គវិធុរបណ្ឌិត ដែលឆ្លើយតបទៅនឹងសំណួរព្រះបាទធនញ្ជ័យកោរព្យ។ ក្នុងដំណើររឿងបានបង្ហាញថា នៅពេលដែលវិធុរបណ្ឌិត ត្រូវបានបុណ្ណកយក្សនាំទៅដើម្បីសម្លាប់យកដួងហឫទ័យ(បេះដូង)។ ពេលនោះព្រះរាជាធនញ្ជ័យកោរព្យ បានសាកសួរទៅកាន់វិធុរបណ្ឌិតថា ម្នាលវិធុរៈ គ្រហស្ថ ដែលគ្រប់គ្រងផ្ទះរបស់ខ្លួន ត្រូវប្រព្រឹត្តយ៉ាងណា ទើបនឹងបានសេចក្តីក្សេមក្សាន្ត? យ៉ាងណា ទើបឈ្មោះថាជាអ្នកសង្គ្រោះ? យ៉ាងណាទើបឈ្មោះថាជាមនុស្សវៀរចាកសេចក្តីបៀតបៀន និងជាអ្នកពោលនូវពាក្យសត្យ? ក្នុងពេលដែលលះលោកនេះទៅកាន់លោកខាងមុខ យ៉ាងណាទើបមិនមានសោកស្តាយ? ពេលនោះ

---

[២] ជួន ណាត, *វចនានុក្រមខ្មែរ,* ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, គ.ស.១៩៦៧ ទំព័រ១២៤៦។

[៣] ពុទ្ធសាសនបណ្ឌិត្យ, *សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ ៦៣,* ភ្នំពេញ, ព.ស.២៥០៣ ទំព័រ៥២។

វិធុរបណ្ឌិត បាទទូលថ្វាយទៅព្រះរាជាថា *អ្នកគ្រប់គ្រងផ្ទះ មិនត្រូវប្រទូស្តករិយាអ្នកដទៃ មិនត្រូវបរិភោគអាហារដែលមានរសឆ្ងាញ់តែម្នាក់ឯង មិនត្រូវសេព មិនត្រូវវៀន មិនត្រូវបង្រៀនរឿងលោកាយតនៈ ព្រោះរឿងនេះមិនមែនជាគ្រឿងចម្រើនប្រាជ្ញាឡើយ*[៤]។

*អ្នកគ្រប់គ្រងផ្ទះ គួរជាអ្នកមានសីល បរិបូណ៌ដោយវត្តចរិយា មិនប្រមាទក្នុងកិច្ចានុកិច្ច និងកល្យាណធម៌ ត្រូវចេះត្រិះរិះពិចារណាឱ្យជាក់ច្បាស់ក្នុងហេតុ និងផល មានសេចក្តីប្រព្រឹត្តបន្ទន់បន្ទាបសុភាពរាបសា មិនត្រូវតម្កើងឫកពាធំចំពោះវុឌ្ឍបុគ្គល ជាអ្នកត្រេកអរតែក្នុងសុចរិតធម៌ មានវាចាផ្អែមល្ហែមក្បោះក្បាយ មានកាយ វាចា ចិត្ត ទន់ភ្លន់ ជាប្រក្រតី*[៥]។ល។

គ្រហស្ថដែលនៅគ្រប់គ្រងផ្ទះរបស់ខ្លួនត្រូវប្រព្រឹត្តយ៉ាងនេះទើបបានសេចក្តីក្សេមក្សាន្ត យ៉ាងនេះទើបឈ្មោះថាជាអ្នកសង្គ្រោះ យ៉ាងនេះទើបឈ្មោះថាជាអ្នកវៀរចាកសេចក្តីបៀតបៀន និងជាអ្នកពោលនូវពាក្យសត្យ យ៉ាងនេះទើបវេលាដែលលះលោកនេះទៅកាន់លោកខាងមុខ នឹងមិនមានសេចក្តីសោកស្តាយឡើយ។ នេះជាតម្លៃអប់រំសម្រាប់អ្នកគ្រប់គ្រងផ្ទះក្នុងរឿងវិធុរបណ្ឌិត។

ជាការពិតការកសាងគ្រួសារមួយ គោលដៅដ៏សំខាន់គឺដើម្បីសុភមង្គល ឬភាពសុខដុមរមនាក្នុងគ្រួសារ, សុភមង្គល ឬភាពសុខសាន្ត កើតឡើងបាន គឺអាស្រ័យនឹងភាគីទាំងពីរស្គាល់អំពីតួនាទី ឬកាតព្វកិច្ចរបស់ខ្លួន ហើយប្រកាន់យករៀងខ្លួន និងបំពេញឱ្យគ្នាទៅវិញទៅមក។ តួនាទី ឬកាតព្វកិច្ចនេះ ព្រះពុទ្ធសម្តែងថាជាសង្គហធម៌ ជាធម៌ដែលត្រូវបំពេញឱ្យគ្នាក្នុងនាមជាស្វាមី ភរិយា។

ជារួមមក ផ្នែកមួយនៃរឿងវិធុរបណ្ឌិត បានបង្ហាញនូវតម្លៃអប់រំអំពីតួនាទី ឬកាតព្វកិច្ចរបស់អ្នកគ្រប់គ្រងផ្ទះ។ អ្នកគ្រប់គ្រងផ្ទះ ត្រូវប្រកាន់យកនូវតួនាទីនឹងកាតព្វកិច្ចរបស់ខ្លួនឱ្យបានល្អទើបសង្គមគ្រួសារមានសេចក្តីសុខក្សេមក្សាន្ត។

**គ- សាធុនរធម៌**[៦]

រឿងវិធុរបណ្ឌិតបានបង្ហាញនូវតម្លៃអប់រំស្តីអំពីសាធុនរធម៌។ សាធុនរធម៌ក្នុងរឿងនេះបានបង្ហាញត្រង់ចំណុចពេលដែលបុណ្ណកយក្ស ព្យាយាមសម្លាប់វិធុរបណ្ឌិត ដោយប្រការផ្សេងៗមានការចាប់បោកនឹងដី ទម្លាក់ចូលក្នុងជ្រោះជ្រៅជាដើម តែមិនបានសម្រេច ទើបវិធុរបណ្ឌិតសាកសួរទៅបុណ្ណកយក្សថាអ្នកព្យាយាមសម្លាប់ខ្ញុំព្រោះយល់ហេតុដូចម្តេច? បុណ្ណកយក្ស ប្រាប់សេចក្តីគ្រប់ប្រការឱ្យវិធុរបណ្ឌិតស្តាប់។ ព្រះពោធិសត្វ ជ្រាបបំណងនៃប្រស្នានោះសព្វគ្រប់ហើយ ទើបសូមឱ្យយក្សឈប់បង្អង់សិនដើម្បីលោកបានសម្តែងអំពីសាធុរធម៌ គឺចរិយារបស់មនុស្សល្អឱ្យយក្សស្តាប់។ សេចក្តីបញ្ជាក់ *ព្រះវិធុរបណ្ឌិតពោលថា ម្នាលមាណព! ចូរអ្នកដើរតាមផ្លូវដែលលោកយាត្រាហើយចុះ អ្នកកុំដុតបាតដៃទាំងទទឹកឡើយ ក្នុងកាលណាៗអ្នកកុំប្រទូស្តចំពោះពួកមិត្រ អ្នកកុំលង់ក្នុងអំណាចនៃអស្ត្រីឡើយ*[៧]។ មានន័យថា

---

[៤] ឈឹម ស៊ុម, ***សង្ខេបទសជាតក,*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, គ.ស.១៩៥៩ ទំព័រ២៧២-២៧២។

[៥] -ដ- ទំព័រ២៧២-២៧៣។

[៦] **សាធុនរធម៌** គឺ ចរិយារបស់មនុស្សល្អ។

[៧] ឈឹម ស៊ុម, ***សង្ខេបទសជាតក,*** ដ.ឯ.ម ទំព័រ២៨៨។

បុគ្គលណាដែលអញ្ជើញជនដែលមិនធ្លាប់នៅជាមួយគ្នា មិនធ្លាប់ស្គាល់គ្នាដោយត្រឹមតែអាសនៈ មិនបាច់និយាយដល់បាយទឹកឡើយ ជនដែលទទួលការអញ្ជើញត្រូវធ្វើប្រយោជន៍តបត្រឡប់ទៅបុគ្គលនោះវិញ បណ្ឌិតទាំងឡាយពោលថា ជននោះឯងជាអ្នកដើរតាមផ្លូវដែលលោកយាត្រាហើយ។

ជនណាបានប្រាស្រ័យក្នុងផ្ទះបុគ្គលតែមួយយប់ បានបាយទឹកក្នុងផ្ទះបុគ្គលណាតែម្តង សូម្បីតែចិត្តក៏ជននោះ មិនត្រូវគិតអាក្រក់ដល់បុគ្គលនោះឡើយ មិនបាច់ដល់ទៅប្រទូស្តដោយកាយ ឬវាចាឡើយជនដែលប្រទូស្តទាំងបំពាននឹងសេចក្តីនេះឈ្មោះថាដុតបាតដៃទាំងទទឹក។ បុគ្គលដែលអាស្រ័យនៅជាសុខក្រោមម្លប់ឈើណា មិនត្រូវកាច់មែកឈើនោះឡើយ ព្រោះថាបើដូច្នោះនឹងចាត់ជាមនុស្សប្រទូស្តមិត្រ ជាមនុស្សអាក្រក់ជួរជាតិ។

បុរសឯណាឱ្យផែនដីនេះ ដែលពេញដោយទ្រព្យដល់ស្រីជាទីស្រឡាញ់ពេញចិត្ត ដែលលោកសន្មតថា ប្រពន្ធ លុះវាបានឱកាសក៏ត្រឡប់មើលងាយបុរសនោះវិញ អ្នកមិនត្រូវលង់ក្នុងអំណាចស្រីដែលប្រកបដោយអសទ្ធម្ម (មិនប្រកបដោយធម៌) នោះឡើយ។

ការប្រកាន់ឥរិយាបថយ៉ាងនេះឈ្មោះថា ដើរតាមផ្លូវដែលលោកយាត្រាទៅហើយ, យ៉ាងនេះឈ្មោះថាមិនដុតបាតដៃទាំងទទឹក, យ៉ាងនេះឈ្មោះថាស្រីនោះប្រកបដោយអសទ្ធម្ម, បុរសនោះឈ្មោះថាជាអ្នកប្រទូស្តមិត្រសម្លាញ់, អ្នកចូរប្រកបដោយធម៌ ចូរលះបង់អំពើដែលមិនមែនជាធម៌ចេញ។

តាមការរៀបរាប់ខាងលើ យើងអាចនិយាយបានថា រឿងវិធុរបណ្ឌិត ពិតជាបានផ្តល់នូវតម្លៃអប់រំស្តីអំពីសាធុនរធម៌យ៉ាងពិតប្រាកដ។

**ឃ- ភារទទួលខុសត្រូវ**

រឿងវិធុរបណ្ឌិត បានបង្ហាញនូវគោលគំនិតអប់រំមួយចំណុចទៀត ស្តីពីការមានទំនួលខុសត្រូវចំពោះតួនាទីរបស់ខ្លួន។ ការមានទំនួលខុសត្រូវនេះបានបង្ហាញតាមរយៈសកម្មភាពរបស់តួអង្គវិធុរបណ្ឌិត ដែលព្យាយាមមើលថែនិងយកចិត្តទុកដាក់ទំនុកបម្រុងគ្រួសារឱ្យមានរបៀបរៀបរយល្អ មុនពេលលោកចាកចេញទៅតាមបុណ្ណកយក្ស។ សេចក្តីបញ្ជាក់ «*វិធុរបណ្ឌិតបាន ...នាំយក្សទៅកាន់និវេសន៍នៃអាត្មា បានចាត់ចែងគ្រឹហាជាទីក្សេមក្សាន្ត រៀបរយដោយប្រពៃ ឱ្យយក្សឈប់សម្រាកអស់វេលា៣ថ្ងៃ រង់ចាំចាត់ចែងការងារនិងផ្តែផ្តាំបុត្រភរិយាហើយស្រេច, លុះចាត់ចែងកិច្ចការដទៃទៀតស្រេចបាច់ហើយ ទើបប្រមូលញាតិមិត្រ បរិវារ ព្រម ទាំងបុត្រភរិយាមកមូលត្រកូលគ្នាហើយ ក៏ប្រាប់ដំណើររឿងដែលខ្លួននឹងចេញទៅឱ្យដឹងគ្រប់ប្រការ...*»[៨]។ តាមរយៈសេចក្តីដែលបានលើកឡើងខាងលើ យើងអាចនិយាយបានថា តួអង្គវិធុរបណ្ឌិត ពិតជាមានទំនួលខុសត្រូវខ្ពស់ក្នុងនាមជាមេគ្រួសារ ដែលតែងតែយកចិត្តទុកដាក់ថែរក្សាក្រុមគ្រួសារ។ នេះក៏ជាព្រហ្មវិហារធម៌ ក្នុងនាមជាឪពុកដែរ។

ម្យ៉ាងទៀត តាមរយៈពាក្យសម្តីដែលវិធុរបណ្ឌិត បានពោលណែនាំទៅកាន់ពពួកញាតិមួយអន្លើដោយបុត្រ ភរិយា អំពីរាជវសតីធម៌ ក៏ជាសម្តីដែលបង្ហាញពីអារម្មណ៍ខ្វល់ខ្វាយ ខ្លាចក្រុមគ្រួសារ និងពពួកញាតិមានទោសកំហុស ពេលចូលទៅគាល់បម្រើស្តេច ក្រោយអត់អំពីលោកទៅ។ សេចក្តីបញ្ជាក់

---

[៨] ឈឹម ស៊ុម, ***សង្ខេបទសជាតក,*** ជ.ឯ.ម ទំព័រ២៧៤។

*«រាជសេវក៍ ដែលព្រះរាជាត្រាស់ប្រើក្នុងរាជកិច្ចណាមួយ មិនគប្បីធ្វើរាជកិច្ចនោះឱ្យកម្រើកទេ ត្រូវធ្វើឱ្យដូចជាជញ្ជីងដែលគេលើកឡើងហើយ មានដងស្មើទៀងល្អ។ រាជសេវក៍ ជាអ្នកឈ្លាសវៃក្នុងរាជកិច្ចទាំងឡាយ ដែលព្រះរាជាត្រូវប្រើក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ មិនគប្បីធ្វើរាជកិច្ចនោះឱ្យកម្រើក។ រាជសេវក៍ ជាអ្នកឈ្លាសវៃក្នុងរាជកិច្ចទាំងឡាយ ធ្វើរាជកិច្ចគ្រប់យ៉ាង ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ ឱ្យសម្រេចដោយរៀបរយ។ ផ្លូវណាដែលគេធ្វើល្អ ចាត់ចែងល្អសម្រាប់ព្រះរាជា រាជសេវក៍ ដែលព្រះរាជាត្រាស់ហើយ មិនត្រូវដើរទៅតាមផ្លូវនោះទេ រាជសេវក៍នោះ ទើបគួរនៅក្នុងរាជត្រកូល»*[៩]។ល។

តាមការលើកឡើងនេះសបញ្ជាក់ថា ទឹកចិត្តខ្វាយខ្វល់ចំពោះបុត្រ ភរិយា និងពពួកញាតិរបស់តួអង្គវិធុរបណ្ឌិត ជាទឹកចិត្តដែលកើតចេញពីការមានទំនួលខុសត្រូវចំពោះគ្រួសារយ៉ាងពិតប្រាកដ។

**ខ- ការបណ្តុះស្មារតីសន្តិភាព**

រឿងវិធុរបណ្ឌិតបានបង្កប់នូវតម្លៃអប់រំស្តីពីការបណ្តុះស្មារតីសន្តិភាព។ ស្មារតីសន្តិភាពក្នុងរឿងនេះ បានបង្ហាញតាមរយៈតួអង្គវិធុរបណ្ឌិតផ្ទាល់ ដែលមិនប្រទូស្តតបនឹងបុណ្ណកយក្ស ដែលបៀតបៀនមកលើអាយុជីវិតរបស់លោក។ ទីបំផុតលោកអាចដោះស្រាយបានដោយសន្តិវិធី។

តាមរយៈដំណើររឿងបានបញ្ជាក់ថា ក្រោយពេលព្រះបាទធនញ្ជ័យកោរព្យ ភ្នាល់ល្បែងបាស្កាចាញ់បុណ្ណកយក្ស ពេលនោះបុណ្ណកយក្ស សូមទាមទារយកវិធុរបណ្ឌិត តែព្រះរាជាពុំព្រម ដោយទ្រង់ពោលថា វិធុរបណ្ឌិតនេះ ទុកស្មើនឹងជីវិតយើង។ ជម្លោះពាក្យសម្តីបានកើតឡើង រហូតបុណ្ណកយក្សថា សូមឱ្យវិធុរបណ្ឌិតជាអ្នកសម្រេចក្តីនេះ ទើបយក្សបានសាកសួរទៅកាន់វិធុរបណ្ឌិតថា លោកអ្នកប្រាជ្ញ! កិត្តិគុណរបស់លោកឮខ្ចរខ្ចាយសុសសាយទៅក្នុងជម្ពូទ្វីបថាលោកជាអ្នកឋិតនៅក្នុងធម៌មិនពោលពាក្យកុហកព្រោះហេតុនៃជីវិត, កិត្តិស័ព្ទនោះតើពិតឬមិនពិត? ខ្ញុំសូមសួរទៀតថា លោកជាអ្វីនឹងព្រះរាជា? ជាខ្ញុំកំដរ ឬព្រះញាតិ? វិធុរបណ្ឌិតគិតថា មានតែសច្ចៈប៉ុណ្ណោះជាគុណធម៌ដ៏ប្រសើរជាងអ្វីដទៃ, ម្យ៉ាងទៀតអាត្មាអញគួរតែលះបង់ជីវិតថ្វាយជារាជពលីឱ្យសមតាមនាទីរបស់អាមាត្យ ដែលជាអ្នកទៀងត្រង់ចំពោះជាតិ សាសនា និងព្រះមហាក្សត្រ ម្យ៉ាងដើម្បីការពារនូវសេចក្តីអន្តរាយ ដែលនឹងកើតមានដល់ចៅហ្វាយនាយ និងផែនដី គិតហើយទើបតបតាមដំណើរពិត ហើយវិនិច្ឆ័យថា ខ្លួនខ្ញុំនេះជាខ្ញុំរបស់ព្រះរាជាតាំងពីកំណើតមក, សេចក្តីចំរើន និងសេចក្តីវិនាស បើមានដល់ព្រះអង្គ ក៏ទុកដូចជាមានដល់ខ្ញុំដែរ ហេតុនេះ បើដោយយុត្តិធម៌ គួរតែព្រះរាជទានខ្លួនខ្ញុំដល់អ្នកឯងដោយពិត[១០]។ ត្រង់ចំណុចនេះវិធុរបណ្ឌិតបានដើរតួនាទីសំខាន់ក្នុងការរក្សានូវសន្តិភាពរវាងព្រះរាជាកោរព្យជាមួយបុណ្ណកយក្ស។ ប្រសិនបើវិធុរបណ្ឌិតមិនប្រកាន់នូវសច្ចធម៌ ហើយពោលប្រាស់ចាកពីការពិត នោះបញ្ហានឹងកើតមានឡើងមិនខាន។ យើងដឹងហើយថាគោលដៅរបស់បុណ្ណកយក្ស គឺមកដើម្បីយកដួងហឫទ័យវិធុរបណ្ឌិតទៅថ្វាយស្តេចនាគ ដូច្នេះបើលោកឆ្លើយដោយវៀចវេរ ទាំងខ្លួនលោកក្តី ទាំងព្រះរាជាក្តី អាចនឹងត្រូវបុណ្ណកយក្សបៀតបៀនដល់អាយុជីវិត ហើយព្រះនគរទាំងមូលក៏អាចនឹងវិនាសដោយសារឫទ្ធិរបស់យក្សក៏ថាបាន។ នេះជាតម្លៃអប់រំស្តីពីការបណ្តុះស្មារតីសន្តិភាព តាមរយៈរឿងវិធុរបណ្ឌិត។

---

[៩] -ដ- ទំព័រ២៧៦-២៧៧។

[១០] ឈឹម ស៊ុម, ***សង្ខេបទសជាតក,*** ដ.ឯ.ម ទំព័រ២៧០-២៧១។

យើងដឹងហើយថា ក្នុងការរកដំណោះស្រាយបញ្ហា មិនមែនគ្រប់រឿងទាំងអស់ត្រូវតែដោះស្រាយដោយការប្រើកំហឹងទល់នឹងកំហល់នោះទេ, មានវិធីជាច្រើនដែលគេអាចយកធ្វើជាដំណោះស្រាយបានដោយសន្តិវិធី។ ការឈរនៅលើស្មារតីសន្តិភាព ជាវិធីសាស្ត្រដ៏សំខាន់មួយក្នុងការដោះស្រាយបញ្ហា។ ក្នុងវិបត្តិសង្គមជាតិក្តី សង្គមគ្រួសារក្តី បើយកដំណោះស្រាយដោយប្រើហឹង្សា ការរកដំណោះស្រាយនោះមិនមានប្រសិទ្ធភាពយូរអង្វែងនោះទេ។ ពាក្យចាស់ខ្មែរយើងបានពោលថា «*អ្នកឈ្នះប្រទះនូវពៀរ, ព្រោះអ្នកចាញ់ដេករកនឹកគ្រប់វិធីដើម្បីតបត្រឡប់វិញ*»។ ព្រះពុទ្ធសម្តែងថា «*ឈ្នះខ្លួនឯង ឈ្នះនូវអ្វីៗទាំងអស់ ហើយក៏ជាការឈ្នះដ៏ប្រសើរ*»។ បុគ្គលកាលបើយកឈ្នះលើខ្លួនឯងហើយ ទៅដោះស្រាយបញ្ហាអ្វីក៏មានប្រសិទ្ធភាពដែរ។ តួអង្គវិធុរបណ្ឌិត ជាបុគ្គលដែលឈ្នះខ្លួនឯង។ ដូច្នេះ រាល់ដំណោះស្រាយបញ្ហាទាំងអស់ លោកដោះស្រាយបានដោយងាយនិងដោយសន្តិវិធីជាបំផុត។

សរុបសេចក្តីមក រឿងវិធុរបណ្ឌិត បានបង្ហាញនូវតម្លៃអប់រំស្តីពីស្មារតីសន្តិភាព ព្រោះគ្រប់យ៉ាងនៃដំណោះស្រាយរបស់លោក គឺតែងតែឈរលើស្មារតីមិនប្រទូស្តជានិច្ចសព្វកាល ហើយតាមរយៈស្មារតីនេះទៀតសោត ក៏កើតចេញពីការយកឈ្នះលើចិត្តខ្លួនឯងជាដំបូងដែរ បន្ទាប់មកទើបលោកអាចយកឈ្នះអ្វីៗទាំងអស់។ ដូច្នេះ រឿងវិធុរបណ្ឌិត ពិតជាបានផ្តល់នូវតម្លៃអប់រំស្តីពីសន្តិភាពយ៉ាងពិតប្រាកដ។

## ៣- សេចក្តីសន្និដ្ឋាន

អក្សរសិល្ប៍ពុទ្ធនិយមរឿងវិធុរបណ្ឌិត គឺជាផ្នែកមួយនៃអក្សរសិល្ប៍ខ្មែរ ដែលមានតួនាទីក្នុងការអប់រំមនុស្សឱ្យមានដំណើរប្រព្រឹត្តទៅក្នុងគន្លងនៃចរិយាធម៌របស់ព្រះពុទ្ធ។ អក្សរសិល្ប៍ប្រភេទនេះ មិនត្រឹមតែអប់រំមនុស្សឱ្យឋិតក្នុងគន្លងចរិយាធម៌របស់ព្រះពុទ្ធតែមួយមុខប៉ុណ្ណោះទេ តែក៏បានរួមចំណែកក្នុងការកសាង អភិវឌ្ឍន៍ វិស័យសង្គមវប្បធម៌ខ្មែរផងដែរ។

ក្នុងការសិក្សាលើស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមរឿងវិធុរបណ្ឌិតនេះ យើងអាចមើលឃើញជាតុចូលសំខាន់ចំនួនពីរគឺ៖

- អប់រំមនុស្សឱ្យមានសីលធម៌ក្នុងការរស់នៅ និងមានសីលធម៌នៅលើការងារ ដែលជាការទទួលខុសត្រូវរបស់ខ្លួន។
- អប់រំផ្នែកស្មារតីរបស់មនុស្សឱ្យរៀនទទួលយកនូវរឿងរ៉ាវដែលកើតឡើងស្របតាមច្បាប់របស់ធម្មជាតិ។

ដូច្នេះ តាមការសិក្សារឿងវិធុរបណ្ឌិតនេះមក យើងឃើញតាមរយៈរឿងនេះពិតជាបានផ្តល់នូវតម្លៃអប់រំចរិយាធម៌ដល់មនុស្សជាតិ យ៉ាងពិតប្រាកដ។

# គន្ថនិទ្ទេស

- ឯកសារតែងនិពន្ធជាភាសាខ្មែរ៖
១- កុល ផេង *ព្រះសុវណ្ណសាមជាតកពិស្ដារ* ភ្នំពេញ ព.ស.២៥៦០។
២- ខ្លូត ធីតា *ព្រះពុទ្ធសាសនា និងពាហិរសាសនានៅក្នុងសង្គមខ្មែរ ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ (១៩៧៩-បច្ចុប្បន្ន)* ភ្នំពេញ ឆ្នាំ២០១២។
៣- គិត សុផល *តួនាទីព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ* ភ្នំពេញ ឆ្នាំ២០១៣។
៤- ធរិន សរៈខាំ *ប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនានៅប្រទេសឥណ្ឌា* ភ្នំពេញ ឆ្នាំ២០០៦។
៥- ឈឹម សុមន៍ *សង្ខេបទសជាតក៍* ភ្នំពេញ ការផ្សាយរបស់ក្រសួងពុទ្ធិសាសនបណ្ឌិត្យ ឆ្នាំ១៩០២។
៦- ឈឹម ស៊ុមន៍ *ពុទ្ធប្បវត្តិកថា* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៩៤។
៧- ញ៉ុក ថែម *បញ្ញាសជាតក* ភ្នំពេញ មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ឆ្នាំ១៩៦៣។
៨- ត្រឹង ងា *អរិយធម៌ខ្មែរ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៧៤។
៩- ធសោ *អក្សរសិល្ប៍ពុទ្ធនិយម* ភ្នំពេញ ឆ្នាំ១៩៩៤។
១០- ប៉ាង ខាត់ *ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០៤។
១១- ពុទ្ធសាសនបណ្ឌិត្យ *ព្រះត្រៃបិដកបាលី និងសេចក្ដីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមាសភាគ៦៣* ភ្នំពេញ ព.ស.២៥០៣។
១២- ពុទ្ធសាសនបណ្ឌិត្យ *ព្រះត្រៃបិដកបាលី នឹងសេចក្ដីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកាទសមាសភាគ៦២* ភ្នំពេញ ព.ស.២៥០០។
១៣- ភាជ ណាង *អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម* ភ្នំពេញ ឆ្នាំ២០១៥។
១៤- លាង ហាប់អាន *អត្ថាធិប្បាយកថា រឿងមហាវេស្សន្តរជាតក* ភ្នំពេញ ផ្សាយចេញពីរោងពុម្ព សឹង ហេង ឆ្នាំ១៩៦៥។

- ឯកសារជាភាសាបរទេស៖
១៥- King Hoc Dy, *Khmer Literature since 1975,* in: Cambodia Culture since 1975, Cornell University Press, London, 1994.
១៦- CHANDLER P. David, *The Tragedy of Cambodian History,* USA, Yale University, 1991.

# ការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

បេក្ខជនបណ្ឌិត៖ **សាន សេង**
ជំនាញ៖ **រដ្ឋបាលសាធារណៈ**

## I-សេចក្តីផ្តើម

កម្ពុជាធ្លាប់ជាប្រទេសប្រឡាក់ដោយឈាមក្រោមព្យុះភ្លៀងបោកបក់ នាំមកនូវក្តីវិនាសអន្តរាយ និងលំបាកវេទនារាប់មិនអស់ អាក្រក់បំផុត នាឆ្នាំ១៩៧៥-១៩៧៩ អ្វីៗទាំងអស់ត្រូវបំផ្លាញដល់កម្រិតសូន្យ សមិទ្ធផលពីសម័យអង្គរត្រូវបានបំផ្លាញទាំងស្រុង ជាកុសលបានបន្សល់នូវប្រទេសជាតិដ៏ល្អបរិសុទ្ធ មានឱកាសបានកសាង និងស្តារឡើងវិញចាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ តាំងពីឆ្នាំ១៩៩៨ ប្រទេសជាតិមានសន្តិភាពពេញលេញ មានស្ថិរភាពនយោបាយ នីតិរដ្ឋ និងការអភិវឌ្ឍ បានកាត់បន្ថយបញ្ហាប្រឈមនានាបន្តិចម្តងៗរហូតស្មើមុខមាត់លើប្រទេសមួយចំនួនធំក្នុងពិភពលោក ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី។

កម្ពុជាបានឈមមុខនឹងការប្រកួតប្រជែងជាមួយអាស៊ាន ដែលជាសហគមន៍សេដ្ឋកិច្ចតែមួយ ចាប់ពីឆ្នាំ២០១៥មក ជាការចូលរួមសហរណកម្ម ដែលគ្រប់វិស័យទាំងអស់នៅលើផ្លូវតែមួយ។ ហេតុនេះកម្ពុជាត្រូវបង្កើនការប្រកួតប្រជែង ដើម្បីអាចដោះស្រាយបញ្ហាប្រឈម និងបង្កើតឱកាសទាំងផលិតផល ទំនិញឱ្យមានគុណភាព និងតម្លៃសមរម្យ ចំណែកឯគុណភាពកម្លាំងពលកម្ម និងលក្ខណៈផ្សេងៗក៏ដូចគ្នាដែរគឺដើម្បីទាក់ទាញអ្នកវិនិយោគទុនក្នុងអាស៊ាន និងអន្តរជាតិបាន ជាពិសេសត្រូវត្រៀមខ្លួនទាំងគុណភាពវិស័យអប់រំ និងបណ្តុះបណ្តាល ដែលបានបំពេញគុណតម្លៃឱ្យគ្នាទៅវិញទៅមក ដោយត្រូវធ្វើកំណែទម្រង់ជាប្រចាំដើម្បីសមត្ថភាពធនធានមនុស្ស ព្រមគ្នាជាមួយនឹងមនសិការជាតិ។

ហេតុនេះហើយ ទើបរាជរដ្ឋាភិបាលបានបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០០៥ តាមរយៈអនុក្រឹត្យលេខ៥២ អនក្រ.បក ដោយបានប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងពិភពការងារ។ ដោយវិស័យទាំងពីនេះកាន់តែរីកចម្រើនរាជរដ្ឋាភិបាលក៏បានបន្តធ្វើកំណែទម្រង់ ដោយបានរៀបចំអង្គភាពចំណុះឡើងវិញ ជាពិសេសវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈ អនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៤។

ការគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. ជាកត្តាយ៉ាងសំខាន់ ដើម្បីជានាការអភិវឌ្ឍធនធានមនុស្ស និងមូលធនមនុស្ស សម្រាប់ផ្គត់ផ្គង់តាមតម្រូវការទីផ្សារការងារដែលកំពុងតែផ្លាស់ប្តូរពីអតិពលកម្មទៅជាកម្លាំងពលកម្មជំនាញ ដែលត្រូវធ្វើយ៉ាងណាបណ្តុះបណ្តាលប្រជាពលរដ្ឋម្នាក់ឱ្យមានជំនាញយ៉ាងតិចមួយក្នុងការចិញ្ចឹមជីវិត។

ផ្ដើមចេញពីបេសកកម្មរបស់ក្រសួង ស្របទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ឆ្នាំ ២០២៤-២០២៨ ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដែលបានផ្ដោតលើការអភិវឌ្ឍមូលធនមនុស្ស ក្នុងអាទិភាពនៃបញ្ចកោណទី១ មុំទី១ គឺ "ការពង្រឹងគុណភាព វិស័យអប់រំ កីឡា និងបច្ចេកទេស" និងអាទិភាពទី២ ដោយ "ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស"។ ទាំងនេះ TVET បានកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមកាត់បន្ថយភាពខ្វះជំនាញ និងភាពក្រីក្រ របស់ប្រជាពលរដ្ឋ។

តាមបរិបទនេះ ការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ជារឿងចាំបាច់ ដោយធ្វើយ៉ាងណាឱ្យមានលក្ខណៈល្អប្រសើរ ជាមូលដ្ឋានដ៏រឹងមាំក្នុងការបណ្ដុះបណ្ដាលជំនាញដល់ប្រជាពលរដ្ឋធ្វើយ៉ាងណា **"ឱ្យចប់ ឱ្យចេះ និងមានការងារ"** ដែលជាអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះ ក្រសួងបានរកឃើញយុទ្ធសាស្ត្រសំខាន់ៗចំនួន៦ ក្នុងការអភិវឌ្ឍវិស័យអ.ប.វ.រួមមាន៖ ១)គោលនយោបាយ បទបញ្ញត្តិ និងអភិបាលកិច្ច ២)ការចូលរួមពីដៃគូអភិវឌ្ឍន៍ ៣)ការអភិវឌ្ឍកម្លាំងពលកម្ម ៤)ការធ្វើទីផ្សារ និងទំនាក់ទំនង ៥)ការអភិវឌ្ឍធនធានមនុស្ស និងហិរញ្ញវត្ថុ និង ៦)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលផ្អែកលើយុទ្ធសាស្ត្រនេះ មានស្តង់ដាគុណភាពទាំង៦ ដើម្បីដឹកនាំ និងគ្រប់គ្រង គ្រឹះស្ថាន អ.ប.វ. ជានាបាននូវការប្រកួតប្រជែង និងផ្លាស់ប្ដូរមុខមាត់មួយចំណែកធំ។

## II- **មូលដ្ឋានទ្រឹស្ដី**

### **១. និយមន័យនៃការគ្រប់គ្រង**

ការគ្រប់គ្រងជាដំណើរការនៃការរៀបចំផែនការ(planning) ការចាត់ចែង(Organizing) ការដឹកនាំ (Leading) និងការត្រួតពិនិត្យ (Controlling) សកម្មភាពរបស់បុគ្គល ឬក្រុមនៅក្នុងអង្គភាព ដោយប្រើប្រាស់ធនធានដូចជា មនុស្ស ហិរញ្ញវត្ថុ សម្ភារ និងបច្ចេកវិទ្យា ដើម្បីសម្រេចបានគោលដៅរបស់អង្គភាពប្រកបប្រសិទ្ធភាព(Efficientcy) និងប្រសិទ្ធផល(Effectiveness)។ ការគ្រប់គ្រងពាក់ព័ន្ធនឹងការសម្រេចចិត្ត ការកំណត់គោលបំណង ការបែងចែកធនធាន ការដោះស្រាយបញ្ហា និងការប្រាស្រ័យទាក់ទងគ្នា ដើម្បីជួយសម្រួលដល់ប្រតិបត្តិការរបស់អង្គភាពមួយដោយរលូន។

### **២. អត្ថន័យនៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ** (TVET)

TVET ជាពាក្យតំណាងឱ្យការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ[9] ដែលពាក្យនេះត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

-"ពាក្យថា "ការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ" ដែលអក្សរកាត់ថា TVET ត្រូវបានដាក់ឱ្យដំណើរការនៅក្នុងសមាជពិភពលោកស្ដីពី TVET ក្នុងឆ្នាំ១៩៩៩ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ។ សមាជបានទទួលស្គាល់ពាក្យ "TVET" ឱ្យទូលំទូលាយ ដើម្បីអាចបញ្ចូលពាក្យផ្សេងទៀតដែល

[9] ច្បាប់អប់រំកម្ពុជា ឆ្នាំ២០០៧។

ធ្លាប់ប្រើ។ ដើម្បីពិពណ៌នាអំពីសកម្មភាពអប់រំ និងបណ្តុះបណ្តាលស្រដៀងគ្នា ការសម្រេចចិត្តក្នុងឆ្នាំ ១៩៩៩ក្នុងការដាក់ឱ្យប្រើប្រាស់ពាក្យ TVET បាននាំឱ្យមានការអភិវឌ្ឍមជ្ឈមណ្ឌលអន្តរជាតិ UNESCO-UNEVOC សម្រាប់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅទីក្រុងBonn ប្រទេសអាល្លឺម៉ង់ (Sanni, 2018)។

-នៅក្នុងពិភពនិយាយភាសាអង់គ្លេស មានពាក្យ និងអក្សរកាត់ជាច្រើនសម្រាប់ផ្នែកនៃការអប់រំដែលរៀបចំសម្រាប់ពិភពការងារ និងជីវិតរួមមាន៖

១)រហូតមកដល់ឆ្នាំ២០០១ អង្គការយូណេស្កូបានប្រើប្រាស់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (Technical and Vocational Education-TVE)

២)សហភាពអឺរ៉ុបសំដៅលើការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (Vocational Education and Training-VET)

៣)រដ្ឋឯករាជ្យ សហគមន៍ និងខ្លះទៀតប្រើពាក្យ ការអភិវឌ្ឍជំនាញបច្ចេកទេស និងវិជ្ជាជីវៈ (Technical and vocational skills development-TVSD)

៤)ចក្រភពអង់គ្លេស និងអាហ្វ្រិកខាងត្បូង ជារឿយៗសំដៅលើការអប់រំបន្ថែម និងបច្ចេកទេស (Further and Technical Education -FET) ដែលត្រូវបានប្រើជាពាក្យមានន័យដូច TVET

៥)សហរដ្ឋអាមេរិកចូលចិត្តការអប់រំការងារ និងបច្ចេកទេស (Career and technical education-CTE)

៦)ពាក្យដែលប្រើញឹកញាប់ផ្សេងទៀតគឺ៖ ការអភិវឌ្ឍកម្លាំងពលកម្ម កម្មវិធីហ្វឹកហ្វឺនកូនជាង ការអប់រំវិជ្ជាជីវៈនិងបច្ចេកទេស (Vocational and Technical Education-VTE)

-ពាក្យ TVET មានការបកស្រាយដូចខាងក្រោម៖

១)បច្ចេកទេស(Technical) សំដៅប្រធានបទដែលមានបច្ចេកទេសទៅតាមលក្ខណៈរបស់វាទាក់ទងទៅនឹងផ្នែករឹង និងផ្នែកទន់ រួមបញ្ចូលទាំងការអនុវត្ត ការដោះស្រាយបញ្ហា និងដំណើរការវិស្វកម្ម

២)វិជ្ជាជីវៈ(Vocational) សំដៅដល់មុខរបរមួយ ឬការងារ និងមុខរបរមួយ ជាញឹកញាប់សំដៅទៅលើភាពស្ទាត់ជំនាញ(ថ្នឹក) នៅក្នុងអាជីពការងារនានា

៣)ការអប់រំ(Education) សំដៅដល់ការអប់រំក្នុងប្រព័ន្ធ ចាប់ផ្តើមនៅកម្រិតមធ្យមនិងក្រោយមធ្យមសិក្សា ដូចជាមហាវិទ្យាល័យ ពហុបច្ចេកទេស និងសាកលវិទ្យាល័យ

៤)ការបណ្តុះបណ្តាល(Training) សំដៅដល់ការអប់រំមិនផ្លូវការ ហៅបានម្យ៉ាងទៀតថាការសិក្សាពេញមួយជីវិត ឬការអប់រំបន្ត ជារឿយៗសំដៅដល់ការបណ្តុះជំនាញថ្មី ឬការបណ្តុះជំនាញបន្ថែមដល់កម្លាំងពលកម្ម(TVET Journal 2021)។ ក្នុងនាម UNESCO-UNEVOC ជាមជ្ឈមណ្ឌលសម្រាប់ TVET បានផ្តល់អនុសាសន៍ឱ្យមានការកែសម្រួល ទៅជាពាក្យ TVET ក្នុងឆ្នាំ ២០១៥ នាពេលនេះហើយ ជាពេលដែលមានអនុសាសន៍ទាក់ទងនឹងការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ពាក្យដែលពេញនិយមនេះសំដៅទៅលើទិដ្ឋភាពនៃដំណើរការអប់រំ ដែលពាក់ព័ន្ធនឹងការបន្ថែមលើការអប់រំទូទៅ ការសិក្សាអំពីបច្ចេកវិទ្យា និងវិទ្យាសាស្ត្រដែលពាក់ព័ន្ធនឹងការទទួលបានជំនាញជាក់ស្តែង អាកប្បកិរិយា ការយល់ដឹង និងចំណេះដឹងទាក់ទងនឹងការកាន់កាប់ក្នុងវិស័យផ្សេងៗនៃជីវិតសេដ្ឋកិច្ច និងសង្គម។ ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានយល់បន្ថែមថាជា៖

១)ផ្នែកសំខាន់មួយនៃការអប់រំទូទៅ

២)មធ្យោបាយនៃការរៀបចំសម្រាប់វិស័យការងារ និងសម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងពិភពការងារ

៣)ទិដ្ឋភាពនៃការរៀនសូត្រពេញមួយជីវិត និងការរៀបចំសម្រាប់ភាពជាពលរដ្ឋដែលមានការទទួលខុសត្រូវ

៤)ឧបករណ៍សម្រាប់លើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពបរិស្ថាន

៥)វិធីសាស្ត្រក្នុងការសម្រួលដល់ការកាត់បន្ថយភាពក្រីក្រ (UNESCO 2001)។

ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) ត្រូវបានគេយល់ជារួមមាន "**ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញ**" ដែលទាក់ទងនឹងវិស័យមុខរបរដ៏ធំទូលាយ ផលិតកម្ម សេវាកម្ម និងជីវភាពរស់នៅ។

TVET ដែលជាផ្នែកមួយនៃការរៀនសូត្រពេញមួយជីវិត អាចប្រព្រឹត្តទៅនៅកម្រិតមធ្យមសិក្សាក្រោយមធ្យមសិក្សា និងឧត្តមសិក្សា ហើយរួមបញ្ចូលទាំងការរៀនផ្អែកលើការងារ និងការបន្តការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈដែលអាចនាំទៅរកគុណវុឌ្ឍិ។ TVET ក៏រួមបញ្ចូលនូវឱកាសអភិវឌ្ឍន៍ជំនាញជាច្រើន ដែលស្របតាមបរិបទជាតិ និងមូលដ្ឋាន។ ការរៀនដើម្បីរៀន ការអភិវឌ្ឍជំនាញអក្ខរកម្ម និងលេខ ជំនាញបំប្លែង និងជំនាញសញ្ជាតិ គឺជាសមាសធាតុសំខាន់នៃ TVET (UNESCO 2015)។

TVET សំដៅដល់គ្រប់ទម្រង់ និងគ្រប់កម្រិតនៃការអប់រំបណ្តុះបណ្តាល ដែលផ្តល់នូវចំណេះដឹងនិងជំនាញ(បំណិន)ទាំងឡាយពាក់ព័ន្ធមុខរបរនានានៅក្នុងបណ្តាវិស័យសេដ្ឋកិច្ច និងសង្គម តាមរយៈការសិក្សាក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ ដែលទទួលបានទាំងក្នុងគ្រឹះស្ថានបណ្តុះបណ្តាល និងទាំងក្នុងឧស្សាហកម្ម (TVET-Wikipedia)។

ដូចនេះ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) ត្រូវបានគេយល់ជារួមថាជាការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញ ដែលទាក់ទងនឹងវិស័យការងារដ៏ធំទូលាយដូចជាផលិតកម្ម សេវាកម្ម និងជីវភាពរស់នៅជាប្រចាំ។

### ៣. ការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ជាទូទៅ TVET តំណាងឱ្យការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ TVET សំដៅទៅលើការអប់រំ និងការបណ្តុះបណ្តាលដែលផ្តល់ចំណេះដឹង និងជំនាញទាក់ទងនឹងពាណិជ្ជកម្ម មុខរបរ និងឧស្សាហកម្មជាក់លាក់។ កម្មវិធី TVET ត្រូវបានរៀបចំឡើងដើម្បីរៀបចំបុគ្គលសម្រាប់អាជីពក្នុងវិស័យបច្ចេកទេស និងវិជ្ជាជីវៈផ្សេងៗដូចជា សំណង់ អគ្គិសនី និងថាមពល អេឡិចត្រូនិក បរិក្ខារត្រជាក់

និងកំដៅ កម្មន្តសាល មេកានិកទូទៅ/មេកានិករថយន្ត ទេសចរណ៍ សេវាកម្ម កសិកម្មនិងកសិឧស្សាហកម្ម ធុរកិច្ចនិងព័ត៌មានវិទ្យា និងអ្នកបច្ចេកទេសថែទាំសុខភាព ជាដើម។ កម្មវិធី TVET ជារឿយៗរួមបញ្ចូលគ្នានូវការរៀនក្នុងថ្នាក់ជាមួយនឹងការបណ្តុះបណ្តាលដោយអនុវត្ត ដើម្បីធានាថា សិក្ខាកាម សិស្ស និស្សិតទទួលបានទាំងចំណេះដឹងទ្រឹស្តី និងជំនាញជាក់ស្តែងដែលត្រូវការ ដើម្បីទទួលបានជោគជ័យលើជំនាញ ក្នុងវិស័យដែលពួកគេបានជ្រើសរើស។

ការគ្រប់គ្រងគ្រឹះស្ថាន TVET សំដៅលើក្របខ័ណ្ឌ និងរចនាសម្ព័ន្ធជាយុទ្ធសាស្ត្រ ដើម្បីធានានូវនិរន្តរភាពគ្រឹះស្ថាន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ការគ្រប់គ្រងគ្រឹះស្ថានរួមបញ្ចូលសមាសធាតុ៨ ដូចជា៖ ១)អភិបាលកិច្ច ២)ការផ្តល់ហិរញ្ញប្បទាន ៣)ការរំពឹងទុកនៃតម្រូវការជំនាញ ៤)ការអភិវឌ្ឍកម្មវិធីសិក្សា ៥)ការគ្រប់គ្រងគុណភាព ៦)ការប្រឹក្សាយោបល់អំពីអាជីព ៧)ការបង្រៀន និងរៀន ៨)ការប្រឡងនិងផ្តល់វិញ្ញាបនបត្រ[២]។ នៅក្នុងសមាសធាតុនេះ ការគ្រប់គ្រងគុណភាពជាផ្នែកមួយនៃការធានាគុណភាពគ្រឹះស្ថាន ដែលមានស្តង់ដាគុណភាពចំនួន៦ ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគ្រឹះស្ថាន និងជាយន្តការក្នុងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពនៅក្នុងវិស័យ អ.ប.វ. កម្ពុជា។

**ដ្យាក្រាមទី១៖ ប្រព័ន្ធ អ.ប.វ. និងទំនាក់ទំនងផ្ទៃក្នុង**




## III-ស្ថានភាពនៃការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពីឆ្នាំ២០១៥

ដោយមានបញ្ហានយោបាយ និងសេដ្ឋកិច្ចនៅក្នុងប្រទេសយូរអង្វែងវិស័យនានាមានការលំបាក និងស្មុគស្មាញជាទីបំផុតជាពិសេសក្នុងយុគសម័យសង្គ្រាមត្រូវចំណាយពេលច្រើន ក្នុងការកសាង និងអភិវឌ្ឍឡើងវិញ ទន្ទឹមនឹងនេះ យើងសូមពិនិត្យមើលការកសាង និងអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដូចខាងក្រោម៖

---

[២] អង្គការអន្តរជាតិខាងការងារ *វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ* ទីក្រុង TURIN ប្រទេសអ៊ីតាលី ឆ្នាំ២០២២។

## ១. ស្ថានភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈពីឆ្នាំ ២០១៥-២០២៤

ក្នុងឆ្នាំ២០១៥ មានគ្រឹះស្ថានអ.ប.វសាធារណៈ ចំនួន៣៩ គ្រឹះស្ថាន ក្នុងនោះមានវិទ្យាស្ថានពហុបច្ចេកទេសចំនួន១៥ ដែលផ្តល់ការបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសនិងវិស្វករ និងមានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន២១ សាលាមធ្យមសិក្សាបច្ចេកទេសចំនួន១ សាលាការដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន១ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន២[៣]។ បើប្រៀបធៀបនឹងស្ថិតិឆ្នាំ២០១៩ និង២០២២ ពុំមានភាពខុសគ្នាប៉ុន្មានទេ ដូចតារាងខាងក្រោម៖

តារាងទី១៖ ចំនួនគ្រឹះស្ថាន អ.ប.វ. សាធារណៈឆ្នាំ២០១៥-២០២៤

| ល.រ | ប្រភេទគ្រឹះស្ថាន | ២០១៥ | ២០១៧ | ២០១៩ | ២០២២ | ២០២៤ |
|---|---|---|---|---|---|---|
| ១ | វិទ្យាស្ថានពហុបច្ចេកទេស | ១២ | ១៥ | ២១ | ២១ | ២៩ |
| ២ | សាលាមធ្យមសិក្សាបច្ចេកទេស | ១ | ១ | ១ | ១ | ០ |
| ៣ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ | ២៤ | ២១ | ១៥ | ១៥ | ៨ |
| ៤ | សាលាការដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ | ១ | ០ * | ០ | ០ |
| ៥ | សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ | ២ | ២ | ១ ** | ០ |
| សរុប | | ៣៩ | ៣៩ | ៣៩ | ៣៨ | ៣៧ *** |

* វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ (វ.ជ.ព.អ)

**សាលាបណ្តុះបណ្តាលវិជ្ជាជីវៈរលាំងខេត្តពោធិ៍សាត់ បញ្ចូលជាមួយវិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់

***មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រះវិហារ-យ៉ាឡាយ ស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី ត្រូវបានបញ្ចូលតែពុំទាន់អនុវត្តពេញលេញ

ទន្ទឹមនឹងនេះ ក្រៅពីគ្រឹះស្ថានសាធារណៈទាំង៣៧ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏នៅមានគ្រឹះស្ថានឯកជនចំនួន ៤៤ អង្គការ និងសមាគម២១ ដែលបានចុះបញ្ជីស្ថិតក្រោមឱវាទក្នុងឆ្នាំ២០២៣ ដូចតារាងខាងក្រោម៖

តារាងទី២៖ ចំនួនគ្រឹះស្ថានក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៥-២០២៣

| ល.រ | បរិយាយ | ឆ្នាំ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២៣ |
| ១ | ចំនួនគ្រឹះស្ថាន អ.ប.វ សាធារណៈ | ៣៩ | ៣៩ | ៣៩ | ៣៩ | ៣៨ | ៣៨ | ៣៧ |
| ២ | ចំនួនគ្រឹះស្ថាន អ.ប.វ ឯកជន | ៤៤ | ៤៨ | ៣៧ | ៤១ | ៤៤ | ៤៥ | ៤៤ |
| ៣ | ចំនួនអង្គការ និងសមាគម | ២៣ | ២៤ | ២៦ | ២៦ | ២៥ | ២៥ | ២១ |
| សរុប | | ១០៦ | ១១១ | ១០២ | ១០៦ | ១០៧ | ១០៨ | ១០២ |

[៣] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ *សៀវភៅព័ត៌មានទូទៅរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ* ភ្នំពេញ ឆ្នាំ២០១៧ ទំព័រ iv ។

វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវបន្តធ្វើកំណែទម្រង់ឆ្លើយតបនឹងគោលដៅរបស់រាជរដ្ឋាភិបាល ជាពិសេសការអភិវឌ្ឍជំនាញដែលកាន់តែមានសារៈសំខាន់គឺការប្រែក្លាយឱ្យប្រជាពលរដ្ឋមានជំនាញត្រឹមឆ្នាំ២០២៥ ធ្វើយ៉ាងណាឱ្យពួកគាត់អាចរៀន និងធ្វើការ ហេតុនេះរាជរដ្ឋាភិបាលបានបើកច្រកយ៉ាងទូលាយ មិនតែប៉ុណ្ណោះគ្រឹះស្ថានបានពង្រឹងការគ្រប់គ្រង ដោយបានកំពុងប្រែក្លាយពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទៅជាវិទ្យាស្ថានជាបន្តបន្ទាប់ និងបានប្តូរឈ្មោះ មួយចំនួនជំនាដើមឆ្នាំ២០២៣នេះ មិនតែប៉ុណ្ណោះបានបញ្ចូលមជ្ឈមណ្ឌលមួយចំនួន និងសាលាបច្ចេកទេសជាមួយវិទ្យាស្ថានបានប្រែក្លាយសាលាមធ្យមសិក្សាបច្ចេកទេសទៅជាវិទ្យាស្ថាន និងបានកំពុងប្តូររបៀបគ្រប់គ្រងទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រង។ បន្ថែមលើនេះក្រសួងក៏មានវិធានការប្រមូលផ្តុំទៅជាសួនបច្ចេកទេសបានចំនួន៣ រួចមកហើយដូចជា (១)សួនបច្ចេកទេសរាជធានីភ្នំពេញ (២)សួនបច្ចេកទេសខេត្តបាត់ដំបង និង(៣)សួនបច្ចេកទេសខេត្តសៀមរាបក្នុងគោលដៅដោះស្រាយបញ្ហាប្រឈមនានាដើម្បីអាចចល័ត និងចែករំលែកធនធាន ដែលមានទាំងធនធានមនុស្ស និងធនធានរូបវន្តនានាសម្រាប់បម្រើឱ្យប្រព័ន្ធបណ្តុះបណ្តាលជំនាញដល់គ្រឹះស្ថានដែលខ្វះខាត គឺអាចគ្រឹះស្ថានធំជួយគ្រឹះស្ថានតូចដែលខ្វះធនធាន និងមានការអភិវឌ្ឍតិចតួច។

រូបទី១៖ ផែនទីនៃកម្រង និងប្រអប់គ្រឹះស្ថាន អ.ប.វ. សាធារណៈ (២ កញ្ញា ២០២២)

| **កម្រងរាជធានីភ្នំពេញ** | **កម្រងទី១** |
|---|---|
| ១.វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ១.វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប |
| ២.វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ២.វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ |
| ៣.វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៣.វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ |
| ៤.វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៤.វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះវិហារ (មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រះវិហារ-យ៉ាឡាយ) |
| ៥.វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម | ៥.មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឧត្តរមានជ័យ |
| ៦.វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ | |
| ៧.វិទ្យាស្ថានបច្ចេកទេស ហ្ស៊ី វ៉េ សេ | |




**ក្រុមទី២**

១.វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង

២.វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង

៣.វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

៤.វិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ

៥.វិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់

៦.មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន

**ក្រុមទី៣**

១.វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត

២.វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ

៣.វិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជាចិនខេត្តព្រះសីហនុ

៤.វិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង

៥.មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកែប

**កម្រងទី៤**

១.វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ
២.វិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន
៣.វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ស្ពឺ
៤.វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ឆ្នាំង
៥.វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ

**កម្រងទី៥**

១.វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង
២.វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម
៣.វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រៃវែង
៤.មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ
៥.វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនឦសានៈ ១.មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង, ២).មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី និង ៣).មជ្ឈមណ្ឌលបណ្តុះ បណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី

**១.សួនអប់រំបណ្តុះបណ្តាលបច្ចេកទេសរាជធានីភ្នំពេញ**

១.វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស
២.វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
៣.វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម
៤.វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍

**២.សួនអប់រំបណ្តុះបណ្តាលបច្ចេកទេសបាត់ដំបង**

១.វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង
២.វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង
៣.វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

**៣.សួនអប់រំបណ្តុះបណ្តាលបច្ចេកទេសសៀមរាប**

១.វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប
២.វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ

ការគ្រប់គ្រងគ្រឹះស្ថានត្រូវបានរៀបចំគោលការណ៍៤ រួមមានៈ ១)កម្រង(Cluster) ២)សួនបច្ចេកទេស(TVET Park) ៣)គ្រឹះស្ថានសាធារណៈរដ្ឋបាល និង៤)ការប្រែក្លាយពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យទៅជាវិទ្យាស្ថានពហុបច្ចេកទេស ដើម្បីបង្កលក្ខណៈ ឱ្យសិក្ខាកាម សិស្ស និស្សិត និងគ្រូបច្ចេកទេសអាចបង្កើនជំនាញ និងគុណវុឌ្ឍិព្រមគ្នា។

## ២. គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ និងវគ្គបណ្តុះបណ្តាល

បច្ចុប្បន្ននេះមានគ្រឹះស្ថានអ.ប.វ.សាធារណៈចំនួន៣៧ នៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

### ក. វិទ្យាស្ថាន/វិទ្យាស្ថានពហុបច្ចេកទេសចំនួន២៩

គ្រឹះស្ថានទាំងនេះ ផ្តល់ជូននូវវគ្គសិក្សាជាច្រើន ចាប់ពីកម្រិតវិញ្ញាបនបត្របត្រវិជ្ជាជីវៈ (វគ្គសិក្សាខ្លី) ដល់ថ្នាក់បរិញ្ញាបត្របច្ចេកវិទ្យា(ឧត្តមសិក្សា) លើកលែងតែ NPIC ដែលបានកំពុងបណ្តុះបណ្តាលថ្នាក់បណ្ឌិត។ វិទ្យាស្ថានទាំងអស់ផ្តល់នូវវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ បច្ចេកវិទ្យា(មានរយៈពេលពី៤ ទៅ ៤,៥ឆ្នាំ) និងសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសឬបរិញ្ញាបត្ររង (CQF កម្រិត៥) ៦០ ក្រេឌីត/២ឆ្នាំ ហើយមានតែវិទ្យាស្ថានចំនួន ៤ ប៉ុណ្ណោះ (NPIC NTTI NIB និង NIEI) បណ្តុះបណ្តាលកម្រិត អនុបណ្ឌិតបច្ចេកវិទ្យា។ ក្រៅពីនេះគ្រឹះស្ថានទាំងអស់ផ្តល់ជូនវគ្គសិក្សារយៈពេលខ្លី(មានរយៈពេលចាប់ពី ១ ទៅ ៤ ខែ)។ (ឧបសម្ព័ន្ធ១៖ គ្រឹះស្ថានអ.ប.វ)

### ខ.វិទ្យាស្ថានបណ្តាលភូមិភាគ (RTIs) ទាំង ៥

RTC ទាំង ៥ ត្រូវបានដំឡើងឋានៈជាវិទ្យាស្ថាន (RTIs) និងផ្តល់ការបណ្តុះបណ្តាលកម្រិតឧត្តម (១២០ ក្រេឌីត/៤ ឆ្នាំនៃបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/បរិញ្ញាបត្រ) សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស/បរិញ្ញាបត្ររង (CQF កម្រិត៥ ៦០ ក្រេឌីត / ២ ទៅ ២,៥ ឆ្នាំ) និង CQF កម្រិត ២ ដល់កម្រិត៤ (៣០ ក្រេឌីត) RTI ទាំងអស់ផ្តល់ជូនវិញ្ញាបនបត្រវិជ្ជាជីវៈ / វគ្គបណ្តុះបណ្តាលរយៈពេលខ្លី (មានរយៈពេលពី១ ទៅ ៤ ខែ)។ (ឧបសម្ព័ន្ធ២៖ លក្ខខណ្ឌចូលរៀនស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា)

### គ.មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈខេត្ត (PTC) ចំនួន ៤

PTC ផ្តល់ការបណ្តុះបណ្តាលត្រឹមកម្រិត២ដល់កម្រិត៤ (៣០ ក្រេឌីត/កម្រិតនីមួយៗ) និងវិញ្ញាបនបត្រវិជ្ជាជីវៈ និងវគ្គបណ្តុះបណ្តាលដែលមានរយៈពេលខ្លី(មានរយៈពេលពី១សប្តាហ៍ដល់៤ខែ)។

តួនាទីរបស់ អ.ប.វ. គឺរៀបចំយុវជនដើម្បីទទួលបានការងារ (រួមទាំងការងារក្នុងប្រព័ន្ធ និងការប្រកបមុខរបរផ្ទាល់ខ្លួន) ដោយផ្តល់នូវចំណេះដឹងបច្ចេកទេស និងជំនាញវិជ្ជាជីវៈ ទូលំទូលាយដែលត្រូវនឹងមុខរបរជាក់លាក់មួយ ក៏ដូចជាមុខរបរទូលំទូលាយ ផ្តល់នូវឱកាសបណ្តុះបណ្តាលដើម្បីទទួលបានជំនាញ លើកកម្ពស់ជំនាញ និងរៀបចំជំនាញឡើងវិញដើម្បីឆ្លើយតបនឹងតម្រូវការការងារដែលកំពុងវិវត្តជឿនលឿនទៅមុខ និងជៀសវាងការលែងត្រូវការតទៅទៀត។ អ.ប.វ. ក៏ជាយានមួយសម្រាប់សមធម៌សង្គមផងដែរ ពីព្រោះវាផ្តល់នូវជំនាញដែលមានការងារនិងការបណ្តុះបណ្តាលដល់អ្នកដែលមានហេតុផលផ្សេងៗ ដែលមិនអាចមានលទ្ធភាពបន្តការសិក្សាទៅឧត្តមសិក្សាបាន។

រូបទី ២៖ រចនាសម្ព័ន្ធគ្រឹះស្ថាន អ.ប.វ. សាធារណៈឆ្នាំ២០២៤




IV-**អភិបាលកិច្ចនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**

ផ្តើមចេញពីព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៦៦/០០៨/២០០៨ កបធ.ធ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៤ ហើយដែលមានសេចក្តីចំនួន៦មាត្រា ក្នុងការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវបានឡាយព្រះហស្តលេខា និងព្រះរាជលញ្ចករព្រះមហាក្សត្រកាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសសកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**១. គណៈកម្មាធិការជាតិបណ្តុះបណ្តាល** (NTB)

គណៈកម្មាធិកាជាតិបណ្តុះបណ្តាលដែលហៅកាត់ថា គ.ជ.ប.ប ត្រូវបានបង្កើតនៅឆ្នាំ១៩៩៨ ដោយអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨ ដែលមានក្រសួងអប់រំ យុវជន និងកីឡាឋានៈរដ្ឋលេខាធិការជាប្រធាន។ គណៈកម្មាធិការជាតិបណ្តុះបណ្តាលមានសមាសភាពចំនួន ២៦ រូប ដែលសមាជិកមានឋានៈចាប់ពីអនុរដ្ឋលេខាធិការ និង រដ្ឋលេខាធិការ។

គណៈកម្មាធិការជាតិបណ្តុះបណ្តាលត្រូវបានកែសម្រួល ដោយអនុក្រឹត្យលេខ៧៩០ អនក្រ .បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥ ដែលមានសមាសភាពចំនួន២៩ រូប មានសម្តេច**វិបុលបញ្ញា សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ ការកែសម្រួលបន្តបន្ទាប់ទៀត

ដោយ អនុក្រឹត្យលេខ១០៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កែសម្រួលសមាសភាព សមាជិកគណៈកម្មាធិការជាតិបណ្តុះបណ្តាលមានចំនួន៣៥រូប អនុក្រឹត្យលេខ១៣៥៩អនក្រ.បក ចុះ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ កែសម្រួលសមាសភាពសមាជិកគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលមានចំនួន៣៧ រូប។

ចុងក្រោយនេះ នាឆ្នាំ២០១៧ យោងអនុសាសន៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសឱ្យស្ថាប័នមួយចំនួនស្ថិតនៅក្នុង ក្រសួងដែលពាក់ព័ន្ធ ក្នុងនោះមានគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងគណៈវិស្វកម្មកម្ពុជាឱ្យ ស្ថិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ហេតុនេះហើយសមាសភាពគណៈកម្មាធិការ ជាតិបណ្តុះបណ្តាលតម្រូវឱ្យកែសម្រួល តាមរយៈអនុក្រឹត្យលេខ៩០៩ អនក្រ.បក ចុះថ្ងៃទី២១ ខែ សីហា ឆ្នាំ២០១៧ ដោយមានឯកឧត្តម**បណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះប ណ្តាលវិជ្ជាជីវៈ ជាប្រធាន។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ លេខ២២ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងចេញ សេចក្តីសម្រេចលេខ៣២ ស.ស.រ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាព គណៈ កម្មាធិការជាតិបណ្តុះបណ្តាល។ (ឧបសម្ព័ន្ធ៣៖ រចនាសម្ព័ន្ធអភិបាលកិច្ចនៃការអប់រំបណ្តុះបណ្តាល បច្ចេកទេសនៅកម្ពុជា)

### ២. រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋាន អ.ប.វ.

រចនាសម្ព័ន្ធអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានបង្កើតឡើងនៅថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ ក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយទទួលបានអាត្តិ ពីរាជរដ្ឋាភិបាលកម្ពុជា ឱ្យដឹកនាំវិស័យបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីចូលរួមកាត់បន្ថយ ភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងលើកកម្ពស់កំណើនសេដ្ឋកិច្ច។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជី វៈជាស្ថាប័នគ្រប់គ្រងជាន់ខ្ពស់បំផុតទទួលបន្ទុកវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅ កម្រិតស្ថាប័ន និងជាថ្នាក់ដឹកនាំមានសិទ្ធិអំណាចគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈនីមួយៗ។ សកម្មភាពប្រតិបត្តិការជាប្រចាំរបស់គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស គឺដឹកនាំ ដោយនាយកមួយរូប នាយករងតាមតម្រូវការចាំបាច់ ហើយមានបុគ្គលិករដ្ឋបាល ឬការិយាល័យ ផ្នែក និងមហាវិទ្យាល័យផ្សេងៗ។

អគ្គនាយកដ្ឋាន អ.ប.វ. នៃក្រសួងការងារ និងបណ្តុះបា្តលវិជ្ជាជីវៈជាអង្គភាពថ្នាក់កណ្តាលទទួល បន្ទុករាល់បញ្ហាទាំងអស់ក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងទទួលខុសត្រូវលើ ប្រសិទ្ធភាពក្នុងការបំពេញការងាររបស់គ្រឹះស្ថាន អ.ប.វ. សាធារណៈ។[៤]

---

[៤] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ *គោលការណ៍ណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងរបាយការណ៍* ភ្នំពេញ ២០១៧ ទំព័រ ១៣

ដើម្បីធានាបាននូវការសម្រេចបានជោគជ័យក្នុងអាណត្តិរបស់វិស័យ អ.ប.វ. រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យមួយ ដើម្បីធ្វើកំណែទម្រង់រចនាសម្ព័ន្ធឡើងវិញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤។

អគ្គនាយកដ្ឋាន អ.ប.វ. មានការងារស្នូលចំនួន៣គឺ៖ ១)គ្រប់គ្រង និងគាំទ្រគ្រឹះស្ថានអ.ប.វ, ២)ប្រមូលទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មាន អ.ប.វ. និងប្រព័ន្ធព័ត៌មានគ្រប់គ្រងការងារ ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍គម្រោងម្ចាស់ជំនួយ និង ៣)គាំទ្រគណកម្មាធិការជាតិបណ្តុះបណ្តាល និងសម្របសម្រួលគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអភិវឌ្ឍជំនាញ។ អគ្គនាយកដ្ឋាន អ.ប.វ. បានរៀបចំកែសម្រួលរចនាសម្ព័ន្ធពី៣ មក៦នាយកដ្ឋាននៅកម្រិតថ្នាក់កណ្តាលដូចខាងក្រោម៖

រូបទី៣៖ នាយកដ្ឋានទាំង៦ ចំណុះអគ្គនាយកដ្ឋាន អ.ប.វ.




## V- **យន្តការនៃការគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ.**

តាមអនុក្រឹត្យលេខ ៣៨៣ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការគ្រប់គ្រងស្ថាប័ន មានរចនាសម្ព័ន្ធ ថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន និងគ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ យន្តការមួយដែលបានដើរតួនាទីក្នុងយន្តការគ្រប់គ្រងគ្រឹះស្ថានមានប្រសិទ្ធភាព និងប្រសិទ្ធផល គឺលក្ខណៈវិនិច្ឆ័យនៃការធានាគុណភាពគ្រឹះស្ថាន ដែលជាម៉ែត្រសម្រាប់វាស់ និងបង្កលក្ខណៈឱ្យគ្រឹះស្ថានអាចយកមកគ្រប់គ្រងខ្លួនឯងបាន និងបានរៀបចំបន្សីជាមួយបទដ្ឋានអន្តរជាតិ តាមរយៈអ្នកជំនាញការអន្តរជាតិ និងធ្លាប់បានឧបត្ថម្ភគាំទ្រដោយគម្រោងធនាគារអភិវឌ្ឍន៍អាស៊ី និងបានធ្វើឱ្យមានសង្គតិភាពជាមួយអាស៊ាន និងពិភពលោក។

### ១. បណ្តាញធានាគុណភាពអាស៊ាន (AQAN)

ដើម្បីបម្រើឱ្យសមាហរណកម្មអាស៊ាន ដែលបានត្រូវបានគូសបញ្ជាក់ក្នុងសសរស្តម្ភទាំង៣ គឺ សហគមន៍សន្តិសុខនយោបាយអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសង្គម-វប្បធម៌ អាស៊ាន ការធានាគុណភាពវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កលក្ខណឱ្យមានការសិក្សាពេញមួយជីវិត និងការចល័តកម្លាំងពលកម្មជាដើម។

សហគមន៍អាស៊ានបានបង្កើតបណ្តាញធានាគុណភាពអាស៊ាន(ASEAN Quality Assurance Network-AQAN) ដែលជាបណ្តាញភ្នាក់ងារធានាគុណភាពមកពីប្រទេសសមាជិកអាស៊ានទាំង១០ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការធានាគុណភាពក្នុងតំបន់ឆ្ពោះទៅរកការចុះសម្រុងគ្នានៃគោលនយោបាយឧត្តមសិក្សានៅក្នុងតំបន់។ AQAN ជាអង្គភាពពាក់ព័ន្ធអាស៊ានដែលបានចុះបញ្ជី។

AQAN ក៏បានបង្កើតគោលការណ៍ណែនាំ ដោយមានការបញ្ចូលពីសមាជិកនៃគណៈ កម្មាធិការប្រឹក្សាបច្ចេកទេសនៃក្របខ័ណ្ឌធានាគុណភាពអាស៊ាន (ASEAN Quality Assurance Framework-AQAF) សមាគមអឺរ៉ុបសម្រាប់ការធានាគុណភាពក្នុងការអប់រំនៅឧត្តមសិក្សា (The European Association for Quality Assurance in Higher Education-ENQA) និងសេវាផ្លាស់ប្តូរការសិក្សាអាឡឺម៉ង់ (The German Acedemic Exchange Service/ Deutscher Akademischer Austauschdienst-DAAD) តាមរយៈកម្មវិធីជំនួយរបស់សហភាពអឺរ៉ុបចំពោះឧត្តមសិក្សាក្នុងតំបន់អាស៊ាន (Support to Higher Education in the ASEAN Region-SHARE)។[៥]

ភាពជាក់លាក់នៃគំរូធានាគុណភាព ដែលសមរម្យសម្រាប់បំពេញតម្រូវការប្រទេសអាស៊ាន និងធានានូវនិរន្តរភាព តាមរយៈជ្រុង៤ ដូចមានក្នុងរូបខាងក្រោម៖

រូបភាពទី៤ ៖ ជ្រុង៤ នៃការធានាគុណភាពអាស៊ាន




[៥] បណ្តាញធានាគុណភាពអាស៊ាន *គោលការណ៍ណែនាំសម្រាប់ការពិនិត្យឡើងវិញនៃទីភ្នាក់ងារធានាគុណភាពខាងក្រៅក្នុងតំបន់អាស៊ាន* ម៉ាឡេស៊ី ២០២១ ទំព័រ v។

## ២. កម្មវិធីគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា

ដោយមានភាពប្រកដប្រជាលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យ អាទិភាពដទៃទៀតរបស់រាជរដ្ឋាភិបាលក្នុងយុទ្ធសាស្ត្រ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដោយផ្អែកលើការរួមចំណែកអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខាងបច្ចេកទេស និងវិជ្ជាជីវៈ ឆ្លើយតបនឹងសេចក្តីត្រូវការទីផ្សារការងារ បង្កើតឱកាសការងារ បង្កើនលិតភាពការងារ និងលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ចេញនូវគោលនយោបាយ ពង្រឹង និងធានាគុណភាព អ.ប.វ. ដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំងអស់ដើម្បី លើកស្ទួយ និងពង្រឹងសមត្ថភាពធនធានមនុស្សឲ្យមានជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងតម្រូវការទីផ្សារការងារ មានគំនិតសហគ្រិនភាព គំនិតច្នៃប្រឌិត មានមនសិការការងារ ការទទួលខុសត្រូវ មានសុជីវធម៌ សីលធម៌ និងគុណធម៌។ ដូច្នេះហើយបានជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបំពាក់នូវប្រព័ន្ធធានាគុណភាពក្នុងគ្រឹះស្ថាន អ.ប.វ.ទាំងអស់ ដើម្បីផ្តល់នូវនីតិវិធី និងវិធីសាស្ត្រ នៃការវាយតម្លៃគុណភាពបណ្តុះបណ្តាល ក៏ដូចជាជួយសម្របសម្រួលដល់មន្ត្រីទទួលបន្ទុកផ្នែកធានាគុណភាព ក្នុងការចុះទៅវាយតម្លៃលើដំណើរការបណ្តុះបណ្តាលរបស់គ្រឹះស្ថាន TVET ប្រកបដោយប្រសិទ្ធភាព ដោយមានសេចក្តីណែនាំសម្រាប់ដំណើរការស្វ័យវាយតម្លៃគ្រឹះស្ថាន របស់ខ្លួន ដើម្បីលើកកម្ពស់គុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

ក្នុងដំណើរការធានាគុណភាពនៃការគ្រប់គ្រង និងការបណ្តុះបណ្តាល ក្នុងផ្នែកធានាគុណភាពគ្រឹះស្ថានមានស្តង់ដាចំនួន៦ ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃគុណភាពគ្រឹះស្ថាន TVET ទាំងមូល។ ស្តង់ដាទាំង៦ ត្រូវបានឯកភាព និងអនុម័តឱ្យប្រើដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាលកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តលក្ខណៈវិនិច្ឆ័យទាំង៦ នៃការធានាគុណភាពនេះ ដោយរដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ លេខ៥២៣ ក.ប/ប្រក នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ដែលជាយន្តការដ៏សំខាន់ និងអាទិភាពទី១ ក្នុងការគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ.។

រូបភាពទី៥ ៖លក្ខណៈវិនិច្ឆ័យនៃការធានាគុណភាពគ្រឹះស្ថាន អ.ប.វ.




**លក្ខណវិនិច្ឆ័យទី១៖ ការគ្រប់គ្រង និងអភិបាលកិច្ច**

-គុណភាពនៃការគ្រប់គ្រងនិងអភិបាលកិច្ច គឺទាក់ទងនឹងដំណើរការនៃយន្តការគោលនយោបាយ ដឹកនាំនិងការគ្រប់គ្រងគ្រប់កម្រិតទាំងអស់នៃគ្រឹះស្ថាន TVET នីមួយៗ

-ដូច្នេះគ្រឹះស្ថាន TVET ដែលផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈគួរតែមាន ផែនការយុទ្ធសាស្ត្រយ៉ាងហោចណាស់ពី ៣-៥ ឆ្នាំ ដោយមានបេសកកម្មនិងគោលដៅច្បាស់លាស់ គ្រប់គ្រាន់ ត្រឹមត្រូវនិងមានការគាំទ្រពីគ្រូ បុគ្គលិក មន្ត្រីរាជការ និងសហគមន៍។

**លក្ខណវិនិច្ឆ័យទី២៖ ធនធានរូបវន្ត**

-សម្ភារ បរិក្ខារ និងឧបករណ៍សម្រាប់បណ្តុះបណ្តាលគួរតែមានបរិមាណគ្រប់គ្រាន់ និងមាន គុណភាព ដើម្បីឆ្លើយតបនឹងទិសដៅនិងតម្រូវការនៃកម្មវិធីបណ្តុះបណ្តាលព្រមទាំងផ្តោត លើបច្ចេកវិទ្យា បច្ចុប្បន្ន

-សម្ភារ បរិក្ខារ និងឧបករណ៍បណ្តុះបណ្តាលគួរមានស្តង់ដាធានាសុខភាព និងសុវត្ថិភាព។

**លក្ខណវិនិច្ឆ័យទី៣៖ បុគ្គលិក មន្ត្រីរាជការ និងគ្រូ**

-បុគ្គលិក មន្ត្រីរាជការ និងគ្រូត្រូវមានសមត្ថភាព និងគុណវុឌ្ឍិ សមស្របទៅតាមភារកិច្ចរបស់ បុគ្គលនីមួយៗ

-បុគ្គលិក មន្ត្រីរាជការ និងគ្រូ គួរតែបានចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជំនាញអាជីពបន្ត សម្រាប់ពង្រីកបន្ថែមនូវគុណភាពបណ្តុះបណ្តាល។

## លក្ខណវិនិច្ឆ័យទី៤៖ សិក្ខាកាម សិស្ស និងនិស្សិត

- គុណភាពសិក្ខាកាម សិស្ស និងនិស្សិត គឺពឹងផ្អែកមួយផ្នែកទៅលើគុណភាពក្នុងការជ្រើសរើសឱ្យចូលរៀន

- ដូចនេះត្រូវមានដំណើរការយ៉ាងល្អក្នុងការជ្រើសរើសសិក្ខាកាម សិស្ស និងនិស្សិត ដែលមានគុណភាពសម្រាប់ឱ្យចូលរៀនក្នុងវគ្គបណ្តុះបណ្តាល

## លក្ខណវិនិច្ឆ័យទី៥៖ កម្មវិធីសិក្សា ការបង្រៀន និងរៀន

- គ្រឹះស្ថាន TVET នីមួយៗត្រូវបានកំណត់បេសកកម្មច្បាស់លាស់ និងបានប្រើប្រាស់កម្មវិធីសិក្សាដែលមានខ្លឹមសារទាំងផ្នែករឹង និងទន់ ព្រមទាំងបានបញ្ជាក់ពីគោលដៅ និងលទ្ធផល នៃការសិក្សាតាមកម្រិតនីមួយៗ។

- មាតិកានៃកម្មវិធីបណ្តុះបណ្តាល គួរតែត្រូវបានវាយតម្លៃ និងកែលម្អឱ្យស្របតាមស្តង់ដា។ ទន្ទឹមនឹងនោះដើម្បីជានានូវភាពជោគជ័យត្រូវមានយុទ្ធសាស្ត្រ និងវិធីសាស្ត្របង្រៀននិងរៀន។

## លក្ខណវិនិច្ឆ័យទី៦៖ ស្រាវជ្រាវ និងអភិវឌ្ឍន៍

-បុគ្គលម្នាក់ៗដែលតំណាងឲ្យសហគមន៍ អង្គភាពអាជីវកម្ម សហគ្រាស សិក្ខាកាម សិស្ស និស្សិត និងឪពុកម្តាយសិស្សដើរតួនាទីសំខាន់ជាគណៈកម្មការផ្តល់ប្រឹក្សានៃការគ្រប់គ្រងគុណភាព ដើម្បីធ្វើការណែនាំ ដល់គ្រឹះស្ថាន TVET ស្តីពីគុណភាពនៃកម្មវិធី បណ្តុះបណ្តាលរបស់ខ្លួន។

-គ្រឹះស្ថាន TVET ប្រើប្រាស់ការផ្តល់យោបល់ និងការណែនាំពីគណៈកម្មការផ្តល់ប្រឹក្សា ដើម្បីធ្វើគម្រោងអភិវឌ្ឍន៍ ប្រតិបត្តិការ វាយតម្លៃ និងគាំទ្រនូវរាល់គំនិតផ្តួចផ្តើមក្នុងការធានាគុណភាពទាំងឡាយរបស់គ្រឹះស្ថាន TVET។ ម៉្យាងទៀតគ្រឹះស្ថាន TVET នីមួយៗត្រូវមានគម្រោងធ្វើវិបុលកម្ម និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ។

- គុណភាពសិក្ខាកាម សិស្ស និងនិស្សិត ដែលបញ្ចប់វគ្គបណ្តុះបណ្តាលគួរតែសម្រេចបានទៅតាមលទ្ធផលសិក្សាដែលបានរំពឹងទុក និងតម្រូវការរបស់អ្នកពាក់ព័ន្ធ ឬក៏ក្រុមប្រឹក្សាឧស្សាហកម្ម។

- សកម្មភាពនៃការស្រាវជ្រាវដែលបានអនុវត្តដោយបុគ្គលិកសិក្សា ឬសិក្ខាកាម សិស្សនិងនិស្សិតគួរតែឆ្លើយតបនឹងតម្រូវការរបស់អ្នកពាក់ព័ន្ធ។

តារាងទី៣៖ សេចក្តីសង្ខេបលក្ខណៈវិនិច្ឆ័យនៃការធានាគុណភាពគ្រឹះស្ថាន

| ល.រ | លក្ខណៈវិនិច្ឆ័យ | អនុលក្ខណៈវិនិច្ឆ័យ |
|---|---|---|
| ១ | ការគ្រប់គ្រង និងអភិបាលកិច្ច | ១.ទស្សនវិស័យ និងបេសកកម្ម<br>២.រចនាសម្ព័ន្ធ នីតិវិធីដឹកនាំ និងគ្រប់គ្រង<br>៣.ផែនការយុទ្ធសាស្ត្រ<br>៤.ផែនការប្រតិបត្តិ<br>៥.ការគ្រប់គ្រងហិរញ្ញវត្ថុ |

| | | |
|---|---|---|
| ២ | ធនធានរូបវន្ត | ១.អគារ ទំហំដី<br>២.បន្ទប់ពិសោធន៍ និង/ឬរោងជាង<br>៣.បន្ទប់សម្រាប់បណ្តុះបណ្តាល និងការិយាល័យ<br>៤.បរិក្ខារសម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាល<br>៥.ការថែទាំធនធាន<br>៦.គ្រឿងសង្ហារឹម និងឧបករណ៍បណ្តុះបណ្តាល<br>៧.ប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារ (OH&S)<br>៨.សុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ការប្រើប្រាស់អ៊ីនធ័រណែត<br>៩.បណ្ណាល័យ និងសម្ភារបណ្ណាល័យ |
| ៣ | បុគ្គលិក មន្ត្រីរាជការ និងគ្រូ | ១.ប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងគ្រូ<br>២.របាយការណ៍ស្តីពីការគ្រប់គ្រងធនធានមនុស្ស |
| | | ៣.ការគាំពារបុគ្គលិកមន្ត្រីរាជការ គ្រូ និងសមភាព<br>៤.ការអភិវឌ្ឍន៍បុគ្គលិក និងគ្រូ |
| ៤ | សិក្ខាកាម សិស្ស និងនិស្សិត | ១.ប្រព័ន្ធគ្រប់គ្រងសិក្ខាកាម សិស្ស និង និស្សិត<br>២.ដំណើរការនៃការប្តឹងតវ៉ារបស់សិក្ខាកាម សិស្ស និស្សិត និងដំណោះស្រាយ<br>៣.ការប្តឹងជំទាស់<br>៤.សមធម៌ យេនឌ័រ និងការគាំពារ |
| ៥ | កម្មវិធីសិក្សា ការបង្រៀន និងរៀន | ១.កម្មវិធីសិក្សា<br>២.ការបង្រៀន និងរៀន<br>៣.គុណវុឌ្ឍិមន្ត្រីវាយតម្លៃ<br>៤.ការប្រឡង ការធ្វើតេស្ត និងការវាយតម្លៃ |
| ៦ | ការស្រាវជ្រាវ និងអភិវឌ្ឍ | ១.សម្ព័ន្ធភាពជាមួយក្រុមហ៊ុន អង្គការ និងសហគមន៍<br>២.ការចុះសហគមន៍<br>៣.ការិយាល័យត្រួតពិនិត្យនិងវាយតម្លៃ |

| | | |
|---|---|---|
| | | ៤.ការអភិវឌ្ឍកម្មវិធី<br>៥.ការប្រឹក្សាយោបល់ សេវាកម្មនិងវិបុលកម្ម<br>៦.ប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយ |

## សន្និដ្ឋាន

ប្រធានបទ ″ការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ″ បានបង្ហាញអំពីប្រតិបត្តិការនៃការគ្រប់គ្រងគ្រឹះស្ថាន តាមរយៈសមាសធាតុ ដែលមានស្រាប់មកឆ្លុះបញ្ចាំងទៅនឹងបរិបទតំបន់ និងពិភពលោក ដែលការគ្រប់គ្រងគ្រឹះស្ថានមានកត្តាមួយចំនួនត្រូវបំពេញឱ្យគ្នាទៅវិញទៅមក។

ការសិក្សាបានរកឃើញនូវសសរស្តម្ភ និងជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍគ្រឹះស្ថានអ.ប.វ. ដែលជាជាតុចូលយ៉ាងសំខាន់ដែលបានបន្សល់ទុកពីការសិក្សារបស់ក្រុមហ៊ុន SBK ២០០៤-២០១៨។ ទន្ទឹមនឹងនេះ ការធានាគុណភាពគ្រឹះស្ថានជាយន្តការដែលមានស្រាប់ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងគ្រឹះស្ថាន អ.ប.វ. ពីឆ្នាំ២០១៧ មក ដែលជាយន្តការអាទិភាពមួយជួយឱ្យការគ្រប់គ្រងគ្រឹះស្ថានអាចផ្លាស់ប្តូរមុខមាត់ និងមាននិរន្តភាពរហូតមកដល់បច្ចុប្បន្ន ព្រមជាមួយនេះដើម្បីធានាសង្គតិភាពជាមួយអាស៊ាន ក៏ត្រូវយោងទៅដល់បណ្តាញធានាគុណភាពអាស៊ានទោះបីផ្តោតសំខាន់លើឧត្តមសិក្សា តែក៏ជាធាតុចូលក្នុងដំណើរការ នៃកំណែទម្រង់វិស័យអប់រំ និងបណ្តុះបណ្តាលក្នុងអាស៊ាន ដែលក្របខ័ណ្ឌធានាគុណភាពអាស៊ានតាមរយៈជ្រុងទាំងបួន ជាគំរូក្នុងបណ្តាប្រទេសអាស៊ាន។ ជ្រុងទាំង៤ បានបំពេញឱ្យគ្នាទៅវិញទៅមក រួមមាន៖ ទីភ្នាក់ងារធានាគុណភាពខាងក្រៅ ស្តង់ដា និងដំណើរការធានាគុណភាពខាងក្រៅ ការធានាគុណភាពផ្ទៃក្នុងគ្រឹះស្ថាន និងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ដែលបានកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យអប់រំ និងបណ្តុះបណ្តាល និងបានរៀបចំឱ្យមាននៅក្នុងប្រព័ន្ធរួចរាល់។

ការសិក្សាអាចរៀបចំជាសមាសធាតុអាទិភាព និងជាយុទ្ធសាស្ត្រទាមសភាពការណ៍ មានស្តង់ដាដែលត្រូវផ្តោតលើការគ្រប់គ្រងគ្រឹះស្ថានដើម្បីឱ្យការប្រតិបត្តិការងារជាប្រចាំក្នុងគ្រឹះស្ថានមានប្រសិទ្ធភាព និងចូលរួមក្នុងដំណើរការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ស្របនឹងគោលដៅរបស់រាជរដ្ឋាភិបាលជាពិសេស អាស៊ាន និងនិន្នាការពិភពលោក។

តាមរយៈការសិក្សានេះ សង្កេតឃើញមានបញ្ហាប្រឈមស្របនឹងអនុសាសន៍ ដូចខាងក្រោម៖

១.រៀបចំប្រព័ន្ធគ្រប់គ្រងគ្រឹះស្ថានឱ្យមានស្តង់ដាតែមួយ ធានាបាននូវគុណភាពទូទាំងប្រទេសសម្រាប់ក្រសួងស្ថាប័ន ដែលផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំងអស់

២.ជំរុញការបន្សីកម្មវិធីសិក្សាជាមួយវិស័យឯកជន និងមានកិច្ចសហការល្អជាមួយនិយោជក

៣.បើកច្រកសិក្សាឱ្យបានទូលាយ និងការទទួលស្គាល់កម្មវិធី អ.ប.វ. ឆ្លងប្រព័ន្ធឱ្យមានលក្ខណៈបត់បែន ជាពិសេសគួរធ្វើសមាហរណកម្មរវាងការអប់រំ និងបណ្តុះបណ្តាល

៤.គួរមានយន្តការជ្រើសរើស និងបណ្តុះបណ្តាលគ្រូពិសេស អ្នកដែលរៀនពូកែមកបណ្តុះបណ្តាល និងរក្សាក្នុងអាជីពជាគ្រូបច្ចេកទេស

៥.បង្កើនថវិកា និងការវិនិយោគលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៦.កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងធនធានមនុស្សក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីផ្លាស់ប្តូទស្សនអវិជ្ជមានមកលើការរៀនជំនាញ

៧.ចំនួនសិក្ខាកាម សិស្ស និស្សិតចូលរៀនជំនាញក្នុងវិស័យ អ.ប.វ. នៅមានចំនួនតិចតួចនៅឡើយដែលមិនទាន់ឆ្លើយតបទៅនឹងកំនើនយ៉ាងលឿន នៃទីផ្សារការងារ ជាពិសេសតម្រូវការជំនាញតាមកម្រិត

៨.កម្មវិធី និងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅមិនទាន់អាចទុកចិត្តបានពីទីផ្សារ និងតម្រូវការបណ្តុះបណ្តាលជំនាញ

៩.គ្រឹះស្ថានធំៗ និងល្អៗប្រមូលផ្តុំនៅតែរាជធានីភ្នំពេញ និងទីរួមខេត្តខណៈក្រុមគោលដៅស្ថិតនៅឆ្ងាយ និងក្រីក្រ

១០.លើកទឹកចិត្តដល់គ្រឹះស្ថានដែលផ្តល់ការបណ្តុះបណ្តាលជំនាញទាំងសាធារណៈ ឯកជនអង្គការ និងសមាគម។

# គន្ថនិទ្ទេស


ក- ភាសាខ្មែរ (Khmer)

១-ក្រសួងអប់រំ យុវជន និងកីឡា៖ *សេចក្តីណែនាំលម្អិតស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត* ភ្នំពេញ ឆ្នាំ២០១២

២-រាជរដ្ឋាភិបាលកម្ពុជា៖ *អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ* លេខ២៨៣ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥

៣-រាជរដ្ឋាភិបាលកម្ពុជា៖ *យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដំណាក់កាលទី៤ នីតិកាលទី៦* ភ្នំពេញ ឆ្នាំ២០១៨

៤-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ *កម្រងសម្រង់ព័ត៌មានពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ* ភ្នំពេញ ត្រីមាសទី៣ ឆ្នាំ២០២១

៥-Kath Marnance៖ *របាយការណ៍បញ្ចប់"ទិសដៅគោលនយោបាយ និងការផ្តល់ហិរញ្ញប្បទាន សម្រាប់វិស័យTVET ក្នុងកម្ពុជា:ផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៤-២០១៨"* ភ្នំពេញ ទំព័រ១២ ឆ្នាំ២០១៣

៦-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ *សៀវភៅព័ត៌មានទូទៅរបស់គ្រឹះស្ថានអ.ប.វ. សាធារណៈ* ភ្នំពេញ ឆ្នាំ២០១៧, ២០១៩, ២០២១, ២០២២

៧-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ *សៀវភៅណែនាំស្តីពីការធានាគុណភាពវិស័យ អ.ប.វ.* ភ្នំពេញ ឆ្នាំ២០១៧

៨-រាជរដ្ឋាភិបាលកម្ពុជា៖ *ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា* ភ្នំពេញ ឆ្នាំ២០១៤

ខ- ឯកសារជាភាសាអង់គ្លេស (English)

៩-International journal for research in vocational education and training: ***Implementing the European quality assurance in vocational education and training (EQAVET) at national level,*** the PEN Leonardo project Gatt, Suzanne; Faurschou, Kim 2016

១០-Competency-Based TVET in Cambodia: ***Promise and Reality***, CDRI, 2020

១១-Europe's Universities: ***Shaping the Future EUA Strategic Plan,*** 1211 Geneva 3, Switzerland, June 2020

១២-AQAN: ***ASEAN Quality Assurance Framework*** *(AQAF),* Malaysia, 2021

១៣-ITCILO, ***Hybrid Distance Learning***, TURIN (Italy) 5-9 October, 2022

គ-អត្ថបទដកស្រង់ចេញពីអ៊ិនធឺណិត

១៤-https://www.cedefop.europa.eu

๑๕-https://tvetjournal.com/tvet-tools/tvet-digital-education

๑๖-https://www.giz.de/akademie/en/html/60702.html

๑๗-https://camudigitalcampus.com/guide/university-management-system

๑๘-https://www.tutorialspoint.com/management_principles/

๑๙-https://unevoc.unesco.org/home/TVETipedia+Glossary/show=term/term

๒๐-https://www. aqan.org

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ គ្រឹះស្ថានអ.ប.វ សាធារណៈ និងអាសយដ្ឋាន

| ទីតាំង | គ្រឹះស្ថាន អ.ប.វ. |
|---|---|
| ១.រាជធានីភ្នំពេញ | |
| ១.១ | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា(NPIC)<br>អាសយដ្ឋាន៖ ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>០៨៩ ៣៣៩ ៩៩៣ |
| ១.២ | វិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេស(NTTI)<br>អាសយដ្ឋាន៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>០១២ ៩៥៧ ៦៨៤/០១១ ៦៦៦ ២២៦ |
| ១.៣ | វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ(PPI)<br>អាសយដ្ឋាន៖ មហាវិថីសហពន្ធ័រុស្ស៊ី ភូមិចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>០១២ ៧៦៦ ៤៨៨/០១៦ ៥២៨ ៨០០ |
| ១.៤ | វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ (NIB)<br>អាសយដ្ឋាន៖ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>០៦៩ ៦០៦ ៥៧២/០១២ ៨៥៣ ០៣០ |
| ១.៥ | វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ (NIEI)<br>អាសយដ្ឋាន៖ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ០១១ ២៩៨ ៤៥៦/០១០ ៣៤៩ ៦៦៦ |
| ១.៦ | វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ITI)<br>អាសយដ្ឋាន៖ មហាវិថីសហពន្ធ័រុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>០៩៩ ៤៤៤ ៣៣០/០១០ ៩០១ ១៧៧ |
| ១.៧ | វិទ្យាស្ថានអភិវឌ្ឍន៍មុខមុខជំនាញកម្ពុជា-ថៃ(CTSDI)<br>អាសយដ្ឋាន៖ ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>០៩២ ៨២៧ ០៨៨/០១៦ ៧៤៩ ០៧០ |

| | |
|---|---|
| ១.៨ | វិទ្យាស្ថានបច្ចេកទេស ហ្ស៊ី វ៉េ សេ (JTI)<br>អាសយដ្ឋាន៖ ភូមិដើមគរ ផ្លូវជាតិលេខ៦អា សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ០១២ ៤៩៩ ៩៥៩/០៩៥ ៨០៦ ១៧៤ |
| ២.ខេត្តសៀមរាប | |
| ២.១ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប (RPITSSR)<br>អាសយដ្ឋាន៖ ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប<br>០១២ ៩១៨ ១៦៧/០៨៦ ៩២៤ ៤៥៨ |
| ២.២ | វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ (NPIA)<br>អាសយដ្ឋាន៖ ភូមិព្រៃគុយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប<br>០១៧ ៦៧៤ ៤៤៦/០៩៣ ៤៩៩ ៧៧៧ |
| ៣.ខេត្តស្វាយរៀង | |
| ៣.១ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង (RPITSSR)<br>អាសយដ្ឋាន៖ ភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង<br>០១២ ២៦៧ ៦៧៩/០៨៨ ៩៥៣២ ៣៣៣ |
| ៤.ខេត្តព្រះសីហនុ | |
| ៤.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ (PIP)<br>អាសយដ្ឋាន៖ ភូមិ២ សង្កាត់ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ<br>០៩២ ៨៨៤ ៨២៨/០១៥ ៨៨៤ ៨២៨ |
| ៤.២ | វិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា ចិនខេត្តព្រះសីហនុ(PCCFPI)<br>អាសយដ្ឋាន៖ ភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ<br>០១២ ២៦១ ២៤២/០១៦ ៦៣៣ ៣៦៧ |
| ៥.ខេត្តបាត់ដំបង | |
| ៥.១ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង (RPITSB)<br>អាសយដ្ឋាន៖ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង<br>០១៧ ៤៨០ ៧៦២/០៨៦ ៨៧៩ ២៩២ |

| | |
|---|---|
| ៥.២ | វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង(BIT)<br>អាសយដ្ឋាន៖ ភូមិរំចេក៤ សង្កាត់រតនៈក្រុងបាត់ដំបង ខេត្តបាត់ដំបង<br>០១២ ២៩០ ០៨៦/០១៦ ៥២២ ២០៦ |
| ៥.៣ | វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង(NVIB)<br>អាសយដ្ឋាន៖ ភូមិអណ្តូងព្រីង ឃុំអូម៉ាល់ ស្រុកអូម៉ាល់ ខេត្តបាត់ដំបង<br>០៦៩ ៥៨៥ ៨៥៥/០៨៦ ៨៧១ ៣៧២ |
| ៦.ខេត្តបន្ទាយមានជ័យ | |
| ៦.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ(PIBMC)<br>អាសយដ្ឋាន៖ ភូមិគាប សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ<br>០៧៧ ៩៦៩ ៨៥៨/០១៧ ៧៥០ ៥០៥ |
| ៧.ខេត្តកោះកុង | |
| ៧.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង(PIKK)<br>អាសយដ្ឋាន៖ ភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង<br>០៨១ ២៥១ ៦៦៦/០៩៧ ៨៣៨ ៨៨៦៥ |
| ៨.ខេត្តពោធិ៍សាត់ | |
| ៨.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់(PIPP)<br>អាសយដ្ឋាន៖ ភូមិចំការចេកខាងត្បូង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់<br>០១២ ៣៣២ ៨៧៦/០១១ ៩៩៥ ០៣៦ |
| ៩.ខេត្តកំពត | |
| ៩.១ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត (RPITSK)<br>អាសយដ្ឋាន៖ ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត<br>០១២ ២៨៩ ៩៩២/០៩៣ ៥៣៦ ៤៦៤ |
| ១០.ខេត្តតាកែវ | |
| ១០.១ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ (RPITST)<br>អាសយដ្ឋាន៖ ភូមិ៣ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ<br>០១៦ ៧៣៣ ៣០៤/០១២ ៩៥៦ ០១២ |
| ១១.ខេត្តកណ្ដាល | |

| | |
|---|---|
| ១១.១ | វិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន (NPIT)<br>អាសយដ្ឋាន៖ ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល<br>០១០ ៣៣៧ ១៦៦/០៩២ ៧៣៥ ២៦៣ |
| ១២.ខេត្តកំពង់ស្ពឺ | |
| ១២.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ស្ពឺ(PIKS)<br>អាសយដ្ឋាន៖ ភូមិទំពូង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ<br>០១២ ៩៩៥ ៩៥២/០៨១ ៩៩៥ ៩៥២ |
| ១៣.ខេត្តកំពង់ចាម | |
| ១៣.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម(PIKP)<br>អាសយដ្ឋាន៖ ផ្លូវជាតិលេខ៧ចាស់ ភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម<br>ខេត្តកំពង់ចាម ០១៧ ៩១៤ ៥៤៧/០៩៧ ៣៨២ ៨២៦១ |
| ១៤.ខេត្តកំពង់ឆ្នាំង | |
| ១៤.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ឆ្នាំង (PIKCHH)<br>អាសយដ្ឋាន៖ ភូមិទួលក្រឡាញ់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង<br>០១២ ៤២៦ ០៣៣/០១២ ៤៧៤ ៣៤១ |
| ១៥.ខេត្តព្រៃវែង | |
| ១៥.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រៃវែង(PIPV)<br>អាសយដ្ឋាន៖ ភូមិលេខ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង<br>០១២ ៧៧២ ០៣៧/០៩៦ ៧៥៧ ៧៧១៤ |
| ១៦.ខេត្តកំពង់ធំ | |
| ១៦.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ(PIKT)<br>អាសយដ្ឋាន៖ ភូមិអាចារ្យលាក់ សង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ<br>០១៦ ៦៤៦ ១៨៨/០១០ ៦៤៦ ១៨៨ |
| ១៧.ខេត្តក្រចេះ | |
| ១៧.១ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនឭសាន(RPITSE)<br>អាសយដ្ឋាន៖ ភូមិអូរឬស្សី២ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ<br>០៩៧ ៧៦៧ ៤០០១/០៩៧ ៧៨៧ ០០០៩ |

| ១៨.ខេត្តព្រះវិហារ | |
|---|---|
| ១៨.១ | វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះវិហារ(PIPVH)<br>អាសយដ្ឋាន៖ ផ្លូវលេខ ៦A ភូមិជំណាក់ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ០១២ ៩៨១ ២៧៥/០៩៦ ៥៧៧ ៥៤៦៧ |
| ១៨.២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ-យ៉ាឡាយ(VTC PHV-YALAY)<br>អាសយដ្ឋាន៖ ភូមិធម្មជាតិសម្តេចតេជោហ៊ុនសែន ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ០៦៨ ២៣៣ ៣០៣ |
| ១៩.ខេត្តកែប | |
| ១៩.១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកែប (KPTC)<br>អាសយដ្ឋាន៖ ភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប<br>០៩២ ៦៩៣ ២៦៩/០៩៧ ៩០០ ១៩៦៣ |
| ២០.ខេត្តត្បូងឃ្មុំ | |
| ២០.១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ (PTCTK)<br>អាសយដ្ឋាន៖ ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ<br>០១២ ៦៧៥ ៦២៨/០៧០ ២៦៩ ២៩២ |
| ២១.ខេត្តឧត្តរមានជ័យ | |
| ២១.១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឧត្តរមានជ័យ (OMCPTC)<br>អាសយដ្ឋាន៖ ភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ<br>០១៧ ៥១៤ ៧១៤/០៩២ ៦២៨ ៨២៨ |
| ២២.ខេត្តប៉ៃលិន | |
| ២២.១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន (PLPTC)<br>អាសយដ្ឋាន៖ ភូមិអូរតាពុកក្រោម សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន<br>០៩៧ ៥៥៥ ៦៦២៧/០១៦ ២៥៥ ៨៥៣ |
| ២៣.ខេត្តស្ទឹងត្រែង | |
| ២៣.១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង (PTCST)<br>អាសយដ្ឋាន៖ ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង<br>០៩៧ ៨៨៨ ៦៦៦២/០៨៨ ៥៨៥ ៥៦៥៦ |

| ២៤.ខេត្តមណ្ឌលគិរី | |
|---|---|
| ២៤.១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី (MKPTC)<br>អាសយដ្ឋាន៖ ភូមិជ្រៃសែន សង្កាត់មនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី<br>០១២ ៣១៣ ៣៦២/០១១ ៩៨០ ៨១៨ |
| ២៥.ខេត្តរតនគិរី | |
| ២៥.១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី (PTCRK)<br>អាសយដ្ឋាន៖ ភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី<br>០១២ ៥៥២ ២៨២/០១២ ៣៨៧ ៦៦៤/០៨៩ ៨៤២ ៧៣៥ |

ចំណាំ៖ គ្រឹះស្ថានទាំងអស់មាន៣៧ សម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះវិហារ-យ៉ាឡាយត្រូវបានបញ្ចូលជាមួយវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះវិហារ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី ត្រូវបានបញ្ចូលជាមួយវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនឫស្សីសាន តែពុំទាន់បានអនុវត្តពេញលេញ។

ឧបសម្ព័ន្ធ២៖ លក្ខខណ្ឌចូលរៀនស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

| កម្រិត | សញ្ញាបត្រ | លក្ខខណ្ឌចូលរៀន | ចំនួនក្រេឌីត |
|---|---|---|---|
| ៨ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសឬសញ្ញាបត្រសមមូល | ៥៤ |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ ឯកទេស | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ ឬសញ្ញាបត្រសមមូល | ៤៥ |
| ៦ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល | ១២០ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ឬជាប់ឬធ្លាក់សញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិឬសញ្ញាបត្រសមមូល | ៦០ |
| ៤ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ | ៣០ |

| | | | |
|---|---|---|---|
| ៣ | សញ្ញាបត្របច្ចេកទេស និង វិជ្ជាជីវៈ២ | សញ្ញាបត្របច្ចេកទេស និង វិជ្ជាជីវៈ១ | ៣០ |
| ២ | សញ្ញាបត្របច្ចេកទេស និង វិជ្ជាជីវៈ១ | សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬលិខិតបញ្ជាក់បានបញ្ចប់ថ្នាក់ទី៩ ឬវិញ្ញាបនបត្រស្ពានចម្លងបន្តជំនាញ ឬកម្រិតសមមូល | ៣០ |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | សិស្សបោះបង់ការសិក្សា អ្នកក្រីក្រ ស្ត្រី ជនជាតិភាគតិច ជនពិការ តំបន់ដាច់ស្រយាល និងជនងាយរងគ្រោះ | ៣០ |

**ឧបសម្ព័ន្ធ៣៖ រចនាសម្ព័ន្ធអភិបាលកិច្ចនៃវិស័យ អ.ប.វ. នៅកម្ពុជា**



# ការលើកទឹកចិត្ត និងការដាក់វិន័យនៃការគ្រប់គ្រង
# ធនធានមនុស្សក្នុងក្រសួងអប់រំ យុវជន និងកីឡា


បេក្ខជនបណ្ឌិតៈ **ទ្រី ចាន់**

ជំនាញៈ **រដ្ឋបាលសាធារណៈ**


## ១. ការលើកទឹកចិត្ត

រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡាបានលើកទឹកចិត្តទៅដល់បុគ្គលិកដែលបម្រើការងារនៅក្នុងវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា ការលើកចិត្តដល់បុគ្គលិកដែលខិតខំបំពេញការងារ គឺជាកត្តាដែលជំរុញការងារគ្រប់គ្រងធនធានមនុស្សកាន់តែល្អប្រសើរឡើង និងធ្វើឱ្យបុគ្គលិកមានកាន់តែមានឆន្ទៈមុះមុត នៅក្នុងការមកបំពេញការងារប្រកបដោយទំនួលខុសត្រូវខ្ពស់ធ្វើឱ្យអង្គភាពកាន់តែរីកចម្រើន។

**ក.ឋានន្តរស័ក្តិៈ** នៅមុនឆ្នាំ២០១៤ ឋានន្តរស័ក្តិមន្ត្រីរាជការមាន ៤ប្រភេទឋានន្តរស័ក្តិក្នុងក្របខ័ណ្ឌប្រភេទ **ក** ឋានន្តរស័ក្តិក្នុងក្របខ័ណ្ឌប្រភេទ **ខ** ឋានន្តរស័ក្តិក្នុងក្របខណ្ឌប្រភេទ **គ** និងឋានន្តរស័ក្តិក្នុងក្របខ័ណ្ឌប្រភេទ **ឃ**។ ប្រភេទនីមួយៗមានបីឋានន្តរស័ក្តិ គឺឋានន្តរសក្តិទី១មាន៦ថ្នាក់ ឋានន្តរស័ក្តិទី២មាន១០ថ្នាក់ ឋានន្តរស័ក្តិទី៣មាន១៤ថ្នាក់។ យើងឃើញថាមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាបម្រើការរហូតទៅដល់ចូលនិវត្តន៍ក៏មិនអាចឆ្លងផុតឋានន្តរស័ក្តិថ្នាក់ទី៣ផុតឡើយ។ ហេតុដូច្នេះហើយ រាជរដ្ឋាភិបាល ក៏ដូចជា ក្រសួងអប់រំ យុវជន និងកីឡាខិតខំប្រឹងប្រែងលើកចិត្តមន្ត្រីរាជការឈានសម្រេចទៅដល់ឋានន្តរស័ក្តិថ្នាក់ទី១មុនពេលដែលពួកគេចូលនិវត្តន៍។ នៅឆ្នាំ២០១៤ ប្រព័ន្ធមុខងារសាធារណៈនេះ ត្រូវបានកែសម្រួលឋានន្តរស័ក្តិក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលដែលមាន ៤ប្រភេទមកត្រឹម ៣ ប្រភេទវិញ គឺឋានន្តរស័ក្តិក្របខ័ណ្ឌ ក ខ និង គ តាមរយៈព្រះរាជក្រឹត្យលេខនស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃមុខងារសាធារណៈរបស់រដ្ឋ។ ហើយឋានន្តរស័ក្តិក្របខ័ណ្ឌ ក និង ខ មានបីថ្នាក់ គឺឋានន្តរស័ក្តិទី១មាន៦ថ្នាក់ ឋានន្តរស័ក្តិទី២មាន៤ថ្នាក់ និងឋានន្តរស័ក្តិទី៣មាន៤ថ្នាក់ ចំណែកឋានន្តរស័ក្តិ គ មាន១០ថ្នាក់ មន្ត្រីរាជការម្នាក់ៗនឹងត្រូវឡើងឋានន្តរស័ក្តិជារៀងរាល់២ឆ្នាំម្តងតាមការវាយតម្លៃផ្ទៃក្នុងរបស់អង្គភាព។ អ្នកគ្រប់គ្រងមន្ត្រីរាជការនៅក្រសួងអប់រំ យុវជន និងកីឡាត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំឯកសារពាក់ព័ន្ធការគ្រប់គ្រងមន្ត្រីរាជការដើម្បីពិនិត្យ និងវាយតម្លៃសម្រាប់ការឡើងថ្នាក់ឱ្យបានទាន់ពេលវេលា ជាប្រយោជន៍សម្រាប់លើកទឹកចិត្តដល់មន្ត្រីរាជការ ក៏ដូចជា ប្រសិទ្ធភាពការងារនៅក្នុងអង្គភាពផ្ទាល់ផង។

**ខ.សន្ទស្សន៍បៀវត្សៈ** បើយើងពិនិត្យមើលសន្ទស្សន៍បៀវត្សមន្ត្រីរាជការចាប់គិតពីឆ្នាំ ២០១៤ តម្លៃឯកតានៃសន្ទស្សន៍មានចំនួន៣៤៥រៀលក្នុងមួយសន្ទស្សន៍ និងបានឡើងដល់៨៧០រៀល ក្នុងមួយសន្ទស្សន៍ក្នុងឆ្នាំ២០១០តាមអនុក្រឹត្យលេខ២០៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សបៀវត្សមូលដ្ឋាន និងការបង្កើនប្រាក់បៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ។

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានត្រូវបានផ្លាស់ប្តូរជារៀងរាល់ឆ្នាំ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលជូនមន្ត្រីរាជការតាមអត្រាកំណើនសេដ្ឋកិច្ច។ ដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការនៅឆ្នាំ២០១៥ រាជរដ្ឋាបាភិបាល បានកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលពីចំនួន ៨៧០ ទៅ ១៥២០រៀល[១]។ នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានកែប្រែសន្ទស្សន៍បៀវត្សមន្ត្រីរាជការពី ១៥២០ រៀលទៅ ១៧០០រៀល នៅឆ្នាំ២០១៧ សន្ទស្សន៍បៀវត្សឡើងពី ១៧០០ទៅ ១៩០០រៀល និងនៅឆ្នាំ២០១៨ បានឡើងពី ១៩០០ ទៅ ២១៣០រៀលក្នុងមួយសន្ទស្សន៍។ យើងឃើញថាឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៨ សន្ទស្សន៍បៀវត្សមន្ត្រីរាជការដែលបម្រើការងារនៅក្នុងក្រសួងអប់រំបានកើនជាជាលំដាប់ នេះឆ្លុះបញ្ចាំងឱ្យឃើញថារាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់នៅក្នុងការលើកទឹកចិត្តដល់មន្ត្រី ដើម្បីជំរុញឱ្យការដឹកនាំ និងគ្រប់គ្រងធនធានមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព។

**គ.ប្រាក់បំណាច់មុខងារៈ** ប្រាក់បំណាច់មុខងារត្រូវបានផ្តល់បន្ថែមពីលើប្រាកបៀវត្សមូលដ្ឋានជូនដល់មន្ត្រីរាជការទៅតាមតួនាទី មុខតំណែង បទពិសោធន៍ការងារ និងប្រសិទ្ធភាពការងារ។ ប្រាក់បំណាច់មុខងារបែងចែកចេញជាបីប្រភេទ គឺវិស័យអប់រំ វិស័យសុខាភិបាល និងវិស័យរដ្ឋបាល ។ ប្រាក់បំណាច់មុខងាររបស់មន្ត្រីដែលបំពេញការងារនៅក្នុងក្រសួងអប់រំ យុវជន និងកីឡាបានកើនឡើងជាបន្តបន្ទាប់ចាប់តាំងឆ្នាំ២០១៤ អនុក្រឹត្យលេខ២៤៤អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញាឆ្នាំ២០១៤ ស្តីពីប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលនៃក្រសួងអប់រំ យុវជន និងកីឡា អនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែប្រែនិងការតម្លើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល។ អនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៤ នៃអនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃទី០៨ មីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល។ អនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៨ ស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល។

**ឃ.ប្រាក់បេសកកម្មៈ** មន្ត្រីរាជការស៊ីវិលដែលបំពេញបេសកកម្មនៅក្នុងនិងក្រៅប្រទេសទទួលបានប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ។ ប្រាក់របបបេសកកម្មត្រូវបានផ្តល់ជូនមន្ត្រីរាជការទៅតាមមុខតំណែង និងទីតាំងជាគោលដៅនៃបេសកកម្ម។ អត្រានៃប្រាក់នេះត្រូវបានកំណត់តាមរយៈតារាងផ្សេងពីគ្នា។ ប្រាក់របបបេសកកម្មរួមមានប្រាក់ហោប៉ៅ ប្រាក់សម្រាប់ការហូបចុក និងការស្នាក់នៅ។ អត្រានៃប្រាក់របបបេសកកម្មខុសគ្នា ទៅតាមចម្ងាយនៃទីតាំងជាគោលដៅនៃបេសកកម្ម។ ប្រាក់របបពិសេសត្រូវបានផ្តល់ជូនមន្ត្រីជាន់ខ្ពស់មានឋានៈចាប់ពីថ្នាក់អគ្គលេខាធិការ អគ្គនាយក ឬមន្ត្រីថ្នាក់ស្មើមុខតំណែងនេះឡើងទៅ។ លើសពីនេះ របបបេសកកម្មដោយឡែកត្រូវបានផ្តល់ជូនមន្ត្រីរាជការ ដែលចូលរួមកិច្ច ប្រជុំថ្នាក់អន្តរជាតិស្ថិតនៅរាជធានី ខេត្តនៅក្រៅពីកន្លែងដែលខ្លួនបំពេញការងារ។ ជាគោលការណ៍ប្រាក់របប

---

[១] រាជរដ្ឋាភិបាល *អនុក្រឹត្យស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល* ភ្នំពេញ ឆ្នាំ ២០១៥ ទំព័រ ១

បេសកកម្មកំណត់ខ្ពស់បំផុតត្រឹម ១០ថ្ងៃ។ ក្នុងករណីគ្មានមធ្យោបាយធ្វើដំណើររបស់រដ្ឋគឺ សោហ៊ុយធ្វើដំណើរនេះ ត្រូវបានដោះស្រាយជូនតាមវិក្កយបត្រជាក់ស្តែង។ ចំពោះប្រាក់បេសកកម្មនេះ រាជរដ្ឋាភិបាលបានលើកទឹកចិត្តដល់មន្ត្រីអប់រំ ដោយដំឡើងប្រាក់បេសកកម្មមួយគុណនឹង២ទៅតាមតួនាទីរបស់មន្ត្រីអប់រំម្នាក់ៗ។ យើងសូមលើកយកបេសកកម្មពីមុនមកបង្ហាញយើងឃើញថាប្រាក់របបពិសេសសម្រាប់មន្ត្រីជាន់ខ្ពស់មានឋានៈចាប់ពីអគ្គលេខាធិការ អគ្គនាយក ឬ មន្ត្រីថ្នាក់ស្មើនឹងមុខតំណែងខាងលើនេះឡើងទៅ សោហ៊ុយបេសកកម្មក្នុងរបបឧបត្ថម្ភក្នុងមួយនាក់/១ថ្ងៃ ឬយប់ សរុបចំនួន១២៦០០០រៀល ចំណែកមន្ត្រីជាន់ខ្ពស់មានឋានៈចាប់ពីអគ្គលេខាធិការរង អគ្គនាយករង ឬមន្ត្រីថ្នាក់ ស្មើមុខតំណែងនេះចុះក្រោម សោហ៊ុយបេសសកម្មក្នុងរបបឧបត្ថម្ភក្នុងមួយនាក់/១ថ្ងៃឬយប់ ថវិកាសរុបចំនួន ៦៣០០០០រៀល។ នៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព ភាពសក្តិសិទ្ធិ តម្លាភាព និងគណនេយ្យភាពនៃការបំពេញបេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេសរបស់ថ្នាក់ដឹកនាំមន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា[២]។ ប្រាក់បេសកកម្មនេះ ចែកចេញជា ៦កម្រិតថ្នាក់ ប្រភេទក១៖ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងប្រធានស្ថាប័ន ឬអង្គភាពដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ប្រភេទក២៖ រដ្ឋលេខាធិការ និងអនុប្រធានស្ថាប័ន ឬអង្គភាពដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ប្រភេទខ៖ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គនាយក ប្រតិភូរាជរដ្ឋាភិបាល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាសភាពក្រុមប្រឹក្សា រាជធានីខេត្ត និងមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ។ ប្រភេទគ៖ អគ្គលេខាធិការរង អគ្គនាយករង ប្រធាននាយកដ្ឋាន អភិបាលរងរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការសាធារណៈដែលមានឋានៈនិងបុព្វសិទ្ធិស្មើមុខតំណែងនេះ ប្រភេទឃ៖ អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ អភិបាលរងក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ប្រភេទង៖មន្ត្រីរាជការសាធារណៈនិងមន្ត្រីជាប់កិច្ចសន្យាទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ប្រាក់បេសកកម្មសម្រាប់មួយថ្ងៃ ឬមួយយប់សរុបសម្រាប់មុខតំណែងក១ សរុបចំនួន ៣៤០០០០រៀល មុខតំណែងក២ សរុបចំនួន ២៨៥០០០រៀល មុខតំណែងខ សរុបចំនួន ២៣០០០០រៀល មុខតំណែងគ សរុបចំនួន ១៩៤០០០ រៀល មុខតំណែង ឃ សរុបចំនួន ១៦០០០០រៀល មុខតំណែង ង សរុបចំនួន ១៣៦០០០រៀល។ យើងឃើញថាបេសកកម្មនេះ បានកំណត់ថវិកាតាមមុខតំណែងដែលស្របទៅនឹងយន្តការនៃការ

[២] រាជរដ្ឋាភិបាល អនុក្រឹត្យស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ភ្នំពេញ ឆ្នាំ ២០១៤ ទំព័រ ២

គ្រប់គ្រងធនធានមនុស្ស។ ក្រៅពីការលើកទឹកចិត្តខាងលើនេះ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការលើកទឹកចិត្តដល់មន្ត្រីរាជការជាច្រើនទៀត ដូចជា តាមការដំឡើងតួនាទីដល់មន្ត្រីដែលមានសមត្ថភាព និងសកម្ម ស្ត្រីឆ្លងទន្លេរបបសន្តិសុខសង្គម។

**ង.ប្រាក់វិភាជន៍គ្រួសារៈ** គឺជាប្រាក់ប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការជាមេគ្រួសារសម្រាប់ឧបត្ថម្ភប្រពន្ធកូន និងកូនចិញ្ចឹមស្របច្បាប់នៅក្នុងបន្ទុក។ ប្រាក់ឧបត្ថម្ភកូន និងកូនចិញ្ចឹមស្របច្បាប់អាចបន្តផ្តល់ជូនរហូតដល់អាយុ២១ឆ្នាំ។ ប្រាក់សម្រាប់ឧបត្ថម្ភប្រពន្ធមួយខែ១៥០០០រៀល ប្រាក់ឧបត្ថម្ភកូនម្នាក់ មួយខែ ១០០០០រៀល។

**ច.ប្រាក់គោលនយោបាយធានារ៉ាប់រងសង្គមៈ** មន្ត្រីរាជការស៊ីវិលត្រូវទទួលបាននូវគោលនយោបាយធានារ៉ាប់រងសង្គមពីរាជរដ្ឋាភិបាលដែលមាន ដូចជា ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ លំហែមាតុភាព ទទួលមរណៈភាព ការពិនិត្យសុខភាព និងព្យាបាលជំងឺ។ ប្រាក់សោធននិវត្តន៍ប្រចាំខែ ក្របខ័ណ្ឌ ក ទទួលបានប្រាក់ទាបបំផុត ៧៣៤៨៥០រៀលក្របខ័ណ្ឌ ខ ទទួលបានប្រាក់ទាបបំផុត ៦៣៩០០០រៀលនិងក្របខ័ណ្ឌគទទួលបានប្រាក់ទាបបំផុត៥៦៤៤៥០រៀល។ នៅពេលដែលនិវត្តជនទទួលមរណៈភាព គ្រួសារនៃសពត្រូវបានរដ្ឋផ្តល់ប្រាក់ឧបត្ថម្ភមួយលើកចំនួន១២ខែ លើប្រាក់សោធននិវត្តន៍សរុបប្រចាំខែរបស់សាមីជន ចំពោះសហព័ន្ធនៃសពត្រូវបានបន្តទទួលប្រាក់ប្រចាំខែរហូតដល់ពេលគាត់ស្លាប់ ឬមានគ្រួសារថ្មី ចំណែកកូនកំព្រានៃសពត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែរហូតដល់អាយុ២១ឆ្នាំ។ ការបាត់បង់សម្បទាវិជ្ជាជីវៈគឺជាការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ ហើយអនុវត្តចំពោះមន្ត្រីរាជការ ដែលពុំគ្រប់អាយុចូលនិវត្តន៍(៦០ឆ្នាំ) និងមានអតីតភាពការងារចាប់ពី២០ឆ្នាំ ទៅដល់ក្រោមអាយុ៣០ឆ្នាំ។ ការបាត់បង់សម្បទាវិជ្ជាជីវៈចែកជា២ប្រភេទ គឺ១.គ្រោះថ្នាក់ការងារ និងក្នុងពេលបេសកកម្ម និង២.គ្រោះថ្នាក់ ដោយជម្ងឺ ឬ គ្រោះថ្នាក់ផ្សេងៗសម្រាប់ក្របខ័ណ្ឌ ក ទទួលប្រាក់ឧបត្ថម្ភទាបបំផុត ៧៣៤៨៥០០រៀល សម្រាប់ក្របខ័ណ្ឌ ខ ទទួលប្រាក់ឧបត្ថម្ភទាបបំផុត ៦៣៩០០០រៀល សម្រាប់ក្របខ័ណ្ឌ គ ទទួលប្រាក់ឧបត្ថម្ភទាបបំផុត ៥៦៤៤៥០រៀល។ លំហែមាតុភាពពេលមន្ត្រីរាជការជាស្ត្រីសម្រាកលំហែមាតុភាព ៨០០០០០រៀល សម្រាប់ការសម្រាលបានកូនមួយ ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបង្កើន ទ្វេគុណ ឬត្រីគុណ ឬច្រើនជាងនេះ តាមចំនួនកូន ដែលបានសម្រាល។ អនុញ្ញាតច្បាប់ឱ្យឈប់សម្រាក ៣ ខែ ដោយទទួលបានប្រាក់បៀវត្ស១០០ ភាគរយ មានសិទ្ធិចេញពីកន្លែងធ្វើការ ០១ ម៉ោង មុនពេលកំណត់ក្នុង១ថ្ងៃ ចំពោះបុគ្គលិកអប់រំជាស្ត្រី ដែលមានកូនអាយុក្រោម១ឆ្នាំ ចំពោះបុគ្គលិកដែលមិនបង្រៀន។ ចំណែកប្រាក់ឧបត្ថម្ភទទួលមរណៈភាព មរណៈភាពពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារទទួលបានប្រាក់ឧបត្ថម្ភចំនួន៤០០០០០០រៀល ប្រាក់ឧបត្ថម្ភគត់ស្មើនឹងបៀវត្សមូលដ្ឋានចុងក្រោយគុណនឹង ០៨ ខែ និងប្រាក់ឧបត្ថម្ភស.ប.ស.ខ ចំពោះមន្ត្រីជាសមាជិកតាមគោលការណ៍របស់សមាគម។ មរណៈភាពដោយជំងឺធម្មតា និងគ្រោះថ្នាក់ផ្សេងៗទទួលបានប្រាក់ឧបត្ថម្ភ ២០០០០០០រៀល ប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្សមូលដ្ឋានចុងក្រោយគុណ ៦ខែ និងប្រាក់ឧបត្ថម្ភ ស.ប.ស.ខ ចំពោះមន្ត្រីជាសមាជិក

តាមគោលការណ៍របស់សមាគម។ មន្ត្រីរាជការគ្រប់រូបទទួលបានការពិនិត្យសុខភាព និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទាំងអស់ និងមន្ទីរពេទ្យឯកជន ដែលបានចុះកិច្ចសន្យាជាបេឡាជាតិរបបសន្តិសុខសង្គម(បសស) ដោយមិនបង់ប្រាក់។ ត្រូវភ្ជាប់ទៅជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ។ ការបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការ ០.៥ ភាគរយនៃបៀវត្សមូលដ្ឋានត្រូវរ៉ាប់រងបង់ជំនួសដោយរាជរដ្ឋាភិបាល[៣]។

**ឆ-ការអនុញ្ញាតច្បាប់ឈប់សម្រាកផ្សេងៗ៖** មន្ត្រីរាជការមានសិទ្ធិឈប់សម្រាកផ្សេងៗរួមមានច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ច្បាប់ឈប់សម្រាករយៈពេលខ្លី ច្បាប់ឈប់សម្រាកលំហែមាតុភាព ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ច្បាប់បន្តការសិក្សាក្នុងរយៈពេលវែង ច្បាប់ស្ថិតក្នុងទំនេរគ្មានប្រាក់បៀវត្ស ច្បាប់ឈប់សម្រាកពិសេស និងច្បាប់ស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

## ២. ការដាក់វិន័យ

ដើម្បីឱ្យការគ្រប់គ្រងធនធានមនុស្សមានប្រសិទ្ធភាពនិងប្រសិទ្ធផល ក្រសួងអប់រំ យុវជន និងកីឡាត្រូវតែមានការដាក់វិន័យសម្រាប់មន្ត្រីដែលប្រព្រឹត្តល្មើសទៅនឹងច្បាប់ និងមន្ត្រីអសកម្មដែលបង្កឱ្យអង្គភាពរាំងស្ទះ។ គ្រប់មន្ត្រីរាជការទាំងអស់មានកាតព្វកិច្ចគោរពច្បាប់ បទបញ្ជា និងសេចក្តីណែនាំនានារបស់ថ្នាក់ដឹកនាំខ្លួន និងមានការទទួលខុសត្រូវផ្ទាល់ចំពោះសកម្មភាពរបស់ខ្លួន។ ការរំលោភបំពានលើកាតព្វកិច្ចនឹងនាំឱ្យមន្ត្រីរាជការនោះទទួលរងទណ្ឌកម្មខាងវិន័យ។ យោងតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលមាត្រា ៣៥ មន្ត្រីរាជការស៊ីវិលត្រូវហាមដាច់ខាតនូវប្រការខាងក្រោម៖

- មិនគោរពអនុវត្តច្បាប់ បទបញ្ជា ការណែនាំពីថ្នាក់លើរបស់ខ្លួន
- មិនទទួលខុសត្រូវចំពោះកិច្ចការរបស់ខ្លួន និងធ្វើអំពើដែលធ្វើឱ្យប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់ខ្លួន
- មិនគោរពបទបញ្ជាថ្នាក់លើក្នុងការចាត់ឱ្យទៅបំរើការងារក្នុងតំបន់ណាក៏ដោយទាំងក្នុងនិងក្រៅប្រទេស
- ឈប់ធ្វើការដោយមិនបានទទួលការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន ឬ ដោយគ្មានមូលហេតុត្រឹមត្រូវ។ការឈប់ធ្វើការ ឬការខានទៅធ្វើការដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវអាចបង្ខំឱ្យអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស។
- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត
- យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬ ដើម្បីសម្លុតគំរាមកំហែង ចំពោះសិទ្ធិប្រជាពលរដ្ឋ

[៣] ក្រសួងអប់រំ យុវជន និងកីឡា **សៀវភៅណែនាំស្តីពីការទូទាត់និងផលប្រយោជន៍របស់មន្ត្រីរាជការ** ភ្នំពេញ ឆ្នាំ ២០១៨ ទំព័រ ១៣។

- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ
- ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬ គ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬ ដោយប្រយោល។
- បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ
- ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការក្នុងករណីដែលលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗហាមឃាត់
- ធ្វើការដើម្បីផលប្រយោជន៍ដល់បក្ខជននយោបាយ ឬប្រឆាំងទៅនឹងបក្ខជននយោបាយណាមួយ

ទណ្ឌកម្មខាងវិន័យមានពីរថ្នាក់ ទណ្ឌកម្មទីមួយ ស្តីបន្ទោស ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់។ ទណ្ឌកម្មទី២ ស្តីបន្ទោសជាទម្ងន់ បណ្តាលឱ្យលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ ប្រសិនចុះឈ្មោះហើយ ឬធ្វើយឺតក្នុងការឡើងឋានន្តរស័ក្តិ ឬ ថ្នាក់ក្នុងថេរវេលាមួយមានកំណត់តែមិនត្រូវឱ្យលើសពី២ឆ្នាំ ក្នុងការដំឡើងឋានន្តរស័ក្តិ ឬ ថ្នាក់តាមវេនជ្រើសរើស ឬតាមវេនអតីតភាពដាក់ឱ្យនៅទំនេរគ្មានបៀវត្សមិនឱ្យលើសពី១ឆ្នាំ ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ និងបណ្តេញចេញពីមុខតំណែងរាជការ។

ផ្អែកទៅលើវិន័យខាងលើនេះ ក្នុងរយៈពេល ៥ឆ្នាំនេះ បុគ្គលិកនៅក្នុងក្រសួងអប់រំ យុវជន និងកីឡាមួយចំនួនទទួលនូវទណ្ឌកម្មស្តីបន្ទោស ដើម្បីកែលម្អពួកគេឱ្យគោរពតាមច្បាប់ដែលបានចែង និងបំពេញការងារកុំឱ្យមានការធេចរហៃ្វង ដោយយកចិត្តទុកដាក់នៅក្នុងការបំពេញការងារប្រកបដោយទំនួលខុសត្រូវច្បាស់លាស់។ ចំណែកទណ្ឌកម្មទី២ មាន ៥ករណី ដែលបានអនុវត្តទៅលើមន្ត្រីអប់រំដែលធ្វើឱ្យមានកំហុសធ្ងន់មាន ៤ករណី ដកតួនាទី(នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នាយកមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានកិច្ចការប្រឡង) និងមួយករណីទៀតបញ្ឈប់ការងារដោយបង្ខំ(នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ)៕

# ប្រសិទ្ធភាពនៃការលូតលាស់របស់មាន់ដោយប្រើប្រាស់ ទងដំឡូងផ្លាលាយជាមួយចំណីសម្រេចដែលជាចំណីគ្រឹះ

បេក្ខជនបណ្ឌិតៈ **ហ៊ាន់ ហៀក**
ជំនាញៈ **វិទ្យាសាស្ត្រសត្វ**

## សង្ខេប

តម្លៃជីវជាតិរបស់ទងដំឡូងផ្លានៅក្នុងចំណីអាហាររបស់មាន់ត្រូវបានវិភាគ។ កូនមាន់ពូជក្នុងស្រុកចំនួន៥០០ក្បាល អាយុ ១ថ្ងៃបានទិញពីកសិករជាអ្នកភ្ញាស់ ហើយចិញ្ចឹមបន្សាំរយៈពេល ២១ថ្ងៃ ហើយបានចាប់ដោយចៃដន្យដាក់បញ្ចូលទៅក្នុងក្រុមរបបចំណីអាហារទាំង ៥ ដែលមាន ១០០ក្បាល ក្នុងមួយក្រុម និងបែងចែកទៅជាសារគឺ ២៥ក្បាលក្នុងមួយសារ។ រូបមន្តផ្សំចំណីសម្រាប់ការសិក្សានេះ បានរៀបចំ និងគណនាដើម្បីរក្សាកម្រិតប្រូតេអ៊ីនប្រមាណ ១៧% ដោយបែងចែកក្រុមត្រួតពិនិត្យ (T0) ក្រុម (T1) បន្ថែមទងដំឡូងផ្លាស្រស់ ១០% ក្រុម (T2) បន្ថែមទងដំឡូងផ្លាស្រស់ ២០% ក្រុម (T3) បន្ថែមទងដំឡូងផ្លាស្រស់ ៣០% និងក្រុម (T4) បន្ថែមម្សៅទងដំឡូងផ្លា ២០%។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា ក្រុម (T1) ដែលបន្ថែមទងដំឡូងផ្លាស្រស់ ១០% មានទម្ងន់ចុងបញ្ចប់ប្រហាក់ប្រហែលគ្នាជាមួយក្រុម T4 ដែលប្រើប្រាស់ម្សៅទងដំឡូងផ្លា ២០% តែមានខុសគ្នាបន្តិចបន្តួចជាមួយនឹងក្រុម T0 ដែលប្រើចំណីផ្សំសុទ្ធ។ ជាមួយគ្នានេះដែរ យើងឃើញថា ទម្ងន់ចុងបញ្ចប់នេះហាក់ដូចជាមានការថយចុះទៅតាមកម្រិតកើនឡើងនៃការប្រើប្រាស់ទងដំឡូងផ្លាស្រស់។ ដោយការស៊ីចូល និងសន្ទស្សន៍នៃការបំប្លែងចំណី (FCR) មិនមានលក្ខណៈខុសគ្នាគួរឱ្យកត់សម្គាល់ឡើយ។

## ១. សេចក្តីផ្តើម

អ្នកសិក្សាស្រាវជ្រាវបានព្យាយាមរិះរកគ្រប់មធ្យោបាយផ្សេងៗ ដើម្បីបង្កើននូវប្រសិទ្ធភាពក្នុងផលិតកម្មមាន់ឱ្យកាន់តែប្រសើរឡើង និងកាត់បន្ថយការចំណាយក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់នូវរូបធាតុដើមដែលមានស្រាប់នៅក្នុងស្រុកដែលមានតម្លៃថោក និងងាយរក មានទាំងអនុផលផលិតកម្មមួយចំនួនទៀតមកផ្សំជាចំណី។ អនុផល និងកាកសំណល់វាក៏ជាប្រភពផ្តល់នូវថាមពល ជីជាតិ ប្រូតេអ៊ីន ខនិជ និងវីតាមីន។ល។ ដំឡូងផ្លា គឺជាប្រភេទដំណាំម្យ៉ាងដែលដើមវាមានលក្ខណៈជាវល្លិ ដើមវារ ហើយគេអាចដាំវាដើម្បីយកមើម ហើយស្លឹកអាចយកធ្វើជាចំណីអាហារមនុស្ស និងសត្វ។ ដំឡូងផ្លានេះ ប្រជាជនពេញនិយមដាំនៅតំបន់ត្រូពិក និងនៅក្បែរតំបន់ត្រូពិក ហើយមើមរបស់វាមានពណ៌ស្វាយ ពណ៌ស និងពណ៌ក្រហម។ ម្យ៉ាងទៀត ទងដំឡូងផ្លាក៏អាចយកទៅទទួលទានបាន និងសម្បូរទៅដោយគុណតម្លៃសារជាតុចិញ្ចឹមខ្ពស់។ ដំណាំដំឡូងផ្លាមានសារប្រយោជន៍ណាស់ ព្រោះមើមអាចធ្វើជាបង្អែម ឬបន្លែដែលសារជាតុល្អៗដូចជា អាមីដុង ស្ករ ជាដើម ចំពោះមនុស្ស និងសត្វ ក្នុងករណីនេះ ទើបគេបង្វែរទិសដៅទៅរកអនុផលផលិតកម្មដែលសល់ពីតម្រូវការរបស់មនុស្សមកធ្វើជាចំណីសម្រាប់សត្វស៊ី

ក្នុងនោះ ទងដំឡូងផ្វាជាអនុផលដែលមាននៅក្នុងស្រុកដ៏សម្បូរបែប ជាពិសេស រដូវភ្លៀងធ្លាក់ឃើញថា ទងដំឡូងផ្វាមានប្រូតេអ៊ីន ២៨ភាគរយ រូបជាតុសោះទឹក ៨៨,៧៥ សែលុយឡូស ១៨,២៧ភាគរយ។ កម្រិតអាស៊ីតអាមីនេនៅក្នុងទងដំឡូងផ្វាក្រៀមគឺ ០,៩៥ បើធៀបនៅក្នុងទងដំឡូងផ្វាស្រស់។ ទងដំឡូងផ្វាមានផ្ទុកប្រូតេអ៊ីន ១៨,៥% រីឯស្លឹកវាមានផ្ទុកប្រូតេអ៊ីនពី ២៥,៦-៣២,៤% គិតជារូបជាតុសោះទឹក។

ដូច្នេះការប្រើប្រាស់ក្នុងកម្រិតសមស្របទាំងស្រស់ ឬក្រៀមអាចចូលរួមជំនួសនៅក្នុងសមាសធាតុចំណី ហើយអាចមិនប៉ះពាល់ដល់ការស៊ីចូល និងការលូតលាស់របស់មាន់។

គោលបំណងនៃការសិក្សា គឺដើម្បីតាមដានពីការលូតលាស់ ការស៊ីចូល និងប្រសិទ្ធភាពនៃការបំប្លែងចំណីតាមរយៈការប្រើប្រាស់កម្រិត និងប្រភេទកែច្នៃទងដំឡូងផ្វាដោយហាលស្ងួតកិនជាម្សៅ។

## ២. វិធីសាស្ត្រសិក្សាស្រាវជ្រាវ

### ២.១. ទីតាំង និងពេលវេលាពិសោធន៍

ការសិក្សាពិសោធន៍នេះ បានធ្វើឡើងនៅស្ថានីយពិសោធន៍សត្វរបស់មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ ការពិសោធចំណាយពេលចំនួន១០សប្តាហ៍សម្រាប់ពិនិត្យតាមដាន និងកត់ត្រាទិន្នន័យ ដោយចាប់ផ្តើមពីថ្ងៃទី១០ មករា ដល់ថ្ងៃទី១៤ មីនា ឆ្នាំ២០២២។

### ២.២ ទ្រុងពិសោធន៍

ទ្រុងសម្រាប់ពិសោធន៍បានបែងចែកជាប្លុកតូចៗចំនួន២០ប្លុក ដែលក្នុងមួយប្លុកមានទំហំ ១,២ម x ២,៨ម ហើយព័ទ្ធជុំវិញដោយសំណាញ់ដ៏ដែលមានកម្ពស់ ១ម ពីផ្ទៃនៃទ្រុងដែលមានក្រាលដោយកម្រាលអង្កាម។ នៅក្នុងសប្តាហ៍ទី១ កូនមាន់ក្នុងប្លុកនីមួយៗបានថែរក្សានៅក្នុងប្លុកដែលបានបែងចែកហើយ ដោយប្រើប្រាស់ប្រភេទនៃស្នូកទឹក និងស្នូកចំណី គឺប្រែប្រួលទៅតាមអាយុបក្សី។ ទ្រុងមានសារសំខាន់ណាស់សម្រាប់ការចិញ្ចឹមសត្វ ព្រោះវាមានតួនាទីក្នុងការការពារសុវត្ថិភាពរបស់សត្វដែលយើងអាចឱ្យសត្វគេចផុតពីជំងឺឆ្លង ឬការចម្លងជំងឺពីសត្វដទៃទៀតថែម ទាំងជួយការពារសត្វរបស់យើងពីគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ ការពារសត្វមិនឱ្យដើរបានឆ្ងាយ ការពារ កម្តៅ ភ្លៀង ខ្យល់ដែលធ្វើឱ្យសត្វមានគ្រោះថ្នាក់ដល់ជីវិតបាន។

### ២.៣ គំរូពិសោធន៍

ការសិក្សានេះត្រូវរៀបចំឡើងតាមគំរូពិសោធន៍ CRD (Completely Randomized Design) ដែលក្នុងនោះមានចំនួន៥បច្ច័យ និងមាន ៤សាក្នុងបច្ច័យនីមួយៗ។ ចំពោះគំរូពិសោធន៍មានដូចខាងក្រោម ៖

តារាង ២.១ គំរូពិសោធន៍

| | | | |
|---|---|---|---|
| T0 | T2 | T3 | T0 |
| T1 | T0 | T4 | T1 |
| T2 | T3 | T2 | T4 |
| T3 | T4 | T1 | T3 |
| T4 | T1 | T0 | T2 |

ដែល៖

- T0 : ក្រុមប្រើប្រាស់ចំណីសម្រេចសុទ្ធដែលជាក្រុមត្រួតពិនិត្យ
- T1 : ក្រុមប្រើប្រាស់ចំណីសម្រេចជាមួយទងដំឡូងផ្វាស្រស់ ១០%
- T2 : ក្រុមប្រើប្រាស់ចំណីសម្រេចជាមួយទងដំឡូងផ្វាស្រស់ ២០%
- T3 : ក្រុមប្រើប្រាស់ចំណីសម្រេចជាមួយទងដំឡូងផ្វាស្រស់ ៣០%
- T4 : ក្រុមប្រើប្រាស់ចំណីសម្រេចជាមួយម្សៅទងដំឡូងផ្វា ២០%

## ២.៤ សត្វពិសោធន៍

ក្នុងការពិសោធនេះមានកូនមាន់ចំនួន៥០០ក្បាលជាពូជមាន់ក្នុងស្រុក អាយុ ១ថ្ងៃ បានទិញពីប្រជាកសិករដែលជាអ្នកភ្ញាស់កូនមាន់នៅស្រុ បាភ្នំ ខេត្តព្រៃវែ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការភ្ញាស់ស៊ុតមាន់ពូជក្នុងស្រុក។ កូនមាន់ទាំងនេះ បានចិញ្ចឹម និងផ្តល់ចំណីបន្សាំរួមគ្នារហូតដល់អាយុ ២១ថ្ងៃ ទើបបែងចែកទៅក្នុងក្នុងក្រុមពិសោធន៍ តាមរយៈការចាប់ដោយចៃដន្យដាក់ក្នុងឡូកទាំង ២០ ដែលក្នុងនោះមានកូនមាន់ចំនួន២៥ក្បាលក្នុងមួយឡូក ឬសា។

## ២.៥ ចំណីពិសោធន៍

ទងដំឡូងផ្វាបានដាំនៅស្ថានីយចិញ្ចឹមសត្វនៃមហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម។ ទងដំឡូងផ្វាបានកាត់យកមកមានប្រវែង ២០សង់ទីម៉ែត្រពីចុងដោយប្រើកាំបិតហាន់ដែលកម្រាស់ចាប់ពី ០,០៣ ទៅ ០,០៥សង់ទីម៉ែត្រ នៅពេលដាក់ឱ្យសត្វស៊ី (ដល់ពេលដាក់ឱ្យស៊ីទើបហាន់) ទងដំឡូងផ្វាស្រស់ត្រូវថ្លឹងទៅតាមទម្ងន់ដងខ្លួនសត្វនៃឡូកនីមួយៗដោយប្រើជញ្ជីងអេឡិចត្រូនិកហើយក្នុងការដាក់ចំណីឱ្យសត្វស៊ីត្រូវប្រើស្នូកចំណីពីរដោយឡែកពីគ្នា មួយដាក់ទងដំឡូងផ្វាស្រស់ និងមួយទៀតដាក់ចំណីគ្រឹះ។ ចំណែកឯ ម្សៅទងដំឡូងផ្វាត្រូវរៀបចំដោយការកាត់យកមកមានប្រវែង ២០សង់ទីម៉ែត្រពីចុង ហើយហាលឱ្យស្ងួតរួចយកមកកិនឱ្យម៉ដ្តជាម្សៅ ហើយយកលាយជាមួយចំណី។

តារាងទី ២.២ សមាសធាតុគីមីរបស់ចំណី

| រូបធាតុដើម | %CP | %DM | %ASH | %OM |
|---|---|---|---|---|
| ទងជំឡូងផ្លាស្រស់ | ២០,៤០ | ១៧,៩៦ | ១៨,០០ | ៨២,០០ |
| ម្សៅទងជំឡូងផ្លា | ២២,០០ | ៩៦,៩០ | ១៨,០០ | ៨២,០០ |
| កន្ទក់ | ៦,២៧ | ៩៣,២៦ | ៥,៦៥ | ៩៤,៣៥ |
| សណ្តែកសៀង | ៣៥,០០ | ៨៦,៨៥ | ៩,១៤ | ៩០,៨៦ |
| ចំណីសម្រេច | ១៦,៨៣ | ៩២,៨០ | ៥,៣៦ | ៩៤,៦៤ |

សមាសធាតុចំណីបានវិភាគរកប្រូតេអ៊ីន(CP) រូបធាតុសោះទឹក(DM) សារធាតុសរីរាង្គ(OM) និងផេះ (ASH) យោងតាមទម្រង់ការវិភាគរបស់ (AOAC, 2014) នៅមន្ទីរពិសោធន៍មហាវិទ្យាល័យវេជ្ជសាស្រ្តសត្វនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

តារាងទី ២.៣ រូបមន្តផ្សំចំណីសម្រាប់ពិសោធន៍

| រូបធាតុដើម | T0 | T1 | T2 | T3 | T4 |
|---|---|---|---|---|---|
| ទងជំឡូងផ្លា | - | ១០ | ២០ | ៣០ | - |
| ម្សៅទងជំឡូងផ្លា | - | - | - | - | ២០ |
| កន្ទក់ | ៣០ | ២៥ | ២០ | ១៥ | ២១ |
| សណ្តែកសៀង | ២០ | ១៥ | ១០ | ៥ | ៩ |
| ចំណីសម្រេច | ៥០ | ៥០ | ៥០ | ៥០ | ៥០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ប្រូតេអ៊ីនក្នុងចំណី (%) | ១៧,៣០ | ១៧,២៧ | ១៧,២៥ | ១៧,២៣ | ១៧,២៨ |

## ២.៦ ការប្រមូលទិន្នន័យ

**ការថ្លឹងចំណីប្រចាំថ្ងៃ៖** ក្នុងការពិសោធនេះ ចំណីត្រូវឱ្យស៊ីដោយសេរី ប៉ុន្តែបានកំណត់ពេលវេលាផ្តល់ចំនួនចំណី ៣ដងក្នុងមួយថ្ងៃ គឺពេលព្រឹកម៉ោង ៧៖០០ ថ្ងៃត្រង់ម៉ោង ១២៖០០ និងពេលល្ងាចម៉ោង ៥៖០០។ ចំណីមុនដាក់ឱ្យសត្វស៊ីត្រូវថ្លឹង និងកត់ត្រា ហើយចំណីដែលនៅសល់ត្រូវប្រមូលថ្លឹង និងកត់ត្រាជាប្រចាំថ្ងៃ។

ការថ្លឹងទម្ងន់មាន់៖ មាន់ត្រូវថ្លឹងរៀងរាល់សប្តាហ៍នៅវេលាម៉ោង ៧ព្រឹក ដោយថ្លឹងម្តងមួយក្បាលៗ លើជញ្ជីងដែលមានរង្វាស់ទម្ងន់ ២គីឡូក្រាម (គិតជាក្រាម) យើងធ្វើរបៀបនេះរហូតដល់គ្រប់ចប់។

## ២.៧ ការវិភាគទិន្នន័យ

ទិន្នន័យបានកត់ត្រានៅក្នុងកម្មវិធី Excell និងវិភាគរកតម្លៃមធ្យម រង្វាស់លម្អៀង និងភាពខុសគ្នាតាមន័យស្ថិតិរបស់ក្រុមពិសោធន៍។

កំណើនទម្ងន់មធ្យមប្រចាំថ្ងៃបានគណនាតាម SLOPE ដែលរូបមន្ត ៖

$$b = \frac{n\sum xy - \sum x \sum y}{n\sum x^2 - (\sum x)^2}$$

## ៣. លទ្ធផល

### ៣.១ បម្រែបម្រួលទម្ងន់ប្រចាំសប្តាហ៍

យោងតាមតារាងលទ្ធផលខាងក្រោម (៣.១) យើងឃើញថា ទម្ងន់ចាប់ផ្តើមរបស់កូនមាន់ក្នុងក្រុមទាំង ៥ មិនមានលក្ខណៈខុសគ្នាតាមន័យស្ថិតិឡើយ ដែលបញ្ជាក់ថា កត្តាទម្ងន់នៅពេលចាប់ផ្តើមមិនមានឥទ្ធិពលលើការសិក្សាឡើយ។

ក្រាហ្វិច ៣.១ បម្រែបម្រួលទម្ងន់មាន់ក្នុងរយៈពេលពិសោធន៍



យោងតាមក្រាហ្វិច ៣.១ ខាងលើបានបង្ហាញឱ្យឃើញថា ក្រុម T0 (ក្រុមត្រួតពិនិត្យ) និង ក្រុម T4 (ក្រុមប្រើប្រាស់ម្សៅទងជំឡូងផ្វា) មានសន្ទុះនៃការលូតលាស់លឿនជាងក្រុមទាំង ៣ផ្សេងទៀតដែលប្រើប្រាស់ទងជំឡូងផ្វាស្រស់។ សន្ទុះនៃការលូតលាស់របស់ក្រុមទាំង ២នេះ រក្សាខ្ពស់រហូតដល់វគ្គចុងបញ្ចប់នៃការសិក្សាដែលជាអាយុសមស្របសម្រាប់ទីផ្សារ។ វាមានន័យថា ទម្ងន់មធ្យមប្រចាំសប្តាហ៍របស់មាន់ក្នុងមួយក្បាលរបស់ក្រុម T0 (ក្រុមត្រួតពិនិត្យ) និង ក្រុម T4 (ក្រុមប្រើប្រាស់ម្សៅទងជំឡូងផ្វា) មានទម្ងន់ប្រហាក់ប្រហែលគ្នា ហើយដែលជាទូទៅមិនមានលក្ខណៈខុសគ្នាតាមន័យស្ថិតិឡើយ។ ដោយឡែក ពួកវាមានតម្លៃខ្ពស់ជាងក្រុម ៣ផ្សេងទៀត ជាពិសេសនៅសប្តាហ៍ទី១០ ចុងក្រោយដែលជាពេលបញ្ចប់ការសិក្សាក្រុម T0 និង T4 នៅតែរក្សាខ្ពស់ជាងគេដដែល។ តែចំពោះក្រុមដែលបន្ថែមទងជំឡូងផ្វាស្រស់ហាក់ដូចជាមានការថយចុះ ទៅតាមការបង្កើនបរិមាណប្រើប្រាស់របស់វានៅក្នុងចំណី (តារាង ៣.១ ខាងក្រោម)។

តារាងទី ៣.១ ទម្ងន់មាន់តាមសប្តាហ៍ (ក្រាម/ក្បាល)

| សប្តាហ៍ | T0 | T1 | T2 | T3 | T4 | SEM | p_value |
|---|---|---|---|---|---|---|---|
| ចាប់ផ្តើម | ១០៨,១០ | ១០៦,៩៣ | ១០៧,២៣ | ១១០,៣៥ | ១០៨,៩០ | ០,៩៨១ | ០,១៤៨ |
| សប្តាហ៍ទី១ | ១៧៥,៤៥$^{a}$ | ១៥២,៦៥$^{bc}$ | ១៤៤,៨៣$^{c}$ | ១៤១,៥០$^{c}$ | ១៦៤,៥៨$^{ab}$ | ៤,០៧៤ | <០,០០១ |
| សប្តាហ៍ទី២ | ២៦១,០៤$^{a}$ | ២១៤,០០$^{b}$ | ១៩៨,៧៣$^{b}$ | ១៩៦,០៥$^{b}$ | ២៥៥,១៤$^{a}$ | ៦,៩៤៧ | <០,០០១ |
| សប្តាហ៍ទី៣ | ៣៣៥,០៩$^{a}$ | ២៩៤,៣៥$^{b}$ | ២៧៤,៧០$^{b}$ | ២៦៩,៨០$^{b}$ | ៣២៨,៦០$^{a}$ | ១០,៣៣៦ | ០,០០១ |
| សប្តាហ៍ទី៤ | ៣៩០,៥៨$^{a}$ | ៣៦២,២៨$^{bc}$ | ៣៥៩,២៥$^{c}$ | ៣៤៨,៤៣$^{c}$ | ៣៨៣,១៧$^{ab}$ | ៨,៦៧២ | ០,០២០ |
| សប្តាហ៍ទី៥ | ៥៤១,៩៤$^{a}$ | ៤៧៥,៤០$^{b}$ | ៤៦១,០៣$^{bc}$ | ៤៣៩,០៣$^{c}$ | ៥៣៣,៤០$^{a}$ | ១១,៧៧ | <០,០០១ |
| សប្តាហ៍ទី៦ | ៦៧៧,៥៤$^{a}$ | ៦២៦,៨៨$^{b}$ | ៦១៤,៧៨$^{b}$ | ៦០២,៤០$^{b}$ | ៦៦២,៦៩$^{a}$ | ១១,០៨៩ | ០,០០១ |
| សប្តាហ៍ទី៧ | ៨២៣,២២$^{a}$ | ៧៧៥,៣០$^{b}$ | ៧៥៩,៦០$^{b}$ | ៧៤៥,២៨$^{b}$ | ៨០៩,០០$^{a}$ | ១១,៣៦៨ | ០,០០១ |
| សប្តាហ៍ទី៨ | ៩៥៧,៨១$^{a}$ | ៩២៧,២៨$^{bc}$ | ៩០៧,៧០$^{c}$ | ៨៩៦,៨៨$^{c}$ | ៩៤០,៣៣$^{ab}$ | ១០,២៧៦ | ០,០០៥ |
| សប្តាហ៍ទី៩ | ១១៦៨,៣៩$^{a}$ | ១០៩១,១៥$^{bc}$ | ១០៥១,៩៥$^{cd}$ | ១០២០,៨៣$^{d}$ | ១១២២,០៥$^{ab}$ | ១៧,៥៣៧ | <០,០០១ |

យោងតាមក្រាហ្វិចទី ៣.២ ខាងក្រោម បានបង្ហាញឱ្យឃើញថា កំណើនទម្ងន់មធ្យមប្រចាំថ្ងៃរបស់ក្រុមទាំង៥ មានលក្ខណៈខុសគ្នាតាមន័យស្ថិតិ (p< ០,០១)។ ក្នុងនោះដែរ ក្រុមប្រើប្រាស់ចំណីសម្រេចសុទ្ធ (T0) និងក្រុមប្រើប្រាស់ម្សៅទងជំឡូងផ្វា (T4) មានការលូតលាស់ខ្ពស់ជាងគេ ដែលមានតម្លៃរៀងគ្នា គឺ ១៦,៤៦ក្រាម/ក្បាល/ថ្ងៃ និង១៥,៩៩ក្រាម/ក្បាល/ថ្ងៃ ហើយបន្តដោយក្រុមប្រើប្រាស់ទងជំឡូងផ្វាស្រស់ ១០%, ២០% និង ៣០%។ ជាមួយគ្នានេះដែរ យើងឃើញថា កំណើនទម្ងន់មធ្យមប្រចាំថ្ងៃរបស់មាន់ហាក់មានការថយចុះទៅតាមការបង្កើនកម្រិតប្រើប្រាស់ទងជំឡូងផ្វាស្រស់។

ក្រាហ្វិចទី ៣.២ កំណើនទម្ងន់មធ្យមប្រចាំថ្ងៃ




| | T0 | T1 | T2 | T3 | T4 | SEM | p_value |
|---|---|---|---|---|---|---|---|
| ADG | ១៦,៤៦$^{a}$ | ១៥,៧៦$^{bc}$ | ១៥,៣៩$^{cd}$ | ១៤,៩៩$^{d}$ | ១៥,៩៩$^{ab}$ | 0,១៨៦ | 0,00១ |

## ៣.២ បរិមាណស៊ីចូលប្រចាំថ្ងៃ

យោងតាមតារាង ៣.២ ខាងក្រោមបានបង្ហាញឱ្យឃើញថា នៅសប្តាហ៍ទី១ នៃការពិសោធ យើងឃើញថា ក្រុមប្រើប្រាស់ចំណីផ្សំមានការស៊ីចូលបានច្រើនជាងក្រុមផ្សេងទៀត (p<0,0៥)។ ចំពោះសប្តាហ៍បន្តទៀត គេមិនអង្កេតឃើញមានឥទ្ធិពលចំណីទៅលើការស៊ីចូលរបស់ក្រុមទាំង ៥ទេ ដែលអាចឱ្យយើងសន្និដ្ឋានបានថា ការស៊ីចូលរបស់ពួកវាមិនមានលក្ខណៈខុសគ្នាតាមអត្ថន័យស្ថិតិឡើយ។ ជាពិសេស បរិមាណនៃការស៊ីចូលជាមធ្យមរបស់ក្រុមពិសោធន៍ទាំងអស់ទូទាំងពេលវេលានៃការសិក្សាទាំងមូលក៏មិនមានភាពខុសគ្នាផងដែរ ហើយដែលមានពី ៨៤,0៨ក្រាម/ក្បាល/ថ្ងៃ ដល់ ៩0,៤២ក្រាម/ក្បាល/ថ្ងៃ។

តារាងទី ៣.២ ទម្ងន់មាន់តាមសប្ដាហ៍ (ក្រាម/ក្បាល/ថ្ងៃ)

| សប្ដាហ៍ | T0 | T1 | T2 | T3 | T4 | SEM | p_value |
|---|---|---|---|---|---|---|---|
| សប្ដាហ៍ទី១ | ២៤,០០ | ១៥,៣៤ | ១៥,០៥ | ១៤,៧៩ | ១៦,២២ | ១,៣៤៦ | ០,០០១ |
| សប្ដាហ៍ទី២ | ៤១,៩០ | ៣៥,២១ | ៣៤,២៧ | ៣៤,៥៩ | ៣៧,៧៩ | ២,៥៨៥ | ០,០២៥ |
| សប្ដាហ៍ទី៣ | ៧០,៦៧ | ៦៥,៨៣ | ៦៣,៨៥ | ៦០,៦៩ | ៦៦,៤៤ | ២,២៥៨ | ០,០៣៧ |
| សប្ដាហ៍ទី៤ | ៨៧,៥២ | ៨៥,៨១ | ៨៦,៣៣ | ៨៣,៩៤ | ៨៦,៩៩ | ៣,៣៦៦ | ០,៩៥១ |
| សប្ដាហ៍ទី៥ | ៩៥,១១ | ៨៩,៣៣ | ៨៩,២៥ | ៨៨,៨២ | ៩១,១៥ | ២,០០៦ | ០,២០៥ |
| សប្ដាហ៍ទី៦ | ១១៥,៥០ | ១១២,៩៤ | ១១២,១១ | ១០៨,២៥ | ១១៤,៥៣ | ៤,៩៣៣ | ០,៨៥៨ |
| សប្ដាហ៍ទី៧ | ១២៣,១៣ | ១១៦,៦៥ | ១១៨,២៣ | ១១៨,៥២ | ១២១,៨៥ | ២,៨៦៧ | ០,៤៩៤ |
| សប្ដាហ៍ទី៨ | ១២៩,២៦ | ១២១,១១ | ១២០,៧៤ | ១២១,០៣ | ១២២,១៧ | ៣,២៤២ | ០,៣៣៤ |
| សប្ដាហ៍ទី៩ | ១២៦,៧០ | ១៣២,១៧ | ១៣៣,៤១ | ១២៦,០៨ | ១៣១,១២ | ២,៨៣៥ | ០,២៩៣ |
| មធ្យម | ៩០,៤២ | ៨៦,០៤ | ៨៥,៩១ | ៨៤,០៨ | ៨៧,៥៨ | ១,៦៣៦ | ០,១៣១ |

## ៣.៣ សន្ទស្សន៍បំប្លែងចំណី (FCR)

តារាងទី ៣.៣ សន្ទស្សន៍នៃការស៊ីចំណីតាមសប្ដាហ៍

| សប្ដាហ៍ | T0 | T1 | T2 | T3 | T4 | SEM | p_value |
|---|---|---|---|---|---|---|---|
| សប្ដាហ៍ទី១ | ២,៥៥ | ២,៤៣ | ២,៨៥ | ៣,៣៥ | ២,០៧ | ០,២៨៩ | ០,០៦៧ |
| សប្ដាហ៍ទី២ | ៣,៥៩ | ៤,០១ | ៤,៤៩ | ៤,៤៩ | ២,៩២ | ០,៣១៣ | ០,០១៤ |
| សប្ដាហ៍ទី៣ | ៦,៧៧ | ៥,៧៧ | ៦,០២ | ៥,៨០ | ៦,៦៣ | ០,៤៥៥ | ០,៥០០ |
| សប្ដាហ៍ទី៤ | ១០,១២ | ៨,៩៥ | ៧,២៧ | ៧,៥០ | ១០,៦២ | ០,៩៧៩ | ០,០១៤ |
| សប្ដាហ៍ទី៥ | ៤,៨៤ | ៥,៥៣ | ៦,១០ | ៦,៨៧ | ៤,៤៨ | ០,១៧៥ | <០,០០១ |
| សប្ដាហ៍ទី៦ | ៥,៩៨ | ៥,២៧ | ៥,១៥ | ៤,៦៤ | ៦,៤០ | ០,៤៧២ | ០,១២១ |
| សប្ដាហ៍ទី៧ | ៥,៩៤ | ៥,៥១ | ៥,៧៤ | ៥,៨១ | ៥,៩៦ | ០,២៨៩ | ០,៨០០ |
| សប្ដាហ៍ទី៨ | ៦,៧៣ | ៥,៦០ | ៥,៧៧ | ៥,៥៩ | ៦,៥៣ | ០,២៥៦ | ០,០១៤ |
| សប្ដាហ៍ទី៩ | ៤,៥៦ | ៥,៦៨ | ៦,៥១ | ៧,៥២ | ៥,១៧ | ០,៦៣១ | ០,០៣៧ |

យោងតាមតារាង ៣.៣ ខាងលើ យើងឃើញថា សន្ទស្សន៍នៃការស៊ីចំណីរបស់ក្រុមទាំង ៥ ហាក់ដូចជាមិនមានភាពខុសគ្នាតាមន័យស្ថិតិ។ ក្នុងនោះដែរ នៅសប្ដាហ៍ទី៩ យើងឃើញថា ក្រុមប្រើប្រាស់ចំណីសម្រេច (T0) និងក្រុមប្រើប្រាស់ម្សៅទងដំឡូងផ្វា (T4) ហាក់ដូចជាមានសន្ទស្សន៍នៃការបំប្លែងចំណីនេះបានល្អដែលមានតម្លៃរៀងគ្នា ៤,៥៦ និង ៥,១៧។

ក្រាហ្វិចទី ៣.៣ សន្ទស្សន៍ស៊ីចំណីជាមធ្យម




| | T0 | T1 | T2 | T3 | T4 | SEM | p_value |
|---|---|---|---|---|---|---|---|
| ADG | ៥,៥0 | ៥,៤៦ | ៥,៥៩ | ៥,៦១ | ៥,៤៨ | 0,១២៤ | 0,៨៧៩ |

ជារួមសន្ទស្សន៍នៃការស៊ីចំណីរបស់ក្រុមទាំង ៥ មិនមានលក្ខណៈខុសគ្នាតាមន័យស្ថិតិទេ ហើយដែលមានប្រហាក់ប្រហែលនឹង ៥,៥0។

## ៤. ពិភាក្សា

នៅសប្ដាហ៍ទី១ ដល់ទី៣ ការស៊ីចូលរបស់ក្រុមពិសោធន៍ទាំង ៥ មានលក្ខណៈខុសគ្នាគួរឱ្យកត់សម្គាល់ដែលក្នុងនោះក្រុមត្រួតពិនិត្យ (T0) មានការស៊ីចូលបានច្រើនជាងគេ ចំពោះសប្ដាហ៍ក្រោយទៀតមិនមានលក្ខណៈខុសគ្នាទេ។ ការរកឃើញនេះដូចគ្នានឹងអ្នកស្រាវជ្រាវជាច្រើនដែលបានបញ្ជាក់ថា បក្សីក្មេងខ្ចីមិនអាចមានលទ្ធភាពរំលាយជាតិសរសៃក្នុងចំណីដែលមានលើសពី ១0%បានទេ ព្រោះផ្លូវអាហាររបស់ពួកវានៅខ្ចីដែលអាចធ្វើមេតាបូលីស និងបញ្ចេញអង់ស៊ីមទៅក្នុងដំណើររំលាយអាហារបានល្អឡើយ (Jiwuba et al 2016; Obakanurhe and Okpara, 2016; Adeyeye et al 2019)។ ជាពិសេសទៅទៀត បរិមាណនៃការស៊ីចូលនេះមានការថយចុះទៅតាមកម្រិតនៃការកើនឡើងនូវការប្រើប្រាស់ទងដំឡូងផ្លាស្រស់។

លទ្ធផលទម្ងន់មាន់ចុងបញ្ចប់ដែលទទួលបានពីការសិក្សានេះ ទាំងក្រុមប្រើ និងមិនប្រើទងដំឡូងផ្ទា គឺមានប្រហាក់ប្រហែល ១ ១០០ក្រាម ដែលទាបជាការសិក្សារបស់ (Puthy, 2006) លើការប្រើប្រាស់ទងដំឡូងផ្ទាបន្ថែមលើចំណីក្រុមហ៊ុន និង (Chansy, 2010) លើការប្រើប្រាស់បន្ថែមអនុផលបង្គា និងទងដំឡូងផ្ទាស្រស់ លើចំណីក្រុមហ៊ុនដែលមានទម្ងន់បញ្ចប់រៀងគ្នាប្រមាណ ២០០១-ក្រាមក្នុងមួយក្បាល និង ១៦៥១ក្រាមក្នុងមួយក្បាល។ ភាពខុសគ្នានេះអាចបណ្តាលមកពីប្រភេទពូជមាន់ដែលជ្រើសរើសយកមកសិក្សា ក្នុងនោះ ការសិក្សារបស់ពួកគេទាំង២ គឺជ្រើសរើសយកពូជមាន់សាច់ដែលមានកំណើនលូតលាស់ខ្ពស់។ ចំពោះទម្ងន់ចុងបញ្ចប់ហាក់ដូចជាមានការថយចុះទៅតាមការបង្កើនបរិមាណប្រើប្រាស់ទងដំឡូងផ្ទាស្រស់ពី ១០ ទៅ ៣០% ដែលដូចគ្នានឹងការរកឃើញរបស់ Obakanurhe and Akpodiete (2021) ដែលបញ្ជាក់ថា ទម្ងន់មានការធ្លាក់ចុះនៅពេលគេប្រើប្រាស់វាហួតដល់ ១១,២៥% និង ១៥%។ ការប្រើប្រាស់ម្សៅទងដំឡូងផ្ទាអាចប្រើប្រាស់រហូតដល់ ២០% ដោយមិនមានឥទ្ធិពលលើកំណើនទម្ងន់ធៀបជាមួយនឹងក្រុមត្រួតពិនិត្យដែលដូចគ្នានឹងការបញ្ជាក់របស់ (Unigwe et al 2014) ថា គេអាចប្រើប្រាស់ម្សៅស្លឹកដំឡូងផ្ទាលើសពី ១០% ហើយមាន់នៅតែរក្សាកំណើនទម្ងន់ដដែល។

## ៥. សន្និដ្ឋាន

ជាមួយគ្នានេះផងដែរ យើងឃើញថាកំណើនទម្ងន់មធ្យមប្រចាំថ្ងៃរបស់មាន់ហាក់មានការថយចុះទៅតាមការបង្កើនកម្រិតប្រើប្រាស់ទងដំឡូងផ្ទាស្រស់។ ដូច្នេះ កម្រិតទងដំឡូងផ្ទាស្រស់ដែលសម្រប គឺកម្រិត ១០% ដែលវាអាចបង្កឥទ្ធិពលតិចតួចលើការលូតលាស់របស់មាន់ក្នុងស្រុក ជាពិសេស វាមិនមានភាពខុសគ្នាខ្លាំងជាមួយក្រុមត្រួតពិនិត្យ និងក្រុមប្រើប្រាស់ម្សៅទងដំឡូងផ្ទាឡើយ។ ក៏ប៉ុន្តែ អ្នកចិញ្ចឹមអាចបង្កើនបរិមាណប្រើប្រាស់ទងដំឡូងបានតាមរយៈការកែច្នៃទៅជាម្សៅ ហើយលាយច្របល់ជាមួយនឹងចំណី ឬប្រើប្រាស់ជាសមាសធាតុគ្រឿងផ្សំចំណី។

# ឯកសារយោង


១.Adeyeye S A, Ayodele S O, Oloruntola O D and Agbede J O 2019 Processed cocoa pod husk dietary inclusion: effects on the performance, carcass, haematogram, biochemical indices, antioxidant enzyme and histology of the liver and kidney in broiler chicken. Bulletin of the National Research Centre (2019) 43:54

២.AOAC 2014 Association of Official Analytical Chemist. Official Methods of Analysis, 19th edn. Washington D.C.

៣.Chansy, K. 2010. Effect of Supplementing of Shrimp by products ans Fresh Sweet Potato Vine in Commercial Feed on Growth Performance of Avian Broiler, Royal University of Agriculture.

៤.Jiwuba P C, Dauda E, Ezenwaka L C and Eluagu C J 2016 Replacement value of maize with sweet potato (*Ipomoea batata*) root meal on growth performance and haematogical characteristics of broiler starter birds. *Arch. Curr. Res.Int.*; 53:1-7.

៥.Obakanurhe O and Okpara O 2016 Performance and Haematological Characteristic of Broiler Finisher Fed*Moringa oleifera* Leaf Meal Diet. *Journal of Northeast Agricultural University*, 23, Pp28-34, Elsevier Publishers

៦.Obakanurhe O and Akpodiete O J 2021 Performance characteristics of broiler chickens fed sweet potato (*Ipomoea batatas*) leaf in the tropics. *Livestock Research for Rural Development. Volume 33, Article #14.* Retrieved July 18, 2022, from http://www.lrrd.org/lrrd33/1/oghen3314.html

៧.Puthy Y. 2006. Effect of Supplementing of Fresh Sweet Potato Vine in Commercial Feed on Growth Performance of Avian Broiler, Royal University of Agriculture.

៨.Unigwe C R, Okorafor U P Atoyebi1 T J and Ogbu U M 2014 The Nutritive Value and Evaluation of Sweet Potato ( *Ipomoea Batatas*) Leaf Meal on the Growth Performance of Broiler Chickens. *Int. J. Pure Appl. Sci. Technol.*, 20(2), pp. 19-26.

# ការវិភាគស្នាដៃគំនូរអំពីពណ៌

និស្សិត ៖ **កែវ សំរិត**
ជំនាញ៖ **វិចិត្រសិល្បៈ**

## I. សេចក្តីផ្តើម

ការប្រើប្រាស់ពណ៌នៅលើគំនូរសិស្ស និស្សិតវិចិត្រករ សិល្បករ ដែលមានជំនាញសិល្បៈវិចិត្រកម្ម ត្រូវតែសិក្សាអំពីមូលដ្ឋានទ្រឹស្តីពណ៌។

### ១.១ និយមន័យពណ៌

ពណ៌គឺសំដៅទៅលើអ្វីដែលមិនមែនខ្មៅហើយនិងស មានដូចជា៖ លឿង បៃតងលឿង បៃតង បៃតងខៀវ ខៀវ ស្វាយខៀវ ស្វាយ ស្វាយក្រហម ក្រហម ទឹកក្រូចក្រហម ទឹកក្រូច លឿងទឹកក្រូច។ល។

### ១.២ ប្រវត្តិសាស្ត្រនៃពណ៌

ពណ៌ត្រូវបានសិក្សាដោយអ្នកវិទ្យាសាស្ត្របុរាណមានដូចជា៖

- លោក NEWTON[១] គឺជាអ្នកប្រាជ្ញផ្នែករូបវិទ្យា ជាទស្សនវិទូ ជាអ្នកគណិតវិទ្យា ជាអ្នកអវកាស ជាសាស្ត្រាចារ្យ គាត់កើតនៅឆ្នាំ១៦៤២ ហើយទទួលមរណភាពនៅឆ្នាំ១៧២៧។ ទ្រឹស្តីរបស់គាត់ដែលបានរកឃើញគឺ ការបំបែងពន្លឺដោយឆ្លងកាត់ព្រិស ជាមួយនឹងភ្នែកគឺញែកបាន ៧ពណ៌ ហើយគាត់បានបង្កើតប្រព័ន្ធមួយនៅឆ្នាំ១៦៦៦ ហើយការវិភាគពណ៌របស់គាត់ចេញអំពីពន្លឺគាត់អាចបំបែកបានពណ៌ដំបូងមាន ៣ពណ៌សំខាន់ៗ គឺ ក្រហម ខៀវ បៃតង។ ពាក្យបច្ចេកទេសនៅក្នុងប្រព័ន្ធអេឡិចត្រូនិក កុំព្យុទ័រ ទូរស័ព្ទ។ល។



Portrait of Isaac Newton ( 1642-1727 )



Goethe in 1828, by Joseph Karl Stieler

- ក្រោយមកទៀតលោក Johann Wolfgang[២] von Goethe គាត់ជាជនជាតិអាល្លឺម៉ង់ កើតនៅថ្ងៃទី១៨ សីហា ១៧៤៩ ហើយទទួលមរណភាពនៅថ្ងៃទី២២ មីនា ១៨៣២ គាត់បានទទួលយកទ្រឹស្តីនេះបន្តពីលោកNewton ដែលជាអ្នកប្រាជ្ញទ្រឹស្តីពណ៌ មកបង្ហាញ និងធ្វើការជជែកវែកញែកទៅឃើញថា មានការប្រែប្រួលមួយចំនួនដែលខុសពីទ្រឹស្តីចាស់។ គឺគាត់បានយកទ្រឹស្តីពណ៌ផ្សារភ្ជាប់ជាមួយការងារជាក់ស្តែងរបស់គាត់ឃើញថា មូលដ្ឋានពិតរបស់ពណ៌ដែលបានប្រើប្រាស់គឺមិនដូចលោកNewton បង្ហាញពីមុនមកទេគឺនៅមានការខ្វះចន្លោះខ្លះៗ។

---

[១] Britannica *Isaac Newton* https://www.britannica.com/biography/Isaac-Newton (Accessed on 17 March 2022)

[២] Britannica *Johann-Wolfgang-von-Goethe* https://www.britannica.com/biography/Johann-Wolfgang-von-Goethe (Accessed on 17 March 2022)

- ក្រោយមកទៀតអ្នកប្រាជ្ញខាងគីមីម្នាក់ គាត់ឈ្មោះ Michel Eugene Chevreul[៣] គាត់កើតនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៧៨៦ ហើយទទួលមរណភាពនៅថ្ងៃទី៩ មេសា ១៩៨៩ គាត់ជាជនជាតិបារាំង មានរោងចក្របង្កើតជាសាច់ក្រណាត់ ហើយគាត់ត្រូវការជ្រលក់ពណ៌ ហើយពណ៌ក្នុងទ្រឹស្តីពីមុនគឺជាពន្លឺ ហើយពន្លឺមិនអាចប្រើប្រាស់ជ្រលក់នៅក្នុងសាច់ក្រណាត់បានទេ ហើយការរកឃើញរបស់គាត់បានបំបែកល្អិតជាងមុន ជាពន្លឺដែលពីមុនមានតែប្រាំពីរពណ៌ ហើយពណ៌ដែលជ្រលក់ទៅលើសាច់ក្រណាត់ ឥទ្ធិពលវាដែលបានផលិតមកពីជាតិគីមីវាខុសប្លែកពីពណ៌នៅក្នុងពន្លឺ ហើយលោក Michel Eugene Chevreul គាត់គឺជាវិចិត្រករមួយដែរ ក្នុងសម័យ Impressionism. Neo Impressionism and orphista គឺជាគំនូរដែលខុសពីគំនូរការពិត គឺគំនូរសម្តែងដោយការប្រើប្រាស់ពណ៌ ពេលនឹងគាត់បានបង្កើតទ្រឹស្តីមួយទៀតខុសពីទ្រឹស្តី Newton ហើយគាត់បានបំបែកពណ៌ជាមួយពន្លឺ និងម្លប់ ដែលធ្វើពណ៌នីមួយៗមានភាពចាស់ និងខ្ចី ។



File: Michel Eugène Chevreul 2.jpg
Created: 31 December 1888



File: Albert-munsell.jpg
Uploaded: 3 March 2009

- ហើយបន្តមកទៀតលោក Albert Henry Munsell[៤] កើតនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៨៥៨ ហើយទទួលមរណភាពនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩១៨ សហរដ្ឋអាម៉េរិក គាត់បានយកពណ៌នីមួយៗ មកបន្សាបពន្លឺមិនឱ្យចែងចាំង គឺប្រើលាយជាមួយល្បាយប្រផេះ គាត់បានបង្កើតពន្លឺជាមួយ ស និងម្លប់ជាមួយ ខ្មៅ System របស់លោក Albert Henry Munsell វាមានសារៈសំខាន់សម្រាប់អ្នកតុបតែងលម្អ និងស្ថាបត្យកម្ម ដែលតម្រូវឱ្យយើងប្រើប្រាស់ពណ៌ទាំងអស់ នៅលើអគារខាងក្នុងមិនឱ្យភ្លឺចែងចាំង ដោយមិនឱ្យប្រើពណ៌សុទ្ធគឺប្រើពណ៌ដែលសាប អាស្រ័យទៅលើការបំបែកវាទៅប្រផេះ ស និងខ្មៅ។

[៣] ipidlibrary *michel-eugène-chevreul* https://lipidlibrary.aocs.org/resource-material/the-history-of-lipid-science-and-technology/michel-eug%C3%A8ne-chevreul-(1786-1889) (Accessed on 17 March 2022)

[៤] britannica *Munsell-color-system* https://www.britannica.com/science/Munsell-color-system (Accessed on 17 March 2022)

- អ្នកចុងក្រោយបំផុតដែលយើងទាំងអស់គ្នាបានយកមកប្រើប្រាស់ទូទៅទូទាំងពិភពលោកគឺទ្រឹស្តីរបស់លោក Johannes Itten[៥] កើតនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៨៨៨ ហើយទទួលមរណភាពនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៦៧ គាត់ជាជនជាតិស្វីសគាត់គឺជាបណ្ឌិតសិល្បៈ ហើយគាត់គឺជាមនុស្សដំបូងគេដែលបន្សំពណ៌បានជោគជ័យ គឺគាត់បានបង្កើតទ្រឹស្តីពណ៌ Itten បានសិក្សារៀនអនុវត្ត កត់សម្គាល់ បង្កើតនិងបោះពុម្ពទ្រឹស្តីពណ៌ក៍ដូចជាទ្រឹស្តីរបស់គាត់លើចិត្តវិទ្យា ដែលទាក់ទងនឹងពណ៌ ។ ពាក្យរបស់ Itten គឺសិល្បៈនៃពណ៌ ពណ៌គឺជាជីវិត សម្រាប់ពិភពលោកដែលគ្មានពណ៌ ហាក់ដូចជាស្លាប់ ភ្លើងបង្កើតពណ៌កាលណាមានពន្លឺគឺយើងអាចមើលឃើញវត្ថុ ឬទម្រង់។



In 1965 Johannes Itten

## ១.៣ ប្រភេទនៃពណ៌

ពណ៌នៃពន្លឺគឺពណ៌ដែលបម្លែងពីពន្លឺនៅលើធម្មជាតិដូចយើងបានមើលឃើញ ពណ៌ស្លឹកឈើ ពណ៌លឿង ពណ៌បៃតង ពណ៌ផ្លែឈើ ពណ៌ ក្រហម ពណ៌លឿង ពណ៌ទឹក ពណ៌មេឃ និងពណ៌រុក្ខជាតិ ពណ៌វត្ថុ ឬពណ៌របស់សារធាតុផ្សេងៗ ដែលនៅជុំវិញខ្លួនយើង ជាក់ស្តែងគឺពណ៌នៅលើឥន្ទធនូ ក្រោយមកអ្នកវិទ្យាសាស្ត្របានយកពន្លឺនឹងមកប្រើប្រាស់ ក្នុងប្រព័ន្ធឌីជីថល ដែលមានប្រព័ន្ធដក C M Y K និងប្រព័ន្ធបូក R G B[៦] មកប្រើប្រាស់នៅលើឧបករណ៍ឌីជីថលដូចជា៖ ទូរទស្សន៍ ម៉ាស៊ីនថត និងគ្រឿងអគ្គិសនីឌីជីថលផ្សេងៗជាច្រើនទៀត។ល។




---

៥ getty.*edu Johannes Itten*
https://www.getty.edu/research/exhibitions_events/exhibitions/bauhaus/new_artist/form_color/form/(Accessed on 17 March 2022)

៦ Adriana Lucia Tafur Del Aguila, ***Color digital:*** medium,
https://medium.com/@a20193010/color-digital-744fd8a540f0 ( Accessed on 6 December 2022 )

១.៤ ចំណាត់ថ្នាក់នៃពណ៌គឺជាក្រុមសុខដុមនៃពណ៌ (Harmony Color[៧]) ដែលបានបែងចែក នៅលើរង្វង់ពណ៌(Chromatic circle) ដូចជា៖

ពណ៌ផ្ទុយរៀងគ្នា (Analogous )

ពណ៌ផ្ទុយទល់មុខគ្នា(Complementary)

ពណ៌ផ្ទុយមួយទល់ពីរ(Split complementary)

ពណ៌ផ្ទុយរាងត្រីកោណ(Triad )

ពណ៌ផ្ទុយរាងចតុកោណកែង(Tetradic)

ពណ៌ផ្ទុយរាងការ៉េ(Square)




## ១.៤ ល្បាយពណ៌

ល្បាយពណ៌គឺជាក្រុមពណ៌ដែលបានប្រើប្រាស់ប្រចាំថ្ងៃទៅលើការងាររបស់សិល្បករ ហើយ បង្កើតឡើងដោយអ្នកវិទ្យាសាស្ត្រជាច្រើនរូប រហូតចុងក្រោយគឺលោក Johannes Itten គាត់បាន បង្កើតរង្វង់ chromatic[៨] និង Achromatic សម្រាប់ជាមូលដ្ឋានទ្រឹស្តី ដើម្បីយកមកប្រើប្រាស់បង្កើតរូប ភាពនៅលើផ្ទាំងគំនូរ ចម្លាក់ សំណង់ស្ថាបត្យកម្ម និងតុបតែងលម្អ។ល។

**ក.** Chromatic circle

Chromaticគឺជាក្រុមពណ៌ដែលកើតឡើងពីការបូកបញ្ចូលគ្នារវាង Primary Color និង Secondary Color បាន Tertiary color ដែលមាន១២ ពណ៌។




---

[៧] Kimberly Aguilar, ***Color Theory,*** Pinterest, https://www.pinterest.com/pin/633387439339048/ (Accessed on 6 December 2022)

[៨] ជាពណ៌ដែលមាននៅលើរង្វង់១២ពណ៌(ហោថា Chromatic color Circle)

ខ. Achromatic circle

Achromatic Color គឺជាក្រុមពណ៌ដែលមិនមាននៅលើរង្វង់ Chromatic Color មានដូចជា៖

- Saturation គឺជាការលាយរវាងពណ៌ដើម (Hue)ជាមួយតុងប្រផេះ។




Saturation

គ. Value គឺជាជម្រាលពីខ្មៅទៅស



ឃ. Mono Chromatic គឺជាការប្រដេញពីពណ៌ដើមណាមួយទៅស និងទៅខ្មៅ។




## II. ការជ្រើសរើសក្រុមពណ៌ត្រជាក់មកបង្កើតស្នាដៃគំនូរនៃទិដ្ឋភាពជនបទរបស់កសិករខ្មែរ

- តើក្រុមនៃពណ៌ត្រជាក់មានអ្វីខ្លះ ?

ក្រុមនៃពណ៌ត្រជាក់នៅលើរង្វង់ Chromatic[៩] មានដូចជា៖

ពណ៌បៃតង (Green)
ពណ៌បៃតងខៀវ (Blue Green)
ពណ៌ខៀវ (Blue)
ពណ៌ស្វាយខៀវ (Blue Violet)
ពណ៌ស្វាយ (Violet)
ពណ៌ស្វាយក្រហម (Red Violet)។




- ការប្រើប្រាស់ក្រុមនៃពណ៌ត្រជាក់ វិចិត្រករយកវាមកលាយជាមួយ ខ្មៅ ស និងប្រផេះ។ លាយខ្មៅដើម្បីបង្កើតម្លប់ លាយស ដើម្បីបង្កើតពន្លឺ ហើយលាយប្រផេះដើម្បីបង្កើតតុង និងបន្ថយចំណាំងពណ៌។

- ពណ៌ដែលបានកំណត់រួចហើយវិចិត្រករយកវាមកប្រើប្រាស់នៅលើផ្ទាំងគំនូរទៅតាមទីកន្លែងរបស់វា។

---

[៩] Anuj Malhotra, Color wheel Basics, https://www.slideteam.net/blog/color-wheel-choose-right-color-scheme-powerpoint-slides (Accessed on 17 March 2023)



វិចិត្រករ ហេង មុនីផល
ប្រធានបទៈ កសិករ
រូបធាតុៈ ពណ៌ប្រេងលើក្រណាត់
ទំហំៈ ៨០ សម x ១២០ សម
ឆ្នាំៈ ២០២២

## ២.១ ទំនាក់ទំនងពណ៌ត្រជាក់នៅលើផ្ទាំងរូបភាពទាំងមូល

នៅលើផ្ទាំងគំនូរ គេបានបែងចែកជាបី Ground ផ្នែកខាងមុខហៅថា (Foreground) នៅផ្នែកកណ្តាលហៅថា (Middle ground) ផ្នែកខាងក្រោយហៅថា (Background)[១០]។ រូបភាពតួអង្គខាងមុខហៅថា Foreground តួអង្គបន្ទាប់ហៅថា Middle ground ចំណែកវាលស្រែ និងផ្ទៃមេឃជា Background។

[១០] Background គឺជាផ្នែកខាងក្រោយនៃប្លង់រូបភាព។

- **Background** នៅលើផ្ទៃមេឃប្រើប្រាស់ Monochrome ខៀវស្រាលជាមួយស ផ្នែកនៃពន្លឺជាផ្ទាំងពពក ត្រូវបានលាយបញ្ចូលពណ៌ក្តៅ និងប្រផេះដើម្បីផ្ទុយជាមួយលម្ហមេឃ ហើយផ្នែកលម្ហមេឃបានប្រើខៀវប្រផេះ Monochrome[១១]។ ចំណែកនៅលើភ្នំពន្លឺនៃពណ៌បៃតងផ្ទុយនិងម្លប់របស់វាប្រផេះស្រាលៗគឺដើម្បីបង្ហាញអំពីចម្ងាយរបស់វា ហើយនៅលើព្រៃនៅតាមជើងភ្នំពន្លឺរបស់វា ផ្ទុយជាមួយនឹងខ្លួនវាហើយផ្ទុយជាមួយផ្ទៃខាងក្រោយផងដែរ។ នៅលើវាលស្រែក្រុមនៃពណ៌បៃតងពន្លឺរបស់វាផ្ទុយជាមួយម្លប់របស់វា ផ្ទុយនឹងក្រុមប្រផេះ ហើយក៏ផ្ទុយជាមួយតួអង្គខាងមុខ ការផ្ទុយគ្នាច្រើនជងដូចនេះគេហៅថា( Simultaneous )។



[១១] Monochrome គឺជាការប្រដេញពណ៌ដើមទៅស និងទៅខ្មៅ។

- **Middle ground**[១២]គឺជាតួអង្គរងដែលនៅចន្លោះ Background និង Foreground នៅលើម្ជុក ប្រើប្រាស់ Monochrome ប្រផេះស្រាលដើម្បីផ្ទុយជាមួយ Background របស់វា នៅលើអាវប្រើប្រាស់ ពណ៌ផ្កាឈូកស្វាយផ្ទុយជាមួយ Background ចំណាំងឆ្លុះផ្ទៃមេឃចំណែកនៅលើខោប្រើប្រាស់ Monochrome ខៀវដើម្បីផ្ទុយ Background របស់វាបៃតង។



[១២] Middle ground គឺជាផ្នែកកណ្តាលនៃរូបភាពដែលនៅចន្លោះពី Foreground និង Background។

- Foreground គឺជាតួអង្គសំខាន់នៅក្នុងប្រធានបទនៅលើម្ជុកប្រើប្រាស់ប្រផេះក្តៅផ្សំយនឹងម្លប់របស់វាត្រជាក់នៅលើថ្ពាល់ប្រើពន្លឺភ្លឺខ្លាំងផ្សំយនឹងម្លប់របស់វាងងឹតខ្លាំងហៅថា(Light and dark) ដើម្បីបង្ហាញចំណុចទាក់ទាញនៅលើអាវប្រើប្រផេះស្រាលផ្សំយនឹងBackground ពណ៌បៃតងនៅលើសំពត់ប្រើប្រាស់ប្រផេះងងឹតដូចនេះហើយភាពរំលេចរបស់វាសម្តែងខ្ពស់ជាងកន្លែងដទៃទៀត វាគឺជាចំណុចទាក់ទាញ(Emphasis) នៃផ្ទាំងគំនូរ ហើយគោលដៅរបស់វាគឺដាក់ចំត្រង់ចំណុចមាស (Golden section)[១៣] ដែលជាវិធីសាស្ត្ររបស់វិចិត្រករភាគច្រើននៅលើសកលលោកដែលបានប្រើប្រាស់តាំងពីសម័យបុរាណរហូតមកដូចនេះវាជាតួអង្គឯកនៃផ្ទាំងរូបភាពទាំងមូល។



[១៣] Golden section គឺជាសមាមាត្រមាស ជាឧបករណ៍រចនាសម្ព័ន្ធដែលផ្អែកលើលំនាំនៃធម្មជាតិ ដែលត្រូវបានប្រើប្រាស់ដោយវិចិត្រករ និងអ្នករចនាជាច្រើនសតវត្សមកហើយ។

# សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការវិភាគអំពីពណ៌នៅលើផ្ទាំងគំនូរបានបង្ហាញឱ្យឃើញថា ស្នាដៃគំនូរដែលល្អ ហើយទាក់ទាញនិងប្រកបដោយសោភ័ណភាពត្រូវបានវិចិត្រករ សិល្បករ អ្នកជំនាញសិក្សាយ៉ាងល្អិតល្អន់ទៅលើមូលដ្ឋាននៃទ្រឹស្តីពណ៌និងការរៀបចំទៅតាមគោការណ៍នៃសិល្បៈនៅលើផ្ទាំងគំនូរឱ្យវាមានទំនាក់ទំនងរណ្តំគ្នា និងបង្កើតសោភ័ណភាពទៅលើទម្រង់នីមួយៗ ហើយវាគឺជាវិធីសាស្ត្រមួយដែលអាចឱ្យអ្នកសិក្សាជំនាញនេះកាន់តែយល់ច្បាស់ និងស៊ីជម្រៅទៅលើការប្រើប្រាស់ពណ៌ទៅតាមទីកន្លែងនៅក្នុងប្លង់រូបភាពថា តើផ្ទៃខាងក្រោយ( Background ) ប្រើបែបណា ហើយផ្ទៃកណ្តាល( Middle Ground ) ប្រើបែបណា និងផ្ទៃខាងមុខ( Foreground ) ប្រើបែបណា។ ដូចនេះមូលដ្ឋាននៃទ្រឹស្តីពណ៌វាមានប្រយោជន៍ទៅដល់អ្នកសំណេរអ្នកសិក្សាមុខជំនាញសិល្បៈ និងបានជាឯកសារពិគ្រោះសម្រាប់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំដល់អ្នកជំនាញវិចិត្រកម្ម និងជំនាញសិល្បៈសូនរូប ក្នុងការប្រើប្រាស់ពណ៌។

# គន្ថនិទ្ទេស

## ១. ភាសាជាតិ

### ១.១ សិក្ខាសាលា


- ហេង មុនីផល *មូលដ្ឋានគ្រឹះនៃសិល្បៈ, បទបង្ហាញអំពី សមាសធាតុ និងការរៀបចំនៃសិល្បៈ,* ទីកន្លែង សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ, កាលបរិច្ឆេទថ្ងៃទី ២៩ ខែ០៩ ឆ្នាំ ២០១៨
- ហេង មុនីផល បទបង្ហាញអំពី *ពណ៌នៃពន្លឺ Color digital* បន្ទប់នៃអគាឥន្ទ្រទេវីនៃរាជបណ្ឌិត្យសភាកម្ពុជា កាលបរិច្ឆេទថ្ងៃទី ១១ ខែ ០២ ឆ្នាំ ២០២៣


### ១.២ សម្ភាស


- សម្ភាសផ្ទាល់ជាមួយនិងវិចិត្រករ ហេង មុនីផល នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ( *ការជ្រើសរើសប្រធានបទទស្សនាវដ្ដី*)ថ្ងៃទី១១ ខែ០២ ឆ្នាំ២០២៤
- សម្ភាសផ្ទាល់ជាមួយនិងវិចិត្រករ ហេង មុនីផល នៅផ្ទះរបស់គាត់ (*អំពី ការរៀបចំ Composition*) នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤
- សម្ភាសផ្ទាល់ជាមួយនិងវិចិត្រករ ហេង មុនីផល នៅផ្ទះរបស់គាត់ ( *អំពី ប្រភេទនៃពណ៌*) នៅថ្ងៃទី១២ខែមីនា ឆ្នាំ ២០២៤


## ២.ភាសាបរទេស

### ២.១ ស្នាដៃនិពន្ធបោះពុម្ពផ្សាយ


- James Gurney, *Color and Light,* China, Andrews McMeel Publishing, LLC, 2010 (page 12, 74 - 86)
- JOHANNES ITTEN, *THE ELEMENTS OF COLOR,* United States of America Published, Van Nostrand Reinhold Company, 1970 (page 15 - 94)


### ២.២ គេហទំព័រ


- Kimberly Aguilar, *Color Theory,* Pinterest,https://www.pinterest.com/pin/633387439339048/ (Accessed on 6 December 2022)
- SETH WILSON, *Color Theory,* https://www.pinterest.com/pin/548524429609024324/ (Accessed on 23 June 2021)
- Shahad.AlFajji, *Color Theory,* Pinterest https://www.pinterest.com/pin/506936501820619766/ (Accessed on 6 December 2022)
- Anuj Malhotra, Color wheel Basics, https://www.slideteam.net/blog/color-wheel-choose-right-color-scheme-powerpoint-slides (Accessed on 17 March 2023)
- Adriana Lucia Tafur Del Aguila, *Color digital:* medium, https://medium.com/@a20193010/color-digital-744fd8a540f0 (Accessed on 6 December 2022)

- Britannica *Isaac Newton* https://www.britannica.com/biography/Isaac-Newton (Accessed on 17 March 2022)
- Britannica *Johann-Wolfgang-von-Goethe* https://www.britannica.com/biography/Johann-Wolfgang-von-Goethe (Accessed on 17 March 2022)
- ipidlibrary *michel-eugène-chevreul* https://lipidlibrary.aocs.org/resource-material/the-history-of-lipid-science-and-technology/michel-eug%C3%A8ne-chevreul-(1786-1889) (Accessed on 17 March 2022)
- britannica *Munsell-color-system* https://www.britannica.com/science/Munsell-color-system (Accessed on 17 March 2022)
- getty.*edu Johannes Itten* https://www.getty.edu/research/exhibitions_events/exhibitions/bauhaus/new_artist/form_color/form/(Accessed on 17 March 2022)

# ការអនុវត្តប្រព័ន្ធកសិកម្មឆ្លាតខ្នាតតូច តាមរយៈការប្រើប្រាស់សេនស័រសម្រាប់ប្រព័ន្ធស្រោចស្រព ក្នុងការដាំដុះដំណាំ

និស្សិត៖ ហ៊ី ឡេងសែ
ជំនាញ៖ បច្ចេកវិទ្យាព័ត៌មាន

## សេចក្តីផ្តើម

សម្រាប់កសិកម្មប្រពៃណី គេនិយមប្រើកម្លាំងមនុស្ស ប្រើសត្វគោក្របីក្នុងការអូសទាញដើម្បីភ្ជួររាស់ធ្វើស្រែ ចំការ និងប្រើប្រាស់ម៉ាស៊ីនបូមទឹកបញ្ចូលស្រែចំការ។ ប៉ុន្មានឆ្នាំនេះ យើងឃើញថា មានការអភិវឌ្ឍទៅលើវិស័យកសិកម្មយ៉ាងខ្លាំងក្លា ដោយមានការណែនាំឱ្យប្រជាជនយល់ដឹងអំពីប្រព័ន្ធបច្ចេកវិទ្យាស្វ័យប្រវត្តិនៅក្នុងដំណើរការ ផលិត និងប្រមូលផលកសិកម្ម។[១]

អ្នកសិក្សាស្រាវជ្រាវមួយក្រុម បានសិក្សាលើគម្រោងមួយ ដែលបានបង្កើតកម្មវិធីទូរសព្ទចល័តអាន់ដ្រយ(Android App) ដើម្បីបញ្ជាឱ្យប្រព័ន្ធធារាសាស្ត្រដំណើរការ ដោយចាប់យកទិន្នន័យសំណើមដីនៅក្បែរដំណាំដើម្បីពិនិត្យលើការបើក/បិទទឹក។ ការវិភាគសមាមាត្ររវាងដីសើមនិងដីស្ងួតត្រូវបានគណនាដោយការថតរូបដី តាមរយៈបង្អួចកញ្ចក់ដោយប្រើប្រាស់កាមេរ៉ា ហើយបញ្ជូនឱ្យប្រព័ន្ធធ្វើការសិក្សាបន្ត។ ប្រព័ន្ធធារាសាស្ត្រដំណើរការបាន អាស្រ័យទៅនឹងកម្មវិធីទូរសព្ទអាន់ដ្រយ ដែលជាអ្នកបញ្ជាវាឱ្យដំណើរការ។[២]

គម្រោងសិក្សាស្រាវជ្រាវលើប្រព័ន្ធកសិកម្មឆ្លាតបានប្រើប្រាស់សេនស័រ សម្រាប់ប្រព័ន្ធដំណើរការស្វ័យប្រវត្តិក្នុងវិស័យកសិកម្ម។ សេនស័រចាប់ទិន្នន័យសំណើមដីដើម្បីពិនិត្យ និងសិក្សាទៅលើការបាញ់ទឹកលើដំណាំ ដោយប្រើប្រាស់នៅក្នុងកម្មវិធីទូរសព្ទជាអ្នកកំណត់ការបាញ់ទឹក ឬមិនបាញ់។ នៅក្នុងគម្រោងសិក្សាស្រាវជ្រាវនេះដែរ មិនទាន់អាចធ្វើការយកទៅប្រើប្រាស់នៅក្នុងកសិដ្ឋានធំៗបាននៅឡើយទេ។[៣]

គម្រោងសិក្សាលើប្រព័ន្ធបាញ់ទឹកឆ្លាត(Smart Sprinkler) បានដើរតួនាទីយ៉ាងសំខាន់លើវិស័យកសិកម្មក្នុងស្រុក។ ប្រព័ន្ធនេះបានផ្គត់ផ្គង់ទឹកទៅតាមតម្រូវការជាក់ស្តែងតាមផែនការកំណត់ផងដែរ។ ប្រព័ន្ធនេះអភិវឌ្ឍឡើងដោយប្រើមីក្រូការត្រួតពិនិត្យ(Microcontroller) Arduino ATMega238។

---

[១] K.Lokesh Krishna, Omayo Silver ៖ *Internet of Things Application for Implementation of Smart Agriculture System*, Publishing: ២០១៧។

[២] Joaquín Gutiérrez, Juan Francisco Villa-Medina ៖ *Automated Irrigation System Using a Wireless Sensor Network and GPRS Module*, JANUARY ២០១៤។

[៣] Chetan Dwarkani M, Ganesh Ram R, Jagannathan S ៖ *Smart Farming System Using Sensors for Agricultural Task Automation*, India, IEEE International Conference, ២០១៥។

មីក្រូការីត្រួតពិនិត្យនេះជាអ្នកគ្រប់គ្រងប្រព័ន្ធបាញ់ទឹកឆ្លាតនេះ និងជាអ្នកបញ្ជាឱ្យបាញ់ទឹកឬបិទទឹក។ ប្រព័ន្ធបាញ់ទឹកឆ្លាតនេះដែរបានជួយសម្រួលកម្លាំងពលកម្ម ចំណេញពេលវេលា និងអាចពង្រីកទំហំកសិដ្ឋានរបស់បងប្អូនប្រជាកសិករ។[៤] ព័ត៌មានទាំងនេះបានបង្ហាញពីឱកាសសម្រាប់យកបច្ចេកវិទ្យាសេនស័រជួយក្នុងវិស័យកសិកម្ម ជាពិសេសការដាំដំណាំបន្លែបង្ការក្បែរផ្ទះសម្រាប់គ្រួសារ។[៥]

អត្ថបទសង្ខេបនេះមានគោលដៅឈ្វេងយល់ពីបច្ចេកវិទ្យាក្នុងវិស័យកសិកម្ម យើងដឹងហើយថា នៅយុគសម័យឌីជីថលនេះ បច្ចេកវិទ្យាដើរតួនាទីយ៉ាងសំខាន់ស្ទើរគ្រប់វិស័យក្នុងការអភិវឌ្ឍប្រទេសជាតិ។ ក្នុងនោះដែរ បច្ចេកវិទ្យាសេនស័រមានការវិវឌ្ឍជឿនលឿនដែលអាចដំណើរការស្វ័យប្រវត្តិ ដែលអាចយកប្រើប្រាស់ដើម្បីចូលរួមដោះស្រាយបញ្ហាការស្រោចស្រពដំណាំបន្លែ ដោយស្វ័យប្រវត្តិពឹងផ្អែកលើសេនស័រនៅកម្ពុជា។

## សម្ភារៈ និងវិធីសាស្ត្រស្រាវជ្រាវ

ប្រព័ន្ធនេះដំណើរការដោយស្វ័យប្រវត្តិចាប់តាំងពីការដាំដុះរហូតដល់ពេលប្រមូលផល និងដំណើរការជាមួយ IoT (Internet of Thing) ក្នុងការបញ្ជា និងប្រើប្រាស់ប៊ិត(Board) ESP៣២។[៦] នៅក្នុងប្រព័ន្ធបញ្ជា យើងមាន២ផ្នែកគឺ ហាដវែរ (Hardware) និងសុសវែរ (Software) ដែលប្រព័ន្ធបញ្ជានេះមានគ្រឿងបង្គុំសំខាន់ៗដូចជា៖

- ប៊ិត(Board) ESP៣២
- ឧបករណ៍បម្លែងចរន្តអគ្គិសនី (Power Supply)
- ឧបករណ៍បញ្ជូនតឬកាត់ផ្តាច់ចរន្តអគ្គិសនី (Relay ៤ channel
- សេនស័រសីតុណ្ហភាព និងសំណើមបរិយាកាស (DHT-១១)
- សេនស័រវាស់សំណើមដី (Soil Moisture)
- សេនស័រវាស់បរិមាណទឹកប្រើប្រាស់ (Water Flow Sensor)
- ក្លក(នាឡិកា) ឆុតកាល (Real Time Clock)
- ម៉ូទ័របូមទឹក



រូបភាពទី១៖ ប្រព័ន្ធបញ្ជា

---

[៤] G.Shruthi, B. SelvaKumari, R. PushpaRani ៖ *A-Real Time Smart Sprinkler Irrigation Control System*, United States, IEEE International Conference, ២០១៧។

[៥] MinVictor O. Abegunde ៖ ***Determinants of the Adoption of Climate-Smart Agricultural Practices by Small-Scale Farming Households in King Cetshwayo District Municipality, South Africa***, South Africa, University of Zululand, Published: 25 December ២០១៩។

[៦] Sensors, Agricultural sensors, ***https://www.okdo.com/blog/five-smart-farming-technologies-transforming-agriculture/*** (Accessed 31 October 2023)។

## ១. ការសិក្សានិងអភិវឌ្ឍន៍សូសវែរ

សុសវែរ ជាផ្នែកមួយដែលប្រើក្នុងការចងក្រងនូវលក្ខខណ្ឌសម្រាប់ដំណើរការរបស់ការីត្រួតពិនិត្យ (Controller) ទៅតាមប្រភេទនៃភាសាផ្សេងៗគ្នា។ សុសវែរជាផ្នែកមួយសម្រាប់សិក្សាលើភាសា និងការរចនាបទផ្សេងៗនៃកូដ(code)សម្រាប់ប្រព័ន្ធបញ្ជាស្វ័យប្រវត្តិ។ វាត្រូវបានប្រើជាការីត្រួតពិនិត្យ ហើយភាសាកម្មវិធីដែលប្រើក្នុងការសរសេរបញ្ជាទៅលើ Arduino គឺភាសាកម្មវិធី C។




បញ្ចូលកូដដែលយើងបានចងក្រងលក្ខខណ្ឌ សម្រាប់ដំណើរការស្រោចស្រពទឹកដោយស្វ័យប្រវត្តិ ផ្អែកលើទិន្នន័យបានពីសេនស័រសីតុណ្ហភាព និងសេនស័រសំណើមដី។ ការីត្រួតពិនិត្យ ដែលបានរៀបចំនិងបញ្ជាទៅកាន់ម៉ូទ័របូមទឹក ធ្វើការបូមទឹកស្រោចស្រពបន្លែដោយស្វ័យប្រវត្តិ។

រូបភាពទី២៖ បញ្ចូលសុសវែរចូលបិត ESP៣២

## ២. មូលទិន្នន័យ

យើងបង្កើតបណ្តាញមួយដែលបង្ហាញការអានទិន្នន័យរបស់សេនស័រនៅក្នុងប្រព័ន្ធ ដែលអ្នកអាចចូលប្រើប្រាស់បានពីគ្រប់ទីកន្លែងក្នុងពិភពលោក។ សរុបមក គឺបង្កើតអតិថិឧបករណ៍(Client) ESP ៣២ ដែលធ្វើការស្នើសុំទៅស្ក្រីប PHP(API) ក្នុងសេវូបករណ៍ (Server site) ដើម្បីបោះផ្សាយការអានទិន្នន័យរបស់សេនស័រនៅក្នុងមូលទិន្នន័យ MySQL (Database) ។ យើងអាចអានទិន្នន័យពីគ្រប់ទីកន្លែងក្នុងពិភពលោកដោយចូលទៅកាន់ឈ្មោះដែនសេវូបករណ៍(Server) របស់អ្នក។[៧]




រូបភាពទី៣៖ ដំណើរប្រព័ន្ធបញ្ជា

---

[៧] Kusumadewi, F., et al. ៖ *Smart agriculture monitoring system using Internet of Things (IoT) and machine learning.* IEEE Access, 9, 59565-59576 (២០២១)។




រូបភាពទី៤៖ ដ្យាក្រាមប្លុកនៃប្រព័ន្ធស្រោចស្រព

នៅក្នុងគំនូសតាងលំហូរការងារខាងលើ ជាការបង្ហាញអំពីដំណើរការបូមទឹកដោយស្វ័យប្រវត្តិ។ ប៊ិត ESP៣២ ជាមីក្រូការីត្រួតពិនិត្យដែលប្រើសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងសេនស័រសំណើមបរិយាកាស និងសីតុណ្ហភាព សេនស័រសំណើមដី ទៅនឹងម៉ាស៊ីនបូមទឹក។ ESP៣២ ត្រូវការថាមពល ៥វ៉ុល (5v) ក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនីដើម្បីប្រើប្រាស់ខ្លួនវា។[៨] ម៉ូទ័របូមទឹកត្រូវបានប្រើសម្រាប់ផ្គត់ផ្គង់ទឹក ដើម្បីស្រោចស្រពដំណាំក្នុងកសិដ្ឋានផ្ទះសំណាញ់ ហើយម៉ូទ័របូមទឹកនេះប្រើភ្លើង ២២០វ៉ុល ដែលចេញពីឧបករណ៍បញ្ជូនតឬកាត់ផ្តាច់(Relay) ដែលជាអ្នកភ្ជាប់ភ្លើងឱ្យទៅម៉ូទ័របូមទឹកដំណើរការ ឬមិនដំណើរការ។ នៅក្នុងប្រព័ន្ធស្រោចស្រពទឹកស្វ័យប្រវត្តិនេះ យើងពឹងផ្អែកទៅលើសេនស័រសំណើមដី និង សេនស័រសំណើមបរិយាកាសនិងសីតុណ្ហភាព ដើម្បីកំណត់នូវកិច្ចការបូមទឹកដោយស្វ័យប្រវត្តិ។ សេនស័រសំណើមបរិយាកាសនិងសីតុណ្ហភាពធ្វើការភ្ជាប់ទៅកាន់ជើង GP១១ នៃ ESP៣២ និង ជើង GP១៥ នៃ ESP៣២ ធ្វើការភ្ជាប់ទៅកាន់សេនស័រសំណើមដី។ សេនស័រសំណើមបរិយាកាសនិងសីតុណ្ហភាពប្រើប្រាស់ សម្រាប់ត្រួតពិនិត្យសំណើមបរិយាកាសនិងសីតុណ្ហភាពក្នុងកសិដ្ឋានផ្ទះសំណាញ់របស់យើង ដើម្បីដឹងកម្រិតសំណើមបរិយាកាស និងសីតុណ្ហភាពក្នុងកសិដ្ឋាន។[៩] ប្រសិនបើសេនស័រសំណើមបរិយាកាស និងសីតុណ្ហភាពទទួលបានកម្រិតសំណើមបរិយាកាសនិងសីតុណ្ហភាពស្ថិតក្នុងកម្រិតដែលយើងបានកំណត់ទុកជាមុន នោះ ESP៣២ នឹងធ្វើការបញ្ជាទៅកាន់ឧបករណ៍បញ្ជូនតឬ

---

[៨] Lee, S. H., et al. ៖ *IoT-based smart farm system for monitoring crop growth conditions*. Sensors, 19(4), 762 (២០១៩)។

[៩] Tan, L., et al. ៖ *A smart IoT-based greenhouse system for efficient crop management*. Computers and Electronics in Agriculture, 176, 105649 (២០២០)។

កាត់ផ្តាច់(Relay) ដើម្បីធ្វើការផ្តល់ចរន្តអគ្គិសនីទៅកាន់ម៉ូទ័របូមទឹក ឱ្យវាដំណើរការបូមទឹកដោយស្វ័យប្រវត្តិ។ ដោយឡែក នៅពេលកម្រិតសំណើមបរិយាកាស និងសីតុណ្ហភាព ក្នុងកសិដ្ឋានផ្ទះសំណាញ់ធ្លាក់ចុះមកវិញ ពេលនោះ ESP៣២ នឹងធ្វើការបញ្ជាទៅកាន់ឧបករណ៍បញ្ជូនត ឬកាត់ផ្តាច់(Relay) ធ្វើការកាត់ផ្តាច់ចរន្តអគ្គិសនីមិនឱ្យម៉ូទ័របូមទឹកដំណើរនោះទេ។ សេនស័រសំណើមដីប្រើប្រាស់ដើម្បីវាស់កម្រិតសំណើមដីក្នុងកសិដ្ឋានផ្ទះសំណាញ់ ប្រសិនបើវាវាស់ឃើញថា កម្រិតសំណើមដីស្ថិតក្នុងកម្រិតដែលបានកំណត់ទុកជាមុន នោះប៊ិតESP៣២ នឹងធ្វើការបញ្ជាទៅកាន់ឧបករណ៍បញ្ជូនត ឬកាត់ផ្តាច់(Relay) ដើម្បីធ្វើការផ្តល់ចរន្តអគ្គិសនីទៅកាន់ម៉ូទ័របូមទឹក ឱ្យដំណើរការបូមទឹកដោយស្វ័យប្រវត្តិ។ នៅពេលសំណើមដីក្នុងកសិដ្ឋានប្រែប្រួលលែងស្ថិតក្នុងកម្រិតដែលបានកំណត់ទុកហើយ ពេលនោះ ESP៣២ នឹងបញ្ជាទៅកាន់ឧបករណ៍បញ្ជូនតឬកាត់ផ្តាច់(Relay) ធ្វើការកាត់ផ្តាច់ចរន្តអគ្គិសនីមិនឱ្យម៉ូទ័របូមទឹកដំណើរការ។ លក្ខខណ្ឌនៃការផ្ទៀតផ្ទាត់ដើម្បីឱ្យម៉ូទ័រធ្វើការបូមទឹកគឺសំណើមដីតូចជាង ៥០ភាគរយ និងម៉ូទ័រឈប់បូមវិញ ពេលសំណើមដីធំជាង ៥០ភាគរយ។

ដើម្បីទទួលបានលទ្ធផលពីការសិក្សាគម្រោង ដែលបានសិក្សាទៅលើប្រព័ន្ធស្រោចស្រពដំណាំស្វ័យប្រវត្តិនេះ ជាដំបូងយើងត្រូវសិក្សាវិភាគ និងគណនាទៅលើគ្រប់ផ្នែកផ្សេងៗដែលមាននៅក្នុងប្រព័ន្ធទាំងមូលជាមុនសិន។ ដើម្បីឱ្យដំណើរការវិភាគនេះគ្រប់ជ្រុងជ្រោយនិងលម្អិត យើងបានបែងចែកផ្នែកសំខាន់ៗជាពីរផ្នែក គឺសុសវែរ និងហាដវែរ ដែលនឹងត្រូវលើកយកមកសិក្សានិងវិភាគ។

## ៣. បំពាក់ប្រព័ន្ធស្រោចស្រពស្វ័យប្រវត្តិក្នុងកសិដ្ឋាន

កសិដ្ឋានដែលនឹងធ្វើការពិសោធលើដំណាំខាត់ណាដើមនេះ ជាប្រភេទផ្ទះសំណាញ់បិទជិតប្រមាណជា៨០ ភាគរយប៉ុណ្ណោះ ពីព្រោះយើងចង់ឱ្យមានខ្យល់ខ្លះចេញចូលក្នុងកសិដ្ឋានផ្ទះសំណាញ់ ដើម្បីឱ្យដំណាំទទួលបាន អុកស៊ីសែនសម្រាប់ធំធាត់បានល្អ។ យើងធ្វើពិសោធន៍ក្នុងផ្ទះសំណាញ់នេះ ដោយសារតែផ្ទះសំណាញ់ជួយការពារ ពីការបំផ្លាញរបស់សត្វល្អិតចង្រៃមកលើដំណាំ។[១០] កសិដ្ឋានផ្ទះសំណាញ់ដែលបានរៀបចំសម្រាប់ធ្វើពិសោធន៍នេះគឺ មានទំហំដីបណ្តោយ ១៥០សង់ទីម៉ែត្រ និងទទឹង ១០០សង់ទីម៉ែត្រ ហើយបានរៀបចំសង់ជាធុងឈើផុតពីដី ចំនួនពីរធុងសម្រាប់ដាក់ដាំដើមខាត់ណាដើម។ យើងប្រើមួយធុងសម្រាប់ធ្វើពិសោធន៍ជាមួយប្រព័ន្ធស្រោចស្រព ស្វ័យប្រវត្តិ និងមួយធុងទៀតសម្រាប់ដាំដោយស្រោចទឹកផ្ទាល់សម្រាប់ធ្វើការប្រៀបធៀបគ្នា។

ដីជាកត្តាមួយចាំបាច់បំផុតសម្រាប់ការដុះ និងលូតលាស់របស់ដំណាំគ្រប់ប្រភេទ។ ដីដែលសម្បូរទៅដោយជាតិ មមោក(Hight organic content) ព្រមទាំងសារជាតុចិញ្ចឹមផ្សេងៗ (Other mineral) ដំណាំប្រភេទ Brassica ត្រូវគេចាត់បញ្ចូលទៅក្នុងក្រុមមិនធន់ទ្រាំទៅនឹងដីអាស៊ីដ(nontolerant to low pH of Soil) វាអាចដុះលូតលាស់ លើប្រភេទដីច្រើនប្រភេទ ជាពិសេស នៅលើប្រភេទដីល្បាប់មាត់ទន្លេមេគង្គ ដីក្រហម ដីខ្មៅ តែវាមិនលូតលាស់ល្អលើ ប្រភេទដីដែលមានល្បាយដីឥដ្ឋខ្ពស់ ព្រោះ

---

[១០] ម៉ុង វណ្ណឌី៖ ***បទដ្ឋានអនុវត្តបច្ចេកវិទ្យាសួនបន្លែគ្រួសារ*** ភ្នំពេញ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ២០០៦។

ដីប្រភេទនេះមិនជ្រាបទឹក ដីដែលដក់ទឹកយូរ ដំណាំប្រភេទនេះមិនអាច លូតលាស់ល្អ។ pH សមស្រប គឺ ចន្លោះពី ៦.៥ ដល់ ៧.៥ ចំពោះសំណើមដីត្រូវមានចន្លោះពី ៧០ ទៅ ៧៥ភាគរយ ជាប្រចាំ។[១១]




រូបភាពទី៥៖ គំនូសតាងថ្នាលសម្រាប់ដាំ និងការរៀបចំដីសម្រាប់ដាំកូនខាត់ណាដើម

ក្នុងកសិដ្ឋានផ្ទះសំណាញ់ដដែលនេះ យើងបានដាក់សេនស័រសំណើមដីនៅត្រង់ចំណុចកណ្តាល អង្កត់ទ្រូង នៃផ្នើរង ដើម្បីដឹងច្បាស់អំពីកម្រិតសំណើមដីក្នុងផ្នើរងបន្លែ។ សេនស័រសំណើមដីដែល ដាក់នៅត្រង់ចំណុច កណ្តាលអង្កត់ទ្រូងនៃផ្នើរងក្នុងកសិដ្ឋានផ្ទះសំណាញ់នេះ ដាក់ជម្រៅ ១០ សង់ទីម៉ែត្រ ពីព្រោះវាសមស្របទៅនឹង ដំណាំខាត់ណាដើម ដែលយើងបានជ្រើសយកមកធ្វើការ ពិសោធន៍។ ទីតាំងនិងជម្រៅនៃការដាក់សេនស័រ សំណើមដីនេះ អាស្រ័យទៅនឹងទីតាំងដាក់ស្តែង និង ប្រភេទដំណាំ ដែលយើងជ្រើសរើសយកមកធ្វើការដាំ។




រូបភាពទី៦៖ គំនូសតាងសេនស័រ និងការដាក់សេនស័រក្នុងថ្នាលដំណាំ

ក្នុងប្រព័ន្ធស្រោចស្រពស្វ័យប្រវត្តិនេះ យើងបានធ្វើការស្រោចទឹកដោយស្វ័យប្រវត្តិដោយកំណត់ ឱ្យប្រព័ន្ធស្រោចទឹកពីរដងក្នុងមួយថ្ងៃ គឺពេលព្រឹកម៉ោង៧ព្រឹក និងពេលរសៀលម៉ោង ៥រសៀល។[១២] ដោយឡែក ពេល ដល់ពេលវេលាកំណត់ ហើយប្រព័ន្ធសិក្សាទៅលើសំណើមដីឃើញថា ដីមាន សំណើមគ្រប់គ្រាន់ នោះប្រព័ន្ធ ស្វ័យប្រវត្តិយើងមិនបូមទឹកស្រោចនោះទេ។ ប្រព័ន្ធនេះប្រមូលទិន្នន័យ

[១១] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖ *ដំណាំខាត់ណាដើម* ភ្នំពេញ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងរដ្ឋបាលជលផល ២០០៨។

[១២] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖ *ការដាំខាត់ណាដើមឱ្យសរម្យ* ភ្នំពេញ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងរដ្ឋបាលជលផល ២០០៨។

រៀងរាល់១៥នាទីម្តង ប្រសិនបើប្រព័ន្ធប្រមូលទិន្នន័យហើយសិក្សាលើលក្ខខណ្ឌ ឃើញថាត្រឹមត្រូវតាមលក្ខខណ្ឌ នោះវានឹងបូមទឹកភ្លាមៗតែម្តង។ លក្ខខណ្ឌដែលបានកំណត់នោះគឺថា ប្រសិនបើសំណើមដីតូចជាង ៥០ភាគរយ ត្រូវបូមទឹកស្រោចដំណាំស្វ័យប្រវត្តិ ពីព្រោះដីក្នុងកសិដ្ឋានមានសភាពស្ងួត។ ដោយឡែក ពេលមានអាកាសធាតុក្តៅខ្លាំងរហូតដល់ ៣៨អង្សា យើងឃើញថាដីនឹងមានសភាពស្ងួត ដូច្នេះយើងបញ្ជាឱ្យប្រព័ន្ធធ្វើការបូមទឹកដែរ។ រាល់ដំណើរការបូមទឹក យើងបានកំណត់រយៈពេលឱ្យវាបូមទឹកស្រោចដំណាំល្មម និងគ្រប់គ្រាន់ បន្ទាប់ពីបូមស្រោចគ្រប់គ្រាន់រួចរាល់ វានឹងបញ្ឈប់ការបូមដោយខ្លួនវាផ្ទាល់។

តារាងទី១៖ លក្ខខណ្ឌផ្ទៀតផ្ទាត់

| សំណើមដី | សីតុណ្ហភាព | ម៉ូទ័របូមទឹក |
|---|---|---|
| > ៥០% | ៣០ អង្សារ | បិទ |
| < ៥០% | > ៣២ អង្សារ | បូម |

## លទ្ធផល និងការពិភាក្សា

បន្ទាប់ពីយើងចាប់ផ្តើមធ្វើការដំឡើង និងតេស្តប្រព័ន្ធស្រោចដំណាំដោយស្វ័យប្រវត្តិរួចមក ឃើញថា ប្រព័ន្ធដំណើរការយ៉ាងរលូន ដោយមានការបង្ហាញព័ត៌មានអំពីកម្រិតសីតុណ្ហភាព សំណើមបរិយាកាស សំណើមដី និងការប្រើប្រាស់ទឹកប្រចាំថ្ងៃ។




រូបភាពទី៧៖ ព័ត៌មានអំពីទិន្នន័យសំណើមដី សីតុណ្ហភាព សំណើមបរិយាកាស និងការប្រើប្រាស់ទឹក




រូបភាពទី៨៖ ទិន្នន័យទិន្នផលដំណាំខាត់ណាដើម

លទ្ធផលបង្ហាញថា វាមានប្រសិទ្ធភាពផ្សេងៗគ្នា *p*-value > 0.05 តាមរយៈការស្រោចស្រពដោយសេនស័រ និងដោយមនុស្ស។ ការប្រើប្រាស់សេនស័រមានប្រសិទ្ធភាពល្អជាង២០.៧៨% រីឯស្រោចស្រពដោយមនុស្សកើនត្រឹម ១៩.៧២%។ ដូច្នេះការចំណាយទឹកបានគត់មត់ជាង ហើយដំណាំក៏បានល្អប្រសើរជាង និងមិនចំណាយកម្លាំងពលកម្ម។

រួមសេចក្តីមក ការប្រើប្រាស់សេនស័រ ចំណេញពេលវេលា និងកើនទិន្នផលសម្រាប់ដំណាំខាត់ណាដើមក្នុងលក្ខខណ្ឌនៃអាកាសធាតុក្នុងប្រទេសកម្ពុជា។




រូបភាពទី៩៖ របាយការណ៍ការប្រើប្រាស់ទឹក

ប្រសិនបើធ្វើការប្រៀបធៀបការស្រោចទឹកដោយដៃ និងស្រោចដោយប្រព័ន្ធស្វ័យប្រវត្តិ ឃើញថាការស្រោចទឹកដោយស្វ័យប្រវត្តិមានការចំណេញជាងរហូតដល់ទៅ ៣៥ ភាគរយ(35%) ហើយមិនត្រូវការមានមនុស្សនៅប្រចាំការជាប់ជានិច្ច និងចំណេញពេលវេលាច្រើន អាចធ្វើការងារផ្សេងបាន។ ស្របតាមគុណសម្បត្តិច្រើនតែពិតមែន តែប្រព័ន្ធរបស់យើងក៏នៅមានគុណវិបត្តិផងដែរ គឺត្រូវការមានភ្លើង និងអ៊ីនធឺណិតសម្រាប់ភ្ជាប់ទៅប្រព័ន្ធជានិច្ច ដោយឡែកប្រព័ន្ធស្រោចស្រពស្វ័យប្រវត្តិរបស់យើងអាចប្រើប្រាស់បានតែលក្ខខណ្ឌក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ហើយមិនទាន់អាចអនុវត្តន៍លើកសិដ្ឋានធំៗបាននៅឡើយទេ។

## សេចក្តីសន្និដ្ឋាន

បច្ចេកវិទ្យាសេនស័រជាបច្ចេកទេសជឿនលឿនមួយក្នុងការអភិវឌ្ឍន៍ពិភពឌីជីថល ដែលគេអាចយកសេនស័រទៅប្រើក្នុងបច្ចេកទេសឡានទំនើប ផ្ទះឆ្លាតវៃ ទីក្រុងឆ្លាតវៃ...។ល។ ក្នុងវិស័យកសិកម្មសេនស័របានបង្កអត្ថប្រយោជន៍ជាច្រើនដល់ការដាំដុះបន្លែ ជាពិសេសការស្រោចស្រពដោយស្វ័យប្រវត្តិមិនចាំបាច់មានមនុស្សនៅចាំមើល។ ការស្រោចស្រពទឹកក៏បានគត់មត់ជាង ចំណេញពេលវេលា ចំណេញថវិកា និងមិនចាំបាច់ចំណាយពលកម្មច្រើន។ វាបានចូលរួមផ្តល់អត្ថប្រយោជន៍កាន់តែល្អជាងនេះទៅទៀត សម្រាប់អ្នកដែលសិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មាន ម្យ៉ាងវិញទៀតចំពោះគម្រោងដែលបានលើកយកមកធ្វើការសិក្សានេះ មិនមែនគ្រាន់តែជាគម្រោងដែលកើតចេញពីការស្រមើស្រមៃនោះទេ គឺមានន័យថា ខ្ញុំបានសិក្សានិងបង្កើតវាឱ្យចេញជាប្រព័ន្ធបញ្ហាគំរូដែលបានបង្ហាញពីដំណើរការពិតៗ ដែលអនុវត្តន៍នៅលើដំណាំខាត់ណាដើមជាក់ស្តែងក្នុងប្រទេសកម្ពុជា។

# ឯកសារយោង


១. K.Lokesh Krishna, Omayo Silver ៖ *Internet of Things Application for Implementation of Smart Agriculture System*, India, International conference on I-SMAC, Publishing: ២០១៧.

២. Joaquín Gutiérrez, Juan Francisco Villa-Medina ៖ *Automated Irrigation System Using a Wireless Sensor Network and GPRS Module*, United States, IEEE, VOL. 63. 1, JANUARY ២០១៤.

៣. Chetan Dwarkani M, Ganesh Ram R, Jagannathan S ៖ *Smart Farming System Using Sensors for Agricultural Task Automation*, India, IEEE International Conference, ២០១៥.

៤. G.Shruthi, B. SelvaKumari, R. PushpaRani ៖ *A-Real Time Smart Sprinkler Irrigation Control System*, United States, IEEE International Conference, ២០១៧.

៥. MinVictor O. Abegunde[1] ៖ *Determinants of the Adoption of Climate-Smart Agricultural Practices by Small-Scale Farming Households in King Cetshwayo District Municipality, South Africa*, South Africa, University of Zululand, Published: ២៥ December ២០១៩.

៦. Sensors, *Agricultural sensors*, https://www.okdo.com/blog/five-smart-farming-technologies- transforming-agriculture/ (Accessed ៣១ October ២០២៣).

៧. Kusumadewi, F., et al. ៖ *Smart agriculture monitoring system using Internet of Things (IoT) and machine learning*. IEEE Access, 9, 59565-59576 (២០២១).

៨. Lee, S. H., et al. ៖ *IoT-based smart farm system for monitoring crop growth conditions*. Sensors, 19(4), 762 (២០១៩).

៩. Tan, L., et al. ៖ *A smart IoT-based greenhouse system for efficient crop management*. Computers and Electronics in Agriculture, 176, 105649 (២០២០).

១០. ម៉ុង វណ្ណឌី៖ *បទដ្ឋានអនុវត្តបច្ចេកវិទ្យាស្ពនបន្លែត្រសារ* ភ្នំពេញ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ២០០៦

១១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖ *ដំណាំខាត់ណាដើម* ភ្នំពេញ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងរដ្ឋបាលជលផល ២០០៨

១២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖ *ការដាំខាត់ណាដើមខុសរដូវ* ភ្នំពេញ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងរដ្ឋបាលជលផល ២០០៨

១៣. គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល៖ *ឯកសារស្រាវជ្រាវគំរូបច្ចេកទេសដាំដុះបន្លែស្លឹក* ភ្នំពេញ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ២០២២

© ២០២៤ រាជបណ្ឌិត្យសភាកម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង
គ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ។

---

©2024 Royal Academy of Cambodia

All rights reserved,
no part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.





**Royal Academy of Cambodia**
Russian Federation Blvd
P.O.Box: 531 Phnom Penh
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: info@rac.gov.kh
Website: www.rac.gov.kh

**រាជបណ្ឌិត្យសភាកម្ពុជា**
**មហាវិថីសហព័ន្ធរុស្ស៊ី**
**ប្រអប់សំបុត្រលេខ ៥៣១ ភ្នំពេញ**
**ព្រះរាជាណាចក្រកម្ពុជា**
**ទូរសព្ទលេខ**: (**៨៥៥**)**២៣ ៨៩០១៨០**
**ទូរសារលេខ**: (**៨៥៥**)**២៣ ៨៩០១៨០**
**អ៊ីម៉ែល**: info@rac.gov.kh
**គេហទំព័រ**: www.rac.gov.kh